# មេរៀនធម៌

# ជំនួយសតិ

## ភាគទី ៤

**រៀបរៀងដោយ**

**ខ្ញុំព្រះករុណា**

**ខ្ញុំបាទ ប៊ុត សាវង្ស**

**សំរាប់ជាធម្មទានតែប៉ុណ្ណោះ**

# ពាក្យផ្តើម

≈≈ ≈≈

សៀវភៅជំនួយសតិភាគទី៤នេះ មានមេរៀនព្រះអភិធម្ម ច្រើនជាងភាគមុនៗ ប៉ុន្តែមានធម៌មួយចំនួនទៀត ពន្យល់អំពីជីវិតប្រចាំថ្ងៃ បើពុទ្ធបរិស័ទមានឧបនិស្ស័យយ៉ាងណាៗ គប្បីសិក្សាយ៉ាងនោះចុះ ។

សៀវភៅនេះ ខ្ញុំព្រះករុណា ខ្ញុំបាទ បានរៀបចំយ៉ាងផ្ចិតផ្ចង់នូវមេរៀនព្រះអភិធម្មគម្ពីរបដ្ឋានគឺ **ហេតុប្បច្ច័យ** និង **អារម្មណប្បច្ច័យ** តាម **ព្រះអភិធម្មបិដក** និង**អដ្ឋកថា** ព្រមដោយឯកសារពិគ្រោះផ្សេងៗទៀត ដូចជាសៀវភៅបដ្ឋានរបស់ **ព្រះភិក្ខុ** សុមន្ត នន្ទិកោ សៀវភៅអភិធម្មត្ថសង្គហៈ របស់ **លោកអាចារ្យ សំផន ស្រីវរាទិត្យ** ជាដើម ។

សៀវភៅមេរៀនធម៌ជំនួយសតិនេះ មានពន្យល់អំពីការបដិបត្តិចំរើនសតិប្បដ្ឋាន ដែលជាផ្លូវទៅកាន់ទីរំលត់ទុក្ខ ។

ការសិក្សាមេរៀនព្រះអភិធម្ម មានប្រយោជន៍ដ៏ធំធេងក្នុងការយល់អំពីជីវិតប្រចាំថ្ងៃ និងជាឧបការៈដល់ការចំរើនសតិប្បដ្ឋាន។

ធម៌ណាដែលកើតឡើង រមែងកើតអំពីហេតុនៃធម៌នោះ នេះជាទិសដៅ និង ជាចំណុចសំខាន់សំរាប់ពុទ្ធបរិស័ទបានឃើញ បានចាក់ធ្លុះ ហើយរមែងបានដល់នូវទីពឹងដ៏ក្សេម ។

ចំពោះសៀវភៅជំនួយសតិទាំង ៤ភាគនេះ បើមានការខ្វះខាតដោយប្រការណា ខ្ញុំម្ចាស់សូមទទួលការបំពេញបន្ថែមដោយសេចក្ដីត្រេកអរជ្រះថ្លា ។

ដោយកុសលធម្មទាន ដ៏ជាអតិសារសម្បត្តិនេះ សូមគំនរនៃបុណ្យកុសល បានសំរេចដល់ពុទ្ធបរិស័ទបរិបូណ៌ដោយបញ្ញាសម្បត្តិ បានឆ្លងកាត់អន្លង់នៃសេចក្ដីទុក្ខដោយជោគជ័យ គ្រប់ព្រះ អង្គ និង គ្រប់គ្នា សូមអនុមោទនា ! ។

**ខ្ញុំព្រះករុណា**

**ខ្ញុំបាទ ម៉ុត សារឿន**

≈≈≈≈≈

**៥រោច ខែ ពិសាខ**

**ព.ស ២៥៤៣**

~~~~~

**សំរាប់ជាធម្មទានតែប៉ុណ្ណោះ**

# មាតិកាធម៌

**លេខរៀង** **ទំព័រ**


១-ត្រូវចេះរស់ជាមួយនឹងជីវិតបច្ចុប្បន្ន .................................. ១
២-បទពិចារណាជុំវិញជីវិត ................................................. ៧
៣-ហេតុប្បច្ចយោ ......................................................... ១៥
៤-បច្ចយុប្បន្នធម៌ ......................................................... ១៩
៥-សហេតុកចិត្តជរូប ១៧ ............................................... ២៥
៦-សហេតុកបដិសន្ធិកម្មជរូប ២០ .................................... ២៨
៧-បច្ចនិកធម៌ ............................................................. ៣៧
៨-សរុបអង្គធម៌នៃហេតុប្បច្ច័យ ..................................... ៤០
៩-បញ្ហាវារៈនៃហេតុប្បច្ច័យ ........................................... ៤៤
១០-សមាធិជាបទដ្ឋាននៃបញ្ញា ....................................... ៥៩
១១-ហេតុប្បច្ច័យសភាគៈ ............................................... ៦៩
១២-ហេតុប្បច្ច័យសភាគៈតាមបញ្ហាវារៈ ............................ ៧១
១៣-សភាគប្បច្ច័យមានក្នុងបញ្ហាវារៈ ................................ ៧៣
១៤-កាល.ភូមិ.បុគ្គល.ទ្វារ របស់ហេតុប្បច្ច័យ ...................... ៧៧
១៥-បទពិចារណា ........................................................ ៨១
១៦-ជីវិតជារបស់ខ្ចីគេ .................................................. ៨៤
១៧-អារម្មណប្បច្ច័យ .................................................... ៨៩
១៨-ពន្យល់ពាក្យអារម្មណ៏ ............................................. ៩៩
~~~~~

១៩-អារម្មណ៍របស់វិបស្សនា ........................................... ១០៥
២០-បញ្ហាវារៈនៃអារម្មណប្បច្ច័យ ..................................... ១០៩
២១-បទគួរយល់ដឹង ....................................................... ១១៧
២២-គប្បីយល់ដឹងក្នុងសតិ-វិបស្សនាថែមទៀត .................... ១២១
២៣-បទគួរយល់ដឹងថែមទៀត ........................................... ១៤៣
២៤-ប្រយោជន៍នៃការសិក្សាអារម្មណប្បច្ច័យ ....................... ១៦១
២៥-អារម្មណប្បច្ច័យសភាគៈ ........................................... ២០៣
២៦-ន័យ ៦ ដ៏ជ្រៅ ........................................................ ២០៥
២៧-ចតុត្ថជ្ឈាន ១២យ៉ាង ................................................ ២៣៣
២៨-អារម្មណ៍ពិស្ដារ ....................................................... ២៤៦
២៩-ចិត្តដឹងអារម្មណ៍ពិស្ដារ ............................................... ២៥០
៣០-ចេតសិកដឹងអារម្មណ៍ពិស្ដារ ....................................... ២៦២
៣១-ចិត្ត ៩១ដួង ចែកជា ៨ពួក ......................................... ២៦៦
៣២-ចិត្ត ៨៩ដួង ចែកជា ៧ពួក ......................................... ២៦៩
៣៣-សមាធិសូត្រ ........................................................ ២៧៤
៣៤-បដិសល្លានសូត្រ ...................................................... ២៧៦
៣៥-អស្សជិសូត្រ ........................................................... ២៨២
៣៦-បរិវដ្ដៈ ៣ ក្នុង ខន្ធ ៥ ............................................... ២៩០
៣៧-សតិសូត្រ សតិវគ្គ .................................................... ២៩៧

≈≈ ≈≈

# ត្រូវចេះរស់ជាមួយនឹងជីវិតបច្ចុប្បន្ន

ជីវិតគឺជាបរមត្ថធម៌ ប្រព្រឹត្តទៅតាមហេតុតាមបច្ច័យ ជីវិតក្នុងអតីតកាល អាស្រ័យបច្ច័យជាអតីតកាល ជីវិតក្នុងអនាគតកាល ក៏មានហេតុដោយឡែកផ្សេងសំរាប់ជីវិតនោះ ឯចំណែកជីវិតក្នុងបច្ចុប្បន្នក៏ត្រូវមានហេតុដោយឡែកសំរាប់ជីវិតបច្ចុប្បន្ននេះដែរ ដូច្នេះជីវិតត្រូវបានផ្លាស់ប្ដូរទៅតាមហេតុទៅតាមបច្ច័យនៃជីវិតនោះៗ ។

មនុស្សយើងគ្រប់គ្នាដែលរស់នៅ ក៏គឺជាការប្រព្រឹត្តិទៅនៃជីវិតដែលដូរផ្លាស់បន្តគ្នាពុំចេះដាច់នេះឯង ព្រះសម្មាសម្ពុទ្ធទ្រង់បានត្រាស់សំដែងអំពីជីវិត នៅក្នុងពួកធម៌ទាំង-ឡាយដូចជានៅក្នុង **អភិធម្មសង្គណី**ជាដើម ជីវិតជាកុសលក៏មាន ជីវិតជាអកុសលក៏មាន ជីវិតជាអព្យាកតក៏មាន ជីវិតជាធម៌កើតដោយហេតុ-បច្ច័យ ជីវិតប្រកបដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មានជីវិតប្រកបដោយអទុក្ខមសុខវេទនាក៏មាន ជីវិតជាវិបាកក៏មាន

ជីវិតនាំឱ្យមានវិបាកក៏មាន ។ល។

ជីវិតអតីតៈមិនមែនជាជីវិតបច្ចុប្បន្ន មិនមែនជាជីវិតអនាគត ជីវិតក្នុងអនាគតមិនមែនជាជីវិតបច្ចុប្បន្ន មិនមែនជាជីវិតអតីតៈ ឯចំណែកជីវិតបច្ចុប្បន្នមិនមែនជាជីវិតអតីតៈ មិនមែនជាជីវិតអនាគតឡើយ ។

អត្តភាពមនុស្សយើងម្នាក់ៗ ក្នុងមួយជាតិ មួយកំណើត គឺមានជីវិតយ៉ាងនេះឯង ដែលជាជីវិត **សន្តតិ** " តំណ " ដូច្នេះ ជីវិតជាមនុស្ស ជាសត្វ ជាតួខ្លួនពុំមានទេ **តែជីវិតគឺជារូបធម៌ និងជានាមធម៌ ដែលសំរេចបានយ៉ាងត្រឹមត្រូវពិតប្រាកដតាមហេតុ-បច្ច័យ ដែលបានញាំងជីវិតឱ្យកើតឡើង ៗ**

ជីវិតកើតឡើងមានតួនាទីជាអ្នកតាមអនុបាលរក្សានូវសហជាតិធម៌ឱ្យតាំងនៅក្នុងឋិតិខណៈ "ខណៈតាំងនៅ " រួចហើយក៏បានបែកធ្លាយទៅវិញ ស្លាប់ទៅវិញព្រមគ្នាដោយសហជាតិធម៌ក្នុងភង្គខណៈ "ខណៈបែកធ្លាយ " ជីវិតត្រូវបានបញ្ចប់ត្រឹមតែប៉ុណ្ណោះឯង ជីវិត ៥០ឆ្នាំ ឬ ៦០ឆ្នាំ ឬ ១០០ឆ្នាំ ពុំមានឡើយ ប៉ុន្តែដែលយើងតែងតែនិយាយគ្នា ថារស់បានប៉ុណ្ណោះឆ្នាំ ប៉ុណ្ណោះឆ្នាំ គឺរាប់ដោយជីវិតសន្តតិក្នុងមួយជាតិកំណើតក្នុងមួយអត្តភាព មួយភ្លែតៗនៃជីវិតមានជាតិផ្សេងៗគ្នាតាមតែបច្ច័យនៃជីវិត ជួនជាជីវិតមានជាតិជាកុសល ជួនជាជីវិតមានជាតិជាអកុសល ជួនកាលជីវិតជាវិបាកជាតិ ពេលខ្លះជាកិរិយាជាតិ ការអប់រំសតិវិបស្សនា គឺជាការហ្វឹកហាត់ចំណេះវិជ្ជាឱ្យចេះដឹងក្នុងរឿង ជីវិតជាប្រក្រតី ពុំមែនជាការហ្វឹកហាត់ ក្នុងចំណេះវិជ្ជាដទៃឡើយ ។

ហេតុបច្ច័យនៃជីវិត ពុំមែនជាបុគ្គលណាដែលថាអ្នកដទៃ ឬខ្លួនយើងឡើយ តាមពិតហេតុបច្ច័យនៃជីវិតបច្ចុប្បន្ន គឺ អវិជ្ជា តណ្ហា ឧបាទាន កម្មភពក្នុងអតីតជាតិ ឯចំណែកអាហារ ផស្សៈ ចេតនា វិញ្ញាណ ជាបច្ច័យក្នុងបច្ចុប្បន្នខណៈនៃជីវិត ដូច្នេះការចំរើនសតិប្បដ្ឋានវិបស្សនា

គឺមិនមែនជាការគិតសាងជីវិតខ្លួនឱ្យយ៉ាងនេះឱ្យយ៉ាងនោះទេ តែត្រូវផ្ដើមសង្កេតពិនិត្យចំពោះជីវិតក្នុងបច្ចុប្បន្ន ខណៈឱ្យឃើញដោយបញ្ញាទៅតាមសេចក្ដីពិតនៃជីវិត រួចហើយបញ្ញាអាចមានកម្លាំងប្រគល់ទុកដាក់ជីវិតក្នុងបច្ចុប្បន្នឱ្យនៅលើហេតុ-បច្ច័យ ដោយមិនបានប្រកាន់ថា ជាខ្លួនយើងអ្នករស់នៅឡើយ ជីវិតកើតឡើងជាទីតាំងនៃជរា-មរណៈ បញ្ញាមានកម្លាំងដោយសតិប្បដ្ឋានបដិបត្តិ ឃើញជីវិតរលត់ ឃើញជីវិតបែកធ្លាយ ពុំមែនខ្លួនជាអ្នកស្លាប់ បញ្ញាជាក់ច្បាស់យ៉ាងនេះឯង ដែលបាននាំសត្វឱ្យបានដល់ទីឋានដែលមិនស្លាប់ ពោលគឺ ព្រះនិព្វាន ។

ការចំរើនសតិប្បដ្ឋាន គឺការហ្វឹកហាត់ស្មារតីរលឹកដឹងទាន់រឿយៗចំពោះសភាវធម៌ដែលកំពុងប្រាកដជាប្រក្រតីក្នុងជីវិតប្រចាំថ្ងៃតាមទ្វារទាំង ៦ ។

ជីវិតជួនកាលជា **កុសលវិបាក** ត្រូវបានលាភ ត្រូវបានយស បានការសរសើរលើកតំកើង សតិប្បដ្ឋានបដិបត្តិកំចាត់សេចក្ដីស្រវឹង ការវង្វេងជ្រុលជ្រប់ក្នុងលាភយស ការសរសើរលើកតំកើង ព្រោះជាក់ច្បាស់ដោយបញ្ញាឃើញថា **កុសលវិបាក** ទាំងអស់នេះ សុទ្ធតែជាធម៌សុទ្ធៗ តាក់តែងដោយហេតុ-បច្ច័យ ដោយកុសលកម្មផ្សេងៗ ត្រូវបានជាចំណីនៃពេលវេលាដែលកន្លងហួសទៅ។

ជួនកាលជីវិតជា **អកុសលវិបាក** ត្រូវមានរោគាព្យាធិ អត់លាភ អត់យស គ្មានការរាប់អាន ទទួលអនិដ្ឋារម្មណ៍ គឺអារម្មណ៍មិនល្អ មិនជាទីប្រាថ្នាសព្វគ្រប់ប្រការ សតិប្បដ្ឋានបដិបត្តិមិននាំឱ្យប្រកាន់នៅក្នុង **អកុសល–វិបាក** នោះៗ ព្រោះបានឃើញពិតដោយបញ្ញា គឺបានឃើញថាជីវិតនេះជារបស់ហេតុ ពិតប្រាកដតាមហេតុ ជាសច្ចធម៌ កែប្រែមិនបាន ហើយក៏ជាទីតាំងនៃការចំរើនប្រាជ្ញាស្មារតី រលាស់ចោលនៅជីវិតនេះប្រគល់ឱ្យហេតុជាអ្នកតាក់តែង ដោយមិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងជីវិតជាបច្ចុប្បន្ននេះ ឃើញជាធម៌ពិតៗ មានសន្ដានចិត្តស្ងប់ត្រជាក់ ធ្វើដំណើរតាមមគ្គដ៏ប្រសើរក្នុងបដិបទាដ៏បរិសុទ្ធ

ទៅកាន់ទីបំផុតទុក្ខគឺ ព្រះនិព្វាន ។

ការចេះរស់នៅជាមួយជីវិតបច្ចុប្បន្ន ពោលគឺមានបញ្ញាឃើញជីវិតពិតទៅតាមហេតុ ដោយមិនប្រកាន់ជីវិតថាជារបស់ខ្លួនឡើយ ។

# បទពិចារណាជុំវិញជីវិត

❋ ធម្មតាលាមក មានក្លិនស្អុយយ៉ាងណា ផ្កាម្លិះ ផ្កាចំប៉ា មានក្លិនក្រអូបយ៉ាងណា ធម្មតានៃជីវិតក៏តែងតែយ៉ាងហ្នឹងឯង ដូចដែលជាក់ស្តែងចំពោះមនុស្សគ្រប់ៗគ្នា ។

❋ ហេតុអ្វីបានជានាងបដាចារបាត់ឆ្កួត ហើយបានទៅជាអរិយសាវិកាដ៏ឆ្នើមមួយអង្គ ?

-នេះមិនមែនមកអំពីកូនទាំងពីរ និង ប្តីរបស់នាងរស់ឡើងវិញ ឬមកអំពីលោកអ្នកដ៏មានគុណទាំងពីរ និងបងប្រុសរបស់នាងរស់មកវិញឡើយ ប៉ុន្តែគឺមកអំពីឧបនិស្ស័យបុណ្យ និង មកអំពីបានយល់ បានចេះដឹងរឿងរបស់ជីវិត ។

❋ មនុស្សលោកតែងកន្ទក់កន្ទេញក្តៅក្រហាយចិត្តក្នុងបុគ្គល-វត្ថុ រឿងដែលទាស់ចិត្ត នេះមកអំពីមិនយល់រឿងរបស់ជីវិត មិនដឹងថាជីវិតវាយ៉ាងហ្នឹងឯង ហើយ

បន្ថែមលើការមិនយល់នេះ បានប្រកាន់យ៉ាងមាំថា ជីវិតនេះគឺជាតួខ្លួន ឬ ជារបស់ខ្លួន ។

✵ ជីវិតប្រកបព្រមដោយឧបាទានក្ខន្ធទុក្ខទាំង ៥ កង ការមិនប្រកាន់នូវជីវិតថា ជាសត្វបុគ្គលតួខ្លួន នេះឯងគឺជាកោះ ជាទីពឹងក្នុងស្រះធំ បុគ្គលបានដល់នូវទីពឹងនោះ ដែលមិនមានជរា និង មច្ចុ ព្រោះជរា និង មច្ចុ គ្រប់គ្រងតែក្នុងដែននៃជីវិត ។

✵ សត្វលោកជាទាសករនៃជីវិតខ្លួនឯង ដោយមិនដឹងថា ជីវិតនេះជាម្រឹត្យូវ ។

✵ ការមើលងាយអ្នកដទៃ ដោយថា គេជាអ្នកក្រខ្សត់ ត្រកូលទាបថោក គេជាមនុស្សល្ងង់ គេជាមនុស្សអាក្រក់ ឬគេជាមនុស្សយ៉ាងនេះៗ ការមើលងាយនេះព្រោះហេតុតែខ្លួនឯងមិនយល់រឿងរបស់ជីវិត ខ្លួនឯងល្ងង់ សូម្បីតែជីវិតខ្លួនឯងជាឃាតករ បាននាំយកខ្មាំង៥នាក់មកឱ្យរស់នៅជាមួយ សំរាប់សម្លាប់ខ្លួនឯង ក៏ខ្លួនឯងមិនដឹង ខំតែប្រឹងលើកតំកើងជីវិតខ្លួនឯង ហើយមើលងាយអ្នកដទៃ។

## តាមពិតគ្រប់ជីវិតស្មើគ្នាត្រង់អនិច្ចដែលជីវិតជាអាហាររបស់ម្រឹត្យូ ។

✵ ជ្រូកស្រុកគេចិញ្ចឹមសំរាប់យកសាច់បរិភោគ ទោះបីជ្រូកនោះធាត់ឬស្គម ក៏មិនមានបានសាច់អ្វីសំរាប់ជ្រូកនោះឡើយ ឬថា ជ្រូកនោះមានសល់អ្វីសំរាប់ខ្លួនឯងជាជ្រូកក៏ទេដែរ ព្រោះថា មនុស្សគេជាអ្នកបរិភោគ យ៉ាងណាគ្រប់ជីវិតទាំងអស់សុទ្ធតែនៅក្នុងទ្រុងរបស់មច្ចុរាជ ដូចឧទាហរណ៍អំពីរឿងជ្រូកស្រុកយ៉ាងនោះឯង ។

មនុស្សលោកដែលមិនបានសិក្សាឱ្យចេះអំពីរឿងជីវិតនេះ តែងតែស្វែងរកសេចក្តីសប្បាយសំរាប់ជីវិតខ្លួន ឯង ទោះជាដឹងថាមុខតែស្លាប់ក្នុងថ្ងៃណាមួយក៏ដោយ តែងយល់ចូលចិត្តថា កើតមកសំរាប់តែស្លាប់ទៅវិញយ៉ាងនេះ ត្រូវតែសប្បាយទៅតាមចំណង់ចំណូលចិត្ត និង ទៅតាមសមត្ថភាពដែលខ្លួនឯងអាចស្វែងរកបាន។

មនុស្សលោកល្ងង់ណាស់ ដែលគិតថា ត្រូវស្វែងរកសេចក្តីសប្បាយឱ្យបានច្រើនសំរាប់ជីវិតដែលកើតមកនេះ។

មនុស្សលោកខំប្រឹងដណ្តើមពេលវេលាអំពីម្រឹត្យូវ ដើម្បីសេចក្តីសប្បាយក្នុងកាមគុណ ។ មនុស្សលោកខ្លាច បាត់បង់ជីវិតទៅទាំងការមិនបានសប្បាយ ខ្លាចខាតពេល វេលាសំរាប់សប្បាយ ។

មនុស្សលោកមើលឃើញការចំណេញអំពីការរស់ នៅ និង ខ្លឹមសារនៃការរស់នៅ គឺសេចក្តីសប្បាយក្នុងជីវិត នេះឯង ប៉ុន្តែ ទោះបីជាខិតខំប្រឹងប្រែងស្វែងរកយ៉ាងណា ក៏ដោយ លទ្ធផលគឺស្លាប់ទៅទាំងមិនឆ្អែត ។

ហេតុអ្វីបានជាមនុស្សលោកស្លាប់ទៅទាំងមិនឆ្អែត ក្នុងសេចក្តីសប្បាយយ៉ាងនេះ ?

តាមពិតពេលវេលាដែលមនុស្សលោកខំប្រឹងដណ្តើម អំពីមច្ចុរាជ ដើម្បីយកមកសំរាប់ស្វែងរកការសប្បាយនោះ ពេលវេលានោះឯងវាជាចោរ តែងតែឆក់ដណ្តើមយកសេចក្តីសប្បាយរីករាយរបស់សត្វលោកទៅ គ្រប់ការសប្បាយ ទាំងអស់ពុំមានសល់ ។ បន្សល់ទុកនៅតែការជាប់ចិត្ត និង ការស្រេកឃ្លានតែប៉ុណ្ណោះ ។

សត្វលោកត្រូវបាត់បង់នូវសេចក្តីសប្បាយដែលខ្លួន ខំស្វែងរកបានទាំងការលំបាក រាល់ពេល រាល់ថ្ងៃ បានបាត់ បានបាត់ ទីបំផុតនៅក្រោមអាជ្ញារបស់មច្ចុរាជ សត្វលោក ត្រូវបាត់បង់នូវវត្ថុជាទីពេញចិត្តគ្រប់យ៉ាងដូចជា ទ្រព្យធន បុត្រភរិយា ស្វាមី ទាសាទាសី ដីធ្លីនគរ និង កាមគុណគ្រប់ យ៉ាង នៅសល់តែសំពត់ ១ផ្ទាំងដែលគេរុំសរីរៈយកទៅដុត តែប៉ុណ្ណោះ ។

សត្វលោកស្លាប់ទៅទាំងខ្វះខាត ទាំងតក់ស្លុត ដូច្នេះ ដែលសត្វលោកខំប្រឹងស្វែងរកការសប្បាយរីករាយមុន ពេលស្លាប់នោះ ពិតជាមិនមានបានប្រយោជន៍អ្វីនៅពេល ដែលសេចក្តីស្លាប់មកដល់នោះឡើយ ព្រោះវាមិនបានឆ្អែត ឡើយ សូម្បីបានរស់នៅដល់អាយុ ១០០ឆ្នាំ ឬ ១០០០ឆ្នាំ ឬ មួយអសង្ខេយ្យក៏ដោយ វារឹងរឹតតែចំរើនដោយការស្រេក ឃ្លានសេចក្តីប្រាថ្នាត្រូវការទៅវិញទេ ។

ហេតុអ្វីបានជាសត្វលោកស្វែងរកសេចក្តីសប្បាយ ពេញចិត្តជាមួយនឹងសេចក្តីសុខ ?

ពីព្រោះសត្វលោកកើតមកមានទុក្ខ មានសេចក្តីលំបាកក្នុងជីវិត ព្រោះបញ្ចក្ខន្ធ ហើយទាស់ចិត្តចំពោះទុក្ខលំបាកនោះ ព្រមទាំងប្រកាន់នូវសេចក្តីទុក្ខដោយបញ្ចក្ខន្ធនោះថាជាខ្លួន ថាជារបស់ខ្លួនទៀតផង ។

បើមិនមានទុក្ខជាប់តាមជីវិតមកទេនោះ មនុស្សលោកមិនចាំបាច់ស្វែងរកសេចក្តីសុខ និង ការសប្បាយរីករាយឡើយ **ប៉ុន្តែព្រោះហេតុតែមនុស្សលោកខ្វេខ្វាយជាប់ជំពាក់ចិត្តជាមួយសុខសោមនស្សរីករាយភ្លើតភ្លើនក្នុងការសប្បាយ ក៏បានជាភ្លេចចំពោះសេចក្តីទុក្ខ មិនបានឃើញទោសនៃជីវិតដែលនាំមកទុក្ខ និង បញ្ហាមកជាមួយ ។**

សត្វលោកល្ងង់ខ្លៅណាស់ ដែលព្រមទទួលយកនូវជីវិតពេញដោយទុក្ខ និង បញ្ហានេះមកធ្វើជាតួខ្លួន ប្រកាន់ថាជាខ្លួន ហើយត្រេកអរនឹងការកង្វល់ រវល់ដោះស្រាយបញ្ហាទុក្ខលំបាករបស់ជីវិត ។

សត្វលោកព្រមទទួលយកការស្រេកឃ្លានមកធ្វើជាតួខ្លួនជារបស់ខ្លួន ហើយពេញចិត្តក្នុងការស្វែងរកអាហារបរិភោគ មាននូវ **មានៈ** ស្រើងក្នុងការបាននូវអាហារសំរាប់បរិភោគ ពេញចិត្តនឹងឆ្អែត ។

មនុស្សលោកយើងល្ងង់ណាស់ ប្រៀបដូចសុខចិត្តឱ្យគេអារសាច់ ព្រមទទួលយកនូវការឈឺផ្សា ហើយទើបពេញចិត្តដើម្បីព្យាបាលនូវរបួសនោះឱ្យជាបន្តិចៗ កាលរបួសក្លាយជាដំបៅឈឺចាប់លំបាក ក៏បានសប្បាយក្នុងការលាងនូវដំបៅ និង បិទដំបៅ ។

សត្វលោកល្ងង់ខ្លៅ មានឧបាទានព្រមទទួលយកទុក្ខលំបាកក្នុងសង្សារវដ្តរាប់ជាតិជាអនេកមកហើយ សត្វលោកមិនដែលដឹងថា អ្វីជាការមិនមានទុក្ខទាំងស្រុង អ្វីដែលជាការមិនមានរោគពិតប្រាកដ អ្វីដែលជាសុខពិតប្រាកដដោយមិនចាំបាច់ស្វែងរកសុខដទៃទៀតនោះទេ ។

សត្វលោកធ្លាប់ជួបប្រទះតែនឹងកាមសុខ និង សុខ

ក្នុងភព ដែលសុខនេះព្រោះការព្យាបាលរបួស ព្រោះការព្យាបាលរោគ ប៉ុន្តែសត្វលោកមិនបានដឹងថា សុខព្រោះមិនមានរោគពិតប្រាកដនោះដូចម្តេចឡើយ ។

ព្រមជាមួយគ្នានឹងការដែលសត្វលោកត្រេកអររីករាយចំពោះសេចក្តីសុខក្នុងភព សត្វលោកក៏បានព្រមទទួលយកនូវទុក្ខក្នុងជីវិតនេះ មកធ្វើជាខ្លួន និង របស់ខ្លួនបន្តទៅទៀតផងដែរ ។

≈≈ ≈≈

# ហេតុប្បច្ចយោ

≈≈ ≈≈

ចេតសិក ៦ ជាតួហេតុ គឺ លោភចេតសិក ទោសចេតសិក មោហចេតសិក ៣ នេះ ជាអកុសលហេតុ ។

អលោភចេតសិក អទោសចេតសិក អមោហចេតសិក ៣ នេះ ជាកុសលហេតុ និង ជាអព្យាកតហេតុ ។

**ព្រះបាលីវិភង្គបាឋ:**

**ហេតូ ហេតុសម្បយុត្តកានំ ធម្មានំ តំសមុដ្ឋានានញ្ច រូបានំ ហេតុប្បច្ចយេន បច្ចយោ ។**

ប្រែ : ហេតុ ជាបច្ច័យដល់ធម៌ទាំងឡាយ ដែលប្រកបដោយហេតុ និង ដល់រូបទាំងឡាយដែលមាន ហេតុព្រមទាំងធម៌ដែលមានហេតុនោះជាសមុដ្ឋានដោយអំណាចហេតុប្បច្ច័យ ។

## បដ្ឋានអត្ថកថា

**មូលដ្ឋេន ឧបការកោ ធម្មោ = ហេតុប្បច្ចយោ** ធម៌ដែលជួយឧបការៈ ព្រោះអត្ថថា ជា **មូលគោល** ឈ្មោះថា ហេតុប្បច្ច័យ ។

**វចនត្ថៈនៃបច្ច័យ** (អត្ថន័យរបស់ពាក្យ) **បដិច្ច ផលំ អយតិ ឯតស្មាតិ បច្ចយោ** ផលធម៌រមែងកើតឡើង តាំងនៅបាន ព្រោះដោយអាស្រ័យធម៌ដែលជាហេតុ ដូច្នេះ ធម៌ដែលជាហេតុនេះឈ្មោះថា បច្ច័យ (បច្ច័យក្នុងមហាបដ្ឋានទាំងអស់) ។

## សេចក្តីពន្យល់អំពីហេតុប្បច្ច័យ

✵ មានមតិមួយចំនួនបានយល់ថា អ្នកបរិភោគសាច់សត្វ ជាហេតុនាំឱ្យគេសម្លាប់សត្វ ការយល់នេះខុសទេ ព្រោះ **ហេតុ** នៃការសម្លាប់សត្វពិត១ បានដល់អកុសលហេតុ ៣ យ៉ាងគឺ :

-លោភហេតុ និង មោហហេតុក្នុងខណៈស្រឡាញ់ខ្លួនឯងជាដើម ។

-ទោសហេតុ និង មោហហេតុក្នុងពេលវេលាត្រូវសម្លាប់ជីវិតសត្វ ។

បើសិនជាការសម្លាប់សត្វ មកអំពីអ្នកបរិភោគសាច់សត្វជាហេតុនោះ ម៉្លេះសមព្រះអរិយបុគ្គលក៏លោកនៅតែសម្លាប់សត្វដែរ ប៉ុន្តែព្រះអរិយបុគ្គលមិនសម្លាប់សត្វ មិនមែនព្រោះអ្នកដទៃមិនបរិភោគសាច់សត្វនោះឡើយ តែគឺព្រោះអរិយមគ្គបានលះបង់នូវអកុសលហេតុដែលជាហេតុនៃការសម្លាប់សត្វបាត់អស់ទៅហើយ ។

ព្រះធម៌សុំសួរថា អ្នកលួចទ្រព្យសម្បត្តិគេ ព្រោះមកអំពីគេមាននូវទ្រព្យសម្បត្តិជាហេតុឬ ? អ្នកប្រព្រឹត្តខុសក្នុងកាម ព្រោះមកអំពីគេមានបុត្រភរិយាជាហេតុឬ? អ្នកនិយាយកុហកគេ មកអំពីមានគេសំរាប់ឱ្យនិយាយកុហកជាហេតុឬ ? អ្នកបរិភោគទឹកស្រវឹង មកអំពីមានអ្នកដទៃធ្វើស្រា ធ្វើទឹកស្រវឹងផ្សេង១ជាហេតុឬ ?

តាមពិតបុគ្គលគួរសិក្សាថា អត្តាអញជាពុទ្ធបរិស័ទ ត្រូវតែយល់អំពីធម៌ទាំងឡាយកើតអំពីហេតុ ត្រូវសិក្សាឱ្យបានយល់ច្បាស់អំពីហេតុ និង ផលរបស់ហេតុ ។

ហេតុក៏ជាធម៌ (បរមត្ថធម៌) ផលរបស់ហេតុក៏ជាធម៌ ក្នុងលោកនេះមានតែធម៌ មិនមានសត្វទេ ។

# បច្ចយុប្បន្នធម៌

<u>**វចនត្ថ**</u> **– បច្ចយតោ ឧប្បន្នំ បច្ចយុប្បន្នំ**

= ផលធម៌ដែលកើតអំពីបច្ច័យឈ្មោះថា **បច្ចយុប្បន្ន** (បច្ចយ + ឧប្បន្ន) ។

## បច្ចយុប្បន្នធម៌របស់ហេតុប្បច្ច័យ

- សហេតុកចិត្ត ៧១ ចេតសិក ៥២ (វៀរមោហចេតសិកដែលប្រកបជាមួយមោហមូលចិត្ត ២ដួង) ។

- សហេតុកចិត្តជរូប ១៧ និង សហេតុកបដិសន្ធិកម្មជរូប ២០ ។

<u>**ពន្យល់ពាក្យ**</u> **:**

- **សហេតុកចិត្ត** = ចិត្តដែលមានហេតុកើតរួមជាមួយ គឺហេតុ ៦ ហេតុណាមួយក៏បាន ចិត្តខ្លះមានហេតុ ១ ចិត្តខ្លះមានហេតុ២ ចិត្តខ្លះមានហេតុ៣ ដូច្នេះ **សហេតុក**

**ចិត្ត** ចែកជា ៣ ចំណែក គឺ :

**-ឯកហេតុកចិត្ត** - មាន ២ដួងបានដល់មោហមូល-ចិត្ត ២ដួង ។

**-ទ្វិហេតុកចិត្ត** - មាន ២២ដួង បានដល់លោភ-មូលចិត្ត ៨ដួង ទោសមូលចិត្ត ២ដួង និង កាមាវចរសោ-ភណចិត្តញាណវិប្បយុត្ត ១២ដួង ។

**-តិហេតុកចិត្ត** - មាន ៤៧ដួង ឬ៧៩ដួង បានដល់កាមាវចរសោភណចិត្តញាណសម្បយុត្ត ១២ដួង មហគ្គតចិត្ត ២៧ដួង និង លោកុត្តរចិត្ត ៨ដួង ឬ ៤0ដួង ។

❋ ដើម្បីឱ្យចេះរកសហេតុកចិត្ត ត្រូវរៀនចេតសិកប្រកបជាមួយចិត្តគ្រប់ដួងទាំងអស់ រួចហើយពិនិត្យរកចេតសិកជាតួហេតុ បើរកឃើញក្នុងចិត្តមួយដួងណាមានហេតុប៉ុន្មាន ចិត្តមួយដួងនោះ ក៏មានហេតុកើតរួមជាមួយតែប៉ុណ្ណោះ ប៉ុន្តែចិត្តដួងនីមួយៗដែលមានហេតុនោះ មិនលើសអំពីមានហេតុ ៣ ទេ ចិត្តដួងខ្លះមានតែហេតុ ២ ចិត្តដួងខ្លះមានតែហេតុ១ ចិត្ត ១៨ដួងមិនមានហេតុគឺ **អហេតុកចិត្ត**ដែលប្រកបតែជាមួយចេតសិកជា **នហេតុ**ប៉ុណ្ណោះ ។

ចេតសិក៥២ ប្រភេទ បានប្រកបជាមួយសហេតុកចិត្ត ៧១ ដួង ប៉ុន្តែក្នុងមោហមូលចិត្ត ២ ដួង ដែលជាឯកហេតុកចិត្ត គឺចិត្តដែលមានហេតុតែមួយ បានដល់មោហចេតសិកជាតួហេតុ ចំណែកចេតសិក ១៤ ទៀត ដែលប្រកបជាមួយដែរនោះ សុទ្ធតែជា **នហេតុ** គឺមិនមែនជាតួហេតុ ដូច្នេះមោហចេតសិកជាតួហេតុ តែជា **អហេតុកចេតសិក** ក្នុងមោហមូលចិត្ត ២ ដួង ប៉ុន្តែបានជារាប់ **សហេតុកចេតសិក ៥២** គ្រប់ទាំងអស់នៃប្រភេទចេតសិក ព្រោះមោហចេតសិកក្នុង លោភមូលចិត្ត ៨ដួងប្រកបជាមួយហេតុ១ គឺលោភចេតសិក ដោយលោភចេតសិកនេះជាតួហេតុ ម្យ៉ាងទៀតមោហចេតសិកក្នុងទោសមូលចិត្ត ២ដួង ប្រកបជាមួយហេតុ ១ដែរ គឺទោសចេតសិកដោយសារទោសចេតសិកជាតួហេតុ ដូចនេះមោហចេតសិក

ក្នុងអកុសលចិត្ត ១០ដួង ជា **សហេតុកចេតសិក** ដោយ ពិត ជាបច្ចយុប្បន្នធម៌ របស់ហេតុប្បច្ច័យ ។

**ពន្យល់ពាក្យ :**

**-សហេតុកចិត្តជរូប** = រូបកើតអំពីសហេតុកចិត្ត ជាសមុដ្ឋាន ។

នៅក្នុងសហេតុកចិត្ត ៧១ ដួង មួយដួង១សុទ្ធតែ មានហេតុ ដូច្នេះរូបដែលកើតអំពីសហេតុកចិត្តក៏ជាបច្ចយុ-ប្បន្នធម៌ របស់ហេតុប្បច្ច័យដោយពិត ។

**មុច្ចជូនតែងប្រកាន់ថា រូបនៅក្នុងអំណាចខ្លួន ព្រោះប្រកាន់ចិត្ត និង ចេត-សិកដែលជាបច្ច័យនាំឱ្យរូបកើតឡើងនោះថាជាតួខ្លួន ។**

តាមពិតចិត្ត និងចេតសិក តែងតែដូរផ្លាស់គ្រប់ពេល កើតឡើងហើយកន្លងទៅ វិនាសទៅវិញយ៉ាងឆាប់រហ័ស ពុំមែនជាសត្វបុគ្គលតួខ្លួនយើងគេឡើយ ។

ម្យ៉ាងទៀត ចិត្ត ចេតសិក មិនមែនជាអ្នកបង្គាប់បញ្ជារូបកាយឡើយ ចិត្តគិតធ្វើអ្វី១ ឬគិតនិយាយពាក្យអ្វី១ តាមពិតចិត្តគិតនេះ កើតឡើងមានតួនាទីតោងយកអារម្មណ៍តែប៉ុណ្ណោះ មានអារម្មណ៍បញ្ញត្តិក្នុងរឿងដែលត្រូវធ្វើ ឬ ដែលត្រូវនិយាយផ្សេង១ជាដើម ប៉ុន្តែដោយសារធម្មជាតិចិត្តមានកម្លាំង ក៏បានជាសមុដ្ឋានញ៉ាំងរូបឱ្យកើតឡើង មានចិត្តជវិញ្ញត្តិធាតុនាំឱ្យកំរើកកាយ និង ចិត្តជបថវីធាតុ នាំឱ្យកំរើកវាចារជាដើម ។

ចិត្តជាសមុដ្ឋានរបស់រូប ពុំបានដឹងរូបដែលកើតអំពីចិត្តឯងទេ គឺដឹងអារម្មណ៍ដែលខ្លួនឯងបានតោងយកតែប៉ុណ្ណោះ ហើយចិត្តសមុដ្ឋានរូបដែលកើតអំពីចិត្តនោះ គឺកើតស្មើដោយឧប្បាទខណៈនៃចិត្តជាសហជាតិធម៌ បើយ៉ាងនេះចិត្តអាចបង្គាប់រូបបានយ៉ាងណាទៅ ប្រៀបដូចអណ្តាតប្រទីបដែលនាំឱ្យពន្លឺកើតឡើង ឬ ដុំរងើកភ្លើងដែលនាំឱ្យមាននូវកំដៅ ឬដើមឈើកណ្តាលថ្ងៃនាំឱ្យមានម្លប់ ឬផ្សិតដុះចេញអំពីក្នុងដីទូលធូលីដីមកជាមួយអញ្ចឹងឯង ។

ចំពោះរូបធមិទាំងអស់ សុទ្ធតែជាធាតុមិនដឹង តើឈ្មោះថា ជាអ្នកទទួលបញ្ហាអំពីចិត្តដូចម្តេចបាន ។

**បរមត្ថធម៌ក្នុងជីវិតប្រចាំថ្ងៃ មានតែ ហេតុ និង ផល ដែលហេតុនេះជាតួបច្ច័យ ទាំងឡាយ មានហេតុប្បច្ច័យ អារម្មណប្បច្ច័យ កម្មប្បច្ច័យ ឧបនិស្សយប្បច្ច័យជាដើម ៗ**

ផលធមិទាំងឡាយដែលជាផលរបស់បច្ច័យ ជាសភាវពិតត្រឹមត្រង់តាមហេតុតាមបច្ច័យ ត្រឹមតែជាផលរបស់ហេតុពិតៗ ពុំមែនសត្វ ពុំមែនមនុស្ស ឬទេវតា គឺជាសង្ខារធមិសុទ្ធ បុគ្គលចំរើនបញ្ញា មិនចាប់យកដោយការប្រកាន់មាំចំពោះសង្ខារថាជាសត្វ ថាជាបុគ្គលតួខ្លួន ឬថាជារបស់ខ្លួនឡើយ ឃើញដោយបញ្ញាពិតៗក្នុងជីវិតប្រចាំថ្ងៃ ចំពោះសង្ខារធមិត្រឹមតែជាផលរបស់បច្ច័យ កើតឡើងហើយកន្លងទៅ វិនាសទៅ មិនតាំងនៅ អស់ទៅ សូន្យទៅ ។

# សហេតុកចិត្តជរូប ១៧ គឺ :

**១-រូបារម្មណ៍** ដែលកើតអំពីសហេតុកចិត្ត ជាលោកនៃការរស់នៅក្នុងខណៈចក្ខុទ្វារវិថីចិត្តកើតឡើង ។

**២-សទ្ទារម្មណ៍**ដែលកើតអំពីសហេតុកចិត្តជាលោកនៃការរស់នៅក្នុងខណៈសោតទ្វារវិថីចិត្តកើតឡើង ។

**៣-គន្ធារម្មណ៍**ដែលកើតអំពីសហេតុកចិត្ត ជាលោកនៃការរស់នៅក្នុងខណៈឃានទ្វារវិថីចិត្តកើតឡើង ។

**៤-រសារម្មណ៍**ដែលកើតអំពីសហេតុកចិត្ត ជាលោកនៃការរស់នៅក្នុងខណៈជិវ្ហាទ្វារវិថីចិត្តកើតឡើង ។

**៥-បឋវីជាផោដ្ឋព្វារម្មណ៍** មានលក្ខណៈ រឹង ឬ ទន់ ដែលកើតអំពីសហេតុកចិត្ត ជាលោកនៃការរស់នៅក្នុងខណៈកាយទ្វារវិថីចិត្តកើតឡើងដឹងបឋវីជាអារម្មណ៍ ។

**៦-តេជោ ជា ផោដ្ឋព្វារម្មណ៍** មានលក្ខណៈក្តៅ ឬត្រជាក់ ដែលកើតអំពីសហេតុកចិត្ត ជាលោកនៃការរស់នៅក្នុងខណៈ កាយទ្វារវិថីចិត្តកើតឡើង ដឹងតេជោ ជាអារ-

ម្មណ៍ ។

**៧-វាយោ ជា ផោដ្ឋព្វារម្មណ៍** មានលក្ខណៈតឹង ឬញ័រ ដែលកើតអំពីសហេតុកចិត្ត ជាលោកនៃការរស់នៅ ក្នុងខណៈ កាយទ្វារវិថីចិត្តកើតឡើងដឹងវាយោជាអារម្មណ៍

❋**សហេតុកចិត្តជរូប ជាធម្មារម្មណ៍** មាន ១០រូបគឺ អាបោ អាកាសធាតុ អាហាររូប វិញ្ញត្តិរូប២ វិការរូប៣ ឧបចយរូប និង សន្តតិរូប ។

ធម្មារម្មណ៍ ជាអារម្មណ៍របស់មនោទ្វារវិថីចិត្ត គឺចិត្ត ដែលកើតក្នុងមនោទ្វារមានការប្រព្រឹត្តិទៅដោយច្រើនក្នុង លោកនៃការនឹកគិត ។

**លោកមនុស្ស លោកទេវតា ព្រហ្ម-លោក ស្រុកខ្មែរ ស្រុកថៃ មនុស្សប្រុស មនុស្សស្រី មាសប្រាក់ ស្រុកភូមិ ផ្ទះ សម្បែង ។ល។ សុទ្ធតែជាលោកនៃការនឹកគិត បើការនឹកគិតមិនមានទេ លោកទាំង នេះ ក៏មិនមានដែរ ។**

❋សត្វលោកដោយច្រើនគ្រប់គ្នា បានហួងហែង បានស្រឡាញ់ បានស្អប់ ចំពោះលោកនៃការគិតនឹកនេះឯង តាមពិតលោកដោយបរមត្ថ មានការកើតប្រាកដរួចក៏រលត់ បាត់ទៅវិញភ្លាម នៅសល់តែចិត្តនឹកគិតដែលកើតបន្តតាម ក្រោយប្រឌិតនូវលោកនេះ លោកនោះ ស្រុកភូមិប្រទេស មានមនុស្ស មានសត្វ មានវត្ថុ ដែលបានតាំងនៅអស់កាល យូរៗ ។

❋សតិប្បដ្ឋានបដិបត្តិ បានរលឹកសិក្សាជារឿយៗ ជាប្រក្រតី ចំពោះវិថីចិត្តដែលបានកើតឡើងដឹងអារម្មណ៍ ក្នុងលោក ៦ និង អាចរលឹកសិក្សាជាទូទៅចំពោះសភាវពិត ជាបរមត្ថ ទើបបានកំចាត់បង់នូវការប្រកាន់លោកហួង ហែងលោកនេះចោលបាន ។

**ពន្យល់ពាក្យ :**

**-សហេតុកបដិសន្ធិកម្មជរូប ២០**

កម្មជ្ជរូប គឺរូបកើតអំពីកម្មអតីតៈ ជាសមុដ្ឋាន ឬជាបច្ច័យ ។

សហេតុកបដិសន្ធិ គឺបដិសន្ធិចិត្តដែលប្រកបដោយហេតុមាន ១៣ដួង គឺ មហាវិបាកបដិសន្ធិ ៨ដួង និង រូបាវចរវិបាកបដិសន្ធិ ៥ដួង ។

រួមសេចក្តីមកគឺ កម្មជ្ជរូបក្នុងខណៈនៃបដិសន្ធិដែលមានហេតុ បានដល់ហេតុបដិសន្ធិនោះជាបច្ច័យ កម្មជ្ជរូបដែលកើតព្រមនោះ ជាបច្ចយុប្បន្នធម៌ ។

កម្មជ្ជរូបកើតគ្រប់ៗខណៈចិត្តតូចៗរហូតទៅទល់គ្នានឹងជិតចុតិចិត្តនោះ ប៉ុន្តែកម្មជ្ជរូបខណៈបដិសន្ធិដែលទើបតែកើតដំបូងក្នុងអត្តភាពនោះ ត្រូវអាស្រ័យចិត្ត និង ចេតសិក ខណៈបដិសន្ធិជាជនកប្បច្ច័យ គឺបច្ច័យនាំឱ្យកើត ចំណែកខណៈចិត្តបន្ទាប់អំពីបដិសន្ធិ គឺបឋមភវង្គ មិនជាជនកប្បច្ច័យនៃកម្មជ្ជរូបទេ ហើយគ្រប់ខណៈចិត្តទៅក៏មិនជាជនកប្បច្ច័យនៃកម្មជ្ជរូបរហូត គ្រាន់តែចិត្តចេតសិកកើតក្រោយៗនោះ ឧបត្ថម្ភដល់រូបដែលបានកើតមុន ហើយរូបនោះពុំទាន់រលត់ទៅតែប៉ុណ្ណោះ ។

ក្នុងខណៈបដិសន្ធិមិនមានចិត្តជ្ជរូបទេ ព្រោះចិត្តនោះមានកម្លាំងខ្សោយ ដោយទើបតែកើតដំបូងក្នុងភពថ្មី ម្ល៉ោះហើយមិនអាចញ៉ាំងចិត្តជ្ជរូបឱ្យកើតបានទេ ហើយម្យ៉ាងទៀត ចិត្តពេលនោះរវល់តែជួយបង្កើតកម្មជ្ជរូបផង ប៉ុន្តែខណៈចិត្តក្រោយៗអំពីបដិសន្ធិចិត្ត ទើបមានកម្លាំងខ្លាំងញ៉ាំងចិត្តជ្ជរូបឱ្យកើតអំពីខ្លួនឯងបាន ទាំងកម្មជ្ជរូបដែលកើតក្នុងខណៈចិត្តក្រោយក៏មានកម្លាំង មិនចាំបាច់មានចិត្តជួយឱ្យកើតទេ ។

## កម្មជ្ជរូប២០ គឺ

អវិនិព្ភោគរូប ៨ អាកាសរូប ១ ឥន្ទ្រិយរូប ៨ ហទយរូប ១ ព្រមដោយជាតិរូប ២ទៀត ។

✵ **អវិនិព្ភោគរូប៨** ប្រែថា រូបមិនបែកគ្នា គឺកើតជាមួយគ្នា រលត់ទៅវិញក៏ជាមួយគ្នា ប៉ុន្តែបែកគ្នាដោយ

កិច្ចធ្វើជាអារម្មណ៍តាមទ្វារ ញ៉ាំងវិថីចិត្តឱ្យកើតឡើង ។ មាន ៨ គឺ :

មហាភូតរូប ៤ និង វណ្ណោ គឺ រូបារម្មណ៍ គន្ធោ គឺ គន្ធារម្មណ៍ រសោ គឺ រសារម្មណ៍ ឱជា គឺ អាហាររូប ។

✵ **ឥន្ទ្រិយរូប** ប្រែថា រូបមានកិច្ចជាធំក្នុងបច្ច័យ និង ជាធំក្នុងភាវៈនៃខ្លួនឯង ។ មាន ៨ គឺ :

**១-ចក្ខុន្ទ្រីយ៍** ជាធំក្នុងបច្ច័យ ញ៉ាំងចក្ខុវិញ្ញាណឱ្យកើតឡើងដោយមិនមានអ្វីជំនួសចក្ខុនេះបានឡើយ ចក្ខុនេះជាទ្វារនៃចក្ខុទ្វារវិថីចិត្ត វិថីចិត្តតាមទ្វារភ្នែកមានរូប គឺ ពណ៌ជាអារម្មណ៍ ។

នៅក្នុងលោកភ្នែកសូន្យទទេ ចាកសត្វបុគ្គល មានត្រឹមតែចិត្តឃើញនូវរូបារម្មណ៍ប៉ុណ្ណោះ នេះជាលោកក្នុងអរិយវិន័យ ជាទីតាំងនៃសតិរលឹក ជាលោកដែលព្រះអរិយលះបង់ការហួងហែង ។

**២-សោតិន្ទ្រីយ៍** ជាធំក្នុងការញ៉ាំងសោតវិញ្ញាណឱ្យកើតឡើង ។

នៅក្នុងលោកត្រចៀកសូន្យចាកអ្នកឮ សូន្យចាកសត្វបុគ្គល មានត្រឹមតែនាមធម៌ប៉ុណ្ណោះ ដែលបង្អោនទៅដឹងសំលេង ។

**៣-ឃានិន្ទ្រីយ៍** ជាធំក្នុងការញ៉ាំងឃានវិញ្ញាណឱ្យកើតឡើង ។

សេចក្តីនេះគឺត្រឹមតែនាមធម៌ បង្អោនទៅដឹងក្លិនក្នុងលោកច្រមុះ រួចក៏រលត់បាត់ទៅទាំងអស់ ។

**៤-ជិវ្ហិន្ទ្រីយ៍** ជាធំក្នុងការញ៉ាំងជីវ្ហាវិញ្ញាណឱ្យកើតឡើង ។

វិញ្ញាណមិនមែនអ្វីមួយទៀងទាត់ឋិតថេរឡើយ គឺអាស្រ័យឥន្ទ្រិយប្បច្ច័យ វិញ្ញាណកើតឡើងផ្សេងៗគ្នា ហើយមិនបានជួបគ្នាទេ មានតែការរលត់ទៅវិញជាបន្តបន្ទាប់ ។

**៥-កាយិន្ទ្រីយ៍** ជាធំក្នុងការញ៉ាំងកាយវិញ្ញាណឱ្យកើតឡើង ។

កាយបសាទជាទីតាំងនៃវេទនាផ្លូវកាយ មានសុខវេទនា និង ទុក្ខវេទនា រាល់ពេលសោយអារម្មណ៍ គប្បីសង្កេតពិនិត្យ រលឹកសិក្សាឱ្យបានជាក់ច្បាស់ថា ពុំមែនជាសត្វបុគ្គលតួខ្លួនយើងគេឡើយ ។

✵ឥន្ទ្រិយ៍ ៥យ៉ាងនេះ គឺជាបសាទរូបទាំង ៥ ជាការថ្លានៃមហាភូតរូបផ្សេងៗគ្នា គួរដល់ការប៉ះខ្ទប់ជាមួយគោចររូបគឺ រូបជាអារម្មណ៍តាមបញ្ចទ្វាររៀងៗខ្លួន មិនធ្វើកិច្ចជំនួសគ្នាបានឡើយ ។

**៦.ឥត្ថិន្ទ្រីយ៍** ជាធំក្នុងការប្រកាសភាពស្រី មិនមែនជាមនុស្សស្រី ជាសត្វជាបុគ្គលទេ តែគឺជាភាវរូបពិតៗ ជារូបបរមត្ថ ទើបមានការបញ្ញត្តិជាបុគ្គលជាសត្វ ជាស្ត្រីដោយអាស្រ័យឥត្ថីភាវរូប ។

**៧.បុរិសិន្ទ្រីយ៍** ជាធំក្នុងការប្រកាសភាពប្រុស មិនគប្បីគិតខុសថា ខ្លួនជាស្ត្រី ឬ ខ្លួនជាបុរសទេ តែគប្បីឃើញមហាភូតរូប និង ឃើញឧបាទាយរូបជាបរមត្ថធម៌ពិតៗវិញ ទើបអាចបានទីពឹង ។

**៨.ជីវិតិន្ទ្រីយ៍** ជាធំក្នុងការញ៉ាំងកម្មជរូបដែលកើតព្រមជាមួយគ្នាឱ្យប្រព្រឹត្តទៅបានរហូតអស់អាយុនៃរូបធម៌នោះ គឺជាធំដោយអនុបាលបច្ច័យ ។

✵រូបជីវិតិន្ទ្រីយ៍ គឺជីវិតនៃកម្មជរូប មិនមែនជាជីវិតសត្វបុគ្គលយើងឡើយ ដែលថាសត្វមានជីវិត គឺបុគ្គលបញ្ញត្តិអាចជាអារម្មណ៍នៃកុសលថ្នាក់ទាន អារម្មណ៍នៃកុសលថ្នាក់សីល ថ្នាក់សមថភាវនាបាន ប៉ុន្តែចំពោះកុសលថ្នាក់សតិប្បដ្ឋាន-វិបស្សនា ត្រូវប្រច័ក្សការពិតចំពោះរូបធម៌នាមធម៌ គឺជាការស្រាវជ្រាវរាវរកសេចក្ដីពិតចំពោះបរមត្ថធម៌ រកសត្វមិនមានឡើយ ។

ដោយឡែកអំពីអវិនិព្ភោគរូប ៨ និង ឥន្ទ្រិយ៍រូប ៨ នៅមានរូប ៤ទៀត គឺ :

**-អាកាសធាតុ ឬ បរិច្ឆេទរូប**

បានដល់រូបដែលចែកសំណុំរូបឱ្យដាច់ចេញដោយឡែកៗអំពីគ្នា ។

តាមពិត បើកុំតែមានអាកាសធាតុ មហាភូតរូបត្រូវជាប់គ្នាទាំងអស់ ម្ល៉ោះហើយ មិនអាចមានមនុស្សច្រើននាក់ទៅបានដូចសព្វថ្ងៃនេះទេ ឬសូម្បីវត្ថុ សម្ភារៈអ្វី១ក៏មិនមានទាំងអស់ដែរ ប៉ុន្តែដោយអាកាសធាតុបានចែកនូវរូបឱ្យជាដុំ១ផ្សេង១គ្នា ទើបបានជាសន្ទតមនុស្ស សត្វ របស់ទៅតាមការវិចិត្ររបស់បច្ច័យ និង ទៅតាមទ្រង់ទ្រាយសណ្ឋានរបស់រូបមួយដុំ១ ។

សេចក្តីនេះទោះជាយ៉ាងណាក៏ដោយក៏គប្បីយល់ចូលចិត្តថា គ្រាន់តែជាការចែករូបធមិប៉ុណ្ណោះ មិនមែនជាការចែកមនុស្ស សត្វ វត្ថុទេ ប្រៀបដូចដីមួយដុំ ហើយគេកេះមួយដុំតូចច្របាច់ធ្វើឱ្យមានរាងរៅផ្សេង១ មួយដុំតូចទៀតក៏កេះច្របាច់ធ្វើឱ្យមានរាងផ្សេងទៅទៀតទៅ ទោះជាច្រើនដុំយ៉ាងណាក៏ដោយចុះ ក៏វានៅតែដុំដី មិនអាចទៅជាវត្ថុអ្វីផ្សេង១គ្នាបានឡើយ នេះគឺវាគ្រាន់អាស្រ័យអាកាសធាតុប៉ុណ្ណោះ ដែលនាំឱ្យមានទ្រង់ទ្រាយសណ្ឋានផ្សេង១គ្នា ។

-**ហទយវត្ថុរូប** គឺវត្ថុដែលជាទីអាស្រ័យនៃមនោធាតុ និង មនោវិញ្ញាណធាតុ បានដល់បេះដូង ។

ចំពោះបេះដូងនេះ មិនសំដៅយកត្រង់ដុំសាច់មួយដុំដែលចាប់ប៉ះបាន វះកាត់ដូរផ្លាស់បាននោះទេ ប៉ុន្តែត្រង់សាច់នៃបេះដូងនោះឯងជាទីកើតនៃ ហទយវត្ថុកម្មជរូប គឺជាសុខុមរូបដ៏ល្អិត មានការកើតរលត់តគ្នាតាំងអំពីខណៈបដិសន្ធិមកម្ល៉េះ ។

-**ជាតិរូប២គឺៈ** ១ រូបសន្ទរ់ និង ១ទៀតរូប តំណរូបពីរនេះគឺជាលក្ខណៈនៃសភាវរូប បានដល់ឧប្បាទ ខណៈនៃកម្មជរូបហ្នឹងឯង ។ (ចំណែករូបពីរដទៃទៀត គឺ រូបជរា និង រូបមិនទៀង ដែលជាលក្ខណៈរូបដែរ នោះ គ្រាន់តែជាឋិតិខណៈ និង ភង្គខណៈ នៃសភាវរូបប៉ុណ្ណោះ ទើបមិនបានរាប់បញ្ចូលក្នុងចតុសមុដ្ឋាននិករូប ។

**ពន្យល់:** ឋិតិខណៈ គឺខណៈតាំងនៅ និង ភង្គខណៈ គឺខណៈបែកធ្លាយនៃរូប ខណៈទាំងពីរនេះ មិនមែនព្រោះសមុដ្ឋានទេ ប៉ុន្តែព្រោះអាយុរបស់សភាវរូបបានដល់ជរារូប **"ឋិតិខណៈ"** និង អនិច្ចតារូប **"ភង្គខណៈ"** ។ ចំណែកជាតិរូប

ពីរ គឺ រូបសទ្ទំ និង រូបតំណ ទើបព្រោះអាស្រ័យសមុដ្ឋាន នាំឱ្យបានសំរេចជាលក្ខណៈរូបក្នុងខណៈនៃសភាវរូបកើតឡើង គឺក្នុងឧប្បាទខណៈ "**ខណៈកើតឡើង** " ។

# បច្ចនិកធម៌

**វចនត្ថ: បច្ចុប្បន្នស្ស បតិបិរុទ្ធំ អនីកំ បច្ចនិកំ** = ពួកធម៌ដែលជាបដិបក្ខចំពោះបច្ចុប្បន្នធម៌ ហៅថា បច្ចនិកធម៌ ។

❈ ចំពោះពួកធម៌ដែលកើតអំពីហេតុប្បច្ច័យទាំងប៉ុន្មានហៅថា បច្ចុប្បន្នធម៌របស់ហេតុប្បច្ច័យ ប៉ុន្តែនៅមានសង្ខារធម៌មួយចំនួនទៀត មិនបានកើតព្រោះហេតុប្បច្ច័យទេ គឺ ជា បច្ចនិកធម៌នៃហេតុប្បច្ច័យ ។

**បច្ចនិកធម៌នៃហេតុប្បច្ច័យគឺ** : អហេតុកចិត្ត ១៨ អញ្ញសមានាចេតសិក ១២ (វៀរឆន្ទៈ) និង មោហចេតសិកក្នុងមោហមូលចិត្ត ២ ។ ព្រមទាំងអហេតុកចិត្តជរូប អហេតុកបដិសន្ធិកម្មជរូប ពាហិររូប អាហារជរូប ឧតុជរូប អសញ្ញសត្តកម្មជរូប បវត្តិកម្មជរូប ។

❈ ពិតមែនពួកធម៌ខ្លះ មិនបានកើតព្រោះហេតុ ៦ ណាមួយជាបច្ច័យក៏ដោយ ក៏ប៉ុន្តែអាចកើតឡើងបានព្រោះបច្ច័យផ្សេងៗទៀត ដែលថាសង្ខារធម៌កើតឡើងដោយឥតហេតុ ឥតបច្ច័យពុំមានឡើយ ។

សូម្បីពាក្យថា ធម៌ទាំងឡាយណាដែលកើតអំពីហេតុ ព្រះតថាគតទ្រង់ត្រាស់នូវហេតុនោះ ពាក្យថាហេតុនេះ មិនចំពោះតែហេតុ ៦ ទេ គឺសំដៅយកបច្ច័យទាំងឡាយ ។

**ពន្យល់ពាក្យធម៌ក្នុងបច្ចនិក** :

**-អហេតុកចិត្តជរូប** = រូបកើតអំពីអហេតុកចិត្ត ៨ ដួង (វៀរទ្វិបញ្ចវិញ្ញាណ) ។

✵ចិត្ត ១៤ ដួងគឺ ទ្វិបញ្ចវិញ្ញាណ ១០ អរូបាវចរវិបាក ៤ ព្រមទាំងបដិសន្ធិចិត្តគ្រប់បុគ្គលទាំងអស់ និង ចុតិចិត្តព្រះអរហន្ត មិននាំឱ្យកើតចិត្តជរូបទេ ។

**-អហេតុកបដិសន្ធិកម្មជរូប** = កម្មជរូបក្នុងខណៈអហេតុកបដិសន្ធិចិត្ត ២ដួង គឺមួយដួងបដិសន្ធិក្នុងអបាយភូមិ និង មួយដួងទៀតបដិសន្ធិជាមនុស្ស និង ទេវតាដែលខ្វះបុណ្យ បានដល់ :

១- អកុសលវិបាកមនោវិញ្ញាណចិត្ត

២- កុសលវិបាកអហេតុកមនោវិញ្ញាណចិត្ត ។

កាលបើកម្មជរូបកើតព្រមដោយបដិសន្ធិចិត្តទាំងពីរដួងនេះណាមួយនោះ គឺមិនអាស្រ័យហេតុប្បច្ច័យទេ ។

**-ពាហិររូប** = រូបជាខាងក្រៅអំពីមនុស្ស សត្វទាំងឡាយ គឺបានដល់រូបក្នុងដើមឈើ ព្រៃភ្នំ ទន្លេ សមុទ្រ ។ល។

**-អាហារជរូប** = រូបកើតអំពីអាហារដែលបរិភោគ រាល់ពេល ។

**-ឧតុជរូប** = រូបកើតអំពីរដូវក្តៅ ឬ ត្រជាក់ដែលជាតេជោធាតុ ។

**-អសញ្ញសត្តកម្មជរូប** = កម្មជរូបដែលកើតក្នុងអសញ្ញីព្រហ្ម តាំងតែអំពីកើតដល់ចុតិដោយរូបចុតិ ។

**-បវត្តិកម្មជរូប** = កម្មជរូបក្នុងបវត្តិកាលនៃសហេតុកបុគ្គល គឺបុគ្គលដែលបដិសន្ធិដោយសហេតុកចិត្ត កម្មជរូបក្នុងបដិសន្ធិខណៈមានហេតុជាបច្ច័យ ប៉ុន្តែក្នុងខណៈបន្ទាប់អំពីបដិសន្ធិ (បវត្តិកាល) កម្មជរូបកើតឡើងដោយអត់មានហេតុប្បច្ច័យឡើយ ។ បវត្តិកម្មជរូបក្នុងបុគ្គលទាំងអស់ ។

# សរុបអត្ថធម៌នៃហេតុប្បច្ច័យ

**បច្ច័យ–** ហេតុ ៦ បានដល់ចេតសិកជាតួហេតុ គឺៈ លោភចេតសិក ទោសចេតសិក មោហចេតសិក អលោភចេតសិក អទោសចេតសិក និង បញ្ញាចេតសិក ។

**បច្ចយុប្បន្ន–** សហេតុកចិត្ត ៧១ ចេតសិក ៥២ (វៀរមោហចេតសិកក្នុងមោហមូលចិត្ត២ដួង) សហេតុកចិត្តជ្ជរូប ១៧ និង សហេតុកបដិសន្ធិកម្មជ្ជរូប ២០ ។

**បច្ចនិក–** អហេតុកចិត្ត ១៨ អញ្ញសមានាចេតសិក ១២ (វៀរឆន្ទៈ) មោហចេតសិកក្នុងមោហមូលចិត្ត ២ ដួង អហេតុកចិត្តជ្ជរូប អហេតុកបដិសន្ធិកម្មជ្ជរូប ពាហិររូប អាហារជ្ជរូប ឧតុជ្ជរូប អសញ្ញសត្តកម្មជ្ជរូប និង បវត្តិកម្មជ្ជរូប ។

✵ ហេតុដែលជាបច្ច័យ និង បច្ចយុប្បន្នរបស់ហេតុប្បច្ច័យនេះ កើតឡើងព្រមគ្នា ទើបចាត់ជា **សហជាតជាតិ** និង **បច្ចុប្បន្នបច្ច័យ** គឺបច្ច័យក្នុងបច្ចុប្បន្នកាលញ៉ាំងផលឱ្យកើតព្រមគ្នា ។

✵ បុគ្គលនៅក្នុងព្រះពុទ្ធសាសនាជាអ្នកមានសីលល្អចំរើនសតិប្បដ្ឋាន បង្អោនទៅរក **វិវេក** គឺស្ងប់ស្ងាត់ បើនៅជាលោកិយ មាន **តទង្គវិវេក**ជាកិច្ច មាន **និស្សរណវិវេក** ជាអធ្យាស្រ័យ បើជាលោកុត្តរ មាន **សមុច្ឆេទវិវេក**ជាកិច្ច មាន **និស្សរណវិវេក** ជាអារម្មណ៏ ។

សតិប្បដ្ឋានបដិបត្តិជាលោកិយ មានតទង្គវិវេកជាកិច្ច គឺកិច្ចលះបង់កិលេសក្នុងខណៈនៃសតិរលឹករូបធម៌ ឬនាមធម៌ និង មាននិស្សរណវិវេក គឺព្រះនិព្វាន ជាទីឈមទៅរក បង្អោនទៅរក ព្រោះធុញទ្រាន់ចំពោះសង្ខារធម៌ ។

ការអប់រំសតិឱ្យមានជាប្រក្រតីរឿយៗ គឺជាអធ្យាស្រ័យនៃបុគ្គលដែលឃើញទោសក្នុងភព មានចិត្តគ្រាកចេញចាកភព ដូចសត្វចាបចង់ចេញអំពីទ្រុង ។

សតិប្បដ្ឋានបដិបត្តិ ដោះស្រាយបញ្ហាជីវិតចំប្រភពនៃបញ្ហា ប្រភពនៃបញ្ហាគឺការប្រកាន់ ប្រៀបដូចបង្ខិច

ទ្រព្យរបស់អ្នកដទៃ ដែលគេទុកនៅតាមផ្លូវ យើងដើរទៅតាមផ្លូវនោះ ហើយកាន់យកនូវបង្វិចទ្រព្យ ដោយមិនដឹងថាជាទ្រព្យរបស់អ្នកដទៃ មានសេចក្តីត្រេកអរថាជារបស់ខ្លួន ដូច្នេះប្រភពនៃបញ្ហាវានៅត្រង់កាន់យកទ្រព្យរបស់គេទៅនឹងឯង ដែលនាំឱ្យសោកស្តាយ ក្តៅក្រហាយ នៅពេលគេតាមមកយករបស់គេវិញ គេវាយប្រហារឬជេរស្តី ។ល។

ឧបាទានក្ខន្ធ ៥ ប្រៀបដូចរបស់អ្នកដទៃ សេចក្តីប្រកាន់ប្រៀបដូចការរើសយកបង្វិចទ្រព្យរបស់គេ ព្រោះមិនបានដឹងការពិត ត្រូវមានទុក្ខទោសដោយប្រការទាំងពួង

សតិប្បដ្ឋានបដិបត្តិ រំលត់សេចក្តីប្រកាន់ កំចាត់បង់នូវការរំភើបញាប់ញ័រ ត្រេកអររំជួលចិត្ត និង សេចក្តីក្តៅក្រហាយ មិនសប្បាយចិត្ត ព្រោះសិក្សារឿងពិតក្នុងជីវិត។

**-តើធម្មតានៃជីវិតតែងតែមាននូវអ្វីខ្លះ?** នេះឯងដែលជាមេរៀនត្រូវសិក្សាឱ្យបានចេះពិតប្រាកដ រំលត់ការសង្ស័យ និង រំលត់អ្វីៗទាំងអស់ដែលកើតអំពីការមិនចេះ ការមិនដឹងក្នុងជីវិត ។

បើការសិក្សាក្នុងជីវិតនេះបានចេះបានដឹងថា ជាធម្មតានៃជីវិតតែងតែមាននូវអ្វីៗដោយសព្វគ្រប់ហើយនោះ បញ្ញារមែងកំណត់ដឹងនូវការពិតដែលបានកើតឡើង ដោយមិនញាប់ញ័រ រន្ធត់តក់ស្លុតឡើយ ។

## បញ្ហាវារៈ

ព្រះអភិធម្មបិដក បដ្ឋាន

បិដកខ្មែរ លេខ ៩៤ ទំព័រ ២២៩

**១-កុសលោ ធម្មោ កុសលស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ កុសលា ហេតូ**

**សម្បយុត្តកានំ ខន្ធានំ ហេតុប្បច្ចយេន បច្ចយោ ។**

ប្រែថា : កុសលធម៌ ជាបច្ច័យនៃកុសលធម៌ ដោយហេតុប្បច្ច័យ គឺពួកកុសលហេតុជាបច្ច័យនៃសម្បយុត្តក្ខន្ធ ដោយហេតុប្បច្ច័យ ។

✵ នៅក្នុងការកើតឡើងនៃកុសលចិត្តមួយដួង១ តែងតែមានហេតុពីរ ឬ បី ជានិច្ចពុំដែលខាន ដូច្នេះ តួចេតសិកដែលជាហេតុនេះឯង រមែងជាឫសគល់ ជាបច្ច័យនាំឱ្យកុសលចិត្ត និង ចេតសិកដែលប្រកបជាមួយកើតឡើងបាន ទាំងបច្ច័យ ទាំងផល ដែលកើតអំពីបច្ច័យ សុទ្ធតែនៅក្នុងអំណាចត្រៃលក្ខណ៍ធម៌ទាំងអស់ សត្វបុគ្គលអ្នកញុំាងកុសលធម៌ឱ្យកើតមិនមានឡើយ ។

តាមពិតនៅពេលកុសលធម៌អាចកើតឡើងបាន មិនមែនមានត្រឹមតែហេតុប្បច្ច័យប៉ុណ្ណឹងទេ គឺត្រូវមាន **អារម្មណប្បច្ច័យ**ទៀតផង ព្រោះបើមិនមានអារម្មណ៍ជាគ្រឿងតោង ចិត្តនិងចេតសិកមិនអាចកើតឡើងបានទេ ទាំងតួហេតុក៏កើតមិនបានដែរ បើមិនមានអារម្មណ៍ជាបច្ច័យទេនោះ ។

ម្យ៉ាងទៀត ក្នុងកុសលធម៌ដែលបានកើតឡើង ខ្លះមានឆន្ទៈជាអធិបតិប្បច្ច័យ ខ្លះមាន **វីរិយៈ** ជាអធិបតិប្បច្ច័យ ខ្លះមាន **ចិត្ត** ជាអធិបតិប្បច្ច័យ ខ្លះមាន **បញ្ញា** ជាអធិបតិប្បច្ច័យ ប៉ុន្តែមិនមានអត្តាតួខ្លួនជាធំក្នុងបច្ច័យឡើយ ។

មិនត្រឹមតែប៉ុណ្ណោះទេ នៅចាំបាច់អាស្រ័យដោយបច្ច័យជាច្រើនទៀត ទើបកុសលអាចកើតឡើងបានដូចជា:

**-អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ** គឺបើមិនអាស្រ័យចិត្តចេតសិកក្នុងខណៈមួយមុនរលត់ទៅជាបច្ច័យទេ ចិត្តចេតសិកខណៈក្រោយមិនអាចកើតឡើងបានឡើយ។ កុសលធម៌ក៏គឺចិត្តចេតសិក ដូច្នេះចាំបាច់ត្រូវអាស្រ័យអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ នត្ថិប្បច្ច័យ វិគតប្បច្ច័យ ។

**–សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ** គឺជាធម្មតា កុសលចិត្តក្នុងការធ្វើទានរក្សាសីលជាដើមត្រូវអាស្រ័យ សទ្ធា សតិ ហិរិ ឱត្តប្បអលោភ អទោស ។ល។ មានចេតសិកជាង ៣០ ដែលកើតព្រមជាសហជាតប្បច្ច័យ ជានិស្សយប្បច្ច័យ ។ សូម្បីតែចេតសិកជាង ៣០ ក៏ត្រូវអាស្រ័យកុសលចិត្តជាបច្ច័យដូចគ្នាវិញដែរ មានសហជាតប្បច្ច័យជាដើម ។ ដូច្នេះ ចិត្ត និង ចេតសិកដែលជាសហជាតិធម៌ រមែងជាអញ្ញមញ្ញប្បច្ច័យអាស្រ័យគ្នាទៅវិញទៅមកកើតឡើង រួចរលត់បាត់ទៅវិញ មិនមែនជាសត្វបុគ្គលឡើយ ។

**–ឧបនិស្សយប្បច្ច័យ** កុសលធម៌ក្នុងបច្ចុប្បន្នត្រូវតែអាស្រ័យកុសលធម៌មុនៗជាកម្លាំង ហើយម្យ៉ាងទៀតសូម្បីក្នុងពួកអកុសលធម៌ក៏អាចជាទីអាស្រ័យដ៏មានកម្លាំងញ៉ាំងលោកិយកុសលឱ្យកើតឡើងបានដែរ ។ល។

## អដ្ឋកថា ហេតុប្បច្ច័យ

ក្នុងបច្ច័យ ២៤ មានហេតុប្បច្ច័យជាដើម ដោយវៀរបច្ឆាជាតប្បច្ច័យ និងវិបាក ប្បច្ច័យចេញ បច្ច័យ ២២ទៀតសុទ្ធ តែជាបច្ច័យនៃកុសលធម៌ទាំងអស់ ។

កុសលធម៌ជាបច្ច័យនៃកុសលធម៌ មាន ២០បច្ច័យ ដោយវៀរបុរេជាតប្បច្ច័យ ១ បច្ឆាជាតប្បច្ច័យ ១ វិបាកប្បច្ច័យ ១ វិប្បយុត្តប្បច្ច័យ ១ ។

" អ្នកមិនចង្វេងគប្បីជ្រាប "

## បញ្ហាវារៈ

២–កុសលោ ធម្មោ អព្យាកតស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ កុសលា ហេតូ

**ចិត្តសមុដ្ឋានានំ រូបានំ ហេតុប្បច្ចយេន បច្ចយោ ៗ**

ប្រែថា : កុសលធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយហេតុប្បច្ច័យ គឺពួកកុសលហេតុជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយហេតុប្បច្ច័យ ។

✵ នៅពេលដេក ដើរ ឈរ អង្គុយ បត់ លាតសណ្តូកដៃ-ជើង ធ្វើកិច្ចការងារជាប្រក្រតី និយាយស្តី ។ល។ ការប្រព្រឹត្តិទៅនៃរូបកាយទាំងអស់នេះ ព្រោះអាស្រ័យធាតុខ្យល់កើតអំពីចិត្ត បក់ក្នុងកាយធ្វើឱ្យកាយកំរើក ។

ចិត្តដូចសារថី ខ្យល់កើតអំពីចិត្តដូចសត្វគោ រូបកាយដូចជារទេះ អត្តាក្នុងកាយជាអ្នកដេកដើរជាដើមពុំ មានឡើយ ។

## បញ្ហាវារៈ

≈≈✿≈≈

**៣–កុសលោ ធម្មោ កុសលស្ស ច អព្យាកតស្ស ច ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ កុសលា ហេតូ សម្បយុត្តកានំ ខន្ធានំ ចិត្តសមុដ្ឋានានញ្ច រូបានំ ហេតុប្បច្ចយេន បច្ចយោ ៗ**

ប្រែថា : កុសលធម៌ជាបច្ច័យនៃកុសលធម៌ និង អព្យាកតធម៌ដោយហេតុប្បច្ច័យ គឺពួកកុសលហេតុជាបច្ច័យនៃពួកសម្បយុត្តក្ខន្ធ និង ពួកចិត្តសមុដ្ឋានរូបដោយហេតុប្បច្ច័យ ។

✵ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងថា **កុសលធម៌ជាបច្ច័យនៃកុសលធម៌** ព្រះអង្គត្រាស់សំដែងធម៌ឱ្យជាទីតាំងនៃសតិរលឹក ធម៌ជាកុសលក្តី ធម៌ជាហេតុនៃកុសលក្តី គឺជាធម្មជាតិមានពិត តែពុំមែនជាសត្វបុគ្គល គ្រាន់តែជាគ្រឿងសំរាប់ចំរើនប្រាជ្ញានិងស្មារតី មិនអាស្រ័យដោយតណ្ហាឧបាទានក្នុងសភាវធម៌នោះៗឡើយ ។

**✵សត្វបុគ្គលតួខ្លួន ពុំមានជាបច្ច័យនៃកុសលធម៌ឡើយ ៕**

នៅក្នុងបញ្ហាវារៈទី ៣ នេះ ព្រះអង្គទ្រង់សំដែងបច្ចយុប្បន្នធម៌មិជាមួយគ្នា គឺ បច្ចយុប្បន្នធម៌នៃបញ្ហាវារៈទី ១ + ទី ២ ។

## សំដែងអត្ថធម៌ក្នុងបញ្ហាវារៈ

-បញ្ហាវារៈទី ១ (**កុ → កុ**) គឺ :

**បច្ច័យ** – កុសលហេតុ ៣ គឺ:

អលោភៈ ១ អទោសៈ ១ អមោហៈ ១

**បច្ចយុប្បន្ន** – កុសលចិត្ត ៣៧ដួង ចេតសិកសម្បយុត្ត ៣៨ ។

-បញ្ហាវារៈទី ២ (**កុ → អព្យា**) គឺ :

**បច្ច័យ** – កុសលហេតុ ៣ ដូចគ្នា

**បច្ចយុប្បន្ន** – កុសលចិត្តជរូបគឺ រូបកើតអំពីកុសលចិត្ត ១៧ ។

-បញ្ហាវារៈទី ៣(**កុ→កុ+អព្យា**) គឺ :

**បច្ច័យ** – កុសលហេតុ ៣ ដូចគ្នា

**បច្ចយុប្បន្ន** – កុសលចិត្ត ៣៧ដួង ចេតសិកសម្បយុត្ត ៣៨ និង កុសលចិត្តជរូប ១៧ ។

## បញ្ហាវារៈ

**៨–អកុសលោ ធម្មោ អកុសលស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ អកុសលា ហេតូ សម្បយុត្តកានំ ខន្ធានំ ហេតុប្បច្ចយេន បច្ចយោ ៕**

ប្រែថា : អកុសលធម៌ ជាបច្ច័យនៃអកុសលធម៌ ដោយហេតុប្បច្ច័យ គឺពួកអកុសលហេតុជាបច្ច័យនៃពួកសម្បយុត្តក្ខន្ធដោយហេតុប្បច្ច័យ ។

**✵បុគ្គលណាមានបញ្ញារំលត់សេចក្តីប្រកាន់អកុសលហេតុថាជាតួខ្លួនបាន បុគ្គល**

**នោះ រមែងរួចអំពីទោស ព្រោះមិនបាន ប្រកាន់ថា ខ្លួនជាអ្នកធ្វើឱ្យអកុសលធម៌ កើតឡើង ៗ**

**តាមពិតអកុសលធម៌ទាំងឡាយ រមែង កើតអំពីហេតុនៃអកុសលធម៌នោះឯង ៗ**

បើលោភហេតុ ទោសហេតុ និង មោហហេតុ មិនមានទេនោះ តើអកុសលធម៌ទាំងឡាយ នឹងកើតមានដូចម្តេចបាន ។

ការចំរើនសតិប្បដ្ឋាន គឺសតិរលឹកសិក្សារឿយៗ ចំពោះលោភៈ ចំពោះទោសៈ ចំពោះមោហៈ រំលត់ការប្រកាន់បន្តិចម្តងៗថា អកុសលហេតុទាំងបីនេះ ជាសត្វបុគ្គលតួខ្លួន ។

អ្នកមិនចំរើនសតិប្បដ្ឋានតាមពិត អាចចេះខ្លាចរង្កៀសចំពោះអកុសលធម៌ផ្សេងៗ ប៉ុន្តែមិនខ្លាចរង្កៀសចំពោះអវិជ្ជា ដែលមិនដឹងសភាវធម៌តាមពិតថា ត្រឹមតែជាធម៌ ដូចជាការមិនដឹងលោភៈថាត្រឹមតែជាធម៌ ទោសៈជាធម៌ ។ល។

**អវិជ្ជាដែលមិនដឹងសភាវធម៌តាមពិត គួរឱ្យខ្លៀសជាងអ្វីទាំងអស់ ព្រោះវាជាអ្នករក្សាទុកនូវសក្កាយទិដ្ឋិ ៗ**

## បញ្ហាវារៈ

**៥– អកុសលោ ធម្មោ អព្យាកតស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ អកុសលា ហេតូ ចិត្តសមុដ្ឋានានំ រូបានំ ហេតុប្បច្ចយេន បច្ចយោ ៗ**

ប្រែថា : អកុសលធម៌ជាបច្ច័យនៃអព្យាកតធម៌ ដោយហេតុប្បច្ច័យ គឺពួកអកុសលហេតុជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូបដោយហេតុប្បច្ច័យ ។

## ✵ការប្រព្រឹត្តិព្រហ្មចរិយធម៌ក្នុងព្រះពុទ្ធសាសនា គឺដើម្បីកំណត់ដឹងទុក្ខ ៗ

បច្ច័យ ៤ ក្ដី សម្បត្តិក្នុងលោកទាំងឡាយទាំងពួងក្ដី កាមគុណ ៥ប្រការក្ដី ត្រូវបានគេប្រើប្រាស់ ព្រោះអាស្រ័យមានឧបាទានក្ខន្ធ ៥ អ្នកប្រាជ្ញមិនបានជាប់ជំពាក់ត្រេកអរចំពោះបច្ច័យ ៤ ជាដើមឡើយ ប៉ុន្ដែអ្នកប្រាជ្ញត្រេកអរចំពោះការរួចផុតអំពីឧបាទានក្ខន្ធ ៥ ។

ការរួចផុតអំពីឧបាទានក្ខន្ធ ៥ ដូចជាការរួចផុតអំពីខ្មាំងសត្រូវ បច្ច័យ ៤ ឬ កាមគុណ ៥ ប្រៀបដូចបាយទឹកនំចំណីរបស់ខ្មាំងសត្រូវ បុរសដែលត្រូវខ្មាំងសត្រូវចាប់បានមិនត្រេកអរក្នុងការបរិភោគបាយ ទឹក នំចំណី របស់សត្រូវទេ តែងតែភ័យតក់ស្លុតខ្លាចសត្រូវសម្លាប់ បើបរិភោគ ក៏បរិភោគគ្រាន់តែដើម្បីរស់ រួចហើយរមែងរស់ដោយស្មារតីប្រុងប្រយ័ត្ន និងរកឧបាយដើម្បីរត់ចេញអំពីជំរុំខ្មាំងសត្រូវ ។

ការដែលអាចរត់រួចអំពីខ្មាំងសត្រូវ គឺឧបាទានក្ខន្ធ៥ បានដល់ការដែលមានស្មារតី មិនវង្វេងត្រេកអរចំពោះអាហារភោជនចំណីចំណុករបស់សត្រូវ ពោលគឺ បច្ច័យ ៤ សម្បត្តិទ្រព្យកាមគុណ ៥ ប្រការក្នុងលោក និងម្យ៉ាងទៀតត្រូវមានស្មារតីកំណត់ដឹងឧបាទានក្ខន្ធ ៥ ថាជាទុក្ខ និងមិនភ្លេចថា វាជាខ្មាំងសត្រូវ ជាអ្នកសម្លាប់ ។ **ការរួចផុតអំពីឧបាទានក្ខន្ធ ៥ គឺព្រះនិព្វាន។**

## បញ្ហាវារៈ

≈≈ ≈≈

**៦-អកុសលោ ធម្មោ អកុសលស្ស ច អព្យាកតស្ស ច ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ អកុសលា ហេតូ សម្បយុត្តកានំ ខន្ធានំ ចិត្តសមុដ្ឋានានញ្ច រូបានំ ហេតុប្បច្ចយេន បច្ចយោ ៗ**

ប្រែថា : អកុសលធម្មិ ជាបច្ច័យនៃអកុសលធម្មិ និង

អព្យាកតធម៌ ដោយហេតុប្បច្ច័យ គឺពួកអកុសលហេតុ ជាបច្ច័យនៃពួកសម្បយុត្តក្ខន្ធ និង ពួកចិត្តសមុដ្ឋានរូប ដោយហេតុប្បច្ច័យ ។

## សំដែងអន្ថធម៌ក្នុងបញ្ហាវារៈ

-បញ្ហាវារៈទី ៤ **(អកុ→ អកុ)** គឺ :

**បច្ច័យ–** អកុសលហេតុ ៣

លោភហេតុ ទោសហេតុ មោហហេតុ ។

**បច្ចយុប្បន្ន–** អកុសលចិត្ត ១២ដួង ចេតសិក ២៧ (វៀរមោហចេតសិកក្នុងមោហមូលចិត្ត ២ ដួង) ។

- បញ្ហាវារៈទី ៥ **(អកុ→អព្យា)** គឺ :

**បច្ច័យ–** អកុសលហេតុ ៣

**បច្ចយុប្បន្ន–** អកុសលចិត្តជរូប ១៧ ។

-បញ្ហាវារៈទី ៦ **(អកុ→អកុ+អព្យា)** គឺ :

**បច្ច័យ–** អកុសលហេតុ ៣

**បច្ចយុប្បន្ន–** អកុសលចិត្ត ១២ដួង ចេតសិក ២៧ (វៀរមោហចេតសិកក្នុងមោហមូលចិត្ត ២ដួង) និង អកុសលចិត្តជរូប ១៧ ។

❋ ការអប់រំចំរើនសតិប្បដ្ឋាន គឺជាការបណ្ដុះពូជនៃបញ្ញា ដូច្នេះត្រូវតែអប់រំរឿយៗ ចាប់តាំងតែអំពីបានស្ដាប់ព្រះធម៌យល់ចូលចិត្តក្នុងសតិប្បដ្ឋានបដិបត្តិមក ចំណែកការងារជាកុសលទាំងឡាយផ្សេងៗ មានការបំពេញធ្វើសំរាប់ជាឧបការៈឱ្យកម្លាំងដល់សតិប្បដ្ឋានបដិបត្តិ ។ **កុសលធម៌ទាំងឡាយផ្សេងៗ គឺជាបរមត្ថធម៌ ត្រូវតែជាទីតាំងនៃសតិរលឹកផងដែរ បើមិនរលឹកដឹងទេនោះ ក៏មិនអាចលះបង់នូវតណ្ហា មានៈ ទិដ្ឋិ បានឡើយ ។** សូម្បីអកុសលធម៌ទាំងពួងក៏ត្រូវតែជាទីតាំងនៃសតិរលឹកដឹង ទើបអាចលះបង់នូវសេចក្ដីប្រកាន់ថា ជាសត្វបុគ្គលតួខ្លួនបាន ។

# សមាធិជាបទដ្ឋាននៃបញ្ញា

≈≈≈≈≈

មានអ្នកយល់ច្រឡំច្រើនណាស់អំពីពាក្យថា សមាធិជាបទដ្ឋានរបស់បញ្ញា គឺយល់ច្រឡំថា ត្រូវធ្វើសមាធិឱ្យបានសិន ចាំធ្វើវិបស្សនាតាមក្រោយ ។

តាមពិតពាក្យនេះមិនមែនមានន័យ មានសេចក្ដីដូច្នេះទេ ព្រះសម្មាសម្ពុទ្ធពុំបានសំដែងថា មុននឹងចំរើនវិបស្សនា អ្នករាល់គ្នាត្រូវធ្វើសមាធិសិន ព្រះអរិយៈទាំងឡាយក៏ពុំបានសំដែងយ៉ាងនេះដែរ ។ ពាក្យថា សមាធិជាបទដ្ឋានរបស់បញ្ញា គឺដោយសេចក្ដីថា កាលបុគ្គលមានប្រក្រតីចំរើនសតិប្បដ្ឋាន ៤ រឿយៗក្នុងជីវិតប្រចាំថ្ងៃ ទើបសម្មាសមាធិដែលបុគ្គលចំរើនដោយល្អតាមចរិតអធ្យាស្រ័យនោះ ជាគ្រឿងទ្រធ្វើឱ្យមានប្រយោជន៍ចំពោះបញ្ញា គឺទិដ្ឋិវិសុទ្ធិ បានដល់សេចក្ដីបរិសុទ្ធក្នុងការឃើញនាមរូប ។

បើបុគ្គលណាមិនបានចំរើនសតិប្បដ្ឋានរលឹករឿយៗនូវរូបធម៌នាមធម៌ជាប្រក្រតីគ្រប់ឥរិយាបថបួនទេនោះ រូបសមាបត្តិក្ដី អរូបសមាបត្តិក្ដី មិនមានប្រយោជន៍អ្វីដល់បញ្ញាទិដ្ឋិវិសុទ្ធិឡើយ ពោលគឺ សមាបត្តិនោះ មិនអាចជាបទដ្ឋាននៃបញ្ញាបានទេ ប្រៀបបីដូចយកជីទៅចាក់លើដីទទេ ទោះបីជីច្រើនប៉ុណ្ណាៗក្ដី ក៏ដំណាំមិនមែនដុះអំពីជីនោះឡើយ ។

សីលប្រៀបដូចជាផែនដី ស្រែចំការ សមាធិប្រៀបដូចជីសំរាប់ដាក់ដំណាំឱ្យបានល្អ បញ្ញាប្រៀបដូចដំណាំមានដូង ចេក ក្រូច ខ្នុរ ជាដើម ដំណាំមិនមែនដុះចេញអំពីជីទេ គឺត្រូវមានពូជនៃដំណាំនោះពិតៗ ចំណែកជី គ្រាន់តែសំរាប់ជួយឱ្យដំណាំល្អតែប៉ុណ្ណោះ ប៉ុន្តែបើមិនមានដំណាំទេនោះ ជីក៏មិនមានប្រយោជន៍អ្វីដែរ ។

ម្យ៉ាងទៀត សមាធិប្រៀបដូចជាថ្មសំលៀងកាំបិត បញ្ញាប្រៀបដូចដាវសំរាប់កាប់ចាក់ខ្មាំងសត្រូវ ដាវមិនមែនកើតអំពីថ្មទេ គឺកើតអំពីដែក វាដោយឡែកផ្សេងអំពីថ្ម ចំណែកថ្មគ្រាន់តែសំរាប់សំលៀងឱ្យដាវមុតតែប៉ុណ្ណោះ

ដូច្នេះត្រូវតែស្លដែកឱ្យកើតបានជាដាវកាំបិតពិតៗ យ៉ាងណា វិបស្សនាត្រូវតែកើតមកអំពីសតិប្បដ្ឋានបដិបត្តិ ដោយផ្ដើមសតិរលឹករឿយៗ សង្កេតពិនិត្យជីវិតប្រចាំថ្ងៃ តាំងតែអំពីសតិទន់ខ្ចី ដូចជាផ្សាំបណ្ដុះពូជដំណាំ ឬ ដូចជាការស្លដែកដើម្បីធ្វើដាវដែរ ។

**បុគ្គលណាធុញទ្រាន់ មិនយកចិត្តទុកដាក់ក្នុងការចំរើនសតិប្បដ្ឋាន៤ បុគ្គលនោះឈ្មោះថាខ្ពើមឆ្អើមអរិយមគ្គអង្គ ៨ ពិតៗ**

ទោះជាយ៉ាងណាក៏ដោយ បញ្ញាត្រូវតែមាន **យោនិសោមនសិការ**ជាបទដ្ឋាន គឺធ្វើទុកក្នុងចិត្តដោយទៅតាមទំនងនៃហេតុផលចំពោះឧបាទានក្ខន្ធ ៥ កាលបើមានបទដ្ឋានយ៉ាងនេះ អាចឱ្យសំរេចនូវសោតាបត្តិមគ្គជាដើមបាន សូម្បីមិនមានសមាបត្តិជាជំនួយក៏ដោយ ។

បុគ្គលសម័យព្រះពុទ្ធគង់ព្រះជន្មនៅ បានសំរេចមគ្គផលច្រើនជាអនេក ដោយមិនមានបានសំរេចឈានសមាបត្តិមាន បឋមជ្ឈានជាដើម ឧទាហរណ៍ដូចជា ឧបាសិកាវិសាខា ឬ ឧបាសក អនាថបិណ្ឌិកៈ ។ល។ ជាអរិយបុគ្គលអស់ជីវិតទៅក៏មានបដិសន្ធិក្នុងកាមសុគតិភព ព្រោះមិនមានឈានសមាបត្តិហ្នឹងឯង ។ បុគ្គលមិនគួរហួងហែងសមាធិឡើយ ព្រោះនៅក្នុងសតិភាវនា គឺការចំរើនសតិប្បដ្ឋាន មានសមាធិជាខណិកសមាធិរួមជាមួយសតិ ។ សតិប្បដ្ឋានដែលនៅជាលោកិយ មានមគ្គអង្គ ៥ គឺ សម្មាទិដ្ឋិ ១ សម្មាសង្កប្បៈ ១ សម្មាវាយាមៈ ១ សម្មាសតិ ១ សម្មាសមាធិ ១ មគ្គអង្គ ៥នេះ កាលដែលចំរើនឱ្យច្រើនហើយ ក៏រមែងបានគ្រប់នៅអង្គ ៨ប្រការជាលោកុត្តរ ព្រោះថា ការចំរើនសតិប្បដ្ឋាន ៤ គឺមហាកុសលញាណសម្បយុត្ត មានតទង្គប្បហានជាកិច្ច មានព្រះនិព្វានជាទីបង្អោនទៅ នេះដោយសារមហាកុសលញាណសម្បយុត្ត គឺជាវិបស្សនាញាណ មានបរមត្ថធម៌ជាអារម្មណ៍ ។

**វិបស្សនាញាណ មិនមែនមានពូជនៅក្នុងសមាបត្តិ៨ទេ នោះជាសមាបត្តិណា**

មួយក៏ដោយ ពីព្រោះសមាបត្តិ ៨ មិនមានអារម្មណ៍នាំឱ្យកើតវិបស្សនា មានតែសតិ-ប្បដ្ឋានទេ ដែលមានអារម្មណ៍នាំមកនូវវិបស្សនា ពុទ្ធបរិស័ទគួរសិក្សាសតិប្បដ្ឋានសូត្រឱ្យបានច្បាស់លាស់ ។

បុគ្គលណាពោលថា ចំរើនសមាធិជាមុនសិន សឹមចំរើនវិបស្សនាជាក្រោយឈ្មោះថាពោលប្រឆាំងនឹងសតិប្បដ្ឋានសូត្រ ដែលសំដែងដោយព្រះសម្មាសម្ពុទ្ធ សតិប្បដ្ឋានសតិ-ប្បដ្ឋាន មានការស្តាប់ព្រះធម៌ចាំបានច្បាស់លាស់ ហើយយល់ចូលចិត្តចំពោះសភាវធម៌ពិតក្នុងជីវិតប្រចាំថ្ងៃជាបទដ្ឋាន ។

ព្រះអរហន្ត បរិបូណ៌ដោយសីលសមាធិបញ្ញា ដូច្នេះសីលសមាធិបញ្ញា ដែលបរិបូណ៌ក្នុងអរហត្តមគ្គនោះ ព្រោះសតិប្បដ្ឋានបដិបត្តិ ។

សីលសមាធិបញ្ញា ឈ្មោះថា **អនុបុព្វសិក្ខា** គឺសិក្ខាតាមលំដាប់ បានដល់លំដាប់តាំងអំពីសោតាបត្តិមគ្គមក ។

សោតាបន្នបុគ្គល និង សកទាគាមិបុគ្គល បរិបូណ៌ដោយសីលសិក្ខា តែមិនទាន់បរិបូណ៌ដោយសិក្ខាពីរទៀត ព្រះអនាគាមី បរិបូណ៌ដោយសីលសិក្ខា និង សមាធិសិក្ខា តែមិនទាន់ធ្វើឱ្យបរិបូណ៌នូវបញ្ញាសិក្ខា ។

**អនុបុព្វសិក្ខា ដែលបរិបូណ៌តាមលំដាប់នៃមគ្គ ៤ ព្រោះអាស្រ័យសតិប្បដ្ឋានបដិបត្តិ មិនមែនព្រោះអាស្រ័យសេចក្តីប្រកាន់តួខ្លួន ជាអ្នកធ្វើឱ្យបរិបូណ៌ទេ ។**

បុគ្គលដែលមិនបានអប់រំ ចំរើនសតិប្បដ្ឋាន មិនបានដឹងថា **ធម៌ទាំងឡាយកើតអំពីហេតុ** ទេ រមែងជាប់ដោយសេចក្តីប្រកាន់ថា **ធម៌ទាំងឡាយកើតអំពីតួខ្លួនជាអ្នកធ្វើឱ្យកើតឡើង** តាមពិត សីល

សមាធិបញ្ញា មិនមានបរិបូណ៌សំរាប់បុថុជ្ជនទេ ដូច្នេះបើមិនអប់រំសតិប្បដ្ឋានជាប្រក្រតីគ្រប់ឥរិយាបថទាំងបួនទេ ពិតជាមិនមានអនុបុព្វសិក្ខាឡើយ ។

**អនុបស្សនា ៧ និងវិបស្សនាញាណជាដើម ជាអនុបុព្វបដិបទា គឺបដិបទាជាលំដាប់រហូតដល់អរហត្តមគ្គ ។**

## **បញ្ហាវារៈ**

≈≈ ≈≈

**៧-អព្យាកតោ ធម្មោ អព្យាកតស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ វិបាកាព្យាកតា កិរិយាព្យាកតា ហេតូ សម្បយុត្តកានំ ខន្ធានំ ចិត្តសមុដ្ឋានានញ្ច រូបានំ ហេតុប្បច្ចយេន បច្ចយោ បដិសន្ធិក្ខណេវិបាកាព្យាកតា ហេតូ សម្បយុត្តកានំ ខន្ធានំ កដត្តា ច រូបានំ ហេតុប្បច្ចយេន បច្ចយោ។**

ប្រែថា ៖ អព្យាកតធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយហេតុប្បច្ច័យ គឺពួកវិបាកាព្យាកតហេតុក្តី ពួកកិរិយាព្យាកតហេតុក្តី ជាបច្ច័យនៃពួកសម្បយុត្តក្ខន្ធ និង ពួកចិត្តសមុដ្ឋានរូបដោយហេតុប្បច្ច័យ ពួកវិបាកាព្យាកតហេតុជាបច្ច័យនៃពួកសម្បយុត្តក្ខន្ធ និង ពួកកដត្តារូប (កម្មជរូប) ដោយហេតុប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ។

✵ វិបាកាព្យាកត និង កិរិយាព្យាកត បានសេចក្តីថា វិបាក និង កិរិយាជាអព្យាកតធម៌ ព្រោះមិនមែនជាកុសល មិន មែនជាអកុសល ។

## **អត្ថធម៌ក្នុងបញ្ហាវារៈទី ៧**

✵ វិបាកហេតុ ជាបច្ច័យនៃសម្បយុត្តក្ខន្ធទាំងឡាយ និង រូបទាំងឡាយ ដែលមានចិត្តជាសមុដ្ឋានដោយហេតុប្បច្ច័យ ។

**បច្ច័យ-** វិបាកហេតុ ៣ គឺ ៖

អលោភៈ ១ អទោស ១ អមោហៈ ១

**បច្ចយុប្បន្ន–** សហេតុកវិបាកចិត្ត ៣៧ (វៀរ អហេតុកវិបាក ១៥) ចេតសិកប្រកបជាមួយសហេតុក-វិបាកចិត្តមាន ៣៨ និង ពួករូបដែលមានសហេតុកចិត្តជាសមុដ្ឋាន ១៤ (វៀរវិញ្ញត្តិរូប ២ សទ្ទរូប ១) ។

❋ កិរិយាហេតុជាបច្ច័យនៃសម្បយុត្តកធម៌ទាំងឡាយ និង ពួករូបដែលមានចិត្តជាសមុដ្ឋាន ដោយអំណាចហេតុ-ប្បច្ច័យ ។

**បច្ច័យ–** កិរិយាហេតុ ៣ គឺៈ

អលោភៈ ១ អទោសៈ ១ អមោហៈ ១

**បច្ចយុប្បន្ន–** សហេតុកកិរិយាចិត្ត ១៧ដួង ចេតសិក ៣៥ និង សហេតុកកិរិយាចិត្តជរូប ១៧ ។

❋ ក្នុងបដិសន្ធិខណៈ វិបាកហេតុជាបច្ច័យដល់ពួកសម្បយុត្តកធម៌ និង កម្មជរូបដោយហេតុប្បច្ច័យ ។

**បច្ច័យ–** វិបាកហេតុ ៣

**បច្ចយុប្បន្ន–** សហេតុកបដិសន្ធិចិត្ត ១៧ដួង ចេតសិក ៣៥ បដិសន្ធិកម្មជរូប ២០ ។

## ចែកតាមភូមិ

❋ ខណៈបដិសន្ធិនៅក្នុង **បញ្ចវោការភូមិ** មានបច្ច័យ និង បច្ចយុប្បន្នដូច្នេះគឺ :

**បច្ច័យ–** វិបាកហេតុ ៣

**បច្ចយុប្បន្ន–** សហេតុកបដិសន្ធិចិត្ត ១៣ គឺ : មហាវិបាក ៨ រូបាវចរវិបាក ៥ ចេតសិក ៣៥ និងបដិសន្ធិ-កម្មជរូប ២០ ។

❋ ខណៈបដិសន្ធិនៅក្នុង **ចតុវោការភូមិ** មានបច្ច័យជាដើមគឺ :

**បច្ច័យ–** វិបាកហេតុ ៣

**បច្ចយុប្បន្ន–** អរូបាវចរវិបាកបដិសន្ធិ ៤ដួង និង ចេតសិក ៣០ ។

# ហេតុប្បច្ច័យសភាគៈ

≈≈❦≈≈

បច្ច័យដែលជាសភាគ គឺចូលគ្នាបានជាមួយ **ហេតុប្បច្ច័យ** មាន ១១ បច្ច័យផ្សេងទៀត គឺ :

១- សហជាតាធិបតិប្បច្ច័យ

២- សហជាតប្បច្ច័យ

៣- អញ្ញមញ្ញប្បច្ច័យ

៤- សហជាតនិស្សយប្បច្ច័យ

៥- វិបាកប្បច្ច័យ

៦- សហជាតិន្ទ្រិយប្បច្ច័យ

៧- មគ្គប្បច្ច័យ

៨- សម្បយុត្តប្បច្ច័យ

៩- សហជាតវិប្បយុត្តប្បច្ច័យ

១០- សហជាតត្ថិប្បច្ច័យ

១១- សហជាតអវិគតប្បច្ច័យ ។

## ពន្យល់សភាគប្បច្ច័យ

✵ អមោហហេតុ គឺបញ្ញាចេតសិក ជាវីមំសាធិបតិ ដូច្នេះត្រូវជាហេតុប្បច្ច័យផង ជាសហជាតាធិបតិប្បច្ច័យផង។

អមោហហេតុនេះ ជាបញ្ញិន្ទ្រិយ៍ និង ជាសម្មាទិដ្ឋិមគ្គ ដូច្នេះត្រូវជាសហជាតិន្ទ្រិយប្បច្ច័យ និង មគ្គប្បច្ច័យផង ។

✵ វិបាកហេតុ ៣ ជាវិបាកប្បច្ច័យផងដែរ ។

✵ ហេតុ៦ ជាសហជាតវិប្បយុត្តប្បច្ច័យចំពោះរូបគឺ :

- សហេតុកចិត្តជរូប និង

- សហេតុកបដិសន្ធិកម្មជរូប ។

ហេតុ ៦ នេះ នៅជាបច្ច័យសភាគៈផ្សេងទៀត ដូចរាប់រួចហើយមាន សហជាតប្បច្ច័យ ជាដើម ។

## ហេតុប្បច្ច័យសភាគៈតាមបញ្ហាវារៈ

**១ –** កុសលជាបច្ច័យនៃកុសលដោយហេតុប្បច្ច័យ មានសភាគប្បច្ច័យ ៩ ដោយវៀរវិបាកប្បច្ច័យ និង សហជាតវិប្បយុត្តប្បបច្ច័យ ក្នុងប្បច្ច័យសភាគៈ ១១ ខាងដើម ។

២ – កុសលជាបច្ច័យនៃអព្យាកតដោយហេតុប្បច្ច័យ មានសភាគបច្ច័យ ៨ ដោយវៀរវិបាកប្បច្ច័យ ១ អញ្ញ-មញ្ញប្បច្ច័យ ១ និង សម្បយុត្តប្បច្ច័យ ១ ក្នុងបច្ច័យសភាគៈ ១១ ខាងដើម ។

៣ – កុសលជាបច្ច័យនៃកុសល និងអព្យាកត ដោយហេតុប្បច្ច័យ មានសភាគប្បច្ច័យ ៧ ដោយវៀរ ៤បច្ច័យក្នុងបច្ច័យសភាគៈខាងដើម បួនបច្ច័យដែលវៀរគឺ :

វិបាកប្បច្ច័យ ១ សហជាតវិប្បយុត្តប្បច្ច័យ ១ អញ្ញ-មញ្ញប្បច្ច័យ ១ និង សម្បយុត្តប្បច្ច័យ ១ ។

៤ – អកុសលជាបច្ច័យនៃអកុសល ដោយហេតុប្ប-ច្ច័យ មានសភាគប្បច្ច័យ ៦ គឺ :

សហជាតប្បច្ច័យ ១ អញ្ញមញ្ញប្បច្ច័យ ១ សហជាត-និស្សយប្បច្ច័យ ១ សម្បយុត្តប្បច្ច័យ ១ សហជាតត្ថិប្បច្ច័យ ១ និង សហជាតអវិគតប្បច្ច័យ ១ ។

៥ – អកុសលជាប្បច្ច័យនៃអព្យាកត ដោយហេតុប្បច្ច័យ មានសភាគបច្ច័យ ៥ គឺ :

សហជាតប្បច្ច័យ ១ សហជាតនិស្សយប្បច្ច័យ ១ សហជាតវិប្បយុត្តប្បច្ច័យ ១ សហជាតត្ថិប្បច្ច័យ ១ សហ-ជាតអវិគតប្បច្ច័យ ១ ។

៦ – អកុសលជាបច្ច័យនៃអកុសល និងអព្យាកត ដោយហេតុប្បច្ច័យ មានសភាគប្បច្ច័យ ៤ទៀត គឺ :

សហជាតប្បច្ច័យ ១ សហជាតនិស្សយប្បច្ច័យ ១ សហជាតត្ថិប្បច្ច័យ ១ សហជាតអវិគតប្បច្ច័យ ១ ។

៧ – អព្យាកតជាបច្ច័យនៃអព្យាកត ដោយហេតុ-ប្បច្ច័យ មានសភាគបច្ច័យ ១១ ទៀតដូចរាប់ខាងដើម ។

## សភាគប្បច្ច័យមានក្នុងបញ្ហាវារៈ

✵ សហជាតប្បច្ច័យ ១ សហជាតនិស្សយប្បច្ច័យ ១ សហជាតត្ថិប្បច្ច័យ ១ សហជាតអវិគតប្បច្ច័យ ១ ដែលជាសភាគៈរបស់ហេតុប្បច្ច័យ អាចបានជាបច្ច័យគ្រប់បញ្ហាវារៈទាំង ៧ ។

✵សហជាតាធិបតិប្បច្ច័យ ដែលជាសភាគៈរបស់ហេតុប្បច្ច័យ អាចបានជាបច្ច័យក្នុង ៤ បញ្ហាវារៈ គឺ បញ្ហាវារៈទី ១ ,ទី ២ ,ទី ៣ ,ទី ៧ ដោយបញ្ហាជាកុសលក៏មាន ជាអព្យាកតក៏មាន ប៉ុន្តែមិនមានបញ្ហាជាអកុសលឡើយ ។

**ហេតុប្បច្ចយា អធិបតិយា ចត្តារិ**

ធម៌ដែលជាហេតុប្បច្ច័យ ស្មើនឹងអធិបតិប្បច្ច័យមាន ៤ បញ្ហាវារៈ **(កុ→ កុ) , (កុ →អព្យា) , (កុ → កុ +អព្យា) , (អព្យា→អព្យា)**

**បច្ច័យ –** បញ្ញាគឺអមោហហេតុជាវីមំសាធិបតិប្បច្ច័យ ។

**បច្ចយុប្បន្ន –** សាធិបតិជវនចិត្តដែលប្រកបដោយបញ្ញា ៣៤ដួង ចេតសិក ៣៧ (វៀរបញ្ញាជាតួបច្ច័យ) និងចិត្តសមុដ្ឋានរូប ១៧ ។

នេះជាបច្ចយុប្បន្នរួមទាំង ៤ បញ្ហាវារៈ បុគ្គលដែលឆ្លាត គប្បីចែកអង្គធម៌បច្ចយុប្បន្នឱ្យទៅតាមបញ្ហាវារៈ ទាំង ៤ ចុះ ។

✵សហជាតិន្ទ្រិយប្បច្ច័យ ដែលជាសភាគៈរបស់ហេតុប្បច្ច័យ អាចបានជាបច្ច័យក្នុង ៤បញ្ហាវារៈ ដូចសហជាតាធិបតិប្បច្ច័យដែរ ព្រោះបញ្ញាជាបច្ច័យ ប៉ុន្តែខុសគ្នាត្រង់បច្ចយុប្បន្នធម៌ ។

**✵ហេតុប្បច្ចយា ឥន្ទ្រិយេ ចត្តារិ**

ធម៌ដែលជាហេតុប្បច្ច័យ ស្មើគ្នានឹងឥន្ទ្រិយប្បច្ច័យក្នុង ៤ បញ្ហាវារៈ គឺ ទី ១ , ទី ២ , ទី ៣ , ទី ៧ ។

**បច្ច័យ –** បញ្ញាគឺអមោហហេតុ ជាបញ្ញិន្ទ្រិយប្បច្ច័យដោយសហជាតិន្ទ្រិយ៍ ។

**បច្ចយុប្បន្ន –** រួមទាំង ៤ វារៈ គឺ ចិត្តប្រកបដោយបញ្ញិន្ទ្រិយ៍ ៤៧ដួង ចេតសិក ៣៧ (វៀរបញ្ញិន្ទ្រិយ៍ជាតួបច្ច័យ) និងចិត្តសមុដ្ឋានរូប១៧ តិហេតុកបដិសន្ធិកម្មជរូប ២០ ។

**✵ហេតុប្បច្ចយា មគ្គេ ចត្តារិ**

ធម៌ជាហេតុប្បច្ច័យ ស្មើគ្នានឹងមគ្គប្បច្ច័យ មាន ៤ បញ្ហាវារៈ ដូចបញ្ចិន្ទ្រិយប្បច្ច័យ សូម្បីអង្គធម៌ក៏ដូចគ្នាដែរ ។

✵**ហេតុប្បច្ចយា វិប្បយុត្តេ តីណិ**

ធម៌ជាហេតុប្បច្ច័យ ស្មើគ្នានឹងវិប្បយុត្តប្បច្ច័យ មាន ៣ វារៈគឺ ទី ២ (**កុ→អព្យា**) , ទី ៥ (**អកុ→អព្យា**) , ទី ៧ (**អព្យា→អព្យា**) , ។

**បច្ច័យ**– ហេតុ៦ ជាបច្ច័យ ដោយសហជាតវិប្បយុត្តប្បច្ច័យ ។

**បច្ចយុប្បន្ន**– សហេតុកចិត្តជរូប១៧ និង សហេតុកបដិសន្ធិកម្មជរូប ២០ ។

អ្នកឆ្លាតគប្បីចែកក្នុង ៣វារៈ ទាំងបច្ច័យ ទាំងបច្ចយុប្បន្នផងចុះ ។

✵**ហេតុប្បច្ចយា សម្បយុត្តេ តីណិ**

ធម៌ជាហេតុប្បច្ច័យ ស្មើនឹងសម្បយុត្តប្បច្ច័យ មាន ៣វារៈ គឺ ទី ១ (**កុ→កុ**) , ទី ៤ (**អកុ→អកុ**) , ទី ៧ (**អព្យា→អព្យា**) ។

**បច្ច័យ**– ហេតុ៦ ជាបច្ច័យដោយសម្បយុត្តប្បច្ច័យ ។

**បច្ចយុប្បន្ន**– សហេតុកចិត្ត ៧១ ចេតសិក ៥២ (វៀរមោហចេតសិកក្នុងមោហមូលចិត្ត ២ដួង) ។

គប្បីចែកក្នុង ៣ បញ្ហាវារៈ ។

✵**ហេតុប្បច្ចយា អញ្ញមញ្ញេ តីណិ**

ធម៌ជាហេតុប្បច្ច័យ ស្មើគ្នានឹងអញ្ញមញ្ញប្បច្ច័យក្នុង ៣វារៈ ដូចសម្បយុត្តប្បច្ច័យ ប៉ុន្តែខុស បច្ចយុប្បន្នធម៌ ។

**បច្ច័យ**– ហេតុ ៦ ជាបច្ច័យដោយអញ្ញមញ្ញប្បច្ច័យ ក្នុង ៣វារៈ ។

**បច្ចយុប្បន្ន**– ដូចបច្ចយុប្បន្នរបស់សម្បយុត្តប្បច្ច័យដែរ ប៉ុន្តែថែមសហេតុកបដិសន្ធិហទយវត្ថុរូប ១ ក្នុងបញ្ហាវារៈទី ៧ (**អព្យា→អព្យា**) ។

✵ **ហេតុប្បច្ចយា វិបាកេ ឯកំ**

ធម៌ជាហេតុប្បច្ច័យ ស្មើគ្នានឹងវិបាកប្បច្ច័យត្រឹមតែ

១វារៈ គឺបញ្ហាវារៈទី ៧ **(អព្យា→អព្យា)** ។

**បច្ច័យ–** វិបាកហេតុ៣ ជាបច្ច័យ ដោយវិបាកប្បច្ច័យ ។

**បច្ចយុប្បន្ន–**សហេតុកវិបាកចិត្ត ៣៧ ចេតសិក ៣៨ សហេតុកវិបាកចិត្តជរូប ១៤ (វៀរវិញ្ញត្តិរូប ២ និង សទ្ទរូប ១) និង សហេតុកបដិសន្ធិកម្មជរូប ២០ ។

## កាល ភូមិ បុគ្គល ទ្វារ របស់ ហេតុប្បច្ច័យ

**កាល–** ហេតុប្បច្ច័យមានក្នុង បដិសន្ធិកាល បវត្តិកាល ចុតិកាល ។

**ភូមិ–** បញ្ចវោការភូមិ (ភូមិដែលមានខន្ធប្រាំ ២៦ ភូមិ) ចតុវោការភូមិ (ភូមិដែលមានខន្ធបួន ៤ភូមិ) ភូមិទាំង ៣០នេះ សុទ្ធតែមានហេតុប្បច្ច័យទាំងអស់ ។

**បុគ្គល–** ហេតុប្បច្ច័យមានក្នុងបុថុជ្ជន ៤ពួក ព្រះអរិយបុគ្គល ៨ពួក ។

បុថុជ្ជន ៤ពួកគឺ អហេតុកបុគ្គល ២ពួក (ដោយអំណាចអហេតុកបដិសន្ធិទាំង ២ដួង) ទុហេតុកបុគ្គល ១ពួក និង តិហេតុកបុគ្គល ១ពួក ។

ព្រះអរិយបុគ្គល ៨ពួកគឺ បុគ្គលដែលបានសំរេចមគ្គ ៤ ផល ៤ ។

រួមជាបុគ្គល ១២ពួក ។

**ទ្វារ–** ហេតុប្បច្ច័យ មានទាំងក្នុងបញ្ចទ្វារ មានទាំងក្នុងមនោទ្វារ សូម្បីក្រៅទ្វាររបស់សហេតុកបុគ្គល និងព្រះអរិយបុគ្គលក៏មានហេតុប្បច្ច័យដែរ ។

## សេចក្តីលំអិតចំពោះ កាល ភូមិ ជាដើម នៃហេតុប្បច្ច័យ

ហេតុប្បច្ច័យក្នុងបញ្ហាវារៈ រាប់ចាប់អំពីទី ១ ដល់ទី ៦ មានតែក្នុង **បវត្តិកាល** ប៉ុណ្ណោះនៅក្នុងភូមិ ៣០ ចំពោះបុគ្គល ១១ ពួក តាមសមគួរចំពោះហេតុ (វៀរ អរហត្តផលបុគ្គល ព្រោះមិនមានកុសលាកុសលហេតុ គឺមាន

តែអព្យាកតហេតុ) មាននៅក្នុងទ្វារ ៦ប៉ុណ្ណោះ ។

ចំពោះហេតុប្បច្ច័យនៅក្នុងបញ្ហាវារៈទី៧ **(អរព្យា→ អរព្យា)** រមែងមានក្នុងកាលទាំងបី គឺ បដិសន្ធិកាល បវត្តិកាល ចុតិកាល និងមានការប្រព្រឹត្តិទៅក្នុងភូមិ ២៦ (វៀរអបាយភូមិ ៤) ព្រោះនៅក្នុងអបាយភូមិ មិនមាន អព្យាកតហេតុឡើយ មានតែកុសលហេតុ និង អកុសល-ហេតុតែប៉ុណ្ណោះ ។

ចំពោះបុគ្គល ត្រូវវៀរអហេតុកបុគ្គលពីរពួក ព្រោះ បុគ្គលពីរពួកនេះ មិនមាននូវអព្យាកតហេតុ ។

ចំពោះមគ្គបុគ្គល ៤ពួក គឺ បុគ្គលកំពុងតាំងនៅក្នុង មគ្គ ៤ មានតែកុសលហេតុ ដោយមគ្គជាកុសល ដូច្នេះមិន មានអព្យាកតហេតុក្នុងអរិយបុគ្គលបួនពួកនេះដែរ ។

អព្យាកតហេតុមានទាំងទ្វារ៦ មានទាំងក្រៅទ្វារ៦ ។

**ចប់ហេតុប្បច្ច័យដោយសង្ខេប**

៙៙៙៙៙

# បឆពិចារណា

≈≈ ≈≈

ស្លឹកឈើលាស់ចេញមក រមែងចាស់ ទុំ ជ្រុះ សំរាប់ ស្លឹកឈើតាំងតែអំពីកើតរហូតដល់ជ្រុះ មិនដើម្បីបានរបស់ អ្វីៗក្នុងលោក ក្រៅអំពីដើម្បីវិនាសទៅវិញតែប៉ុណ្ណោះ ចំពោះនាមរូបក៏ដូចគ្នាដែរ ។

នាមរូបកើតក្នុងលោក មិនមានខាត មិនមាន ចំណេញ ព្រោះមុននឹងកើត នាមរូបមិនបានតាំងនៅក្នុង ទីណាប្រុងចាំកើតឡើយ ដល់ពេលកើតហើយវិនាសទៅ វិញ ក៏វាដូចគ្នានឹងនាមរូប ដែលមុននឹងកើតឡើងគឺវាមិនមាន ដូចគ្នា ។

ចំពោះការកើតឡើងនៃនាមរូបព្រោះអាស្រ័យ បច្ច័យផ្សេងៗនោះ មិនមានចំណេញសំរាប់នាមរូបខ្លួនឯង ទេ ព្រោះត្រូវវិនាសទៅវិញនូវនាមរូបនោះទាំងអស់ ត្រង់ សេចក្តីនេះ សត្វលោកល្ងង់ខ្លៅ រមែងត្រេកអរនឹងការបាន

ហើយរមែងសោយសោក កន្ទក់កន្ទេញចំពោះការបាត់បង់ ។

ការប្រកាន់ជាហេតុនាំឱ្យមាននូវការខ្សឹកខ្សួលរៀប-រាប់ និង មាននូវសេចក្ដីទុក្ខច្រើនបែបច្រើនយ៉ាងទៀត ។

បើយើងរើសកាបូបប្រាក់ដែលអ្នកដទៃភ្លេចត្រង់កន្លែងណាមួយនោះ យើងត្រេកអរប្រកាន់ទុកថាជារបស់យើង លុះដល់បានជួបម្ចាស់កាបូប គេទាមទារយករបស់គេទៅវិញ វាជាហេតុនាំឱ្យយើងជាអ្នករើសបាននោះសោកស្ដាយ ហើយវាអាចនាំឱ្យមានរឿងរ៉ាវផ្សេងៗ ព្រោះតែមិនព្រមសងទៅឱ្យម្ចាស់របស់គេ ។

សេចក្ដីនេះ បើយើងប្រគល់ឱ្យទៅម្ចាស់កាបូបវិញនោះ យើងមិនមានបង់ខាតអ្វីឯណា ព្រោះថា វាមិនមែនជារបស់យើងស្រាប់ទៅហើយ ដូច្នេះបញ្ហាវាមិនមែននៅលើម្ចាស់គេមកទារនោះទេ ប៉ុន្តែបញ្ហាវានៅលើការត្រេកអរប្រកាន់ទុក ប្រកាន់មាំចំពោះរបស់ដែលរើសបាននោះឯង ។

ចំពោះសង្ខារធម៌ក្នុងលោក ក៏មានន័យដូចកាបូបប្រាក់ដែរ សត្វលោកល្ងង់ខ្លៅ បានចាប់យកសង្ខារធម៌ដែលកើតឡើងអំពីហេតុបច្ច័យថាជាខ្លួន ថាជារបស់ខ្លួនដោយការប្រកាន់មាំ មិនបានដឹងតាមពិតចំពោះសង្ខារធម៌ដែលមានការកើតឡើងហើយ រមែងតែងតែវិនាសទៅវិញជាធម្មតា មិនបានដឹងថាសង្ខារធម៌ជារបស់ដែលមិនគួរប្រកាន់ហួងហែងឡើយ ។

សត្វលោកសោយសោកព្រោះហេតុ តែការហួងហែង មានការកង្វល់ក្នុងរបស់ដែលខ្លួនឯងហួងហែង ការហួងហែងនាំឱ្យធ្វើកម្ម នាំឱ្យមានភព មានភពរមែងមានជាតិ ជរា មរណៈ ។

អ្នកប្រាជ្ញឃើញសង្ខារធម៌ដែលកើតឡើងក្នុងលោកថាមិនគួរឱ្យចាប់យក កាលដែលសង្ខារធម៌ប្រែប្រួលទៅវិនាសទៅ បាត់បង់ទៅ រមែងមិនបានសោយសោកឡើយ ។

# ជីវិតជារបស់ខ្ចីគេ

✵ជីវិតក្នុងកំណើតមនុស្សនេះ មានភារកិច្ចប្រព្រឹត្តព្រហ្មចរិយធម៌ រួចហើយត្រូវសងជីវិតនេះឱ្យទៅម្ចាស់របស់គេ គឺ ជរា មរណៈ ។

ព្រហ្មចរិយធម៌ គឺជាយានជំនិះដ៏ប្រសើរ នាំសត្វលោកទៅកាន់ទីបំផុតទុក្ខ ដោយលះបង់ចោលនូវជីវិតដែលប្រកបដោយឧបាទានក្ខន្ធ ៥ ។

ជីវិតប្រៀបដូចសម្ភារៈសំរាប់ធ្វើទូក ឬ ក្បូនតែប៉ុណ្ណោះ សម្ភារៈទាំងនោះដែលខ្ចីអំពីគេមក ដូចជាកាំបិត ពូថៅជាដើម ចាំបាច់ត្រូវតែសងឱ្យទៅម្ចាស់គេវិញ ប៉ុន្តែអ្វីដែលជាការគួរឱ្យកក់ក្តៅ គឺក្បូនឯណោះទេ ដែលសំរាប់ឆ្លងទៅកាន់ត្រើយនាយ ។ កាំបិត ពូថៅ សម្ភារៈដែលខ្ចីគេមកនោះ មិនមែនសំរាប់ឱ្យប្រកាន់មាំថាជារបស់អញទេ ប៉ុន្តែសំរាប់ធ្វើក្បូន រួចហើយត្រេកអរក្នុងការសងជូនទៅឱ្យម្ចាស់គេវិញ ម្យ៉ាងវាជារបស់គេ ម្យ៉ាងទៀតវាជារបស់ធ្ងន់មិនអាចយកទៅតាមក្បូនបាន និងម្យ៉ាងទៀតនោះ កិច្ចការបានធ្វើស្រេចហើយ ។

សូម្បីតែជីវិតឥឡូវនេះ ក៏បុគ្គលខ្លួនឯងមិនអាចទាមទារតវ៉ា ការពារបានផង ចាំបាច់និយាយទៅថ្វីចំពោះបរិក្ខារខាងក្រៅ ។

យើងគ្រប់គ្នាដែលអាចរស់នៅបានមកដល់សព្វថ្ងៃនេះ មិនមែនដោយសារនៅលើខ្លួនឯងទេ ព្រោះបើសិនជាត្រូវស្លាប់ កាលអំពីខែមុន ឬឆ្នាំមុននោះ ក៏មុខតែស្លាប់បាត់ទៅហើយ គឺពេលដែលត្រូវស្លាប់ ហើយអាចស្លាប់បានដោយពិត តាំងតែអំពីបដិសន្ធិរួចមកម្ល៉េះ ប៉ុន្តែដែលចេះតែបាននៅរស់នេះ ព្រោះបច្ច័យនៃជីវិតនេះឯង គឺមិនមែននៅលើជីវិតខ្លួនឯងទេ ។

ប្រទីបប្រេងអាចរលត់បានគ្រប់ពេលបើសិនជាប្រេងអស់ ឬប្រឆេះអស់ ហើយសូម្បីនៅប្រេងនៅប្រឆេះ ក៏វាអាចរលត់បានដែរ ដោយខ្យល់បក់ ឬសត្វហើរប៉ះទង្គិចនោះ

ដូច្នេះអណ្តាតប្រទីប មិនអាចការពារអ្វីខ្លួនឯងបានឡើយ យ៉ាងណាមិញ ជីវិតសព្វសត្វក្នុងមនុស្សលោកយើងនេះ ក៏ដូចប្រទីបប្រេងយ៉ាងនោះដែរ ។

ហេតុ-បច្ច័យមិនមែនតាក់តែងឱ្យតែជីវិតបាននៅរស់ប៉ុណ្ណឹងទេ ជីវិតត្រូវរស់នៅយ៉ាងណាៗ ក៏សម្រេចទៅលើហេតុ-បច្ច័យផងដែរ ការមានបាននូវទ្រព្យសម្បត្តិ ការជួបការព្រាត់ សត្វនិងសង្ខារ ឈឺ ជា សុខ ទុក្ខ ឬ ស្លាប់ពេលណាកន្លែងណា ស្លាប់ដោយសារអ្វី ។ល។ ត្រូវសំរេចនៅលើហេតុ-បច្ច័យទាំងអស់ ។

ព្រោះហេតុនេះ មនុស្សលោកគួរតែមានសេចក្តីសន្តោស ត្រូវរៀនឱ្យចេះមានការយោគយល់ដល់គ្នានិងគ្នា ការប្រព្រឹត្តិអាក្រក់ កាប់សម្លាប់លួចប្លន់ មិនមែនជាវិធីដោះស្រាយបញ្ហាឱ្យជីវិតខ្លួនឯងឡើយ ផ្ទុយមកវិញ វារឹងរឹតតែបង្កើតបញ្ហា និង កម្មពៀរវេរា មិនមានឈប់ឈរឱ្យខ្លួនឯង និង អ្នកដទៃទៅវិញទេ ។

សេចក្តីព្យាយាមសាងល្អក្នុងកាលមុន ក្នុងជាតិមុនបានរៀបចំជីវិតឱ្យកើតមកក្នុងកំណើតមនុស្ស វាជាដើមទុនមួយសំខាន់ណាស់សំរាប់មនុស្សលោករើបម្រះចេញអំពីពិភពងងឹតនៃកម្មពៀរវេរា ។

អំពើអាក្រក់ ការព្យាបាទ បៀតបៀន អមនុស្សធម៌ វាជាអន្លង់ភក់នៃកាមគុណតែប៉ុណ្ណោះ វាជាការបំរើកិលេសពិតៗ និង វាជាការងារដ៏ថោកទាបសៅហ្មង ។

ជីវិតមនុស្សកើតដោយបុណ្យកុសលអំពីជាតិមុនមានតម្លៃស្មើគ្នានឹងព្រហ្មចរិយធម៌ ព្រោះមនុស្សអាចប្រព្រឹត្តព្រហ្មចរិយធម៌បាន មិនត្រូវបណ្តោយប្រាណដោយក្តី ប្រមាទឱ្យមានការលង់លិចក្នុងអន្លង់ខ្មៅងងឹត ធ្វើជីវិតឱ្យថោកទាបនោះឡើយ អ្នកប្រាជ្ញបានពោលថា ជីវិតនេះមានប្រមាណតិច ។

បើដឹងថាខ្លួនឯងចាញ់ស្តេចមច្ចុរាជទេ ហេតុអ្វីក៏បានជាចង់តែយកឈ្នះមនុស្សជាតិគ្នាឯង តើបានប្រយោជន៍អ្វីទៅ សូមមនុស្សលោកឈប់ឈ្លោះទាស់ទែងគ្នា ឈប់ចងគំនុំជាមួយនឹងគ្នា ហើយនាំគ្នាស្តាប់ឱវាទព្រះសម្មាសម្ពុទ្ធ

ដើម្បីរត់ចេញអំពីអំណាចមច្ចុរាជ ធ្វើដំណើរទៅកាន់ទីដែលផុតស្លាប់ នេះទើបជាកិច្ចដែលគួរធ្វើ ។

បើសិនជាការបានឈ្នះគេលើលោកនេះ ហើយមច្ចុ-រាជទុកជីវិតឱ្យ ក៏គួរតែខំប្រឹងទៅចុះ តែបើវាពិតជាពុំមែនដូចនេះហើយនោះ យើងមិនគួរចំណាយពេលវេលាទៅក្នុងការងារឥតប្រយោជន៍ឡើយ សប្បុរសដែលបានដឹងច្បាស់ហើយលោកមិនបង្អែបង្អង់ទេ លោកទៅឆ្ងាយហើយ គឺឆ្ងាយចាកភពបី សូមមនុស្សប្រុសស្រីកុំបំភ្លេចការពិតនៃជីវិតរបស់ខ្លួនឯងចោលឱ្យសោះ ព្រោះការពិតវានៅតែជាការពិតគ្រប់គ្រា គ្រប់ពេលវេលា ហើយការពិតនេះ វាអាចជួយដោះស្រាយបញ្ហាចំពោះបុគ្គលណាដែលបានដឹងការពិតនៃជីវិតនេះ គឺគ្រប់បញ្ហាទាំងអស់ រួមទាំងបញ្ហា ជាតិ ជរា មរណៈ ទៀតផង ។

# អារម្មណប្បច្ច័យ

✵ **ព្រះអភិធម្មបិដក បដ្ឋាន បិដកខ្មែរ ៩៤ ទំព័រ ២ បច្ចយនិទ្ទេសវារៈ**

**១–រូបាយតនំ ចក្ខុវិញ្ញាណធាតុយា តំសម្បយុត្តកានញ្ច. ធម្មានំ. អារម្មណប្បច្ច. យេន. បច្ចយោ**

ប្រែថាៈ រូបាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណធាតុ និងពួកធម៌ដែលប្រកបជាមួយចក្ខុវិញ្ញាណធាតុនោះផង ដោយអារម្មណប្បច្ច័យ ។

**បច្ច័យ**–រូបារម្មណ៍ គឺវណ្ណរូប

**បច្ចយុប្បន្ន**–ចក្ខុវិញ្ញាណចិត្ត ២ដួង និង សព្វចិត្តសាធារណចេតសិក ៧ ។

**២–សទ្ទាយតនំ. សោតវិញ្ញាណធាតុយា**

**តំសម្បយុត្តកានញ្ច ធម្មានំ អារម្មណប្បច្ច-យេន បច្ចយោ ។**

ប្រែថា ៖ សទ្ទាយតនៈ ជាបច្ច័យនៃសោតវិញ្ញាណ-ធាតុ និង ពួកធម៌ដែលប្រកបជាមួយ.សោតវិញ្ញាណធាតុនោះផង ដោយអារម្មណប្បច្ច័យ ។

**បច្ច័យ** – សទ្ទារម្មណ៍គឺ សំឡេង

**បច្ចយុប្បន្ន** – សោតវិញ្ញាណចិត្ត ២ដួង និង សព្វចិត្តសាធារណចេតសិក ៧ ។

**✵ត្រឹមតែចិត្តឃើញនូវរូបារម្មណ៍ ត្រឹមតែចិត្តឮនូវសទ្ទារម្មណ៍ កាលបើត្រឹមតែចិត្តប៉ុណ្ណោះ សត្វបុគ្គលមិនមានក្នុងលោក។**

**៣ – គន្ធាយតនំ ឃានវិញ្ញាណធាតុយា តំសម្បយុត្តកានញ្ច ធម្មានំ អារម្មណប្បច្ច-យេន បច្ចយោ ។**

ប្រែថា ៖ គន្ធាយតនៈ ជាបច្ច័យនៃឃានវិញ្ញាណធាតុ និង ពួកធម៌ដែលប្រកបជាមួយឃានវិញ្ញាណធាតុនោះផង ដោយអារម្មណប្បច្ច័យ ។

**បច្ច័យ** – គន្ធារម្មណ៍ គឺ ក្លិន

**បច្ចយុប្បន្ន** – ឃានវិញ្ញាណធាតុ ២ដួង និង សព្វចិ-........ ចេតសិក ៧ ។

**✵វិញ្ញាណធម្មតាៗ ជាប្រក្រតី គឺជាទីតាំងនៃសតិរលឹកដឹងដោយពិត ។**

**៤ – រសាយតនំ ជីវ្ហាវិញ្ញាណធាតុយា តំសម្បយុត្តកានញ្ច ធម្មានំ អារម្មណប្បច្ច-យេន. បច្ចយោ ។**

ប្រែថា ៖ រសាយតនៈ ជាបច្ច័យនៃជីវ្ហាវិញ្ញាណធាតុ និង ពួកធម៌ដែលប្រកបជាមួយជីវ្ហាវិញ្ញាណធាតុនោះផង ដោយអារម្មណប្បច្ច័យ ។

**បច្ច័យ** – រសារម្មណ៍ គឺ រសរូប

**បច្ចយុប្បន្ន** – ជីវ្ហាវិញ្ញាណធាតុ ២ដួង និង សព្វចិ-

........ ចេតសិក ៧ ។

**✵គួរអប់រំឧបនិស្ស័យ ឱ្យបានទៅជាទម្លាប់ ក្នុងការលើកសិក្សានូវចិត្តវិញ្ញាណជាធម្មតាៗ ជាការមាវចរ ។**

**៥–ផោដ្ឋព្វាយតនំ កាយវិញ្ញាណធាតុយា តំសម្បយុត្តកានញ្ច ធម្មានំ អារម្មណប្បច្ចយេន បច្ចយោ ។**

ប្រែថា : ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណធាតុ និង ពួកធម៌ដែលប្រកបជាមួយកាយវិញ្ញាណធាតុនោះផង ដោយអារម្មណប្បច្ច័យ ។

**បច្ច័យ–** ផោដ្ឋព្វារម្មណ៍គឺមហាភូតរូប ៣ ដី ភ្លើង ខ្យល់ ។

**បច្ចយុប្បន្ន–** កាយវិញ្ញាណចិត្ត ២ដួង និង សព្វចិ-....... ចេតសិក ៧ ។

**✵បើដឹងចិត្តធម្មតាថាយ៉ាងណាហើយនោះ មិនចាំបាច់ត្រូវការចិត្តដទៃទៀតមកជួរផ្លាស់ឡើយ គឺមានតែការមិនប្រកាន់ប៉ុណ្ណោះ ។**

**៦–រូបាយតនំ. សទ្ទាយតនំ. គន្ធាយតនំ រសាយតនំ ផោដ្ឋព្វាយតនំ មនោធាតុយា តំសម្បយុត្តកានញ្ច ធម្មានំ អារម្មណប្បច្ចយេន បច្ចយោ ។**

ប្រែថា : រូបាយតនៈ សទ្ទាយតនៈ គន្ធាយតនៈ ជិវ្ហាយតនៈ ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃមនោធាតុ និង ពួកធម៌ដែលប្រកបជាមួយមនោធាតុនោះផង ដោយអារម្មណប្បច្ច័យ ។

**បច្ច័យ–** គោចររូប ៧ គឺ រូប សំលេង ក្លិន រស បឋវី តេជោ វាយោ ។

**បច្ចយុប្បន្ន–** មនោធាតុ ៣ដួង និង ចេតសិក ១០ កើតបានក្នុងបញ្ចទ្វារ ។

## មនោធាតុ៣ដួងគឺអ្វី ?

គឺ : កិរិយាមនោធាតុ ១ដួង និង វិបាកមនោធាតុ ២ដួង ។

- កិរិយាមនោធាតុ គឺជាធាតុចិត្ត ដែលជាហេតុជិតនៃបញ្ចវិញ្ញាណ ចក្ខុវិញ្ញាណជាដើមត្រូវអាស្រ័យកិរិយា-មនោធាតុនេះកើតមុន រួចហើយរលត់ទៅជាអនន្តរប្ប-ច្ច័យ ។

កិរិយាមនោធាតុធ្វើអាវជ្ជនកិច្ចតាមបញ្ចទ្វារ **"បញ្ចទ្វារាវជ្ជនកិច្ច"** ជាជើងទ្របញ្ចទ្វារវិថីចិត្ត គឺជាចិត្តកើតឡើងមុនគេក្នុងបញ្ចទ្វារ បើចិត្តនេះមិនបានកើតឡើងទេ បញ្ចវិញ្ញាណជាដើមមិនបានកើតឡើងជាដាច់ខាត ពោលគឺ វិថីចិត្តតាមបញ្ចទ្វាររមែងមិនមានឡើយ ។

កិរិយាមនោធាតុ គឺជាធាតុចិត្ត ពុំមែនសត្វបុគ្គល មានកិរិយាគ្រាន់តែសំរាប់ផ្លាស់វិបាកជាភវង្គៈឱ្យមកជាវិបាកក្នុងបញ្ចទ្វារ ស្ថានរបស់កិរិយាមនោធាតុគឺនៅរវាងចន្លោះភវង្គៈ និង បញ្ចវិញ្ញាណ ។

កិរិយាមនោធាតុ អាស្រ័យហទយវត្ថុ ទើបមិនមែនជាបញ្ចវិញ្ញាណធាតុ ម្យ៉ាងទៀតមិនកើតនៅក្នុងមនោទ្វារ ទើបមិនមែនជាមនោវិញ្ញាណធាតុ ។

ក្នុងចំនួនចិត្ត ១២១ដួង មានចែកជាវិញ្ញាណធាតុ ៧ គឺៈ ចក្ខុវិញ្ញាណធាតុ ១ សោតវិញ្ញាណធាតុ ១ ឃានវិញ្ញា-ណធាតុ ១ ជិវ្ហាវិញ្ញាណធាតុ ១ កាយវិញ្ញាណធាតុ ១ មនោធាតុ ១ និង មនោវិញ្ញាណធាតុ ១ ។

មនោធាតុបានដល់ចិត្ត ៣ដួង ដូចដែលបានរាប់រួចហើយមានពីរជាតិគឺៈ កិរិយាជាតិមានមួយដួង និង វិបាក-ជាតិមានពីរដួង ។

វិបាកមនោធាតុធ្វើកិច្ចទទួលអារម្មណ៍បន្ទាប់បន្តអំពីបញ្ចវិញ្ញាណ កើតតែក្នុងបញ្ចទ្វារ មាន ២ដួងគឺ : ១ដួងជាកុសលវិបាក ដឹងអារម្មណ៍ល្អ និង ១ដួងទៀត ជាអកុសលវិបាក ដឹងអារម្មណ៍មិនល្អ ទាំងពីរដួងនេះ អាស្រ័យហទយ-វត្ថុរូប ប៉ុន្តែមិនបានកើតនៅក្នុងមនោទ្វារឡើយ ទើបជាមនោធាតុប៉ុណ្ណោះ ដូចកិរិយាមនោធាតុដែរ ។

មនោធាតុ ៣ដួងនេះ ក្នុងមួយដួងៗ មានចេតសិក

១០ ប្រកបជាមួយ គឺសព្វចិត្តសាធារណចេតសិក ៧ និង វិតក្កៈ វិចារៈ អធិមោក្ខៈ ។

បញ្ចវិញ្ញាណធាតុ មានស្ថាននៅរវាងកិរិយាមនោ-ធាតុ និង វិបាកមនោធាតុ នេះឯងគឺមនោធាតុ ៣ដួង ។

**៧–សព្វេ ធម្មា មនោវិញ្ញាណធាតុ-យា តំសម្បយុត្តកានញ្ច ធម្មានំ អារម្ម-ណប្បច្ចយេន បច្ចយោ ។**

ប្រែថា ៈ ធម៌ទាំងពួង ជាបច្ច័យនៃមនោវិញ្ញាណ-ធាតុ និង ពួកធម៌ដែលប្រកបដោយមនោវិញ្ញាណធាតុនោះផង ដោយអារម្មណប្បច្ច័យ ។

**បច្ច័យ**–បរមត្ថធម៌ទាំង ៤ ព្រមទាំងបញ្ញត្តិ (មិនមានវៀរអ្វីឡើយ)

**បច្ចយុប្បន្ន**–មនោវិញ្ញាណធាតុ ៧៦ បើដោយពិស្តារ ១០៨ដួង (វៀរទ្វិបញ្ចវិញ្ញាណ ១០ មនោធាតុ ៣) ចេតសិក ៥២ ។

## ប្ញូតសរុបបច្ច័យ និង បច្ចយុប្បន្ន

**✵ យំ. យំ. ធម្មំ. អារព្ភ. យេ. យេ. ធម្មា. ឧប្បជ្ជន្តិ. ចិត្តចេតសិកា. ធម្មា. តេ. តេ. ធម្មា. តេសំ. តេសំ. ធម្មានំ. អារម្មណប្បច្ចយេន. បច្ចយោ ។**

ប្រែថា ៈ **យេ. យេ. ធម្មា** ពួកធម៌ណាៗ (ចិត្ត ១២១ ចេតសិក ៥២)

**យំ យំ ធម្មំ អារព្ភ** ប្រារព្ធនូវធម៌ណាៗ (បរមត្ថ ធម៌ ៤ និង បញ្ញត្តិ)

**ឧប្បជ្ជន្តិ ចិត្តចេតសិកា ធម្មា** ធម៌ទាំងឡាយគឺចិត្ត និង ចេតសិក រមែងកើតឡើង

**តេ. តេ. ធម្មា** ពួកធម៌នោះៗ (បរមត្ថធម៌ ៤ និង បញ្ញត្តិ)

**តេសំ. តេសំ. ធម្មានំ. អារម្មណប្បច្ចយេន . បច្ចយោ ។**

ជាបច្ច័យ នៃពួកធម៌នោះ។ (ចិត្ត ១២១ ចេតសិក ៥២) ដោយអារម្មណប្បច្ច័យ ។

<u>**ខចនត្ថ**</u> :

✵**ចិត្តចេតសិកា. អាគន្ត្វា. រមន្តិ. ឯត្ថាតិ=អារម្មណំ** ចិត្ត និងចេតសិកទាំងឡាយមកត្រេកអរក្នុងធម្មជាតិនេះ ដូច្នេះ ធម្មជាតិនេះ ហៅថាអារម្មណ៍។

≈≈≈✧✧✧≈≈≈

≈≈

# ពន្យល់ពាក្យអារម្មណ៍

≈≈≈≈≈

អារម្មណ៍ គឺជាគ្រឿងតោងនៃចិត្ត និង ចេតសិក ។

វិថីចិត្តតាមទ្វារទាំង ៦ មិនអាចកើតឡើងបានទេ បើមិនមាននូវអារម្មណ៍ទេនោះ ។

ផែនដី ព្រៃភ្នំ ទន្លេ សមុទ្រ ស្រុកមនុស្ស ស្រុកទេវតា ជាបញ្ញត្តិ ជាលោកដែលចិត្តនឹកគិតតែប៉ុណ្ណោះ ។

លោកដែលព្រះសម្មាសម្ពុទ្ធត្រាស់ដឹងគឺ រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ និង បរមត្ថធម្មារម្មណ៍ ។

តាមបរមត្ថធម៌ពិត មិនមាននូវលោកអ្វីក្រៅអំពីលោកដែលជាអារម្មណ៍ មានរូបារម្មណ៍ជាដើមនេះឡើយ ។

ក្រៅអំពីចិត្ត និង ចេតសិក មិនមានអ្វីកើតឡើងដឹងនូវលោកទៀតទេ ការដឹងនូវលោក ពុំមែនជាមនុស្សសត្វបុគ្គលឡើយ ។

ចិត្តចេតសិកកើតឡើងដឹងលោកគឺ អារម្មណ៍តាមទ្វារ ៦ ហើយត្រូវរលត់បាត់ទៅវិញ ព្រាត់ប្រាសចោលលោកទាំងពួង គ្រប់គ្រា គ្រប់ពេលវេលាតែយ៉ាងនេះរហូត ។

ការចំរើនសតិប្បដ្ឋាន គឺការរលឹកសិក្សារឿយៗនូវសភាវធម៌ដែលកំពុងប្រាកដ បញ្ញាមានការបានឃើញនូវនាមរូប ពុំមែនជាសត្វបុគ្គលតួខ្លួន ទីបំផុតក៏បានដឹងច្បាស់ថា ការរួចផុតចាកទុក្ខគឺនៅត្រង់រំលត់សេចក្តីប្រកាន់ ។

ការស្វែងរកនូវកាមសុខ ដើម្បីបំបាត់ទុក្ខសោកនោះគឺមិនអាចរួចផុតចាកទុក្ខបានទេ ពីព្រោះការស្វែងរកនូវកាមសុខ គឺជាតណ្ហា ជាហេតុនាំឱ្យកើតទុក្ខ នាំឱ្យមាននូវជាតិ ជរា មរណៈ កាមទាំងឡាយមានសេចក្តីសុខតិច មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ។

ការលះបង់នូវទុក្ខដោយការប្រព្រឹត្តិព្រហ្មចរិយធម៌គឺចំរើននូវអរិយមគ្គអង្គ ៨ ប្រការ ទើបជាការលះបង់បាននូវទុក្ខយ៉ាងពិតប្រាកដ ។

សតិប្បដ្ឋានបដិបត្តិ កំចាត់បង់នូវកិលេសជា តទង្គប្បហាន ហើយមានការបង្អោនទៅកាន់ព្រះនិព្វាន គឺជាការបដិបត្តិដើម្បីបាននូវអរិយមគ្គជាលោកុត្តរ មានព្រះនិព្វានជាអារម្មណ៍ រំលត់កិលេសដាច់ជាសមុច្ឆេទប្បហាន នេះជាការបដិបត្តិ កំចាត់បង់នូវទុក្ខ ។

ការសិក្សាអំពីអារម្មណប្បច្ច័យ និង ការចំរើនសតិប្បដ្ឋាន នាំឱ្យបានស្គាល់លោកក្នុងអរិយវិន័យ ហើយបានដឹងអំពីការជាប់ជំពាក់នៅក្នុងលោក និង បានដឹងអំពីការរួចផុតចាកលោក ការរំលត់ទុក្ខ គឺព្រះនិព្វាន ។

តាមពិត លោកដែលពពួកសត្វជាប់ជំពាក់នៅនោះគឺរូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ និង ធម្មារម្មណ៍ ដែលអារម្មណ៍ទាំង ៦ នេះជា **សំយោជនិយធម៌** ហ្នឹងឯង ។

សំយោជនិយធម៌ បានដល់ធម៌ដែលជាគ្រឿងនាំឱ្យជាប់ជំពាក់ គឺនាំឱ្យកើត **សំយោជនៈ** ដោយអារម្មណប្បច្ច័យ ។

សំយោជនៈនេះឯងដែលជាគ្រឿងចងព័ទ្ធព័ន្ធសត្វ

លោកឱ្យជាប់នៅក្នុងវដ្តសង្សារ ព្រោះថា សេចក្តីប្រកាន់ថា នុ៎ះ ជារបស់យើង នុ៎ះជាយើង នុ៎ះជាខ្លួនរបស់យើង ក៏គឺជាតួសំយោជនៈហ្នឹងឯង ដូច្នេះទើបឈ្មោះថា សំយោជនៈជាគ្រឿងចងទុកនូវពពួកសត្វឱ្យជាប់ក្នុងភព តាមពិតដោយបរមត្ថ សត្វ មិនមានទេ ព្រោះហេតុដូចនេះហើយ ទើបការកាត់នូវសំយោជនៈដោយបញ្ញា បានឈ្មោះថា សត្វរមែងរួចផុតចាកលោក បានដល់ទីបំផុតទុក្ខគឺព្រះនិព្វាន ។

**ព្រះនិព្វាន មិនមែនជាការរស់នៅនៃសត្វបុគ្គលចាកភពនោះទេ ប៉ុន្តែជាការរស់នៅនៃតណ្ហាដែលប្រាថ្នាភពនោះឯង** តាមពិតសត្វបុគ្គល មិនមានដោយបរមត្ថស្រាប់ទៅហើយ ប៉ុន្តែដោយអំណាចតណ្ហា មានៈ ទិដ្ឋិ ទើបមានសេចក្តីប្រកាន់ថា ខ្លួនយើងមានក្នុងភព មានយើង និង មានអ្វីៗជារបស់យើង។

**អរិយមគ្គជាលោកុត្តរ រំលត់សេចក្តីប្រកាន់ខ្លួនពេលណា អរិយមគ្គនោះឈ្មោះថាជាផ្លូវដ៏ប្រសើរ ព្រោះនាំសត្វចេញចាកអំពីលោកនេះ ឬធ្វើឱ្យសត្វរួចផុតចាកលោកនេះ និង លោកដទៃ ពោលគឺបានដល់នូវព្រះនិព្វាន ។**

ការអប់រំសតិប្បដ្ឋាន បានធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន មិនមានសេចក្តីយល់ថាខ្លួនមានក្នុងលោកនេះ ហើយដល់ពេលស្លាប់ទៅ ខ្លួនត្រូវទៅកើតក្នុងលោកខាងមុខនោះឡើយ ។

សួរថា បើស្លាប់ទៅខ្លួនមិនទៅកើតទៀតទេ មានតែឧច្ឆេទទិដ្ឋិ ដែលយល់ថា សត្វស្លាប់ទៅសូន្យ មិនកើតទៀតមិនមែនទេឬ ?

ឆ្លើយថា មិនមែនទេ ការចំរើនសតិប្បដ្ឋាន-វិបស្សនា បានជាក់ច្បាស់ បានត្រាស់ដឹង នូវទុក្ខសច្ចៈ សមុទយសច្ចៈ និរោធសច្ចៈ និង មគ្គសច្ចៈ ឃើញការកើតក្នុងភពថ្មី

គឺជាទុក្ខសច្ចៈ សូន្យចាកសត្វបុគ្គលតួខ្លួនអ្នកកើត ការរំលត់នូវសេចក្តីប្រកាន់ថា មានតួខ្លួនក្នុងលោកនេះ និង រំលត់ការប្រកាន់ថា មានតួខ្លួនក្នុងលោកដទៃ ការរំលត់នូវសេចក្តីប្រកាន់នេះ គឺជានិរោធសច្ច ។

✵✵✵✵✵
✵✵✵
✵

# អារម្មណ៍របស់វិបស្សនា

ការចំរើនសតិប្បដ្ឋានក្នុងជីវិតប្រចាំថ្ងៃ ត្រូវអាស្រ័យសេចក្តីអត់ធន់គឺខន្តីធម៌ សេចក្តីអត់ធន់នេះ គឺហាមឃាត់នូវចំណង់ដែលចង់បានសតិបញ្ញាច្រើនៗ ព្រោះបើមិនមាននូវសេចក្តីអត់ធន់ទេនោះ លោភៈវានឹងនាំឱ្យឃ្លាតចាកអំពីសេចក្តីព្យាយាម ក្នុងការសង្កេតពិនិត្យ រលឹកសិក្សា នូវសភាវធម៌តាមពិតក្នុងជីវិតប្រចាំថ្ងៃ ។

**ការមិនមានសតិច្រើនៗ ក្នុងមួយថ្ងៃៗនោះ មិនមែនព្រោះយើងមិនចំរើនសតិ ឬព្រោះយើងមិនបានបង្ខាប់សតិ ប្រើសតិនោះទេ តាមពិតព្រោះហេតុរបស់សតិ មិនបានគ្រប់គ្រាន់ ៗ**

ជាចាំបាច់ត្រូវឱ្យបានដឹងថា តើសតិ-វិបស្សនា មានលក្ខណៈយ៉ាងណា ហើយតើសតិវិបស្សនា មានការរលឹក

ដឹងអ្វី ឃើញច្បាស់នូវអ្វី ហើយក្នុងពេលណា កន្លែងណា ដូច្នេះត្រូវរៀន ត្រូវស្តាប់ ត្រូវសន្ទនាឱ្យបានយល់ច្បាស់ ។

សតិមានមានការរលឹកដឹងជាលក្ខណៈ វិបស្សនាមានការឃើញច្បាស់ដោយបញ្ញាដោយលក្ខណៈ ។

រលឹកដឹងអ្វី-ឃើញច្បាស់នូវអ្វី? សភាវធម៌ក្នុងជីវិតប្រចាំថ្ងៃ គឺជាអារម្មណ៍របស់សតិ-វិបស្សនា ព្រោះថា ជីវិតប្រចាំថ្ងៃនេះ មិនមែនយ៉ាងដទៃ ក្រៅអំពីសេចក្តីពិតឡើយ

បើមិនរលឹកសិក្សាឱ្យទាល់តែបានជាក់ច្បាស់ថា សភាវធម៌ក្នុងជីវិតប្រចាំថ្ងៃ មិនមែនជាសត្វបុគ្គលតួខ្លួនទេនោះ គឺដាច់ខាតប្រាកដជាមិនអាចដឹងថា ការចាកផុតទុក្ខនោះ នៅត្រង់ការរំលត់សេចក្តីប្រកាន់ឡើយ ហើយក៏នៅតែមានការប្រកាន់ចំពោះសភាវធម៌ជាដដែល ឈ្មោះថាបុថុជ្ជន អាស្រ័យវដ្តៈ ។

ការមានខន្តី មិនឱ្យមានចំណង់ចង់បានសតិច្រើនៗ ដែលចំណង់នេះវានាំឱ្យទៅរកការប្រព្រឹត្តិខុសនោះ ការមាននូវខន្តីនេះ នាំឱ្យមានការចំរើននូវសេចក្តីព្យាយាម សង្កេតពិនិត្យរឿយៗ ចំពោះរូបធម៌ និង នាមធម៌នៅពេលដែលកំពុងប្រាកដ តាមផ្លូវភ្នែក ផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ និង ផ្លូវចិត្ត ។

សតិ-វិបស្សនា មានការស្រាវជ្រាវរាវរកការពិតនៅក្នុងសភាវធម៌ ដូច្នេះទើបសតិប្បដ្ឋានវិបស្សនា មានតែរូបធម៌ នាមធម៌ ជាបរមត្ថសុទ្ធជាអារម្មណ៍ គឺមិនមានបញ្ញត្តិទាំងអស់ជាអារម្មណ៍ឡើយ ដោយបញ្ញត្តិមិនមែនជាសភាវធម៌ពិត បញ្ញត្តិមិនមាននូវសភាវលក្ខណៈ មិនមាននូវការកើត ការរលត់ ដូចជាសភាវធម៌ទេ ។

**បុគ្គលអ្នកចំរើនសតិប្បដ្ឋាន មិនបានឃើញសតិ-វិបស្សនា មានការចំរើនឡើងកើតឡើងដោយតួខ្លួនជាអ្នកឱ្យចំរើនឱ្យកើតនោះឡើយ គឺបានដឹង បានឃើញតាមពិតនូវការចំរើនឡើង កើតឡើងនៃសតិ-វិបស្សនានោះ ព្រោះហេតុពិតៗ សូន្យចាកតួ**

**ខ្លួនជាអ្នកបន្ទាប់បញ្ជាសតិ សូន្យចាកតួខ្លួនក្នុងលោកភ្នែក សូន្យចាកតួខ្លួនក្នុងលោកត្រចៀក សូន្យចាកតួខ្លួនក្នុងលោកច្រមុះ សូន្យចាកតួខ្លួនក្នុងលោកអណ្តាត សូន្យចាកតួខ្លួនក្នុងលោកកាយ សូន្យចាកតួខ្លួនក្នុងលោកចិត្ត** តាមពិតធមិទាំងឡាយកើតអំពីហេតុ ។

# អភិធម្មបិដក៩៤ ទំព័រ ២៣១

## បញ្ហាវារៈនៃអារម្មណប្បច្ច័យ

**I- កុសលោ ធម្មោ កុសលស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ។**

ប្រែថា ៖ កុសលធមិជាបច្ច័យនៃកុសលធមិ ដោយអារម្មណប្បច្ច័យ ។

**មាន ១០ចំណុចគឺ ៖**

1- **ទានំ.ទត្វា.សីលំ.សមាទយិត្វា.ឧបោសថកម្មំ កត្វា.តំ.បច្ចវេក្ខតិ ។**

បុគ្គលឱ្យទាន រក្សាសីល ធ្វើឧបោសថកម្ម ហើយពិចារណានូវកុសលនោះ ។

**បច្ច័យ**– មហាកុសល ៨ ចេតសិក ៣៨ ។

**បច្ចយុប្បន្ន**– មហាកុសល ៨ និង ចេតសិក ៣៣ ( វៀរអប្បមញ្ញា ២ វីរតិ ៣ ដោយមិនមែនជាចេតសិក

សំរាប់ពិចារណា) ។

## អត្ថកថាអារម្មណប្បច្ច័យ

បទថា **ទានំ. ទត្វា** គឺលះបង់នូវរបស់ដែលគួរឱ្យម្យ៉ាងទៀត បានដល់ចេតនាជាហេតុនៃការឱ្យ **ទត្វា** គឺជំរះចេតនាឱ្យផូរផង់ លះបង់ដោយហ្មត់ចត់ ។

បទថា **សីលំ. សមាទយិត្វា** គឺ សមាទាននិច្ចសីល ដោយអំណាចសីលមានអង្គ ៥ ឬអង្គ ១០ ជាដើម សមាទានវិរតិទ្រង់សំដែងហើយដោយពាក្យនេះ ចំណែកសម្បត្តវិរតិ និង សមុច្ឆេទវិរតិ មិនបានត្រាស់ទុក ព្រោះមិនបានប្រាកដថា ជាសីលក្នុងលោក សូម្បីមិនបានត្រាស់ទុកក៏ពិតមែន ប៉ុន្តែក៏ជាអារម្មណប្បច្ច័យបានដូចគ្នា ។

សមុច្ឆេទវិរតិ ជាអារម្មណប្បច្ច័យនៃកុសលរបស់ព្រះសេក្ខបុគ្គលតែប៉ុណ្ណោះ មិនចំពោះបុគ្គលដទៃឡើយ ។

បទថា **ឧបោសថកម្មំ. កត្វា** គឺធ្វើឧបោសថកិរិយា ដែលមានអង្គ៨ ក្នុងថ្ងៃឧបោសថ ដូចលោកបានពោលទុកថា មិនគប្បីសម្លាប់សត្វ និង មិនគប្បីកាន់យកនូវវត្ថុដែលម្ចាស់ទ្រព្យគេមិនបានឱ្យជាដើម ។

បទថា **តំ បច្ចវេក្ខតិ** មានសេចក្តីថា ព្រះសេក្ខបុគ្គល ឬ បុថុជ្ជនក៏ដោយ រមែងពិចារណានូវកុសលនោះម្យ៉ាងទៀត សូម្បីព្រះអរហន្តក៏រមែងពិចារណា ។ ពិតណាស់ សំរាប់ព្រះអរហន្ត កុសលដែលធ្វើហើយក្នុងកាលមុនក៏ឈ្មោះថាជាកុសល កាលលោកពិចារណាដោយចិត្តណាចិត្តនោះឈ្មោះថា កិរិយាចិត្ត ព្រោះដូច្នោះ កិរិយាចិត្តនោះទើបមិនបាននៅក្នុងអធិការនេះថា កុសលោ ធម្មោ កុសលស្ស ធម្មស្ស ដែលជាបញ្ហាវារៈទី ១ ។

## រំលឹកសតិប្បដ្ឋាន

✵ នៅពេលណាមានការពិចារណាចំពោះកុសលធម៌ដែលបានធ្វើហើយ ឬ ដែលនឹងត្រូវធ្វើក្នុងពេលខាងមុខនៅពេលនោះ ការពិចារណានោះឯង ជាទីតាំងនៃសតិរលឹកបើពិចារណាដោយកុសលចិត្តពិត១ កុសលធម៌ដែលពិចារណានោះ ក៏ជា **ធម្មា** ពុំមែនជាយើងឡើយ ។

**ចំពោះអារម្មណប្បច្ច័យ គឺជាបច្ច័យនាំឱ្យកើតចិត្ត និង ចេតសិកតែប៉ុណ្ណោះ មិនមានមនុស្សសត្វបុគ្គលកើតដោយអារម្មណ-ប្បច្ច័យសោះឡើយ** នេះហើយគឺជាការសិក្សាដោយល្អ នៅក្នុងព្រះសាសនា ។

## 2- បុព្វេ សុចិណ្ណានិ បច្ចវេក្ខតិ ។

បុគ្គលពិចារណាពួកកុសល ដែលធ្លាប់សន្សំល្អហើយក្នុងកាលមុន ។

**បច្ច័យ**– មហាកុសល ៨ និង ចេតសិក ៣៨ ជាអារម្មណប្បច្ច័យ ។

**បច្ចយុប្បន្ន**– មហាកុសល ៨ និង ចេតសិក ៣៣ ជាតួពិចារណា ។

### អត្ថកថាក្នុងចំណុចទី ២

ពិតណាស់ កម្មដែលធ្វើជិត១គ្នា ទ្រង់ត្រាស់ថា ឱ្យហើយ សមាទានហើយ ធ្វើហើយ ។

ពាក្យថា **បុព្វេ សុចិណ្ណានិ** កម្មទាំងអស់នេះគប្បីជ្រាបថា មិនបានធ្វើជិត១គ្នាទេ ម្យ៉ាងទៀត ពាក្យនេះទ្រង់ត្រាស់ទុកមក ដើម្បីសំដែងដល់កាមាវចរកុសលដទៃអំពីមុន ។

## 3- ឈានា វុដ្ឋហិត្វា ឈានំ បច្ចវេក្ខតិ ។

បុគ្គលចេញចាកឈានហើយ ពិចារណាឈាន ។

**បច្ច័យ**– មហគ្គតកុសលចិត្ត ៩ និង ចេតសិក ៣៥ (វៀរវិរតិ៣) ជាអារម្មណប្បច្ច័យ ។

**បច្ចយុប្បន្ន**– មហាកុសលចិត្ត ៨ និង ចេតសិក ៣៣ ជាតួពិចារណា ។

### អត្ថកថាចំណុចទី ៣

ពាក្យថា **ឈានំ វុដ្ឋហិត្វា** ប្រែថា ចេញហើយ ចាកឈាន ម្យ៉ាងទៀត នេះឯងជាបាលី ។

### សតិប្បដ្ឋាន

សង្ខតធម៌ទាំងឡាយ ទោះបីជាឈានកុសលក៏ដោយ

ក៏នៅក្នុងអំណាចមិនទៀង ដែលបច្ច័យតាក់តែងហើយ ដែលកើតឡើងហើយ មិនមែនជាទីបំផុតទុក្ខ ។

ព្រះសម្មាសម្ពុទ្ធត្រាស់ដឹងនូវទីបំផុតទុក្ខ គឺព្រះនិព្វាន ជាអសង្ខតធម៌ មិនប្រែប្រួល គឺជាបរមសុខ ។

ការអប់រំសតិប្បដ្ឋាន ប្រព្រឹត្តទៅដើម្បីជាក់ច្បាស់ក្នុង នាមរូប ហើយរំលត់រសេចក្តីប្រកាន់នូវនាមរូបថាជាសត្វ បុគ្គលតួខ្លួន ការបដិបត្តិរំលត់នូវសេចក្តីប្រកាន់យ៉ាងនេះ ទើបឈ្មោះថា ជាហេតុនៃនិរោធសច្ចៈ គឺព្រះនិព្វាន ។

ពាក្យថាហេតុ មិនមែនជាបច្ច័យនាំឱ្យកើតផលធម៌ ទេ តែជាហេតុ ព្រោះស្របគ្នាជាមួយផល គឺសតិប្បដ្ឋាន បដិបត្តិ កំចាត់សេចក្តីប្រកាន់ថាមានសត្វបុគ្គលតួខ្លួននៅក្នុង នាមរូប ដោយបានឃើញនាមរូបតាមពិតក្នុងជីវិតប្រចាំថ្ងៃ ឯចំណែកការមិនប្រកាន់នោះឯងជាព្រះនិព្វាន ទើបព្រះ និព្វានឈ្មោះថាជាផល ។

ពាក្យថាផលក្នុងទីនេះ មិនមែនជាបច្ចយុប្បន្នធម៌ទេ តែជាផលដោយមកអំពីស្របជាមួយគ្នានឹងការបដិបត្តិត្រូវ គឺជាផលប្រៀបដូចជាទីបំផុតនៃផ្លូវដើរ ។

**បើមិនមានការអប់រំនូវសតិប្បដ្ឋាន រលឹកដឹងរូបធម៌ នាមធម៌ ជាប្រក្រតី ជានូវទៅទេនោះ ឈ្មោះថាមិនអប់រំហេតុនៃ និរោធសច្ចៈឡើយ ។**

**ចំណុចទី ៤ នៃបញ្ហាវារៈទី I**

**សេក្ខា គោត្រភុំ បច្ចវេក្ខន្តិ វោទានំ បច្ចវេ-ក្ខន្តិ ។**

ព្រះសេក្ខបុគ្គលទាំងឡាយ ពិចារណាគោត្រភូញាណ ពិចារណា វោទាន (សេចក្តីផូរផង់) ។

**បច្ច័យ** – មហាកុសលញាណសម្បយុត្តចិត្ត ៤ដួង ចេតសិក ៣៣ (វៀរវិរតិ អប្បមញ្ញា) ជាគោត្រភូ វោទាន។

**បច្ចយុប្បន្ន** – មហាកុសលចិត្ត ៨ និង ចេតសិក ៣៣ ជាតួពិចារណា ។

**ចំណុចទី៥ - សេក្ខា មគ្គា វុដ្ឋហិត្វា មគ្គំ បច្ចវេក្ខន្តិ ។**

ព្រះសេក្ខបុគ្គលទាំងឡាយចេញចាកមគ្គ ពិចារណាមគ្គ ។

**បច្ច័យ** – មគ្គខាងក្រោម ៣ បានដល់លោកុត្តរកុសលចិត្ត ១៥ និង ចេតសិក ៣៦ ជាអារម្មណប្បច្ច័យ ។

✵ បានជាមិនមានព្រះអរហត្តមគ្គ ព្រោះអរហត្តមគ្គគួរដល់ព្រះអសេក្ខបុគ្គលពិចារណាដោយមហាកិរិយាតែប៉ុណ្ណោះ ។

**បច្ចយុប្បន្ន** – មហាកុសលញ្ញាណសម្បយុត្តចិត្ត ៤ ដួង ចេតសិក ៣៣ ។

✵ មហាកុសលញ្ញាណវិប្បយុត្តចិត្ត ៤ដួង មិនអាចមានលោកុត្តរជាអារម្មណ៍ទេ ទើបត្រូវវៀរ ។

**អត្ថកថាចំណុចទី ៤ និងទី ៥**

ពាក្យថា **សេក្ខា គោត្រភុំ** ទ្រង់ត្រាស់សំដៅដល់ព្រះសោតាបន្នបុគ្គល ពិតណាស់ ព្រះសោតាបន្នបុគ្គលនោះ រមែងពិចារណាគោត្រភូ ។

ពាក្យថា **វោទាន** ទ្រង់ត្រាស់សំដៅដល់ព្រះសកទាគាមី និង ព្រះអនាគាមី ព្រោះថាចិត្តរបស់លោកទាំងអស់នោះ ឈ្មោះថាជាធម្មជាតិផូរផង់ ។

បទថា **សេក្ខា** គឺព្រះសោតាបន្នបុគ្គល ព្រះសកទាគាមី និង ព្រះអនាគាមី ។

បទថា **មគ្គា វុដ្ឋហិត្វា** គឺចេញចាកមគ្គដែលខ្លួនបានហើយ ដោយអំណាចការឈានកន្លងភវង្គនៃមគ្គ និងផល ចំណែកការចេញចាកមគ្គសុទ្ធៗនោះ ហើយពិចារណារមែងមិនមាន ។

## បទគួរយល់ដឹង

មិនមែនសំខាន់នៅត្រង់ការប្រកាន់ថាមានខ្លួន ហើយខ្លួនជាអ្នកបាន ឬ នឹងជាអ្នកបាននូវអ្វីៗច្រើនៗនោះទេ ប៉ុន្តែដែលពិតជាសំខាន់ហើយប្រសើរណាស់នោះ គឺឃើញធម៌

ទាំងឡាយមិនមែនខ្លួន ។

ការឃើញធម៌ទាំងឡាយថាមិនមែនតួខ្លួន គឺត្រូវឃើញចំពោះធម៌ពិតៗដែលមាននៅក្នុងជីវិតប្រចាំថ្ងៃ ដោយអប់រំសតិប្បដ្ឋានរលឹករឿយៗ មិនរំលងចាកអំពីរូបធម៌ និង នាមធម៌ជាធម្មតាៗ ដែលកើតអំពីហេតុ-បច្ច័យ និង ដែលកំពុងប្រាកដ ។

តាមពិតសេចក្តីប្រកាន់ថា មានតួខ្លួនឯងនោះ គឺប្រកាន់ចំពោះសភាវធម៌ដែលកើតមានជានិច្ចជាកាល ធម្មតាៗរាល់ថ្ងៃ ឱ្យតែមានអ្វីកើតឡើង អាស្រ័យនឹងខ្លួន ក៏ប្រកាន់ថាជាខ្លួន ឬ ជារបស់ខ្លួនឯងទៅ ។

រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ដែលកើតមានឡើងយ៉ាងណា ត្រឹមប៉ុណ្ណា ក្នុងភូមិណា ការប្រកាន់ក៏មានត្រឹមតែចំពោះខន្ធប៉ុណ្ណោះ ក្នុងភូមិនោះ ដូច្នេះ សតិប្បដ្ឋានបដិបត្តិ ក៏រមែងរលឹកដឹងសិក្សាចំពោះ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ដែលកំពុងកើតមានប្រាកដនោះៗ រំលត់ការប្រកាន់បន្តិចម្តងៗ ដោយឃើញត្រឹមតែជាបរមត្ថធម៌ ។

**ចំណុចទី៦ – សេក្ខា វា បុថុជ្ជនា វា កុសលំ អនិច្ចតោ ទុក្ខតោ អនត្តតោ វិបស្សន្តិ .**

ព្រះសេក្ខបុគ្គលទាំងឡាយក្តី ពួកបុថុជ្ជនក្តី ពិចារណាឃើញច្បាស់នូវកុសល ដោយសេចក្តីថា ជារបស់មិនទៀង ជាទុក្ខ ជាអនត្តា

**បច្ច័យ –** លោកិយកុសលចិត្ត១៧ និងចេតសិក៣៨ ជាទីតាំងនៃសតិរលឹកដឹង និងជាអារម្មណ៍របស់វិបស្សនា ។

**បច្ចយុប្បន្ន –** មហាកុសលចិត្ត ៨ ចេតសិក ៣៣ ជាតួពិចារណា ។

✵ កាលសតិមិនមានកំឡាំង ការពិចារណាដោយមហាកុសលញាណវិប្បយុត្តក៏មានដែរ សតិអាចប្រាសចាកបញ្ញាបាន ប៉ុន្តែបញ្ញាមិនបានប្រាសចាកសតិទេ ។

## អត្ថកថាចំណុចទី ៦

ការចូលដល់វិបស្សនា ជាកុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ( មានភូមិ៣ ជាអារម្មណ៍) តែប៉ុណ្ណោះ ។

អ្នកសិក្សាគប្បីជ្រាបក្នុងពាក្យនេះថា **កុសលំ អនិច្ចតោ**ក៏កុសលថ្នាក់វិបស្សនា ជាកាមាវចរតែម្យ៉ាង ។

✵ សតិ-បញ្ញា ក៏អាចមានលោកុត្តរជាអារម្មណ៍បានដែរ ប៉ុន្តែសតិ-បញ្ញានោះ នៅក្នុងពួកគោត្រភូ មគ្គ-ផល បច្ចវេក្ខណ អភិញ្ញា ។

# គប្បីយល់ដឹងក្នុងសតិ-វិបស្សនាថែមទៀត

≈≈≈≈≈

✵ ការប្រកាន់ថាមានតួខ្លួន អាចជាអ្នកធ្វើទាន រក្សាសីល ចំរើនសមថកម្មដ្ឋានបានទាំងអស់ ប៉ុន្តែមិនអាចនៅក្នុងការប្រកាន់ថាជាតួខ្លួន អ្នកលើកវិបស្សនាពិចារណាអារម្មណ៍ បានជាដាច់ខាត ពីព្រោះបើវានៅតែក្នុងការសំគាល់ថា មានតួខ្លួនអញជាអ្នកបង្គាប់សតិឱ្យរលឹកដឹងតែអារម្មណ៍នេះ មិនរលឹកដឹងអារម្មណ៍នោះ និង ប្រកាន់ថាមានខ្លួនជាអ្នកធ្វើវិបស្សនាទេនោះ តើមានការចំរើននូវកុសលធម៌អ្វីទៀតទៅ ដើម្បីលះការប្រកាន់ និងការសំគាល់ខុសថា មានតួខ្លួន តួសត្វ តួបុគ្គលនោះ ។

តាមពិតបើយើងមិននិយាយពាក្យថាវិបស្សនាទេ យើងគ្រាន់តែនិយាយតាមការឃើញច្បាស់ថា មានត្រឹមតែជាធម៌ពិតៗក្នុងលោកដែលកើតអំពីហេតុ-បច្ច័យផ្សេងៗ បើឃើញច្បាស់ដូចនេះ តើវាមាននៅសេចក្ដីសំគាល់ថាខ្លួនជាអ្នកធ្វើវិបស្សនា ឬថា ត្រូវដឹងតែត្រឹមអារម្មណ៍ប៉ុណ្ណោះ

អារម្មណ៍ប៉ុណ្ណោះទៀតដែរទេ តើនៅចំរើនការប្រកាន់អត្តាទៀតដែរឬទេ ។

វិបស្សនាប្រែថា ការឃើញច្បាស់ គឺឃើញ អនិច្ចំ ទុក្ខំ អនត្តា នៃសង្ខារធម៌ បើឃើញអនត្តា គឺជាវិបស្សនា ចុះការឃើញថា កុសលធម៌ទាំងឡាយ ខ្លួនអញ ជាអ្នកចាត់ចែងរៀបចំធ្វើសូម្បីតែកុសលថ្នាក់វិបស្សនាក៏ត្រូវតែខ្លួនជាអ្នកចាត់ចែងដែរនោះ តើនឹងមាននូវអនត្តានុបស្សនាដែរឬទេ ?

តាមពិត ធម៌ទាំងពួងដែលប្រាកដនូវលក្ខណៈ មិនមែនជាសត្វបុគ្គលតួខ្លួននោះ មិនមានធម៌អ្វីដទៃក្រៅអំពីជីវិតប្រចាំថ្ងៃនេះឡើយ ជាធម៌ដែលកើតអំពីហេតុបច្ច័យ។ ដោយអាស្រ័យការបានស្តាប់យល់ចូលចិត្តនូវព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធ អំពីការពិតនៃជីវិតច្បាស់លាស់ហើយនោះ **សទា សតោ** ជាអ្នកមានសតិសព្វកាល គឺមិនចំពោះថា ចាំពេលនេះ ឬ ពេលនោះឡើយ ។

**ការយល់ថា សតិប្បដ្ឋានបដិបត្តិ ចាំចំរើនពេលនេះ ឬពេលនោះ នេះគឺសក្កាយទិដ្ឋិ** តើពុទ្ធបរិស័ទ មានធម៌បដិបត្តិដើម្បីលះសក្កាយទិដ្ឋិដែរឬទេ ? ដរាបណានៅតែក្នុងសេចក្តីប្រកាន់ចាត់ចែងឱ្យសតិ-វិបស្សនា មានក្នុងពេលនេះ ឬ ក្នុងអារម្មណ៍នេះ ដរាបនោះលទ្ធផលនៅតែសំគាល់ថា ខ្លួនអញជាអ្នកបាននូវធម៌ ឆន្ទរាគៈរមែងចំរើន ។

តាមពិត មិនមែនយើងកុំទាន់ចំរើនវិបស្សនាទេ តែព្រោះវិបស្សនាខ្វះហេតុគ្រប់គ្រាន់ ទើបមិនបានកើតឡើង ហើយបើមិនបានអប់រំនូវហេតុនៃវិបស្សនាទេនោះ ទោះជាពេលណាក៏ដោយ វិបស្សនានៅតែមិនបានកើតឡើងដដែល សូម្បីគិតធ្វើឱ្យកើតវិបស្សនានៅពេលណាដែលខ្លួនយល់ថាដល់ពេលលើកវិបស្សនាមកពិចារណាសង្ខារធម៌ហើយក៏ដោយ ។

រាល់ពេលដែលមានសតិ-វិបស្សនា គឺមិនមានការចាត់ចែងពេលវេលា និង អារម្មណ៍ឱ្យឡើយ ស្រេចហើយតែ ហេតុ-បច្ច័យ នៃវិបស្សនានោះ ។

ពុទ្ធបរិស័ទកំពុងស្តាប់ធម៌ កំពុងពីរោះនៅក្នុងព្រះ

ធម៌ ព្រោះបានយល់សេចក្តីនៃព្រះធម៌ដែលកំពុងស្តាប់ បញ្ញាយល់ចូលចិត្តនូវសេចក្តីអត្ថន័យរបស់ព្រះសទ្ធម្មនោះឯង ជាសង្ខារក្ខន្ធតាក់តែងឱ្យមានសតិ-វិបស្សនារហូតបានស្តាប់ព្រះធម៌ចប់កាលណា ក៏បានសម្រេចមគ្គ-ផលតាមឧប-និស្ស័យ ។

ពិតមែនតែវិបស្សនាជាធម៌ជាន់ខ្ពស់ ប៉ុន្តែមិនមែនជាធម៌ត្រូវតែចំរើនតាមក្រោយសមាធិដោយចាត់ចែងថាជាចំណេះវិជ្ជាបន្តអំពីសមាធិ បើមិនមានសមាធិទេ គឺមិនអាចធ្វើវិបស្សនាបានសំរេចដូច្នេះឡើយ វាមិនមាន ហេតុ-ផលត្រង់ណាដែលថា វិបស្សនាត្រូវតែតាមក្រោយសមាធិ បើប្រៀបទៅនឹងចំណេះវិជ្ជា សមាធិជាចំណេះមួយផ្សេង ចំណែកវិបស្សនា ជាចំណេះមួយផ្សេងទៀត ចំណេះវិជ្ជាទាំងពីរនេះទោះជាមានការទាក់ទងគ្នាខ្លះក៏ដោយ តែក៏ត្រូវផ្តើមអំពីដំបូងដូចគ្នា ។

សមាធិប្រៀបដូចចំណេះចេះធ្វើថ្មសំលៀងកាំបិតដាវ ដាវ ឯចំណែកវិបស្សនាប្រៀបដូចចំណេះចេះធ្វើកាំបិតដាវ ។

ពេលចូលកាន់ស្ថានទីប្រយុទ្ធ ឬ ថាខ្មាំងសត្រូវកំពុង តែចូលលុយលុកភូមិស្រុក អ្នកស្រុកនាំគ្នាហាត់រៀនដំដែកធ្វើដាវ-កាំបិតជាដើម ដើម្បីច្បាំងជាមួយសត្រូវ ដាវ-កាំបិត គ្រឿងប្រយុទ្ធទាំងឡាយ វាជាសម្ភារៈដ៏ចម្បងដែលអ្នកស្រុកយកចិត្តទុកដាក់មុនគេ និង ចាប់ផ្តើមយ៉ាងប្រញាប់ប្រញាល់ ស្វែងរកដាវលំពែងគ្រឿងសព្វាវុធ ដើម្បីតយុទ្ធដោយមិនបង្អែបង្អង់ ប្រៀបដូចបុគ្គលត្រូវ ភ្លើងឆេះក៏ប្រញាប់លត់នូវភ្លើងនោះ ឬបុគ្គលត្រូវព្រួញសរ ក៏ប្រញាប់ដកនូវព្រួញសរនោះ យ៉ាងណា ការលះបង់នូវសេចក្តីប្រកាន់គឺសក្កាយទិដ្ឋិ ក៏ប្រញាប់ប្រញាល់យ៉ាងនោះដែរ ។

បើដែកល្អ ដំទៅជាដាវ កាំបិត វាមុតស្រួចណាស់ទៅហើយនោះ ការស្វែងរកថ្មមកសំលៀងមិនមានឡើយ ប៉ុន្តែបើដាវនោះវាមិនសូវមុតទេ មិនមែនហាមឃាត់ថាមិនឱ្យសំលៀងឡើយ តែនៅពេលហាត់រៀនធ្វើថ្ម ឬនៅពេលកំពុងស្វែងរកថ្មក្តី នៅពេលកំពុងសំលៀងដាវនោះក្តី គឺដាវវាត្រូវតែមានជាប្រចាំ ទុកជាប់នឹងខ្លួនជានិច្ច ព្រោះពេល

កំពុងមានសត្រូវ អ្នកស្រុកមិនត្រូវទុកដាវចោល ដោយអាងថា ចាំធ្វើថ្មបានសិននោះទេ ប្រយ័ត្នសត្រូវវាសម្លាប់អ្នក ដូច្នេះទោះបីជាដាវអ្នកមិនសូវមុតក៏ដោយ យ៉ាងហោចណាស់ក៏គង់បានទប់ បានរងការពារដែរ ។

✵ **ក្នុងសាសនានេះ សមថៈមិនមែនជាសារៈ មិនមែនជាសាចពុ្ញផលទេ វិបស្សនា មគ្គ ផល និព្វាន ទើបជាសារៈខ្លឹមសារក្នុងសាសនានេះ**( មានក្នុងព្រះសូត្រខាងមុខ) ។

ការលះបង់ចោល ឬទុកចោលសិន នូវសតិប្បដ្ឋាន ៤ សត្រូវវាអាចមានឱកាសដើម្បីសម្លាប់ឧបនិស្ស័យនៃការត្រាស់ដឹងបាន ដូចជាការបានសំរេចនូវសេចក្តីសុខស្ងប់ក្នុងសមថៈ ក៏ចំរើនការប្រកាន់យ៉ាងខ្លាំងក្លា ដោយយល់ថាអញជាអ្នកធ្វើឱ្យបានសំរេចនូវសេចក្តីសុខស្ងប់នេះ ដែលជាធម៌ដ៏ខ្ពង់ខ្ពស់ ផុតហួសអំពីមនុស្សធម្មតា **អតិមានៈ គឺ** មានះដ៏ក្រៃលែង មើលទៅឃើញអ្នកស្រុក អ្នកភូមិបរិភោគកាមគុណ សុទ្ធតែជាមនុស្សទ្រមក់ខ្ជិល ចំណាយពេលវេលាដ៏មានតំលៃដេកលង់លក់ សុទ្ធតែជាអ្នកមានសេចក្តីប្រមាទ ចំណែកអាត្មាអញវិញជាបុគ្គលប្រសើរវិសេសអស្ចារ្យ ឱ ! គួរឱ្យអាណិតមនុស្សផងទាំងពួងណាស់ ។

**សូមពុទ្ធបរិស័ទស្ថិតនៅក្នុងទីគោចររបស់បិតា គឺ សតិប្បដ្ឋាន ៤ កុំបោះបង់ចោល យ៉ាងនេះទើបកិលេសមារ មិនអាចមានឱកាសសម្លាប់ឧបនិស្ស័យ នៃការសំរេចអរិយមគ្គអង្គ ៨ នោះបានឡើយ ។**

ជាការប្រកាន់មាំណាស់ ដែលយល់ថា ធម៌ទាំងឡាយអាត្មាអញជាអ្នកធ្វើ ហើយធម៌ទាំងនោះជារបស់អាត្មាអញ នេះជាការជាប់នៅក្នុងពន្ធនាគាររបស់មច្ចុរាជត្រូវជាប់ដោយចំណងដ៏មាំ ។

**មានតែសតិប្បដ្ឋាន៤ទេ ដែលប្រព្រឹត្តទៅរកការឃើញធម៌តាមសេចក្តីពិត គឺបាន**

ឃើញថា ធម៌ទាំងឡាយកើតចាកហេតុ ការឃើញដូចនេះ ត្រូវបានរំលត់កិលេសជាលំដាប់ៗ ទាំងដែលសតិ និង បញ្ញាមិនបានគិតថាឱ្យកិលេសរលត់នោះផងទេ ព្រោះសតិប្បដ្ឋាន ៤ មិនមែនជាការបដិបត្តិក្នុងការហួងហែងលោកឡើយ តែជាការបដិបត្តិដោយមិនប្រកៀកប្រកាន់អ្វីតិចតួចនៅក្នុងលោក ៗ

**ចំណុចទី៧– បញ្ហាបារៈទី I ជាបន្ត**

**ចេតោបរិយញ្ញាណេន កុសលចិត្តសមង្គិស្ស ចិត្តំ ជានន្តិ ។**

បុគ្គលដឹងចិត្ត របស់បុគ្គលអ្នកព្រមព្រៀងដោយកុសលចិត្ត ដោយចេតោបរិយញ្ញាណ ។

**បច្ច័យ**– កុសលចិត្ត ៣២ដួង គឺ លោកិយកុសល ១៧ និង លោកុត្តរកុសល ១៥ (វៀរអរហត្តមគ្គចិត្ត៥) និង ចេតសិក ៣៨ ជាអារម្មណ៍ ។

✵ អរហត្តមគ្គ មិនបានជាអារម្មណ៍នៃកុសលធម៌ទេ ព្រោះបុគ្គលបានអរហត្តមគ្គរួចហើយ នៅមានចិត្តតែ ២ ជាតិប៉ុណ្ណោះ គឺជាតិជាវិបាក និង ជាតិជាកិរិយា ទោះជាអភិញ្ញាកុសលរបស់ព្រះសេក្ខបុគ្គល ក៏មិនមានអរហត្តមគ្គជាអារម្មណ៍ដែរ ។

អភិញ្ញាកុសលរបស់ព្រះអនាគាមីមានមគ្គ ៣ (វៀរអរហត្តមគ្គ) ជាអារម្មណ៍ ។

អភិញ្ញារបស់ព្រះសកទាគាមី មានមគ្គ ២ ជាខាងក្រោម ជាអារម្មណ៍ ។

អភិញ្ញារបស់ព្រះសោតាបន្ន មានសោតាបត្តិមគ្គជាអារម្មណ៍ ។

អភិញ្ញារបស់បុថុជ្ជន មិនមានមគ្គជាលោកុត្តរណាមួយជាអារម្មណ៍ឡើយ ។

**បច្ចយុប្បន្ន**– កុសលអភិញ្ញា ១ដួង និង ចេតសិក ៣០ របស់បុថុជ្ជន និង របស់សេក្ខបុគ្គល ។

## អដ្ឋកថា ចំណុចទី ៧

ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់សំដែងរូបាវ-ចរកុសលដោយពាក្យនេះថា **ចេតោបរិយញ្ញាណេន** (ញាណដឹងចិត្តអ្នកដទៃ) ។

## ចំណុចទី ៨

អាកាសានញ្ចាយតនកុសលំ វិញ្ញាណញ្ចាយតនកុស-លស្ស អារម្មណប្បច្ចយេន បច្ចយោ ។

អាកាសានញ្ចាយតនកុសល ជាបច្ច័យនៃវិញ្ញាណ-ញ្ចាយតនកុសល ដោយអារម្មណប្បច្ច័យ ។

**បច្ច័យ –** អាកាសា-កុ- ១ដួង +៣០

**បច្ចយុប្បន្ន –** វិញ្ញា-កុ- ១ដួង + ៣០

## ចំណុចទី ៩

អាកិញ្ចញ្ញាយតនកុសលំ នេវសញ្ញានាសញ្ញាយតន-កុសលស្ស អារម្មណប្បច្ចយេន បច្ចយោ ។

អាកិញ្ចញ្ញាយតនកុសល ជាបច្ច័យនៃនេវសញ្ញានា-សញ្ញាយតនកុសលដោយអារម្មណប្បច្ច័យ ។

**បច្ច័យ –** អាកិញ្ច-កុ- ១ដួង ចេតសិក ៣០

**បច្ចយុប្បន្ន –** នេវ-កុ- ១ដួង + ៣០ ។

## អដ្ឋកថា ទី៨ និង ទី៩

ទ្រង់សំដែង អរូបាវចរកុសលដែលកំពុងកើតឡើងដោយអំណាចមានអរូបាវចរកុសលជាអារម្មណ៍ ។

✵ អារម្មណប្បច្ច័យក្នុងចំណុចទី ៨ និង ទី៩នេះ ជាអតីតៈផង ជាខាងក្នុងផង ដោយឯកន្តៈ ។

## ចំណុចទី ១០

**កុសលា ខន្ធា ឥទ្ធិវិធញ្ញាណស្ស ចេតោបរិយ-ញ្ញាណស្ស បុព្វេនិវាសានុស្សតិញ្ញាណស្ស យថាកម្មុប-គញ្ញាណស្ស អនាគតំសញ្ញាណស្ស អារម្មណប្បច្ចយេន បច្ចយោ ។**

កុសលក្ខន្ធទាំងឡាយ ជាបច្ច័យនៃឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុប-

គញ្ញាណ និង អានាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។

**បច្ច័យ** – កុសលចិត្តដោយសង្ខេប ២០ (វៀរអរហត្តមគ្គ) បើដោយពិស្តារ ៣២ គឺ : លោកិយកុសលចិត្ត ១៧ លោកុត្តរចិត្ត ១៥ ដែលជាកុសល (បានដល់មគ្គ ៣ គុណនឹងឈានទាំង ៥) ចេតសិក ៣៨ ។

**បច្ចយុប្បន្ន** – កុ-អភិញ្ញា១ដួង និងចេតសិក៣០ ។

អង្គធម៌ចំណុចទី ១០នេះ ដូចគ្នានឹងចំណុចទី ៧ ។

## អត្ថកថាចំណុចទី១០

ទ្រង់សំដែងដោយអំណាចធម៌ប៉ុណ្ណោះ មិនទាក់ទងនឹងបុគ្គល ដោយពាក្យថា **កុសលា ខន្ធា ឥទ្ធិវិធញ្ញាណស្ស** ជាដើម ។

ព្រោះហេតុនោះឯង ចេតោបរិយញ្ញាណ សូម្បីទ្រង់សំដែងខាងដើម (ចំណុចទី ៧) រួចហើយក៏ដោយ ក៏ទ្រង់នៅត្រាស់ដដែលទៀតទុកក្នុងអធិការនេះ (ចំណុចទី១០) ។

✵ **ក្នុងអធិការទាំង ១០ចំណុច ក៏គួរតែកុំភ្លេចថា កុសលធម៌ជាបច្ច័យនៃកុសលធម៌ ដោយអារម្មណប្បច្ច័យ ។**

**ចំពោះការដឹងអារម្មណ៍គឺពុំមែនមនុស្សសត្វ បុគ្គល អ្នកនេះ ឬអ្នកនោះ ជាអ្នកដឹងឡើយ ។**

**ការបញ្ញត្តិបុគ្គលមានបុថុជ្ជនឬព្រះសេក្ខបុគ្គលជាដើមនោះ ដោយអាស្រ័យការប្រព្រឹត្តិទៅនៃបរមត្ថធម៌សុទ្ធៗ តាមពិតក្នុងបរមត្ថធម៌ដែលដឹងអារម្មណ៍ ត្រឹមតែចិត្ត និង ចេតសិក ដែលកើតមកបន្តគ្នាតែប៉ុណ្ណោះ ចិត្តចេតសិកដែលកន្លងហួសទៅមិនបានវិលត្រឡប់មកដឹងអារម្មណ៍ជាថ្មីទៀតទេ កន្លងហួសទៅហើយ កាន់តែឆ្ងាយទៅៗ លែងវិលត្រឡប់មកវិញរហូតថែមទាំងមិនបានតាំងនៅក្នុងទីណាផង ។**

# ជប់ចំណុចជុំគ្នា

≈≈ ≈≈

កុសលធម៌ ជាបច្ច័យនៃកុសលធម៌ដោយអារម្មណ-បច្ច័យ គឺ :

១- បុគ្គលឱ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ហើយពិចារណានូវទាន សីល ឧបោសថកម្មនោះ ។

២- បុគ្គលពិចារណានូវកុសលទាំងឡាយ ដែលសន្សំទុកល្អហើយ ក្នុងកាលមុន ។

៣- បុគ្គលចេញចាកឈាន ហើយពិចារណាឈាន ។

៤- ព្រះសេក្ខបុគ្គល ពិចារណាគោត្រភូ ពិចារណាវោទាន ។

៥- ព្រះសេក្ខបុគ្គល ចេញចាកមគ្គ ពិចារណាមគ្គ ។

៦- ព្រះសេក្ខបុគ្គល ឬបុថុជ្ជនក៏ដោយ ពិចារណាឃើញច្បាស់នូវកុសល ថាមិនទៀង ជាទុក្ខ ជាអនត្តា ។

៧- បុគ្គលដឹងចិត្តរបស់អ្នកដទៃមានការព្រមព្រៀងដោយកុសលចិត្ត ដោយចេតោបរិយញ្ញាណ ។

៨- អរូបាវចរកុសលទី ១ ជាបច្ច័យនៃអរូបាវចរ-កុសលទី ២ ដោយអារម្មណប្បច្ច័យ ។

៩- អរូបាវចរកុសលទី ៣ ជាបច្ច័យនៃអរូបាវចរ-កុសលទី ៤ ដោយអារម្មណប្បច្ច័យ ។

១០- កុសលក្ខន្ធទាំងឡាយ ជាបច្ច័យដល់ឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថា-កម្មូបគញ្ញាណ និង អនាគតំសញ្ញាណ ដោយអារម្មណប្ប-ច្ច័យ ។

## បច្ច័យ និង បច្ចយុប្បន្នធម៌ផ្សេងៗ

**បច្ច័យ –** កុសលចិត្ត ២០ (វៀរអរហត្តមគ្គ) ចេត-សិក ៣៨ ។

**បច្ចយុប្បន្ន –** មហាកុសលចិត្ត ៨ អភិញ្ញាជវន ១ ដួង ដែលជាកុសល អរូបាវចរកុសលទី ២ និង ទី ៤ ត្រូវជា ២ដួង រួមចិត្តទាំងអស់មានចំនួន ១១ដួង ចេតសិកមាន៣៣

(វេវរីរតិ ៣ អប្បមញ្ញា ២) ។ នេះចំពោះកុសលធម៌ដែលមាននូវកុសលធម៌ជាអារម្មណ៍ ។

## ចប់បញ្ហាវារៈទី I នៃអារម្មណប្បច្ច័យដោយសង្ខេប

៙៙៙៙៙

# បញ្ហាវារៈនៃអារម្មណប្បច្ច័យ

≈≈≈≈≈

**II- កុសលោ ធម្មោ អកុសលស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ។**

កុសលធម៌ ជាបច្ច័យ នៃអកុសលធម៌ ដោយអារម្មណប្បច្ច័យ ។

**មាន ៣ ចំណុច គឺ :**

**១- ទានំ ទត្វា សីលំ សមាទយិត្វា ឧបោសថកម្មំ កត្វា តំ អស្សាទេតិ អភិនន្ទតិ តំ អារព្ភ រាគោ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ វិចិកិច្ឆា ឧប្បជ្ជតិ ឧទ្ធច្ចំ ឧប្បជ្ជតិ ទោមនស្សំ ឧប្បជ្ជតិ ។**

បុគ្គលឱ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ហើយត្រេកអររីករាយភ្លើតភ្លើន នឹងកុសលនោះ ព្រោះប្រារព្ធនូវកុសលនោះ រាគៈកើតឡើង ទិដ្ឋិកើតឡើង វិចិកិច្ឆា

កើតឡើង ឧទ្ធច្ចៈកើតឡើង ទោមនស្សកើតឡើង ។

**បច្ច័យ** – មហាកុ- ៨ដួង និង ចេតសិក ៣៨ ជាអារម្មណ៍ ។

**បច្ចយុប្បន្ន** – អកុសលចិត្ត ១២ដួង និង ចេតសិក ២៧ បានកាន់យកនូវកាមាវចរកុសលជាអារម្មណ៍ ។

**២-បុព្វេ សុចិណ្ណានិ អស្សាទេតិ អភិនន្ទតិ តំ អារព្ភ រាគោ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ វិចិកិច្ឆា ឧប្បជ្ជតិ ឧទ្ធច្ចំ ឧប្បជ្ជតិ ទោមនស្សំ ឧប្បជ្ជតិ ។**

បុគ្គលត្រេកអររីករាយភ្លើតភ្លើន នឹងកុសលទាំង-ឡាយ ដែលខ្លួនសន្សំទុកល្អហើយក្នុងកាលមុន ព្រោះប្រារព្ធនូវកុសលនោះ រាគៈកើតឡើង ទិដ្ឋិកើតឡើង វិចិកិច្ឆាកើតឡើង ឧទ្ធច្ចកើតឡើង ទោមនស្សកើតឡើង ។

**បច្ច័យ** – មហាកុ- ៨ + ៣៨ ដែលសន្សំទុកល្អហើយក្នុងកាលមុន ជាអារម្មណប្បច្ច័យ ។

**បច្ចយុប្បន្ន** – អកុ-១២ +២៧ បានប្រារព្ធយកនូវកុសលធម៌នោះ ហើយកើតឡើង ។

**៣-ឈានា វុដ្ឋហិត្វា ឈានំ អស្សាទេតិ អភិនន្ទតិ តំ អារព្ភ រាគោ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ វិចិកិច្ឆា ឧប្បជ្ជតិ ឧទ្ធច្ចំ ឧប្បជ្ជតិ ឈានេ បរិហីនេ វិប្បដិសារិស្ស ទោមនស្សំ ឧប្បជ្ជតិ ។**

បុគ្គលចេញចាកឈានហើយ ត្រេកអរ ភ្លើតភ្លើននឹងឈាន ព្រោះប្រារព្ធនូវឈាននោះ រាគៈកើតឡើង ទិដ្ឋិកើតឡើង វិចិកិច្ឆាកើតឡើង ឧទ្ធច្ចកើតឡើង សំរាប់បុគ្គលអ្នកមាននូវការស្ដាយក្រោយ កាលដែលឈានសាបសូន្យទៅហើយ ទោមនស្សរមែងកើតឡើង ។

**បច្ច័យ** – មហគ្គតកុសលចិត្ត ៩ និង ចេតសិក ៣៥ ជាអារម្មណ៍ ។

**បច្ចយុប្បន្ន** – អកុ-១២ + ២៧ ។

### បច្ច័យ និង បច្ចយុប្បន្នរួមគ្នា ៣ ចំណុច

**បច្ច័យ** – លោកិយកុសលចិត្ត១៧ និងចេតសិក៣៨

**បច្ចុប្បន្ន** – អកុសលចិត្ត ១២ដួង និង ចេតសិក ២៧ ដែលបានប្រារព្ធនូវលោកិយកុសលធម៌ទាំងពួងជាអារម្មណ៍ ។

## អត្ថកថាភ្ជួចបញ្ហាវារៈទី II

បទថា **អស្សាទេតិ** គឺសោយនិងត្រេកអរដោយចិត្តប្រកបជាមួយលោភៈ សហគតដោយសោមនស្សវេទនា

បទថា **អភិនន្ទតិ** បានដល់ត្រេកអរ គឺជាអ្នករីករាយដោយតណ្ហាប្រកបដោយបីតិ ឬថារមែងត្រេកអរដ៏ក្រៃលែងដោយអំណាចការភ្លើតភ្លើននៃចិត្ត ក្នុងធម៌ដែលខ្លួនបានឃើញហើយ ។

បទថា **រាគោ ឧប្បជ្ជតិ** សេចក្តីថា រាគៈរមែងកើតឡើង ដល់បុគ្គលអ្នកដែលត្រេកអរនោះឯង ពាក្យនេះទ្រង់ត្រាស់សំដៅដល់ចិត្តដែលប្រកបដោយលោភហេតុទាំង ៨ដួង ។

បទថា **ទិដ្ឋិ ឧប្បជ្ជតិ** សេចក្តីថា ទិដ្ឋិដែលសម្បយុត្តដោយចិត្ត ៤ដួង ដោយអំណាចការឃើញខុសថា តួខ្លួនមាន របស់ខ្លួនមានដូចនេះជាដើម រមែងកើតឡើងដល់បុគ្គលអ្នកដែលមានការត្រេកអររីករាយ ។

ក៏ក្នុងករណីនេះ វិចិកិច្ឆារមែងកើតដល់បុគ្គលអ្នកមិនមានការសំរេចចិត្ត ។

ឧទ្ធច្ចៈ រមែងកើតដល់បុគ្គលអ្នកមានចិត្តរវើរវាយ ទោសៈរមែងកើតដល់បុគ្គលអ្នកដែលក្តៅក្រហាយថា កម្មល្អយើងនៅមិនទាន់បានធ្វើជាដើម ។

បទថា **តំ អារព្ភ** សេចក្តីថា ធ្វើកម្មទាំងអស់នោះ ដែលខ្លួនសន្សំទុកហើយ ក្នុងកាលមុនឱ្យជាអារម្មណ៍ពិតណាស់ ស័ព្ទនេះ អាទេសពហុវចនៈ ជាឯកវចនៈ ម្យ៉ាងទៀតពាក្យនេះ ជាឯកវចនៈ ដោយអំណាចជាតិ ។

# បទគួរយល់ដឹងថែមទៀត

≈≈≈≈≈

តាមសតិប្បដ្ឋានសូត្រ និង ព្រះសូត្រផ្សេងៗជាច្រើនទៀត ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែង **សភាវធម៌ពិតក្នុងជីវិតប្រចាំថ្ងៃ ឱ្យជាទីតាំងនៃសតិ-វិបស្សនា ។**

ក្នុងដំណើងមកថា អ្នកស្រុកក្នុងនគរសាវត្ថី សម័យពុទ្ធកាល នៅក្នុង ៧ភាគ មានអ្នកស្រុក ៥ភាគជាព្រះអរិយបុគ្គល គេមានការរស់នៅក្នុងរបៀបជា ឃរាវាស គ្រប់គ្រងផ្ទះធ្វើស្រែ ធ្វើចំការ មានបុត្រធីតា ភរិយា ស្វាមី ទាសាទាសី គោក្របី ។ល។

ពុទ្ធបរិស័ទមិនគួរមើលស្រាល ចំពោះសភាវធម៌ជាធម្មតាក្នុងជីវិតរាល់ថ្ងៃ ដែលខ្លួនរស់នៅតាមអធ្យាស្រ័យនេះទេ ពោលគឺមិនត្រូវរំលងចោលដោយមិនអប់រំសតិរឿយៗនោះឡើយ ។

ការរៀបចំខ្លួនឯងឱ្យខុសអំពីអធ្យាស្រ័យនៃការរស់នៅ តម្កល់ខ្លួនឱ្យខ្ពស់បន្តិច ឬខ្ពស់មែនទែន រំលងចោល ឬបោះបង់ចោល ដោយការមិនយកចិត្តទុកដាក់ចំពោះសភាវធម៌ជាសាមញ្ញធម្មតា ដែលមនុស្សសត្វគ្រប់គ្នាតែងមាន ហើយរៀបចំចាត់ចែងដោយខ្លួនឯងនូវអារម្មណ៍ផ្សេងៗ ឱ្យបានជាពិធីពិសេស ដើម្បីខ្ពង់ខ្ពស់ជាងជីវិតមនុស្សសាមញ្ញធម្មតា ហើយទើបចំរើនវិបស្សនា នេះគឺជាការចំរើនសេចក្ដីប្រកាន់អត្តាតួខ្លួនឯង ឱ្យរីងរឹតតែធំថ្លោសឡើងតែប៉ុណ្ណោះឯង ។

ការធ្វើទាន ការរក្សាសីល ៥ ការសមាទានឧបោសថសីល ការចំរើនសមាធិ បំពេញបុញ្ញកិរិយាវត្ថុផ្សេងៗក្នុងភាពជា ឃរាវាសក្ដី ការសាងផ្នួសជាភិក្ខុសាមណេរក្ដី ការប្រព្រឹត្តិតាមអធ្យាស្រ័យទាំងអស់នេះ ឈ្មោះថាជីវិតធម្មតានៃបុគ្គលមានសទ្ធា ។

ជីវិតត្រូវបានរៀបចំដោយហេតុ-បច្ច័យទាំងអស់ ប៉ុន្តែដោយមិនមានវិបស្សនា ក៏បានប្រកាន់នូវជីវិតថា ជារបស់ខ្លួន និង អ្វីៗជារបស់ខ្លួន គឺខ្លួនជាអ្នកធ្វើទាន ខ្លួនជាអ្នករក្សាសីល ខ្លួនជាអ្នកធ្វើសមាធិកម្មដ្ឋាន ឬខ្លួនជាអ្នកបួស ជាអ្នកសាងផ្នួស ។ល។

ដោយក្នុងព្រះពុទ្ធសាសនា មានការចង្អុលបង្ហាញការបដិបត្តិដើម្បីរួចផុតចាកទុក្ខ ពុទ្ធបរិស័ទបានអប់រំចំរើនវិបស្សនា អាស្រ័យសតិប្បដ្ឋាន៤ ក៏បានត្រាស់ដឹងនូវអរិយ-សច្ចធម៌ បានឃើញនូវជីវិតសត្វលោក និង គ្រប់សង្ខារធម៌ទាំងអស់ ជារបស់សោះសូន្យទទេ គឺគ្រាន់តែជាផលរបស់ហេតុ-បច្ច័យតែប៉ុណ្ណោះ រំលត់នូវសេចក្តីប្រកាន់ថាមានតួខ្លួន និង ថាមានតួខ្លួនជាអ្នកធ្វើនូវកុសលផ្សេងៗជាដើម ។

សេចក្តីនេះដោយអាស្រ័យសតិប្បដ្ឋានរលឹកសិក្សាចំពោះសភាវធម៌ជាទូទៅ មិនចំពោះថា ជាកុសលធម៌ ឬជាអកុសលធម៌ ឬ ជាអព្យាកតធម៌ឡើយ ហើយទោះជាតាំងនៅក្នុងភេទអ្វីក៏ដោយ កំពុងធ្វើការងារអ្វីក៏ដោយ ក្នុងជីវិតដែលរស់នៅតាមអធ្យាស្រ័យធម្មតា ។

**ពាក្យថា ជីវិតរស់នៅតាមអធ្យាស្រ័យ ឬ ជីវិតយ៉ាងសាមញ្ញធម្មតានោះ តើជីវិតដូចម្តេច ?**

មិនមែនមិនធ្វើទាន មិនរក្សាសីល មិនចំរើនភាវនា ឬមិនបួស ទើបឈ្មោះថា ជីវិតធម្មតា ឬថាទើបរស់នៅតាមអធ្យាស្រ័យនោះទេ ។ តាមពិតទោះបីជាជីវិតរស់នៅយ៉ាងណាក៏ដោយ ធ្វើកម្មអ្វីក៏ដោយ **ឈ្មោះថាជីវិតយ៉ាងសាមញ្ញធម្មតា ព្រោះថា ជីវិតនេះតាក់តែងដោយហេតុ-បច្ច័យ ។**

ពាក្យថាជីវិតធម្មតា ឬសាមញ្ញធម្មតានេះ មិនមែនអ្នកនិយាយពាក្យនេះគ្រប់គ្នា សុទ្ធតែបានដឹងការពិតគ្រប់គ្នានោះទេ ។

តាមពិតមានតែអ្នកចំរើននូវសតិប្បដ្ឋាន ៤ ប៉ុណ្ណោះ ទើបបានយល់ច្បាស់ ចាក់ធ្លុះនូវជីវិតធម្មតានៃខ្លួនឯង និង ជីវិតធម្មតានៃសព្វសត្វទាំងអស់បាន ។

សតិប្បដ្ឋាន ៤ មានការសិក្សារឿយៗជាប្រក្រតីនៅក្នុងជីវិតធម្មតានេះ រហូតបានចេះយ៉ាងច្បាស់លាស់ ដូច្នេះ ការចេះការដឹងយល់ច្បាស់ចំពោះជីវិតធម្មតាគឺជា

**វិបស្សនា** ។

ការតាំងតួខ្លួនជាអ្នកធ្វើវិបស្សនា ដោយប្រកាន់ជីវិតធម្មតាថា ជាតួខ្លួន តាំងតួខ្លួនជាអ្នករៀបចំអារម្មណ៍នេះ អារម្មណ៍នោះ ឱ្យវិបស្សនា សាងជីវិតថ្មី ឱ្យខុសអំពីប្រក្រតី ដើម្បីជាទីតាំងនៃវិបស្សនា ដោយប្រកាន់ថា ជីវិតធម្មតាដូចមុន មិនអាចជាទីតាំងនៃការចំរើនវិបស្សនាបានឡើយ ការរស់នៅដោយសេចក្តីប្រកាន់យ៉ាងនេះ ឈ្មោះថាជីវិតខុសប្រក្រតី ។

តាមពិតមិនមានអ្វីដែលមិនអាស្រ័យ ហេតុ-បច្ច័យទេ ឱ្យតែជាប់ទាក់ទងនៅក្នុងជីវិត ប៉ុន្តែ **ការតាំងតួខ្លួនជាអ្នករៀបចំឱ្យជីវិត ដើម្បីចំរើនវិបស្សនា ជីវិតនេះឈ្មោះថា រស់នៅមិនតាមអធ្យាស្រ័យ គឺខុសប្រក្រតី។**

ការរស់នៅដូចម្តេចក៏បានដែរ ស្រេចតែតាមអធ្យាស្រ័យ តាមហេតុ តាមបច្ច័យ ប៉ុន្តែហេតុអ្វីបានជាគិតថា រស់នៅយ៉ាងនេះ ទើបចំរើនវិបស្សនាបាន បើរស់នៅបែបនោះ ចំរើនវិបស្សនាមិនបាន ការពិតឱ្យតែបានស្តាប់ព្រះធម៌ យល់ចូលចិត្តអំពីលក្ខណៈរបស់សតិ-វិបស្សនា និងអារម្មណ៍របស់សតិប្បដ្ឋាន៤ទៅ អំពីការរស់នៅយ៉ាងណានោះ មិនជាបញ្ហាអ្វីទាំងអស់ ។

ការតាំងតួខ្លួនជាអ្នករក្សាសីល ឬចំរើនសមាធិ អាចធ្វើសំរេចបានទាំងអស់ ប៉ុន្តែបើតាំងតួខ្លួនឱ្យជាអ្នកចំរើនវិបស្សនា គឺមិនអាចសំរេចបានជាដាច់ខាត ព្រោះវាមិនមែនជាវិបស្សនាទេ តាមពិតវាជាសក្កាយទិដ្ឋិ ដូច្នេះប្រៀបបីដូចជាការប្រើចោរឱ្យទៅរកចាប់ចោរអញ្ចឹង ចោរសក្កាយទិដ្ឋិ វាមិនចាប់ខ្លួនវាទេ វាមានតែចោទប្រកាន់គេឯងជាអ្នកដទៃផ្សេងទៅវិញទេ ។

**ការចោទប្រកាន់សតិប្បដ្ឋាន ៤ ដែលប្រព្រឹត្តទៅនៅក្នុងជីវិតជាប្រក្រតីប្រចាំថ្ងៃថា មិនមែនជាការបដិបត្តិធម៌ដើម្បីលះកិលេសទេ ថាជាការធ្វើស្រាលៗធូរៗ ព្រោះមិនមានការចំរើនឱ្យតាំងនៅក្នុងអារម្មណ៍តែមួយ ការចោទនេះ គឺសក្កាយទិដ្ឋិជាអ្នកចោទ ព្រោះសក្កាយទិដ្ឋិវាជាសត្រូវរបស់សតិប្បដ្ឋាន៤ៗ**

# បញ្ហាវារៈនៃអារម្មណប្បច្ច័យទី III

≈≈≈≈≈

**កុសលោ ធម្មោ អព្យាកតស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ។**

កុសលធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយអារម្ម-ណប្បច្ច័យ ។

**មាន ៦ ចំណុចគឺ :**

**១ក-អរហា មគ្គា វុដ្ឋហិត្វា មគ្គំ បច្ចវេក្ខតិ។**

ព្រះអរហន្ត ចេញចាកមគ្គហើយ ពិចារណាមគ្គ ។

**ខ-បុព្វេ សុចិណ្ណានិ បច្ចវេក្ខតិ ។**

ពិចារណាពួកកុសល ដែលសន្សំទុកល្អហើយក្នុងកាលមុន ។

**គ-កុសលំ អនិច្ចតោ ទុក្ខតោ អនត្តតោ វិបស្សតិ ។**

ពិចារណាឃើញច្បាស់នូវកុសល ដោយសេចក្តីថា ជា

របស់មិនទៀង ជាទុក្ខ ជាអនត្តា ។

**ឃ-ចេតោបរិយញ្ញាណេន កុសលចិត្តសមង្គិស្ស ចិត្តំ ជានាតិ ។**

ដឹងចិត្តរបស់បុគ្គលអ្នកព្រមព្រៀងដោយកុសលចិត្ត ដោយចេតោបរិយញ្ញាណ ។

## អង្គធម៌ក្នុងចំណុចទី ១

**ក-បច្ច័យ-** អរហត្តមគ្គ ១ និង ចេតសិក ៣៦ ជាអារម្មណ៍ ។

**បច្ចយុប្បន្ន-** មហាកិរិយាចិត្តញាណសម្បយុត្ត ៤ ដួង និង ចេតសិក ៣៣ ជាបច្ចវេក្ខណញ្ញាណ របស់ព្រះអរហន្ត ។ ។

**ខ-បច្ច័យ-** មហាកុសលចិត្ត ៨ដួង និង ចេតសិក ៣៨ ដែលព្រះអរហន្ត ធ្លាប់បានសន្សំទុកល្អហើយក្នុងកាលមុនជាអារម្មណ៍ ។

**បច្ចយុប្បន្ន-** មហាកិរិយាចិត្ត ៨ ដួង ចេតសិក ៣៣ ជាតួពិចារណា ។

**គ-បច្ច័យ-** លោកិយកុសលចិត្ត ១៧ ដួង ចេតសិក ៣៨ ដែលមិនទៀង ជាទុក្ខ ជាអនត្តា ជាអារម្មណ៍ ។

**បច្ចយុប្បន្ន-** មហាកិរិយាចិត្ត ៨ ដួង ចេតសិក ៣៣ ជាតួពិចារណាត្រៃលក្ខណ៍របស់កុសល ។

**ឃ-បច្ច័យ-** កុសលចិត្ត ២១ដួង ឬ ៣៧ដួង ចេតសិក ៣៨ ជាអារម្មណ៍ ។

**បច្ចយុប្បន្ន-** អភិញ្ញាជវន ១ដួង ជាកិរិយាចិត្ត របស់ព្រះអរហន្ត ចេតសិក ៣០ ។

**ចំណុចទី ២ - សេក្ខា វា បុថុជ្ជនា វា កុសលំ អនិច្ចតោ ទុក្ខតោ អនត្តតោ វិបស្សន្តិ កុសលេ និរុទ្ធេ វិបាកោ តទារម្មណតា ឧប្បជ្ជតិ ។**

ព្រះសេក្ខបុគ្គលទាំងឡាយ ឬបុថុជ្ជនក៏ដោយ ពិចារណាឃើញច្បាស់នូវកុសល ដោយសេចក្ដីមិនទៀង ជាទុក្ខ ជាអនត្តា កាលកុសលរលត់ទៅហើយ តទារម្មណចិត្ត ដែល

ជាវិបាក រមែងកើតឡើង ។

**បច្ច័យ** – មហាកុសលចិត្ត ៨ដួង និង ចេតសិក ៣៨ ជាអារម្មណ៍ ។

**បច្ចយុប្បន្ន** – កាមាវចរវិបាកចិត្ត ១១ដួង ធ្វើតទាលម្ពណកិច្ចក្នុងមនោទ្វារ ចេតសិក ៣៣ ។

កាលណាមហាកុសលពិចារណាមហគ្គតកុសលចិត្ត ៩ ដួង ចេតសិក ៣៥ ដោយសេចក្ដីមិនទៀងជាដើម លុះរលត់ទៅនូវមហាកុសលជាតួពិចារណានោះ តទាលម្ពណកិច្ចរមែងមិនមាន ព្រោះអារម្មណ៍ជាមហគ្គត ដូចនេះទើបបច្ច័យក្នុងចំណុចទី ២ ដែលបានសំដែងហើយ មិនមានមហគ្គតកុសល ។

## អត្ថកថាចំណុចទី១ និង ទី២

ពាក្យថា **អរហោ មគ្គា វុដ្ឋហិត្វា** សេចក្ដីថា ចេញហើយដោយអំណាចការឈានកន្លងនូវភវង្គ ក្នុងលំដាប់នៃផលក្នុងមគ្គវិថី ក៏បច្ចវេក្ខណចិត្តជាកិរិយាព្យាកតរបស់ព្រះអរហន្តនោះ ។

ព្រះដ៏មានព្រះភាគជាម្ចាស់ កាលទ្រង់សំដែងអារម្មណប្បច្ច័យនៃកិរិយាព្យាកតៈយ៉ាងនេះហើយ ទើបទ្រង់សំដែងនូវអារម្មណប្បច្ច័យនៃវិបាកាព្យាកតៈទៀត ទើបទ្រង់ត្រាស់ថា **សេក្ខា វា** ជាដើម ។

បទថា **កុសលេ និរុទ្ធេ** គឺកាលវិបស្សនាជវនវិថីដាច់ទៅ ។

បទថា **វិបាកោ** បានដល់កាមាវចរវិបាក ។

បទថា **តទារម្មណតា** ជា តទារម្មណៈ អធិប្បាយថា តទារម្មណចិត្តនោះ ធ្វើកុសលដែលបានឃើញច្បាស់ហើយ ដោយវិបស្សនាឱ្យជាអារម្មណ៍កើតឡើងបន្ទាប់អំពីកុសលជវន ដែលមានកុសលហ្នឹងឯងជាអារម្មណ៍ដាច់ផុតទៅ ។

នៅក្នុងចំណុចនេះ មិនមែនមានចំពោះតែតទារម្មណចិត្តតែម្យ៉ាងប៉ុណ្ណោះទេ គឺនៅមានបដិសន្ធិភវង្គៈនិងចុតិផង

ពិតណាស់ វិបាករមែងមានកុសលជាអារម្មណ៍បាន ដូចគ្នា សំរាប់បុគ្គលអ្នកធ្វើកម្មឱ្យជាអារម្មណ៍ ហើយបដិសន្ធិ តែវិបាកនោះទ្រង់មិនបានសំដែងទុកក្នុងទីនេះ ព្រោះលំបាកយល់ ។

**ចំណុចទី៣– កុសលំ អស្សាទេតិ អភិនន្ទតិ តំ អារព្ភ រាគោ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ វិចិកិច្ឆា ឧប្បជ្ជតិ ឧទ្ធច្ចំ ឧប្បជ្ជតិ ទោមនស្សំ ឧប្បជ្ជតិ អកុសលេ និរុទ្ធេ វិបាកោ តទារម្មណតា ឧប្បជ្ជតិ។**

បុគ្គលត្រេកអរភ្លើតភ្លើនចំពោះកុសល ព្រោះប្រារព្ធនូវកុសលនោះ រាគៈកើតឡើង ទិដ្ឋិកើតឡើង វិចិកិច្ឆាកើតឡើង ឧទ្ធច្ចៈកើតឡើង ទោមនស្សកើតឡើង ។ កាលអកុសលរលត់ទៅហើយ តទារម្មណចិត្តដែល ជាវិបាករមែងកើតឡើង ។

**បច្ច័យនិងបច្ចយុប្បន្ន ដូចចំណុចទី២**

**អដ្ឋកថាចំណុចទី ៣**

ពាក្យថា **កុសលំ អស្សាទេតិ** ជាដើម ត្រាស់ទុកដើម្បីសំដែងវិបាក ដែលមានកុសលជាអារម្មណ៍ ក្នុងទីបំផុតនៃអកុសលជវន ។

**ចំណុចទី ៤– អាកាសានញ្ចាយតនកុសលំ វិញ្ញាណញ្ចាយតនវិបាកស្ស ច កិរិយស្ស ច អារម្មណប្បច្ចយេន បច្ចយោ ។**

អាកាសានញ្ចាយតនកុសល ជាបច្ច័យ នៃវិញ្ញាណញ្ចាយតនវិបាក និង កិរិយា ដោយអារម្មណប្បច្ច័យ ។

**បច្ច័យ–** អរូបាវចរកុសលចិត្តទី ១ និង ចេតសិក ៣០ ជាអារម្មណ៍ ។

**បច្ចយុប្បន្ន–** អរូបាវចរចិត្តទី២ ដែលជាវិបាក និង កិរិយា មានអរូបាវចរកុសលទី ១ ជាអារម្មណ៍ ។

**អដ្ឋកថា ចំណុចទី ៤**

ពាក្យថា **វិញ្ញាណញ្ចាយតនវិបាកស្ស** សូម្បីជាធម៌ដែលលំបាកយល់ក៏ដោយ ព្រះអង្គបានត្រាស់

ទុក ដោយអំណាចវិបាកដែលអាចប្រព្រឹត្តទៅបាន ព្រោះមហគ្គតវិបាក មិនកើតដោយភាពជាតទារម្មណៈ ។

បទថា **កិរិយស្ស** គឺអាកាសានញ្ចាយតនកុសល ជាបច្ច័យដោយអារម្មណប្បច្ច័យ ចំពោះកិរិយាចិត្ត របស់បុគ្គលបានសំរេចនូវព្រះអរហត្ត ហើយចូលសមាបត្តិដោយបដិលោម ឬ ដោយមានឈានមួយខណ្ឌ ក្នុងអារម្មណ៍ដែលជាអាកាសានញ្ចាយតនៈ ដែលនៅមិនធ្លាប់ចូល ។

✵ អាកាសានញ្ចាយតនកុសល ជាបច្ច័យនៃអាកាសានញ្ចាយតនវិបាក ដោយកម្មប្បច្ច័យ ប៉ុន្តែមិនមែនដោយអារម្មណប្បច្ច័យទេ ។

អាកាសានញ្ចាយតនកុសល ជាបច្ច័យនៃវិញ្ញាណាយតនវិបាក ដោយអារម្មណប្បច្ច័យ ប៉ុន្តែមិនមែនដោយកម្មប្បច្ច័យទេ ។

បុថុជ្ជន ឬព្រះសេក្ខបុគ្គល កាលចេញអំពីអាកាសានញ្ចាយតនកុសលមក ក៏បានសំរេចជាព្រះអរហន្ត រួចក៏ចូលកាន់វិញ្ញាណញ្ចាយតនកិរិយា មានអាកាសានញ្ចាយតនកុសល ជាអារម្មណ៍ ។

**ចំណុចទី៥ – អាកិញ្ចញ្ញាយតនកុសលំ នេវសញ្ញានាសញ្ញាយតនវិបាកស្ស ច កិរិយស្ស ច អារម្មណប្បច្ចយេន បច្ចយោ ។**

អាកិញ្ចញ្ញាយតនកុសល ជាបច្ច័យនៃនេវសញ្ញានាសញ្ញាយតនវិបាក និង កិរិយា ដោយអារម្មណប្បច្ច័យ ។

**បច្ច័យ** – អរូបាវចរកុសលទី ៣ ជាបច្ច័យនៃអរូបាវចរវិបាក និង កិរិយាទី ៤ ដោយអារម្មណប្បច្ច័យ ។

" អាកិញ្ច-កុសលចិត្ត +៣០"

**បច្ចយុប្បន្ន** – អរូបាវចរចិត្តទី ៤ ដែលជាវិបាក និង កិរិយា +៣០ អ្នកសិក្សាគប្បីជ្រាបន័យ តាមចំណុចទី ៤ ។

**ចំណុចទី៦– កុសលា ខន្ធា ចេតោបរិយញ្ញាណស្ស យថាកម្មូបគញ្ញាណស្ស អនាគតំ សញ្ញាណស្ស អាវជ្ជនាយ អារម្មណប្បច្ចយេន បច្ចយោ ។**

**អាវជ្ជនាយ** គឺមនោទ្វារាវជ្ជនៈ ។

**បច្ច័យ** – កុសលចិត្តចេតសិកទាំងអស់ បានដល់ ២១ដួង ឬ ៣៧ដួង + ៣៨ ជាអារម្មណ៍នៃកិរិយាព្យាកត ។

**បច្ចយុប្បន្ន** – អភិញ្ញាជាកិរិយាចិត្តរបស់ព្រះអរហន្ត +៣0 មនោទ្វារាវជ្ជនចិត្ត+១១ ។

### អត្ថកថា នៃចំណុចទី ៦

បទថា **ចេតោបរិយញ្ញាណស្ស** ជាដើម គប្បីយោងយកអាវជ្ជនមកជាខាងមុខ ក៏ក្នុងសេចក្តីនេះ មានអធិប្បាយដូចនេះថា ខន្ធទាំងឡាយដែលជាកុសល (កុសលា ខន្ធា) ជាបច្ច័យដល់អាវជ្ជននៃអភិញ្ញាជវន ដោយអារម្មណប្បច្ច័យ ។

### ចប់បញ្ហាវារៈទី III នៃអារម្មណប្បច្ច័យ ដោយសង្ខេប

# ប្រយោជន៍នៃការសិក្សា អារម្មណប្បច្ច័យ

អារម្មណប្បច្ច័យគឺជាជីវិតប្រចាំថ្ងៃ នៃចិត្តចេតសិក។

រូបកាយជាធាតុមិនដឹង មិនគិត មិនពិចារណា មិនសោយអារម្មណ៍ មិនមែនជាសត្វ ប៉ុន្តែអាស្រ័យនឹងរូបកាយនេះ មានចិត្តចេតសិកកើតឡើងបន្តជាប់ខណៈគ្នា មានរបៀបត្រឹមត្រូវជា **ចិត្តនិយាម** គឺទំនៀមទៀងទាត់ជាវិធីតាមច្បាប់កំណត់នៃការកើត តាមជាតិ តាមកិច្ច តាមស្ថាន តាមអារម្មណ៍ ។ល។

ចិត្តចេតសិកជាធម្មជាតិដឹងនូវអារម្មណ៍ ដែលអារម្មណ៍នោះ បាននាំឱ្យចិត្តចេតសិកហ្នឹងឯងកើតឡើង ដោយអារម្មណប្បច្ច័យ ព្រោះចិត្តចេតសិក មិនអាចដឹងអារម្មណ៍ដទៃណា ក្រៅអំពីអារម្មណ៍ដែលនាំឱ្យខ្លួនឯងកើតឡើង

ហ្នឹងទេ ។

បុគ្គលពិចារណានូវទានដែលបានឱ្យហើយក្ដី ឬពិចារណានូវកុសលដទៃៗទៀតក្ដី ដោយចិត្តជ្រះថ្លា តាមពិតបុគ្គលអ្នកពិចារណានោះ ក៏គឺជាមហាកុសលចិត្ត ៨ដួង ចេតសិក ៣៣ ហ្នឹងឯង មិនមែនជាគ្រហស្ថ ឬ បព្វជិតឡើយ ។

ការពិចារណាចំពោះកុសល ដែលបានសន្សំទុកល្អហើយ ក្នុងកាលមុន បុគ្គលអ្នកពិចារណានោះ មានចិត្តជ្រះថ្លាយ៉ាងណាៗ ប៉ុន្តែដែលថាបុគ្គលនោះក៏គឺ មហាកុសលចិត្ត និង ចេតសិកជាតួពិចារណា កើតរលត់បន្តគ្នា ដោយមានបុណ្យកុសលក្នុងកាលមុនជាអារម្មណប្បច្ច័យ ។

ទោះជាបុគ្គលអ្នកពិចារណាឈានក្ដី បុគ្គលអ្នកពិចារណាគោត្រភូ-វោទានៈក្ដី បុគ្គលអ្នកពិចារណាមគ្គក្ដី មិនមានអ្វីក្រៅអំពីមហាកុសលចិត្តុប្បាទ ជាតួពិចារណាតែប៉ុណ្ណោះ ពិចារណាហើយរលត់ទៅ សូន្យទៅ ត្រូវចិត្តុប្បាទថ្មីៗកើតបន្ត សុទ្ធតែជា **ធម្មា**គឺពួកបរមត្ថធម៌ ជាតំណនៃសង្ខារធម៌សុទ្ធ រកសត្វក្នុងគំនរនៃសង្ខារធម៌ពុំមានឡើយ ។

នៅផ្ទះចិត្តចេតសិកផ្សេង អាស្រ័យអារម្មណប្បច្ច័យនៅឯផ្ទះ ចេញទៅផ្សារ ចិត្តចេតសិកផ្សេង អាស្រ័យអារម្មណប្បច្ច័យនៅឯផ្សារ ឃើញរូបចិត្តចេតសិកផ្សេង ឮ សំឡេងចិត្តចេតសិកផ្សេង ធំក្លិន ដឹងរស ដឹងផោដ្ឋព្វៈ ចិត្តចេតសិកផ្សេង **មិនមានតួខ្លួន តួសត្វបុគ្គល ជាអ្នកដឹងអារម្មណ៍ឡើយ** កាលចិត្តចេតសិករលត់អស់ពុំមានសល់ ដោយប្រការណា **សេចក្ដីដឹងខ្លួនថាអញ នៅក្នុងរូបក្ខន្ធស្កន្ធនេះ ពុំមានទេ ។**

ព្រះអរិយបុគ្គលពុំមានសេចក្ដីត្រិះរិះថា ចិត្តចេតសិកជាខ្លួនអញ ហើយក៏មិនបានត្រិះរិះថា មានខ្លួនអញផ្សេងអំពីចិត្តចេតសិកទៀតដែរ ។

ដោយឡែកអំពីរូបកាយ ក្នុងជីវិតប្រចាំថ្ងៃ មិនមានអ្វីក្រៅអំពីការប្រព្រឹត្តិទៅនៃចិត្តចេតសិកដែលជាតួដឹងអារម្មណ៍ឡើយ ។

ចិត្តចេតសិក មិនមានអ្វីជារបស់ខ្លួនសោះ កាលដែលកើតឡើងហើយការពារតែខ្លួនឯងមិនបានផង តាមពិតចិត្តចេតសិក រូប គឺគ្រាន់តែជាផលនៃបច្ច័យតែប៉ុណ្ណោះ ។

ការសិក្សាអំពីអារម្មណប្បច្ច័យ មានប្រយោជន៍ធំធេងដល់ការយល់អំពីជីវិតពិត និង មានប្រយោជន៍យ៉ាងសំខាន់ គឺជំនួយដល់ការចំរើនសតិប្បដ្ឋាន ។

បុគ្គលដែលមិនបានអប់រំចិត្តក្នុងធម៌របស់ព្រះអរិយៈ មិនបានហ្វឹកហាត់ចិត្តក្នុងធម៌របស់សប្បុរស រមែងមិនបានឃ្លាតឆ្ងាយអំពីបញ្ចក្ខន្ធឡើយ ជាប់ដោយចំណងគឺ សេចក្តីប្រកាន់ថា បញ្ចក្ខន្ធជាខ្លួនអញ ។

បុគ្គលដែលប្រកាន់មាំនូវបញ្ចក្ខន្ធ រមែងនិយមចូលចិត្តធ្វើការងារមិនជាប្រយោជន៍ ដោយសំគាល់ថា មានខ្លឹមសារក្នុងជីវិតរបស់ខ្លួន គឺដោយច្រើននិយមការងារដែលសប្បាយរីករាយភ្លើតភ្លើន ជួបជុំគ្នានិយាយសើចលេង ។ល។ ហើយក៏និយមចូលចិត្តណាស់ដែរ ក្នុងការនិយាយរឿងប្លែកៗរបស់អ្នកដទៃ សូម្បីកំហុសបន្តិចបន្តួចរបស់គេ ក៏ខំចាំទុកមិនភ្លេច សំរាប់និយាយនៅពេលជួបអ្នកនេះ អ្នកនោះ ព្រោះគិតថា បើបាននិយាយអំពីរឿងអាក្រក់របស់គេច្រើននាក់ទៅ ធ្វើឱ្យខ្លួនឯងបានប្រសើរឡើង ដូច្នេះហើយទើបបានជាពោលថា ខ្ញុំមិនអញ្ចឹងទេ ។

ម្យ៉ាងទៀត អ្នកប្រកាន់មាំចំពោះបញ្ចក្ខន្ធ និយមបង្ករឿងឈ្លោះ ចូលចិត្តស្តីបន្ទោសឱ្យអ្នកដទៃ ហើយឆ្ងាញ់ក្នុងការនិយាយពាក្យបញ្ឈឺចិត្តឱ្យគេណាស់ ព្រោះថាបើអ្នកដទៃណា ដែលខ្លួនឯងបានអន់ចិត្តជាមួយនោះ អ្នកដទៃនោះគេបានសុខសប្បាយ ខ្លួនឯងឯណេះទៅជាបាយមិនឆ្ងាញ់ ម្ល៉ោះហើយនឹករករឿងរករ៉ាវយ៉ាងនេះយ៉ាងនោះដែលជាការឥតប្រយោជន៍ យ៉ាងហោចណាស់ ក៏បាននិយាយពាក្យស៊ិកសៀតឱ្យគេខ្លះដែរ ទើបខ្លួនឯងគិតថា បានសុខចិត្ត ។

សត្វលោកដោយច្រើន តែងតែអន់ចិត្ត ដោយគិតថា អ្នកនេះ អ្នកនោះ បំភ្លេចខ្លួនចោល ទាំងដែលខ្លួនឯងធ្លាប់បានជួយទំនុកបំរុង ឬធ្លាប់បានផ្តល់ឱ្យនូវអ្វីៗទោះតិចទោះ

ច្រើនក្តី ក៏ក្នុងគំនិតគិតថា គេនោះបានជំពាក់ខ្លួនឯងទៅហើយ ដូច្នេះគេមិនសមបំភ្លេចខ្លួនឡើយ ។

តាមពិតមនុស្សលោក គួរតែខិតខំកសាងខ្លួន រៀនសូត្រការងារល្អៗអំពីអ្នកដទៃ ព្រោះថា ការកើតមកជាមនុស្ស គឺកើតមកដើម្បីប្រយោជន៍ **គួរជ្រះថ្លាក្នុងការបំពេញសេចក្តីល្អឱ្យបានច្រើនឡើងៗ ព្រោះកម្របានណាស់នូវឱកាសពេលវេលានៃការយល់ដឹងអំពីគុណប្រយោជន៏នៃអំពើល្អ ៗ**

ពិតណាស់ ឱកាសពេលវេលានៃការបានយល់ បានដឹង អំពីប្រយោជន៍របស់គុណធម៌ទាំងពួង ហៅពេញសែនក្រ ដូច្នេះបុគ្គលមិនគួរប្រមាទក្នុងការបណ្តែតបណ្តោយពេលវេលាឡើយ ។

ការចំណាយពេលវេលា ប្រកែកតវ៉ា យកឈ្នះ យកចាញ់ រក្សាទុកនូវការប្រកាន់អញ គឺអញមិនចាញ់ឯង អញស៊ីបាយអញ ប្រាក់ចាយកំលាំងរបស់អញ យកការឈ្លោះស្តីថា ធ្វើជាអាជ្ញារបស់ខ្លួន យកមានះលើកធ្វើជាទង់ឱ្យខ្ពស់នេះហើយការរស់នៅក្នុងគំនរភ្នក់ភ្លើង និង ជាការបាត់បង់របស់ដ៏មានតំលៃ ហើយបានមកវិញនូវរបស់ដែលមានទោស ប្រៀបដូចបុគ្គលចំណាយដុំមាស ដុំពេជ្រ ទៅដូរយកខ្ជួយ ក្អែប មកទុកក្នុងផ្ទះអញ្ចឹងដែរ ។

ការចំណាយពេលវេលា ដើម្បីបានសប្បាយនៅក្នុងកាមគុណ និង ចំណាយពេលវេលាដើម្បីនិយាយគ្នាពីនេះពីនោះ ឥតប្រយោជន៍ ប្រៀបដូចជាការបណ្តេញមនុស្សល្អស្លូតត្រង់ ជាមនុស្សបានការចោល ហើយហៅយកនូវមនុស្សខូច មនុស្សអែបអប បញ្ជោរលើកជើងលើកដៃ ឱ្យមកនៅជាមួយធ្វើការងារក្នុងផ្ទះ អញ្ចឹងដែរ ។

ការសង្រួមកាយ-វាចា-ចិត្ត ពិតជាមិនងាយសង្រួមបានមែនក៏ដោយ ប៉ុន្តែគុណធម៌គឺ សេចក្តីព្យាយាម ព្រោះសេចក្តីសង្វេគជាបទដ្ឋាន បានរុញច្រានឱ្យបុគ្គលឃ្លាតចេញអំពីបាបកម្មបន្តិចម្តងៗ បានទៅជាអ្នកសង្រួមដ៏ប្រពៃ យប់ថ្ងៃប្រព្រឹត្តទៅដោយសេចក្តីមិនប្រមាទ ។

បុគ្គលអ្នកសង្រួម មានចិត្តស្ថិតនៅក្រោមម្លប់ព្រះធម៌ដ៏ត្រជាក់ មិនខឹងក្រោធ ឬអាក់អន់ចិត្តចំពោះអ្នកណាៗ ព្រោះតែការមិនជំពាក់ចិត្តនៅក្នុងលោក ។

បុគ្គលអ្នកសង្រួមមានមេត្តាចំពោះសព្វសត្វនានា ព្រោះឃើញសព្វសត្វទាំងអស់ប្រាថ្នាសេចក្ដីសុខ មានករុ-ណា ព្រោះឃើញសត្វលោកកំពុងតែប្រឹងរត់គេចចេញអំពីសេចក្ដីទុក្ខ ទាំងដែលមិនបានដឹងផ្លូវ ដើម្បីរត់ឱ្យបានរួចផុតចាកអំពីទុក្ខនោះផង ។

បុគ្គលអ្នកសង្រួម មានវាចាពិរោះ និយាយទៅរកអ្នកដទៃដោយទឹកចិត្តមានមេត្តា មានករុណា ពាក្យសំដីជាផ្កា ជាទឹកឃ្មុំ ពាក្យសំដីមានប្រយោជន៍ ផ្អែមស្រទន់ ធ្វើឱ្យអ្នកស្ដាប់ស្ងប់ចិត្ត មានស្មារតី ។

បុគ្គលអ្នកសង្រួម មិនមានបំណងឱ្យអ្នកណាម្នាក់មានសេចក្ដីទុក្ខឡើយ ទោះជាបុគ្គលនោះបានធ្វើអំពើមិនជាប្រយោជន៍មកលើលោកយ៉ាងណាក៏ដោយ លោកអ្នកសង្រួមតែងតែឱ្យអភ័យជានិច្ចជាកាល ។

បុគ្គលអ្នកសង្រួម មានចិត្តរួចផុតចាកការប្រកាន់មាំ ការជាប់ជំពាក់មាំ សុខចិត្តប្រគល់ឧបាទានក្ខន្ធ ៥ ឱ្យម្ចាស់គេនៅក្នុងលោកនេះ ដោយអាស្រ័យព្រហ្មយានដ៏ប្រសើរបានកើតឡើងនៅក្នុងអត្តភាពរបស់លោក ព្រហ្មយានដ៏ប្រសើរនោះ បាននាំលោកចេញចាកឱ្យឃ្លាតឆ្ងាយអំពីត្រើយអាយ កាត់សមុទ្រតណ្ហា ទៅកាន់ត្រើយនាយ ដែលជាត្រើយបរមសុខ ។

បុគ្គលអ្នកសង្រួម មិនធ្វើនូវអំពើអ្វីៗដែលមានលក្ខណៈជាប់នៅក្នុងលោកនេះឡើយ ព្រោះលោកបានកំណត់ដឹងហើយនូវលោកនេះ និង បរលោក ដោយបញ្ញាដ៏ប្រពៃ ។

**កាយនេះ កើតឡើងដោយអាស្រ័យសមុដ្ឋានផ្សេងៗ មានការចំរើនធំធាត់ដោ-យចំណីអាហារ ប៉ុន្តែទោះជាធាត់ស្គមយ៉ាងណា ក៏ត្រឹមតែជាមហាភូតរូប ៤ គឺ ដី**

**ទឹក ភ្លើង ខ្យល់ និងឧបាទាយរូបផ្សេងៗ ទៀតប៉ុណ្ណោះ ពុំមែនជាសត្វបុគ្គលតួខ្លួន ឡើយ ឯចំណែកវិញ្ញាណរបស់សត្វលោក បានអាស្រ័យនឹងរូបកាយនេះ ព្រោះមាន ចក្ខុរូបជាទីអាស្រ័យ និងព្រោះដោយអារម្ម ណប្បច្ច័យ ទើបមានវិញ្ញាណកើតឡើង បន្តគ្នា ពុំមានវិញ្ញាណណាមួយជាសត្វ ឡើយ ៗ**

ការសិក្សាអំពីអារម្មណ៍របស់ចិត្ត និង ចេតសិក នាំឱ្យបានយល់អំពីការកើតរលត់នៃចិត្តចេតសិក និង នាំឱ្យបានយល់អំពីអារម្មណ៍របស់សតិប្បដ្ឋាន ៤ ព្រមទាំងនាំឱ្យមានការចំរើនសតិប្បដ្ឋាន-វិបស្សនា បានជាប្រក្រតីធម្មតាក្នុងការបានដល់ទីពឹងពិតប្រាកដទៀតផង ។

# បញ្ហាវារៈទី ៤ នៃអារម្មណប្បច្ច័យ

≈≈≈≈≈

**IV- អកុសលោ ធម្មោ អកុសលស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ៗ**

ប្រែៈ អកុសលធម៌ ជាបច្ច័យនៃអកុសលធម៌ ដោយអារម្មណប្បច្ច័យ ។

**បច្ច័យ**– អកុសលចិត្ត ១២ + ២៧ ជាអារម្មណប្បច្ច័យ ។

**បច្ចយុប្បន្ន**– អកុសលចិត្ត ១២ ចេតសិក ២៧ កើតឡើង ។

## មាន ៥ ចំណុច

**១- រាគំ អស្សាទេតិ អភិនន្ទតិ តំ អារព្ភ រាគោ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ វិចិកិច្ឆា ឧប្បជ្ជតិ ឧទ្ធច្ចំ ឧប្បជ្ជតិ ទោមនស្សំ ឧប្បជ្ជតិ ។**

បុគ្គលត្រេកអរភ្លើតភ្លើន ចំពោះរាគៈ ព្រោះប្រារព្ធ

ចំពោះរាគៈនោះ រាគៈរមែងកើតឡើង ទិដ្ឋិកើតឡើង វិចិកិច្ឆាកើតឡើង ឧទ្ធច្ចៈកើតឡើង ទោមនស្សកើតឡើង។

**បច្ច័យ –** លោភមូលចិត្ត ៨ដួង និង ចេតសិក ២២ ជាអារម្មណប្បច្ច័យ ។

**បច្ចយុប្បន្ន –** អកុសលចិត្ត ១២ + ២៧ ។

**២ – ទិដ្ឋឹ អស្សាទេតិ អភិនន្ទតិ តំ អារព្ភ រាគោ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ វិចិកិច្ឆា ឧប្បជ្ជតិ ឧទ្ធច្ចំ ឧប្បជ្ជតិ ទោមនស្សំ ឧប្បជ្ជតិ ។**

**បច្ច័យ –** ទិដ្ឋិគតសម្បយុត្តចិត្ត ៤ដួង និង ចេតសិក ២១ ជាអារម្មណ៍ ។

**បច្ចយុប្បន្ន –** អកុ-១២ + ២៧ ។

អ្នកសិក្សាគប្បីប្រែបាលីក្នុងចំណុចទី ២នេះផង ដូចគ្នានឹងចំណុចទី១ដែរ គ្រាន់តែដូរបច្ច័យមកជាទិដ្ឋិវិញប៉ុណ្ណោះ ។

**✵ព្រះអង្គទ្រង់ត្រាស់សំដែងអំពីការកើតឡើងនៃសភាវធម៌ ក្នុងជីវិតរាល់ថ្ងៃ បើសភាវធម៌ពិតទាំងអស់ បានប្រាកដជាបរមត្ថសុទ្ធៗដល់បញ្ញាហើយនោះ ការចង់បានអ្វីៗយកមកឱ្យខ្លួន ក៏ត្រូវធូរថយ គឺមិនខ្លាំងក្លា ជាពិសេសការចង់បានធម៌នេះធម៌នោះផ្សេងៗក៏ត្រូវលែងមានតទៅហើយ ព្រោះបានដឹងច្បាស់ថា ការបានឃើញធម៌ពិតក្នុងជីវិតប្រចាំថ្ងៃច្បាស់ឡើងៗ ដោយសតិប្បដ្ឋានបដិបត្តិ ពិតជារំលត់សេចក្តីប្រកាន់បាន ពុំមានសង្ស័យ ។**

**៣ – វិចិកិច្ឆំ អារព្ភ វិចិកិច្ឆា ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ ឧទ្ធច្ចំ ឧប្បជ្ជតិ ទោមនស្សំ ឧប្បជ្ជតិ ។**

ព្រោះប្រារព្ធវិចិកិច្ឆា វិចិកិច្ឆាកើតឡើង ទិដ្ឋិកើតឡើង ឧទ្ធច្ចៈកើតឡើង ទោមនស្សកើតឡើង ។

✵វិចិកិច្ឆាសម្បយុត្តចិត្តុប្បាទជាអារម្មណប្បច្ច័យ ។

**៤-ឧទ្ធច្ចំ អារព្ភ ឧទ្ធច្ចំ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ វិចិកិច្ឆា ឧប្បជ្ជតិ ទោមនស្សំ ឧប្បជ្ជតិ ។**

ព្រោះប្រារព្ធឧទ្ធច្ចៈ ឧទ្ធច្ចៈកើតឡើង ទិដ្ឋិកើតឡើង វិចិកិច្ឆាកើតឡើង ទោមនស្សកើតឡើង ។

❃ ឧទ្ធច្ចសម្បយុត្តចិត្តុប្បាទ ជាបច្ច័យ ដោយអារម្មណប្បច្ច័យ ។

**៥-ទោមនស្សំ អារព្ភ ទោមនស្សំ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ វិចិកិច្ឆា ឧប្បជ្ជតិ ឧទ្ធច្ចំ ឧប្បជ្ជតិ ។**

❃ បដិឃសម្បយុត្តចិត្តុប្បាទ ជាបច្ច័យដោយអារម្មណប្បច្ច័យ ។

## អដ្ឋកថា បញ្ហាវារៈទី ៤

បទថា **រាគំ** គឺរាគៈរបស់ខ្លួន ឬរបស់អ្នកដទៃ តែក្នុងអធិការនេះ វណ្ណនាប្រាកដហើយ ដោយអំណាចនៃរាគៈរបស់ខ្លួន ។

បទថា **អស្សាទេតិ** ជាដើម មានអត្ថដូចពោលទុកហើយ តែក្នុងធម៌មានវិចិកិច្ឆាជាដើម មិនត្រាស់ថា **អស្សាទេតិ** (រមែងត្រេកអរ) ព្រោះមិនមានភាវៈដែលនឹងគួរឱ្យត្រេកអរ ក៏ទិដ្ឋិរមែងកើតឡើងក្នុងឋានៈនេះ ។

ទិដ្ឋិព្រះដ៏មានព្រះភាគជាម្ចាស់ មិនបានត្រាស់ទុកមុនតាមលំដាប់ដែលមកដល់ ព្រោះបទថា **អស្សាទេតិ** ធ្លាក់បាត់ទៅ (មិនមាន) ។

ព្រះដ៏មានព្រះភាគត្រាស់ធម៌នោះៗ ក្នុងបណ្ដាធម៌មានវិចិកិច្ឆាជាដើម ដែលជាសភាគៈនឹងគ្នាមុន ហើយទ្រង់ត្រាស់នូវទិដ្ឋិនោះទុកក្នុងលំដាប់នៃធម៌នោះៗ ។

បណ្ដាធម៌ (បច្ច័យ) មានរាគៈជាដើមនេះ គប្បីជ្រាបការកើតឡើងនៃទោមនស្ស ដោយអំណាចការអត់ទ្រាំមិនបានថា បាបធម៌ទាំងអស់នេះកើតឡើងធ្វើអ្វី ឬដោយអំណាចការស្ដាយក្រោយមានជាអាទិ៍ថា យើងបានធ្វើសេចក្ដីអាក្រក់ទុក យើងបានធ្វើកម្មអាក្រក់គ្រោតគ្រាតទុកមក ។

# បញ្ហាវារៈទី ៥ នៃអារម្មណប្បច្ច័យ

≈≈≈≈≈

V- **អកុសលោ ធម្មោ កុសលស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ។**

ប្រែ- អកុសលធម៌ ជាបច្ច័យនៃកុសលធម៌ ដោយអារម្មណប្បច្ច័យ ។

**មាន ៣ ចំណុច**

✵ រួមបច្ច័យ និង បច្ចយុប្បន្ន ទាំង ៣ ចំណុចគឺ :

**បច្ច័យ**– អកុសលចិត្ត ១២ និង ចេតសិក ២៧ ជាអារម្មណ៏ ។

**បច្ចយុប្បន្ន**– មហាកុសលចិត្ត ៨ កុសលអភិញ្ញា ១ និង ចេតសិក ៣៣ ។

**<u>ចំណុចទី១</u> : សេក្ខា បហីនក្កិលេសេ បច្ចវេក្ខន្តិ វិក្ខម្ភិតក្កិលេសេ បច្ចវេក្ខន្តិ បុព្វេ សមុទាចិណ្ណេ កិលេសេ ជានន្តិ ។**

ព្រះសេក្ខបុគ្គលទាំងឡាយ ពិចារណាពួកកិលេសដែលលះបង់បានហើយ ពិចារណាពួកកិលេសដែលសង្កត់សង្កិនបានហើយ ដឹងពួកកិលេសដែលលោកធ្លាប់សន្សំហើយក្នុងកាលមុន ។

**✵ដោយបរមត្ថ មិនមានព្រះសេក្ខ–បុគ្គលជាអ្នកពិចារណា ឬថាជាអ្នកដឹងនូវកិលេសធម៌នោះៗទេ តាមពិតគឺមហាកុស–លចិត្តុប្បាទ ៨ដួង ដែលកើតឡើងដោយមានកិលេសនោះជាអារម្មណប្បច្ច័យ ។**

**ដោយឡែកអំពីកាយ ដែលប្រកបដោយមហាភូតរូប ៤ គឺមានចិត្ត និងចេតសិក ដែលប្រព្រឹត្តទៅក្នុងការដឹងនូវអារម្មណ៏ ចំណែកបុគ្គលអ្នកដឹង គ្រាន់តែជាការសន្មតិប៉ុណ្ណោះ ។**

**<u>ចំណុចទី២</u> : សេក្ខា វា បុថុជ្ជនា វា**

**អកុសលំ អនិច្ចតោ ទុក្ខតោ អនត្តតោ វិបស្សន្តិ ។**

ចេតោបរិយញ្ញាណេន អកុសលចិត្តសមង្គិស្ស ចិត្តំ ជានន្តិ ។

ព្រះសេក្ខបុគ្គលទាំងឡាយក្តី បុថុជ្ជនទាំងឡាយក្តី ឃើញច្បាស់នូវអកុសល ដោយសេចក្តីថា មិនទៀង ជាទុក្ខ ជាអនត្តា ។

ដឹងនូវចិត្តរបស់បុគ្គលអ្នកមានសេចក្តីព្រមព្រៀង ដោយអកុសលចិត្ត ដោយចេតោបរិយញ្ញាណ ។

**✵ អកុសលធម៌ជាប្រក្រតីក្នុងជីវិតប្រចាំថ្ងៃ ជាអារម្មណ៍របស់សតិប្បដ្ឋានបានពិតៗ ទើបអាចលះបង់សេចក្តីប្រកាន់ថា មានសត្វបុគ្គលតួខ្លួន ទិបស្សនាបានចំរើនតាមសតិប្បដ្ឋាន ឃើញអកុសលធម៌ មិនទៀង ជាទុក្ខ ជាអនត្តា ប៉ុន្តែថា មិនមានបុគ្គលជាអ្នកឃើញច្បាស់នូវត្រៃលក្ខណ៍នោះទេ តាមពិតគឺ មហាកុសលចិត្ត និង ចេតសិក ឯចំណែកការដឹងចិត្តរបស់អ្នក ដទៃការដឹងនោះក៏មិនមានអ្វីក្រៅអំពីចិត្ត និង ចេតសិកដែរ បានដល់អភិញ្ញាជវន ហ្នឹងឯងដែលកើតអំពីបច្ច័យផ្សេងៗ មានអកុសលធម៌ជាអារម្មណប្បច្ច័យជាដើម ៗ**

**<u>ចំណុចទី៣ :</u> អកុសលា ខន្ធា ចេតោបរិយញ្ញាណស្ស បុព្វេនិវាសានុស្សតិញ្ញាណស្ស យថាកម្មូបគញ្ញាណស្ស អនាគតំសញ្ញាណស្ស អារម្មណប្បច្ចយេន បច្ចយោ ។**

✵ ក្នុងអារម្មណប្បច្ច័យ បញ្ហាវារៈទី ៥ ចំណុចទី៣នេះ គឺពួកកងអកុសលធម៌ជាបច្ច័យនៃអភិញ្ញា ដែលជាកុសលជវន ដូចដែលបាលីបានសំដែងហើយ ឯចំណែកការពន្យល់អំពីអភិញ្ញា មាននៅខាងមុខ ដោយល្អិតល្អន់ ។

✵ ✵ ✵

# បញ្ហាវារៈទី ៦

≈≈ ≈≈

VI- **អកុសលោ ធម្មោ អព្យាកតស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ។**

ប្រែ- អកុសលធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយអារម្មណប្បច្ច័យ ។

**បច្ច័យ –** អកុសលធម៌ទាំងអស់ ជាអារម្មណប្បច្ច័យ ( ១២ + ២៧ ) ។

**បច្ចយុប្បន្ន –** កិរិយាចិត្ត ១០ ដួង វិបាកចិត្ត ១១ ដួង ចេតសិករួមទាំងអស់ ៣៣ ។

## មាន ៤ ចំណុច

**១- អរហា បហីនក្កិលេសេ បច្ចវេក្ខតិ បុព្វេ សមុទាចិណ្ណេ កិលេសេ ជានាតិ អកុសលំ អនិច្ចតោ ទុក្ខតោ អនត្តតោ វិបស្សតិ ចេតោបរិយញ្ញាណេន អកុសលចិត្តសមង្គិស្ស ចិត្តំ ជានាតិ ។**

ព្រះអរហន្តពិចារណាកិលេសដែលបានលះបង់ហើយ ដឹងកិលេសដែលធ្លាប់កើតហើយក្នុងកាលមុនៗ រមែងពិចារណាឃើញច្បាស់នូវអកុសលធម៌ ដោយសេចក្ដីថាមិនទៀង ជាទុក្ខ ជាអនត្តា ដឹងចិត្តរបស់បុគ្គលអ្នកមានសេចក្ដីព្រមព្រៀងដោយអកុសលចិត្ត ដោយចេតោបរិយញ្ញាណ **(កិរិយាចិ – ៩ចេ – ៣៣)** ។

**✵ដែលថាបុគ្គលជាព្រះអរហន្ត លោកបានពិចារណាក្ដី បានដឹងក្ដី បានឃើញច្បាស់ក្ដី គ្មានអ្វីក្រៅអំពីមហាកិរិយាចិត្ត ៨ ដួង ចេតសិក ៣៣ និង អភិញ្ញាជវនចិត្ត ១ដួង ដែលជាកិរិយា មានចេតសិក ៣០ ប្រកបជាមួយនោះទេ ។**

**ចិត្តប្បាទ ៩ដួង ដែលជាកិរិយាកើតដោយអកុសលធម៌ ជាអារម្មណប្បច្ច័យ ។**

**ក្នុងជីវិតប្រចាំថ្ងៃ ចូរកុំប្រមាទ ចូរ**

មានស្មារតីរឿយៗ រលឹកសិក្សាចំពោះគ្រប់ចិត្ត និង ចេតសិក ដែលមិនមែនជាសត្វបុគ្គល តួខ្លួន ៗ

ព្រះអរហន្តបានឃើញច្បាស់នូវកិលេសអកុសលធម៌របស់បុគ្គលដទៃ ដោយសេចក្តីថាមិនទៀង ជាទុក្ខ ជាអនត្តា ជាប្រក្រតីធម្មតារបស់លោក ៗ

ការឃើញដោយបញ្ញាដ៏ប្រពៃថា អកុសលធម៌មិនមែនជាសត្វបុគ្គល រមែងមិនប្រកាន់ខឹងគ្រោធជាមួយអ្នកដទៃណាៗ ព្រោះថាអកុសលធម៌ដែលនាំឱ្យប្រព្រឹត្តឆ្គាំឆ្គងនោះ វាជាព្រាយបិសាចប្រចាំវដ្ត:បានចូលស្ថិតនៅ ក្នុងសព្វសត្វទាំងអស់ បើពុំតែអាស្រ័យខ្មោចបិសាចនោះ គឺពិតជាមិនមានមនុស្ស ឬទេវតាណាប្រព្រឹត្តអាក្រក់ឆ្គាំឆ្គងឡើយ ៗ

<u>ចំណុចទី២</u> **ក្នុងបញ្ហាវារៈទី ៦**

**សេក្ខា វា បុថុជ្ជនា វា អកុសលំ អនិច្ចតោ ទុក្ខតោ អនត្តតោ វិបស្សន្តិ កុសលេ និរុទ្ធេ វិបាកោ តទារម្មណតា ឧប្បជ្ជតិ ។**

ព្រះសេក្ខបុគ្គលទាំងឡាយក្តី បុថុជ្ជនទាំងឡាយក្តី ពិចារណាឃើញច្បាស់នូវអកុសល ដោយសេចក្តីថា មិនទៀង ជាទុក្ខ ជាអនត្តា កាលដែលកុសលរលត់ទៅហើយ តទារម្មណចិត្ត ដែលជាវិបាក រមែងកើតឡើង ។

✵ ព្រះអង្គទ្រង់សំដែងកាមាវចរវិបាកចិត្ត ១១ដួង ធ្វើតទាលម្ពណកិច្ចខាងមុខកុសលជវន មាននូវអកុសលធម៌ជាអារម្មណ៍ក្នុងមនោទ្វារ ។

✵ **ពិភពលោកសព្វថ្ងៃក្តី ក្នុងពេលដទៃទៀតក្តី អាស្រ័យវិថីចិត្ត ទើបបានប្រាកដឡើង ចិត្តមាន៤ជាតិ គឺ : កុសលជាតិ១**

អកុសលជាតិ ១ វិបាកជាតិ ១ កិរិយាជាតិ ១ ៗ

កាលវិថីចិត្តអស់ទៅ លោកក៏បាត់ទៅដែរ កាលវិថីចិត្តមិនទាន់កើតឡើង លោកក៏មិនទាន់មាន កាលវិថីចិត្តកំពុងកើតឡើង មានការប្រព្រឹត្តិទៅក្នុងអារម្មណ៍ណា អារម្មណ៍នោះក៏ប្រាកដជាលោក នោះជាលោកដោយបរមត្ថក្ដី នោះជាលោកនៃការនឹកគិតក្ដី ក៏ប្រាកដបានស្មើគ្នានឹងវិថីចិត្តតែប៉ុណ្ណោះ ៗ

ពិភពលោកដ៏ធំធេង សត្វលោកសន្ធឹកសន្ធាប់រាប់មិនអស់ក្ដី កិលេសកាម វត្ថុកាម មាសប្រាក់ ទ្រព្យសម្បត្តិជាទីស្រឡាញ់ពេញចិត្តយ៉ាងណាក្ដី មានត្រឹមតែមួយភ្លែតនៃការត្រិះរិះប៉ុណ្ណោះ ពេលវេលាដែលកន្លងទៅភ្លាមៗនោះ បានលេបត្របាក់យកទៅនូវអ្វីៗទាំងអស់ ឱ្យបាត់អស់ពុំមានសេសសល់នៅឡើយ ៗ

**ចំណុចទី៣ : អកុសលំ អស្សាទេតិ អភិនន្ទតិ តំ អារព្ភ រាគោ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ វិចិកិច្ឆា ឧប្បជ្ជតិ ឧទ្ធច្ចំ ឧប្បជ្ជតិ ទោមនស្សំ ឧប្បជ្ជតិ អកុសលេ និរុទ្ធេ វិបាកោ តទារម្មណតា ឧប្បជ្ជតិ។**

✵ ព្រះអង្គទ្រង់ត្រាស់សំដែង នូវអកុសលចិត្ត ១២ ចេតសិក ២៧ ជាអារម្មណ៍នៃអកុសលជវន ក្នុងមនោទ្វារ កាលអកុសលជវនដាច់អស់ទៅ វិបាកចិត្ត ១១ដួង ណា មួយ កើតបន្តធ្វើតទាលម្ពណកិច្ច មាននូវអកុសលនោះ ជាអារម្មណ៍ ដោយមហាវិបាក ៨ដួង និង អហេតុកវិបាក មនោវិញ្ញាណ ៣ដួង ធ្វើតទាលម្ពណកិច្ចនោះ ជាអព្យាកត ទើបអធិការនេះគឺ អកុសលជាបច្ច័យនៃអព្យាកតៈ ដោយអារម្មណប្បច្ច័យ ។

**<u>ចំណុចទី៤</u> : អកុសលោ ខន្ធា ចេតោបរិយញ្ញាណស្ស បុព្វេនិវាសានុស្សតិញ្ញាណស្ស យថាកម្មូបគញ្ញាណស្ស អនាគតំសញ្ញាណស្ស អាវជ្ជនាយ អារម្មណប្បច្ចយេន បច្ចយោ ។**

✵ ក្នុងចំណុចទី ៤ នៃបញ្ហាវារៈទី ៦នេះ មាន អកុសលចិត្ត ១២ដួង និង ចេតសិក ២៧ ជាអារម្មណប្បច្ច័យ នៃអភិញ្ញាកិរិយាចិត្ត១ដួង ចេតសិក ៣០ និង មនោទ្វារាវជ្ជនៈ ១ ដួង ចេ-១១ ។

✵ មនោទ្វារាវជ្ជនៈ គឺជាកិច្ចរបស់អហេតុកកិរិយា មនោវិញ្ញាណធាតុ ប្រកបដោយឧបេក្ខាវេទនា ជាជើងទ្រ ជវនចិត្តក្នុងទ្វារទាំង ៦ ធ្វើនូវវោដ្ឋព្វនកិច្ចក្នុងបញ្ចទ្វារ ។

កិច្ចការក្នុងទ្វារទាំង ៦ក្តី ក្រៅទ្វារ ៦ក្តី គឺជាកិច្ចរបស់ចិត្តចេតសិក ដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ ដូចនេះ អារម្មណ៍ គឺជាលោកនៃកិច្ចការងារច្រើនយ៉ាង ប៉ុន្តែជាកិច្ចការងារ របស់ចិត្តបរមត្ថ និង ចេតសិកបរមត្ថតែប៉ុណ្ណោះ ។

# បញ្ហាវារៈទី ៧

≈≈ ≈≈

**VII- អព្យាកតោ ធម្មោ អព្យាកតស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ។**

អព្យាកតធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយ អំណាចអារម្មណប្បច្ច័យ ។

## <u>មាន ១២ ចំណុច</u>

**១-អរហា ផលំ បច្ចវេក្ខតិ និព្វានំ បច្ចវេក្ខតិ។**

ព្រះអរហន្ត ពិចារណាផលចិត្ត ពិចារណាព្រះនិព្វាន ។

**បច្ច័យ**– អរហត្តផលចិត្ត ១ដួង ចេ-៣៦ និង ព្រះនិព្វាន ជាអារម្មណ៍ ។

**បច្ចយុប្បន្ន**– មហាកិរិយាញាណសម្បយុត្តចិត្ត ៤ដួង ចេ-៣៣ ។

**២-និព្វានំ ផលស្ស អាវជ្ជនាយ អារម្មណប្បច្ចយេន បច្ចយោ ។**

ព្រះនិព្វានជាបច្ច័យ នៃផលចិត្ត និង អាវជ្ជនចិត្ត ដោយអំណាចអារម្មណប្បច្ច័យ ។

**បច្ច័យ –** ព្រះនិព្វានជាអារម្មណ៍ ។

**បច្ចយុប្បន្ន –** ផលចិត្ត ៤ដួង ឬលោកុត្តរវិបាកចិត្ត ២០ ចេ-៣៦ និងមនោទ្វារាវជ្ជនចិត្ត ១ដួង ចេតសិក១១ ។

**✵ យើងតែងនិយាយថា បុគ្គលអ្នកត្រាស់ដឹងនូវអរិយសច្ចធម៌ បានឃើញនូវព្រះនិព្វាន ប៉ុន្តែដោយបរមត្ថធម៌ ដែលថា បុគ្គលនោះក៏គឺចិត្តចេតសិកតែប៉ុណ្ណោះ អ្នកសត្វក្នុងគំនរនៃសង្ខារធម៌មិនមានឡើយ ៗ**

**៣-អរហា ចក្ខុំ អនិច្ចតោ ទុក្ខតោ អនត្តតោ វិបស្សតិ សោតំ ឃានំ ជិវ្ហំ កាយំ រូបេ សទ្ទេ គន្ធេ រសេ ផោដ្ឋព្វេ វត្ថុំ វិបាកាព្យាកតេ កិរិយាព្យាកតេ ខន្ធេ អនិច្ចតោ ទុក្ខតោ អនត្តតោ វិបស្សតិ ។**

ព្រះអរហន្តរមែងឃើញច្បាស់នូវចក្ខុ ដោយសេចក្តីថាជារបស់មិនទៀង ជាទុក្ខ ជាអនត្តា ឃើញច្បាស់នូវសោតៈ ឃានៈ ជីវ្ហា កាយ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ហទយវត្ថុ និង ខន្ធទាំងឡាយ ដែលជាអព្យាកតវិបាក អព្យាកតកិរិយា ដោយសេចក្តីថា មិនទៀង ជាទុក្ខ ជាអនត្តា ។

✵ ឱឡារិករូប១២ ហទយវត្ថុរូប១ លោកិយវិបាកចិត្ត ៣២ កិរិយាចិត្ត ២០ ចេតសិក ៣៥ ជាអារម្មណ៍នៃវិបស្សនារបស់ព្រះអរហន្ត ព្រោះសតិ.សម្បជញ្ញៈបរិបូណ៌ ។

**៤-ទិព្វេន ចក្ខុនា រូបំ បស្សតិ ទិព្វាយ សោតធាតុយា សទ្ទំ សុណាតិ ចេតោបរិយញ្ញាណេន វិបាកាព្យាកតកិរិយាព្យាកតចិត្តសមង្គិស្ស ចិត្តំ ជានាតិ ។**

ព្រះអរហន្ត ឃើញរូបដោយទិព្វចក្ខុ ស្តាប់សំលេងដោយទិព្វសោតធាតុ ដឹងចិត្តរបស់អ្នកដែលព្រមព្រៀងដោយអព្យាកតចិត្ត គឺវិបាកនិងកិរិយា ដោយចេតោបរិយ-

ញ្ញាណ ។

**បច្ច័យ** – រូបារម្មណ៍និងសទ្ទារម្មណ៍ ដែលជាបច្ចុប្បន្ន វិបាកចិត្ត ៣៦ កិរិយាចិត្ត ២០ ចេតសិករួមទាំងវិបាក និង កិរិយា ៣៨ ។

**បច្ចយុប្បន្ន** – អភិញ្ញាជវន១ដួង ចេតសិក ៣០ ជាកិរិយាចិត្តរបស់ព្រះអរហន្ត ប្រព្រឹត្តទៅជាទិព្វចក្ខុ ទិព្វសោត និង ចេតោបរិយញ្ញាណ ។

**៥-អាកាសានញ្ចាយតនកិរិយំ វិញ្ញាណញ្ចាយតនកិរិយស្ស អារម្មណប្បច្ចយេន បច្ចយោ ។**

**បច្ច័យ** – អរូបាវចរកិរិយាចិត្តទី ១ ចេតសិក ៣០ ជាអារម្មណ៍ ។

**បច្ចយុប្បន្ន** – អរូបាវចរកិរិយាចិត្តទី ២ ចេតសិក ៣០ កើតឡើង ។

**៦-អាកិញ្ចញ្ញាយតនកិរិយំ នេវសញ្ញានាសញ្ញាយតនកិរិយស្ស អារម្មណប្បច្ចយេន បច្ចយោ ។**

**បច្ច័យ** – អរូបាវចរកិរិយាចិត្តទី ៣ ចេតសិក ៣០ ជាអារម្មណ៍ ។

**បច្ចយុប្បន្ន** – អរូបាវចរកិរិយាចិត្តទី ៤ ចេតសិក ៣០ កើតឡើង ។

**៧-រូបាយតនំ ចក្ខុវិញ្ញាណស្ស អារម្មណប្បច្ចយេន បច្ចយោ ។**

**បច្ច័យ** – រូបាយតនៈ ជាអារម្មណប្បច្ច័យ ។

**បច្ចយុប្បន្ន** – ចក្ខុវិញ្ញាណ ២ដួង ចេតសិក ៧ ។

**៨-សទ្ទាយតនំ សោតវិញ្ញាណស្ស អារម្មណប្បច្ចយេន បច្ចយោ ។**

**បច្ច័យ** – សទ្ទាយតនៈ ជាអារម្មណប្បច្ច័យ ។

**បច្ចយុប្បន្ន** – សោតវិញ្ញាណ ២ដួង ចេតសិក៧ ។

**៩-គន្ធាយតនំ ឃានវិញ្ញាណស្ស អារម្មណប្បច្ចយេន បច្ចយោ ។**

**បច្ច័យ** – គន្ធាយតនៈ ជាអារម្មណប្បច្ច័យ ។

**បច្ចុប្បន្ន** – ឃានវិញ្ញាណ ២ដួង ចេតសិក ៧ ។

**១០-រសាយតនំ ជីវ្ហាវិញ្ញាណស្ស អារម្មណប្ប-ច្ចយេន បច្ចយោ ។**

**បច្ច័យ** – រសាយតនៈ ជាអារម្មណប្បច្ច័យ ។

**បច្ចុប្បន្ន** – ជីវ្ហាវិញ្ញាណ ២ដួង ចេតសិក ៧ ។

**១១-ផោដ្ឋព្វាយតនំ កាយវិញ្ញាណស្ស អារម្ម-ណប្បច្ចយេន បច្ចយោ ។**

**បច្ច័យ** – ផោដ្ឋព្វាយតនៈ ជាអារម្មណប្បច្ច័យ ។

**បច្ចុប្បន្ន** – កាយវិញ្ញាណ ២ដួង ចេតសិក ៧ ។

**១២-អព្យាកតា ខន្ធា ឥទ្ធិវិធញ្ញាណស្ស ចេ-តោបរិយ-ញ្ញាណស្ស បុព្វេនិវាសានុស្សតិញ្ញាណស្ស អនាគតំសញ្ញាណស្ស អាវជ្ជនាយ អារម្មណប្បច្ចយេន បច្ចយោ។**

**បច្ច័យ** – វិបាកចិត្ត៣៦ (ពិស្តារ ៥២) កិរិយាចិត្ត ២០ ចេតសិករួម ៣៨ រូបបរមត្ថ ២៨ ជាអារម្មណ៍ ។

**បច្ចុប្បន្ន** – អភិញ្ញាកិរិយា ១ដួង និង ចេតសិក ៣០ មនោទ្វារាវជ្ជនចិត្ត ១ដួង និង ចេតសិក ១១ ។

**អត្ថកថា ត្រូវបញ្ហាវារៈទី ៧**

បទថា **ចត្តុំ អនិច្ចតោ** (ចំណុចទី៣) សេចក្តីថា ឱឡារិកាយតនៈ ១០ និងវត្ថុរូប ១ ទ្រង់កាន់យកហើយ ព្រោះប្រាកដតាមលំដាប់វិបស្សនា ។

រូបាយតនៈជាដើម ទ្រង់ក៏កាន់យកទៀត (ចំណុចទី៧) ព្រោះជាអារម្មណ៍នៃចក្ខុវិញ្ញាណជាដើម ក៏ព្រោះទេស-នានេះត្រាស់ដោយអំណាចនៃវិញ្ញាណ មិនបានត្រាស់ដោយអំណាចធាតុ ដូច្នោះទើបមិនកាន់យក មនោធាតុផង ។

គប្បីជ្រាបអារម្មណ៍ដែលកាន់យកហើយ និង ដែលនៅមិនបានកាន់យកក្នុងទីទាំងពួងយ៉ាងនេះ ។

# បញ្ហាវារៈទី ៨

≈≈≈≈≈

**VIII-អព្យាកតោ ធម្មោ កុសលស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ។**

អព្យាកតធម៌ ជាបច្ច័យនៃកុសលធម៌ ដោយអារម្មណប្បច្ច័យ ។

## មាន ៥ ចំណុច

**១-សេក្ខា ផលំ បច្ចវេក្ខន្តិ និព្វានំ បច្ចវេក្ខន្តិ។**

ព្រះសេក្ខបុគ្គលទាំងឡាយ ពិចារណាផលចិត្ត ពិចារណាព្រះនិព្វាន ។

**បច្ច័យ**– ផលថ្នាក់ក្រោម ៣ ឬ លោកុត្តរវិបាកចិត្ត ១៥ដួង (វៀរអរហត្តផល) ចេតសិក ៣៦ និង និព្វាន ។

**បច្ចយុប្បន្ន**– មហាកុសលញាណសម្បយុត្តចិត្ត ៤ដួង ចេតសិក ៣៣ ជាតួពិចារណានូវអារម្មណ៍ដែលជាលោកុត្តរ ។

**២-និព្វានំ គោត្រភុស្ស វោទានស្ស មគ្គស្ស អារម្មណប្បច្ចយេន បច្ចយោ ។**

ព្រះនិព្វានជាបច្ច័យដល់គោត្រភូ វោទាន និង មគ្គ ដោយអំណាចនៃអារម្មណប្បច្ច័យ ។

**បច្ច័យ**– ព្រះនិព្វាន ជាអារម្មណ៍ ។

**បច្ចយុប្បន្ន**– មហាកុសលញាណសម្បយុត្តចិត្ត ៤ ចេតសិក ៣៣ ជាគោត្រភូ និង ជាវោទានៈ ។

លោកុត្តរកុសលចិត្ត ២០ និង ចេតសិក ៣៦ មាននិព្វានជាអារម្មណ៍ រំលត់កិលេស ។

**៣-សេក្ខា វា បុថុជ្ជនា វា ចក្ខុំ អនិច្ចតោ ទុក្ខតោ អនត្តតោ វិបស្សន្តិ សោតំ ឃានំ ជិវ្ហំ កាយំ រូបេ សទ្ទេ គន្ធេ រសេ ផោដ្ឋព្វេ វត្ថុំ វិបាកាព្យាកតេ កិរិយាព្យាកតេ ខន្ធេ អនិច្ចតោ ទុក្ខតោ អនត្តតោ វិបស្សន្តិ ។**

ព្រះសេក្ខបុគ្គលទាំងឡាយក្តី បុថុជ្ជនទាំងឡាយក្តី

ពិចារណាឃើញច្បាស់នូវចក្ខុ ដោយសេចក្ដីថាមិនទៀង ជាទុក្ខ ជាអនត្តា ពិចារណាឃើញច្បាស់នូវសោតៈ ឃានៈ ជីវ្ហា កាយ រូប សំលេង ក្លិន រស ផោដ្ឋព្វៈ ហទយវត្ថុ និង ខន្ធទាំងឡាយដែលជាអព្យាកតវិបាក និង អព្យាកតកិរិយា ដោយសេចក្ដីថា ជារបស់មិនទៀង ជាទុក្ខ ជាអនត្តា ។

**បច្ច័យ** – ឱឡារិករូប១២ ហទយវត្ថុរូប ១ លោកិយវិបាកចិត្ត ៣២ កិរិយាចិត្ត ២០ ចេតសិករួម ៣៥ ជាអារម្មណ៍របស់វិបស្សនា ដែលអារម្មណ៍ទាំងនេះជាអព្យាកតៈ ហើយតែងមានជាធម្មតា ក្នុងជីវិតប្រចាំថ្ងៃ ។

**បច្ចយុប្បន្ន** – មហាកុសលចិត្ត ៨ ដួង ចេតសិក ៣៣ ។

**✵បុគ្គលគួរពិចារណាអភិធម្មក្នុងជីវិតប្រចាំថ្ងៃ ដោយសេចក្ដីព្យាយាម អំណត់អត់ធន់ រហូតទាល់តែលះបង់បាន នូវការតម្កើងខ្លួន ព្រោះគេខ្លួនមិនឃើញ ៗ**

**៤–ទិព្វេន ចក្ខុនា រូបំ បស្សន្តិ ទិព្វាយ សោតធាតុយា សទ្ទំ សុណន្តិ ចេតោបរិយញ្ញាណេន វិបាកាព្យាកតកិរិយាព្យាកតចិត្តសមង្គិស្ស ចិត្តំ ជានន្តិ ។**

(បុគ្គលមិនមែនជាព្រះអរហន្ត) ឃើញរូបដោយទិព្វចក្ខុ ស្ដាប់សំលេងដោយទិព្វសោតធាតុ ដឹងចិត្តរបស់បុគ្គលអ្នកដែលព្រមព្រៀងដោយអព្យាកតចិត្ត គឺវិបាកនិងកិរិយា ដោយចេតោបរិយញ្ញាណ ។

**បច្ច័យ** – រូបារម្មណ៍ និង សទ្ទារម្មណ៍ ដែលជាបច្ចុប្បន្ន វិបាកចិត្ត ៣៥ (វៀរអរហត្តផល) កិរិយាចិត្ត ២០ ចេតសិករួម ៣៨ រូប ២៨ ជាអារម្មណ៍របស់អភិញ្ញាជវនដែលជាកុសល ។

**បច្ចយុប្បន្ន** – អភិញ្ញាកុសល ១ដួង ចេតសិក ៣០ ដែលជាទិព្វចក្ខុ ទិព្វសោត និង ចេតោបរិយញ្ញាណ ។

**✵ដោយឡែកអំពីកាយជាធាតុមិនដឹង មិនមែនសត្វ មានចិត្តនិងចេតសិកជាធាតុ**

ដឹងនូវអារម្មណ៍ គឺជាទីតាំងនៃសតិរលឹកដឹងរឿយៗ ៗ ការមិនចំរើនសតិក្នុងអារ-ម្មណ៍ធម្មតាៗ ពិតជាមិនអាចឃើញព្រះសម្មាសម្ពុទ្ធបានឡើយ សេចក្តីត្រិះរិះយល់ថាខ្លួនមាន របស់ខ្លួនមាន រមែងបិទបាំងមិនឱ្យឃើញព្រះតថាគត ៗ

ព្រះតថាគតមានគុណប្រមាណមិនបាន ពុទ្ធបរិស័ទបានឃើញបដិច្ចសមុប្បាទធម៌ក្នុងពេលណា ក្នុងពេលនោះទើបបានឃើញព្រះតថាគតទ្រង់នូវគុណដ៏ធំ ៗ

ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងនូវព្រះសទ្ធម្ម បញ្ញាថ្វាត់ស្តាប់ព្រះធម៌ គាត់តែងឱ្យមានសតិ-រលឹក សតិប្បដ្ឋាន ៤ នាំឱ្យបាននូវអរិយមគ្គប្រកបដោយអង្គ ៨ ប្រការ បានដល់ សីល-សមាធិ-បញ្ញា ជាលោកុត្តរ ប៉ុន្តែកាលដែលបុគ្គលនៅប្រ-កាន់ថា ខ្លួនអញជាអ្នកធ្វើសីល ធ្វើសមាធិ និងជាអ្នកចំរើនវិបស្សនា តើនឹងឱ្យឃើញព្រះគុណរបស់ព្រះសម្មាសម្ពុទ្ធ ដែលព្រះអង្គកសាងបារមីធម៌អស់កាលដ៏យូរអង្វែង ដើម្បីជួយស្រោចស្រង់សត្វលោកឱ្យរួចផុតចាកទុក្ខនោះ បានយ៉ាងណាទៅ បើនៅតែក្នុងសេ-ចក្តីឃើញថា ខ្លួនអញជាម្ចាស់ធម៌ ព្រោះខ្លួនអញជាអ្នកធ្វើធម៌ឱ្យកើតឡើងទេនោះៗ

**៥-អព្យាកតោ ខន្ធា ឥទ្ធិវិធញ្ញាណស្ស ចេ-តោបរិយ ញ្ញាណស្ស បុព្វេនិវាសានុស្សតិញ្ញាណស្ស អនាគតំ សញ្ញាណស្ស អារម្មណប្បច្ចយេន បច្ចយោ។**

**បច្ច័យ**-អព្យាកតា ខន្ធា បានដល់វិបាកចិត្ត ៣៥ (វៀរអរហត្តផល) កិរិយាចិត្ត ២០ ចេតសិករួម ៣៨ រូប ២៨ ជាអារម្មណប្បច្ច័យ នៃអភិញ្ញាកុសល ។

**បច្ចយុប្បន្ន** – អភិញ្ញាជវនដែលជាកុសលចិត្ត ១ ដួង ចេតសិក ៣០ ។

**<u>ចំណាំ</u>** : ឥទ្ធិវិធញ្ញាណកុសល មានតែកុសលធម៌ និង អព្យាកតធម៌ ជាអារម្មណ៍ប៉ុណ្ណោះ គឺមិនមានអកុសលធម៌ជាអារម្មណ៍ឡើយ ។

ឥទ្ធិវិធញ្ញាណកិរិយា មានតែអព្យាកតធម៌ជាអារម្មណ៍ប៉ុណ្ណោះ ។

យថាកម្មុបគញ្ញាណទាំងកុសល ទាំងកិរិយា មិនមានអប្យាកតៈជាអារម្មណ៍ទេ ព្រោះយថាកម្មមានតែកុសល និងអកុសលតែប៉ុណ្ណោះ សូម្បីកុសលក៏ជាលោកិយកុសល ដែរ ។

ចូរសិក្សាចតុត្ថជ្ឈាន ១២យ៉ាង នឹងបានយល់អំពីអារម្មណ៍របស់អភិញ្ញាដោយសព្វគ្រប់ ។

# បញ្ហាវារៈទី ៩

**IX-អព្យាកតោ ធម្មោ អកុសលស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ។**

អព្យាកតធម៌ ជាបច្ច័យនៃអកុសលធម៌ ដោយអារម្មណប្បច្ច័យ ។

**បច្ច័យ** – លោកិយវិបាកចិត្ត ៣២ កិរិយាចិត្ត ២០ ចេតសិករួម ៣៥ រូប ២៨ ជាអព្យាកតារម្មណ៍ ។

**បច្ចយុប្បន្ន** – អកុសលចិត្ត ១២ និង ចេតសិក ២៧ ។

**ចក្ខុំ អស្សាទេតិ អភិនន្ទតិ តំ អារព្ភ រាគោ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ វិចិកិច្ឆា ឧប្បជ្ជតិ ឧទ្ធច្ចំ ឧប្បជ្ជតិ ទោមនស្សំ ឧប្បជ្ជតិ ។**

**សោតំ ឃានំ ជិវ្ហំ កាយំ រូបេ សទ្ទេ គន្ធេ រសេ ផោដ្ឋព្វេ វត្ថុំ វិបាកាព្យាកតេ កិរិយាព្យាកតេ ខន្ធេ អស្សាទេតិ អភិនន្ទតិ តំ អារព្ភ រាគោ**

ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ វិចិកិច្ឆា ឧប្បជ្ជតិ ឧទ្ធច្ចំ ឧប្បជ្ជតិ ទោមនស្សំ ឧប្បជ្ជតិ ។

✵ព្រះអង្គទ្រង់ត្រាស់សំដែងនូវពួកធម៌ដែលជាអារម្មណ៍របស់អកុសល ឱ្យជាទីតាំងនៃវិបស្សនា ក្នុងការបណ្តេញចេញឬលះបង់ចោលនូវអកុសលធម៌ មានសេចក្តីប្រកាន់ជាដើម ។

ព្រះអង្គសំដែងលោកិយធម៌ ទោះជាកុសលក្តី ជាអកុសលក្តី ជាអព្យាកតក្តី ឱ្យជាអារម្មណប្បច្ច័យនៃវិបស្សនា ព្រោះកិច្ចការនេះប្រព្រឹត្តទៅក្នុងការហាមឃាត់រារាំងនូវអកុសលធម៌ ដោយមកអំពីអកុសលធម៌ មានតែលោកិយធម៌ជាអារម្មណ៍ប៉ុណ្ណោះ ។

# អារម្មណប្បច្ច័យសភាគៈ

**អភិធម្មបិដកខ្មែរ លេខ ៩៥ ទំព័រ ៥**

អារម្មណប្បច្ចយា អធិបតិយា សត្ត និស្សយេ តីណិ ឧបនិស្សយេ សត្ត បុរេជាតេ តីណិ វិប្បយុត្តេ តីណិ អត្ថិយា តីណិ អវិគតេ តីណិ ។

អារម្មណប្បច្ច័យ ជា **អារម្មណជាតិ** ដូចនេះ បច្ច័យដែលជាសភាគៈជាមួយអារម្មណប្បច្ច័យ ទើបត្រូវតែជា **អារម្មណជាតិ** ផងដែរ ។

តាមព្រះបាលីដែលបានសំដែងទុកមក ធ្វើឱ្យជ្រាប ថា បច្ច័យដែលស្មើគ្នាជាមួយអារម្មណប្បច្ច័យនោះ មាន ៧ បច្ច័យគឺ : **អធិបតិ និស្សយ ឧបនិស្សយ បុរេជាត វិប្បយុត្ត អត្ថិ និង អវិគត**

**ប្បច្ច័យ ៗ**

គប្បីជ្រាបផងដែរថា ក្នុងសភាគប្បច្ច័យនោះ បច្ច័យមួយៗបែងជាវារៈ តើបានប៉ុន្មានបញ្ហាវារៈ ដោយចំនួនសង្ខ្យា (គឺតួលេខ) ដែលទ្រង់សំដែងទុកចុងក្រោយនៃបច្ច័យសភាគៈនោះៗ ដូចជា **អារម្មណប្បច្ចយា អធិបតិយា សត្ត** ដោយសេចក្តីថា ធម៌ដែលជាអារម្មណប្បច្ច័យ ស្មើគ្នានឹងអធិបតិប្បច្ច័យនោះមាន ៧វារៈ (សត្ត=៧) ។

**អារម្មណប្បច្ចយា និស្សយេ តីណិ**

ធម៌ដែលជាអារម្មណប្បច្ច័យ ស្មើគ្នានឹងនិស្សយប្បច្ច័យ មាន ៣វារៈ (តីណិ=៣) ដូច នេះជាដើម ។

✵ចំពោះបញ្ហាវារៈក្នុងហេតុប្បច្ច័យក្តី ក្នុងអារម្មណប្បច្ច័យក្តី ដូចមានមកហើយនោះ ចំពោះ **កុសលត្តិកៈ** តែប៉ុណ្ណោះ ចំណែក **វេទនាត្តិកៈ**ជាដើមទៀតនោះ មានបញ្ហាវារៈដោយឡែកផ្សេងទៀត ។

# ន័យ ៦ដ៏ជ្រៅ

≈≈ ≈≈

**(បិដក ៩៤ ទំព័រ៣០)**

**✵តិកញ្ច បដ្ឋានវរំ ទុកុត្តមំ**

**ទុកត្តិកញ្ចេវ តិកទុកញ្ច**

**តិកត្តិកញ្ចេវ ទុកទុកញ្ច**

**ឆ. អនុលោមម្ហិ. នយា. សុគម្ភីរា ៗ**

ប្រែ- ន័យទាំង ៦ គឺ តិកប្បដ្ឋាន ដ៏ប្រសើរ ១ ទុកប្បដ្ឋាន ដ៏ឧត្តម ១ ទុកត្តិកប្បដ្ឋាន ១ តិកទុកប្បដ្ឋាន១ តិកត្តិកប្បដ្ឋាន ១ ទុកទុកប្បដ្ឋាន ១ មានន័យដ៏ជ្រៅ ក្នុងអនុលោម ។

**អដ្ឋកថា បរមត្ថទីបនី**

**បណ្ណត្តិវារៈ**

ក្នុងអនុលោមន័យ ទ្រង់ចំណែកបុច្ឆានៃកុសលត្តិកៈទុក **៣៩២៨០០** សំនួរ ។

កុសលត្តិកៈយ៉ាងណា វេទនាត្តិកៈជាដើមក៏យ៉ាងនោះ ក្នុង ២២ តិកៈ គឺតិកៈទាំងអស់ ដោយការចែកប្រភេទនៃតិកៈ មានបុច្ឆា **៧៧៦១៦០០** សំនួរ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់សំដែងទុកដោយសង្ខេប ។

ក្នុងអនុលោមន័យនៃហេតុទុកៈ មានបុច្ឆា **៦៨៨០០**សំនួរ សូម្បីក្នុងសហេតុទុកៈជាដើម ក៏ដូចគ្នានឹងហេតុទុកៈដែរ ។

ក្នុងទុកៈទាំងអស់ ១០០ ទ្រង់ជាអ្នកប្រាជ្ញត្រាស់បុច្ឆាទុកក្នុងទុកៈ ១០០ទុកៈមាន **៦៨៨០០០០**សំនួរ ។

នេះជាការកំណត់ចំនួនបុច្ឆាក្នុង **តិកប្បដ្ឋាន** (តិកៈមាន ២២តិកៈ មានកុសលត្តិកៈជាដើម)និង **ទុក-ប្បដ្ឋាន** (ទុកៈមាន១០០ ទុកៈ មានហេតុទុកៈជាដើម) សុទ្ធៗជាមុន ។

ចំណែកដែលឈ្មោះថា **ទុកត្តិកប្បដ្ឋាន** ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់កាន់យកតិកៈ ២២ មកបញ្ចូលក្នុងទុកៈ ១០០ទុកៈ សំដែងបន្តអំពីនោះក្នុងទុកត្តិកប្បដ្ឋានដូច្នេះឯង ។

អ្នកសិក្សាគប្បីជ្រាបកំណត់ចំនួនបុច្ឆា ដែលសំដែងប្រកបតិកៈនីមួយៗក្នុងបណ្តាតិកៈ ២២ ចូលជាមួយទុកៈ ១០០ ដោយអំណាចនៃន័យដែលមានមូលមួយជាដើមទាំងអស់ តាមន័យដែលព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ហើយយ៉ាងនេះថា **កុសលធម៌ដែលជាហេតុ ពឹងអាស្រ័យកុសលធម៌ដែលជាហេតុកើតឡើងព្រោះហេតុប្បច្ច័យ ឬ ?**

✵ ក្នុងបិដកខ្មែរយើងលេខ ១០៥ ចាប់អំពីទំព័រទី១ទៅ ត្រង់ **អនុលោមទុកត្តិកប្បដ្ឋាន ហេតុទុកកុសលត្តិកៈ បដិច្ចវារៈ ៗ**

**(១) ហេតុំ កុសលំ ធម្មំ បដិច្ច ហេតុ កុសលោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ៗ**

កុសលធម៌ ជាហេតុ អាស្រ័យនូវកុសលធម៌ ជា ហេតុ

ទើបកើតឡើងព្រោះហេតុប្បច្ច័យ ។

ប៉ុណ្ណេះជាដើម គ្រាន់តែបញ្ជាក់ថា ក្នុងបិដកខ្មែរយើង មិនមានពាក្យ **ឬ ?** នៅខាងចុងទេ ដើម្បីកុំឱ្យឆ្ងល់ការពន្យល់របស់អត្ថកថា ។

ម្យ៉ាងទៀត ដូចជានៅក្នុងលេខ ៩៤ បិដកខ្មែរយើង ត្រង់ **អនុលោមត្តិកប្បដ្ឋាន កុសលត្តិកៈ បដិច្ចវារៈ** (ទំព័រ១៩) ។

**(២៦) សិយា កុសលំ ធម្មំ បដិច្ច កុសលោ ធម្មោ ឧប្បជ្ជេយ្យ ហេតុប្បច្ចយា។**

កុសលធម៌ អាស្រ័យកុសលធម៌ គប្បីកើតឡើងព្រោះហេតុប្បច្ច័យក៏មាន ។

ក្នុងអត្ថកថាប្រែតាំងជាសំនួរដូច្នេះថា កុសលធម៌អាស្រ័យកុសលធម៌កើតឡើងព្រោះហេតុប្បច្ច័យ គប្បីមានឬ ?

ឯចម្លើយនៅទំព័រ ៣៦

ព្រះអង្គទ្រង់ត្រាស់ថា

**(៩៦) កុសលំ ធម្មំ បដិច្ច កុសលោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា កុសលំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា តយោ ខន្ធេ បដិច្ច ឯកោ ខន្ធោ ទ្វេ ខន្ធេ បដិច្ច ទ្វេ ខន្ធា ។**

កុសលធម៌ អាស្រ័យកុសលធម៌ ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺ ខន្ធ៣ អាស្រ័យខន្ធ ១ ដែលជាកុសលកើតឡើង . ខន្ធ ១ អាស្រ័យខន្ធ ៣ កើតឡើង . ខន្ធ ២ អាស្រ័យខន្ធ ២ កើតឡើង ។

នៅក្នុងការតាំងសំនួរទី ២ ទំព័រ ១៩ ដដែល អ្នកសិក្សាគប្បីពិនិត្យ (២៦) ........ ។ **សិយា កុសលំ ធម្មំ បដិច្ច អកុសលោ ធម្មោ ឧប្បជ្ជេយ្យ ហេតុប្បច្ចយា។**

អកុសលធម៌ អាស្រ័យកុសលធម៌ គប្បីកើតឡើង

ព្រោះហេតុប្បច្ច័យ ក៏មាន ។

ក្នុងសំនួរទី២នេះ ព្រះសម្មាសម្ពុទ្ធទ្រង់ពុំបានវិសជ្ជនាទេ គឺទ្រង់លះចោល ព្រោះកុសលធម៌និងអកុសលធម៌មិនអាចកើតព្រមគ្នាបានឡើយ ។

ដូច្នេះអ្នកសិក្សាមិនគប្បីកាន់យកពាក្យថា **ក៏មាន** តាមដែលបានប្រែហើយនោះទេ ត្រូវប្រែតាំងជាសំនួរដូច្នេះវិញថា

អកុសលធម៌ អាស្រ័យ កុសលធម៌ កើតឡើង ព្រោះហេតុប្បច្ច័យ គប្បីមានឬ ?

ក្នុង **តិកប្បដ្ឋាន** ៧៧៦១៦០០ និង **ទុក–ប្បដ្ឋាន** ៦៤៨០០០០ គឺត្រូវតាំងជាសំនួរទាំងអស់ ប៉ុន្តែព្រះអង្គពុំបានវិសជ្ជនាគ្រប់សំនួរទេ ដូចជានៅក្នុង **កុស–លត្តិក:** ព្រោះហេតុប្បច្ច័យមាន **៤៩**សំនួរ ទ្រង់វិសជ្ជនាតែ ៩ សំនួរប៉ុណ្ណោះ ៤០សំនួរទៀតទ្រង់លះចោល ។

អ្នកសិក្សាអភិធម្មបិដក គប្បីជ្រាបក្នុង ៤០ សំនួរនោះ ថាគ្រាន់តែព្រះអង្គតាំងសំនួរទុកតែប៉ុណ្ណោះ មិនត្រូវយល់ឬប្រែថា **ក៏មាន** ដូច្នេះទេ ។

នៅក្នុងអដ្ឋកថា បានតាំងសំនួរ សួរថា ក្នុងសេចក្តីនេះគប្បីមានពាក្យសួរថា បញ្ហា ៤៩ ដោយហេតុប្បច្ច័យជាដើមនេះ រមែងវិសជ្ជនាមិនបានទាំងអស់ ហើយចុះតើព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់សំដែងទុកធ្វើអ្វី ដូចម្តេចក៏មិនសំដែងតែបញ្ហាណាដែលព្រះអង្គគួរវិសជ្ជនាបានទៅ?

ឆ្លើយថា ពិតណាស់ កាលព្រះអង្គទ្រង់សំដែងបញ្ហាទុកយ៉ាងនេះ ហើយទ្រង់វិសជ្ជនានូវបញ្ហាណាដែលអាចវិសជ្ជនាបាន លះចោលនូវបញ្ហាណាដែលមិនអាចវិសជ្ជនាបាន គឺដើម្បីឱ្យកុលបុត្រយល់ចូលចិត្តបានដោយងាយ ។

**បន្តអដ្ឋកថា**– ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់កាន់យកទុក: ១០០ មកបញ្ចូលក្នុង តិក: ២២ ហើយសំដែងបដ្ឋានឈ្មោះថា **តិកទុកប្បដ្ឋាន** ។

ព្រះអង្គទ្រង់បញ្ចូលតិក:ទាំងឡាយក្នុងតិក:នោះ ឯង

ហើយទ្រង់សំដែងបដ្ឋានឈ្មោះថា **តិកត្តិកប្បដ្ឋាន** ។

បន្ទាប់ពីនោះមក ទ្រង់បញ្ចូលទុកៈជាមួយនិងទុកៈនោះឯង ហើយទ្រង់បានសំដែងបដ្ឋានដែលឈ្មោះថា **ទុកទុកប្បដ្ឋាន** ។

ពាក្យថា **ឆ. អនុលោមម្ហិ. នយា. សុគម្ហិរា** សេចក្តីថា អ្នកសិក្សាគប្បីជ្រាប ន័យ ៦ ដ៏មានជម្រៅដោយល្អ មាន **តិកប្បដ្ឋានជាដើម**នេះ ក្នុងអនុលោម ។

បណ្តាន័យទាំងអស់នោះ **អនុលោម** មាន ២ គឺៈ **ធម្មានុលោម** និង **បច្ចយានុលោម** ។

បដ្ឋានដែលព្រះអង្គឱ្យប្រព្រឹត្តទៅដោយអំណាចទេសនា ដែលអនុលោមដល់ធមិ ដោយបទអភិធម្មមាតិកាយ៉ាងនេះថា **កុសលធម៌ អាស្រ័យកុសលធម៌** ឈ្មោះថា **ធម្មានុលោម** ។

បដ្ឋានដែលព្រះអង្គឱ្យប្រព្រឹត្តទៅដោយអំណាចទេសនា ដែលបានអនុលោមដល់បច្ច័យ ២៤យ៉ាង ដូចនេះថា **ហេតុប្បច្ចយា អារម្មណប្បច្ចយា** ឈ្មោះថា **បច្ចយានុលោម** ។

✵**តិកញ្ច បដ្ឋានវរំ ទុកុត្តមំ ឆ. បច្ចនីយម្ហិ. នយា សុគម្ភីរា** ។

**បច្ចនីយប្បដ្ឋាន** ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ផ្តើមដូចនេះថា **កុសលធម៌ គប្បីអាស្រ័យកុសលធម៌កើតឡើង ព្រោះនហេតុប្បច្ច័យឬ ?**

✵ បាលីព្រះអភិធម្មបិដកលេខ ៩៤ ទំព័រ ៣០

**(៩៥) សិយា កុសលំ ធម្មំ បដិច្ច កុសលោ ធម្មោ ឧប្បជ្ជេយ្យ នហេតុ-ប្បច្ចយា** ។

នៅក្នុង **កុសលត្តិកៈ** ព្រោះ **នហេតុប្បច្ច័យ**នេះ ដែលជាបច្ចនីយប្បដ្ឋាន ព្រះអង្គទ្រង់តាំងសំនួរ **៤៩** ដូចអនុលោមប្បដ្ឋានដែរ ប៉ុន្តែទ្រង់ត្រាស់វិសជ្ជនាមានតែ **២**

វិសជ្ជនាតែប៉ុណ្ណោះ ។

អ្នកសិក្សាត្រូវមើលវិសជ្ជនាក្នុងទំព័រ ៩៨ និង ៩៩ បិដកលេខ ៩៤ ។

✵វិសជ្ជនាទី ១ គឺ អកុសលធម៌ អាស្រ័យអកុសលធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។

បានដល់មោហចេតសិកក្នុងមោហមូលចិត្ត ២ ដួង អាស្រ័យសម្បយុត្តធម៌ កើតឡើងដោយ នហេតុប្បច្ច័យ ។

✵វិសជ្ជនាទី ២ គឺ អព្យាកតធម៌ អាស្រ័យអព្យាកតធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។

បានដល់អហេតុកវិបាកក្ខន្ធ និង អហេតុកកិរិយាខន្ធ អាស្រ័យគ្នានិងគ្នាទៅវិញទៅមកក្នុងចិត្តុប្បាទនីមួយៗ និងចិត្តជរូបដែលកើតអំពីអហេតុកចិត្តនោះៗ ដោយ នហេតុប្បច្ច័យ ។

ម្យ៉ាងទៀត អហេតុកបដិសន្ធិកម្មជរូប កើតឡើងដោយ នហេតុប្បច្ច័យ ។

វិបាកក្ខន្ធបដិសន្ធិ អាស្រ័យវត្ថុរូបកើតឡើង ដោយ នហេតុប្បច្ច័យ ។

មហាភូតរូប អាស្រ័យមហាភូតរូបកើតឡើងក្តី ឧបាទាយរូប អាស្រ័យមហាភូតរូប ៤ កើតឡើងក្តី គឺកើតដោយ នហេតុប្បច្ច័យ ។

ព្រះអង្គទ្រង់បុច្ឆា ៤៩សំនួរ ដោយ **នហេតុប្ប-ច្ច័យ** ប៉ុន្តែទ្រង់លះចោល ៤៧សំនួរ ព្រោះមិនគួរដល់ការវិសជ្ជនា ដូចជាបុច្ឆាទី ១ ដែលទ្រង់លះចោលនោះ ក្នុងបិដកខ្មែរយើងប្រែថា **កុសលធម៌ អាស្រ័យកុសលធម៌ គប្បីកើតឡើង ព្រោះនហេតុប្បច្ច័យក៏មាន** ពាក្យថា «**ក៏មាន**»នេះឯង ដែលធ្វើឱ្យអ្នកសិក្សាមិនយល់ ហើយចេះតែឆ្ងល់ពេញតែសៀវភៅអភិធម្មប្បដ្ឋាន ព្រោះបាលីថា **សិយា**ក៏ត្រូវប្រែថា «**ក៏មាន**» យ៉ាងនឹងឯង ប៉ុន្តែដូចជាកុសលធម៌មិនដែលអាស្រ័យកុស-លធម៌ កើតឡើង ដោយមិនមានហេតុប្បច្ច័យនោះទេ ។

នៅក្នុងកុសលត្តិកៈ ព្រោះ **នអារម្មណប្បច្ច័យ**

ព្រះអង្គទ្រង់តាំងបុច្ឆាទុក ៤៩ សំនួរដែរ ប៉ុន្តែទ្រង់វិសជ្ជនាតែ ៥ ប៉ុណ្ណោះ ។

**(៤៦) សិយា កុសលំ ធម្មំ បដិច្ច កុសលោ ធម្មោ ឧប្បជ្ជេយ្យ នអារម្មណប្បច្ចយា ។**

កុសលធម៌ អាស្រ័យកុសលធម៌ គប្បីកើតឡើងព្រោះ នអារម្មណប្បច្ច័យ គប្បីមានឬ ?

ព្រះអង្គទ្រង់មិនវិសជ្ជនាទេ ព្រោះជាធម្មតាកុសលធម៌ អាស្រ័យកុសលធម៌ កើតឡើង សុទ្ធតែមាននូវអារម្មណប្បច្ច័យ ជានិច្ច ។

អ្នកសិក្សាគប្បីមើលទំព័រ ៦០ ក្នុងលេខ ៩៤ ដែលព្រះអង្គទ្រង់វិសជ្ជនានូវកុសលត្តិកៈដោយនអារម្មណប្បច្ច័យ ៥ វិសជ្ជនាផងចុះ ។

**បន្តអត្ថកថា**

**បច្ចនីយៈ** មានពីរយ៉ាងគឺ : **ធម្មបច្ចនីយៈ ១ និង បច្ចយបច្ចនីយៈ ១ ។**

ក្នុងពីរយ៉ាងនោះ ន័យដែលព្រះដ៏មានព្រះភាគជាម្ចាស់ឱ្យប្រព្រឹត្តទៅហើយ ដោយអំណាចការសំដែងធម៌ដែលសង្គ្រោះ ដោយបទអភិធម្មមាតិកាយ៉ាងនេះថា **កុសលា ធម្មា** ដោយសំដែងជា **បច្ចនីយៈ** ថា **នកុសលំ ធម្មំ បដិច្ច នកុសលោ ធម្មោ** ធម៌ដែលមិនមែនជាកុសល អាស្រ័យធម៌ ដែលមិនមែនជាកុសល នេះឈ្មោះថា **ធម្មបច្ចនីយៈ ។**

ន័យដែលព្រះដ៏មានព្រះភាគ ឱ្យប្រព្រឹត្តទៅដោយអំណាចការសំដែងបច្ច័យ ២៤ ដោយជាបច្ច័យយ៉ាងនេះថា **នហេតុប្បច្ចយា នារម្មណប្បច្ចយា** ឈ្មោះថា **បច្ចយបច្ចនីយៈ ។**

**✵តិកញ្ច បដ្ឋានវរំ ។ល។ ឆ. អនុលោមបច្ចនីយម្ហិ. នយា. សុគម្ភីរា ។**

ដើម្បីនឹងសំដែង **អនុលោមបច្ចនីយប្បដ្ឋាន**

ព្រះដ៏មានព្រះភាគជាម្ចាស់ ទើបផ្ដើមពាក្យថា **កុសលធម៌ គប្បីអាស្រ័យកុសលធម៌ កើតឡើង ព្រោះហេតុប្បច្ច័យ នអារម្មណប្បច្ច័យឬ ?**

✵ ជាធម្មតា កុសលធម៌ គប្បីអាស្រ័យកុសលធម៌ កើតឡើង ព្រោះហេតុប្បច្ច័យផង អារម្មណប្បច្ច័យផង មិនមែនអត់មានអារម្មណប្បច្ច័យទេ ដូច្នេះ បុច្ឆានេះទ្រង់មិនវិសជ្ជនាឡើយ ។

## បន្តអត្ថកថា

**អនុលោមបច្ចនីយប្បដ្ឋាន** មានពីរយ៉ាងគឺៈ **ធម្មានុលោមបច្ចនីយៈ ១ និង បច្ចយានុលោមបច្ចនីយៈ ១ ៗ**

**កុសលំ. ធម្មំ. បដិច្ច. នកុសលោ. ធម្មោ** ធម៌ដែលមិនមែនជាកុសល អាស្រ័យធម៌ដែលជាកុសលនេះឈ្មោះថា **ធម្មានុលោមបច្ចនីយប្បដ្ឋាន ៗ** បដ្ឋានដែលព្រះពុទ្ធអង្គទ្រង់ឱ្យប្រព្រឹត្តទៅដោយអំណាច-ការសំដែងបទដែលមានក្នុងបច្ច័យ ២៤ យ៉ាងនេះថា **ហេតុប្បច្ចយា នអារម្មណប្បច្ចយា** ដោយអនុលោមបច្ចនីយន័យ ឈ្មោះថា **បច្ចយានុលោមបច្ចនីយប្បដ្ឋាន ៗ**

✵**តិកញ្ច បដ្ឋានវរំ ៗលៗ ឆ. បច្ចនីយានុលោមម្ហិ នយា សុគម្ភីរា ៗ**

បច្ចនីយានុលោមប្បដ្ឋាន ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ផ្ដើមជាអាទិ៍ថា **កុសលធម៌ ពឹងអាស្រ័យកុសលធម៌ កើតឡើង ព្រោះនហេតុប្បច្ច័យ អារម្មណប្បច្ច័យឬ ?** ( ព្រះអង្គទ្រង់មិនវិសជ្ជនាបុច្ឆានេះឡើយ) ។

✵ខ្ញុំព្រះករុណា ខ្ញុំបាទ សរសេរអំពី **ន័យ ៦ ដ៏ជ្រៅ** នេះ ដោយសង្ខេប ទុកគ្រាន់ពុទ្ធបរិស័ទបានជាពន្លឺក្នុងការសិក្សាព្រះអភិធម្មគម្ពីរទី ៧ គឺ **បដ្ឋាន**។

ក្នុងអភិធម្មបិដកលេខ ៩៤ ពុទ្ធបរិស័ទសិក្សាអំពី

**បច្ចយវិភង្គវារៈ** ក្នុងទំព័រទី ១ មកដល់ទំព័រទី ១៨ គឺជាវារៈនៃការបែងចែកបច្ច័យ **២៤បច្ច័យ** ។

ក្នុងទំព័រទី ១៩ **អនុលោមត្តិកប្បដ្ឋាន កុសលត្តិកៈ បដិច្ចវារៈ** ពុទ្ធបរិស័ទ្ធ ត្រូវរៀនទន្ទេញ បុច្ឆាវារៈ **៤៩**វារៈ ឱ្យចាំបាលីទាំងអស់ ហើយឱ្យយល់នូវសេចក្ដីប្រែ ត្រូវមានពាក្យ **ឬ?** ខាងចុងនៃសេចក្ដីប្រែបាលីទាំងអស់ ។

ពាក្យថា **អនុលោមត្តិកប្បដ្ឋាន** (អនុលោម + តិក + បដ្ឋាន) គឺតិកៈមានកុសលត្តិកៈជាដើម ព្រះអង្គទ្រង់សំដែងអនុលោមឱ្យស្របតាមបដ្ឋាន បានដល់បច្ច័យ ២៤ ។

ពាក្យថា **កុសលត្តិកៈ**(កុសល + តិកៈ) គឺតិកៈមាតិកា ២២ មានកុសលត្តិកៈជាដើម ( **កុសលា ធម្មា អកុសលា ធម្មា អព្យាកតា ធម្មា ធម្មាបីនេះហៅថា កុសលត្តិកៈ** ) ។

ពាក្យថា **បដិច្ចវារៈ** បដិច្ច ប្រែថា អាស្រ័យ គឺធម៌អាស្រ័យធម៌ ។

**ឧទាហរណ៍ បុច្ឆាវារៈទី ១**

**(២៦) សិយា កុសលំ ធម្មំ បដិច្ច-កុសលោ ធម្មោ ឧប្បជ្ជេយ្យ ហេតុប្បច្ច-យា ។**

កុសលធម៌ អាស្រ័យកុសលធម៌ កើតឡើង ព្រោះហេតុប្បច្ច័យ គប្បីមាន ឬ? (មើលវិសជ្ជនាទំព័រ ៣៦ នៃបិដកលេខ ៩៤)

**បុច្ឆាវារៈទី ២**

**សិយា កុសលំ ធម្មំ បដិច្ច អកុស-លោ ធម្មោ ឧប្បជ្ជេយ្យ ហេតុប្បច្ចយា ។**

អកុសលធម៌ អាស្រ័យកុសលធម៌ កើតឡើង ព្រោះហេតុប្បច្ច័យ គប្បីមាន ឬ? (ទ្រង់មិនវិសជ្ជនា) ។

**បុច្ឆាវារៈទី ៣**

**សិយា កុសលំ ធម្មំ បដិច្ច អព្យាកតោ ធម្មោ ឧប្បជ្ជេយ្យ ហេតុប្បច្ចយា ។**

អព្យាកតធម៌ អាស្រ័យកុសលធម៌កើតឡើង ព្រោះហេតុប្បច្ច័យ គប្បីមានឬ?

ទំព័រ ៣៦ ទ្រង់បានវិសជ្ជនា នូវបុច្ឆាវារៈទី ៣ អំពីចិត្តសមុដ្ឋានរូប អាស្រ័យកុសលក្ខន្ធទាំងឡាយ ។

ក្នុង **កុសលត្តិកៈ**៤៩ បុច្ឆាវារៈ មានកុសលធម៌ជាមូល ៧ អកុសលធម៌ជាមូល ៧ អព្យាកតធម៌ជាមូល ៧ កុសលធម៌ និង អព្យាកតធម៌ជាមូល ៧ អកុសលធម៌ និង អព្យាកតធម៌ជាមូល ៧ កុសលធម៌ និង អកុសលធម៌ជាមូល ៧ កុសលធម៌ផង អកុសលធម៌ផង អព្យាកតធម៌ផង ជាមូលមាន ៧ដែរ រួមទៅត្រូវជា (៧គុណនឹង៧)= ៤៩ បុច្ឆាវារៈ ។

ក្នុង ៤៩ បុច្ឆាវារៈ ព្រោះហេតុប្បច្ច័យមួយមុខប៉ុណ្ណោះ នៅមានបន្តព្រោះអារម្មណប្បច្ច័យ ៤៩ បុច្ឆាវារៈទៀត ព្រោះអធិបតិប្បច្ច័យក៏ ៤៩ បុច្ឆាវារៈទៀតដែរ គឺព្រះអង្គទ្រង់សំដែងបុច្ឆាវារៈ ៤៩ ស្មើគ្នាក្នុងបច្ច័យ ២៤ ដូច្នេះ បុច្ឆាវារៈត្រូវជា (៤៩គុណនឹង ២៤)= ១១៧៦ បុច្ឆាវារៈ ។

ក្នុងបុច្ឆាវារៈ **១១៧៦**វារៈ ព្រះអង្គទ្រង់វិសជ្ជនាតែ **១៣៩**វារៈប៉ុណ្ណោះគឺ : ហេតុប្បច្ច័យមាន ៩វារៈ អារម្មណប្បច្ច័យមាន ៣វារៈ អធិបតិប្បច្ច័យមាន ៩វារៈ អនន្តរប្បច្ច័យមាន ៣វារៈ សមនន្តរប្បច្ច័យមាន ៣វារៈ សហជាតប្បច្ច័យមាន ៩វារៈ អញ្ញមញ្ញប្បច្ច័យមាន ៣វារៈ និស្សយប្បច្ច័យមាន ៩វារៈ ឧបនិស្សយប្បច្ច័យមាន ៣វារៈ បុរេជាតប្បច្ច័យមាន ៣វារៈ អាសេវនប្បច្ច័យមាន ៣វារៈ កម្មប្បច្ច័យមាន ៩វារៈ វិបាកប្បច្ច័យមាន ១វារៈ អាហារប្បច្ច័យមាន ៩វារៈ ឥន្ទ្រិយប្បច្ច័យមាន ៩វារៈ ឈានប្បច្ច័យមាន ៩វារៈ មគ្គប្បច្ច័យមាន ៩វារៈ សម្បយុត្តប្បច្ច័យមាន ៣វារៈ វិប្បយុត្តប្បច្ច័យមាន ៩វារៈ អត្ថិប្បច្ច័យមាន ៩វារៈ នត្ថិប្បច្ច័យមាន ៣វារៈ វិគតប្បច្ច័យមាន ៣វារៈ អវិគតប្បច្ច័យមាន ៩វារៈ ។

ក្នុងវារៈវិសជ្ជនា ទ្រង់លះចោលការវិសជ្ជនា **បច្ឆាជាតប្បច្ច័យ**ទាំង ៤៩វារៈ ព្រោះបច្ច័យមួយនេះ គ្រាន់តែជាឧបត្ថម្ភកប្បច្ច័យតែប៉ុណ្ណោះ ចំណែកក្នុង **បដិច្ច-វារៈ**នេះ សំដៅយកបច្ច័យនាំឱ្យកើតឡើងគឺជនកប្បច្ច័យ ទើបមានបាលីថា **ឧប្បជ្ជតិ** ក្នុងវារៈនៃវិសជ្ជនាទាំង អស់ ដែលប្រែថា «**កើតឡើង**»ដូចជា **កុសលំ ធម្មំ បដិច្ច អព្យាកតោ ធម្មោ ឧប្បជ្ជតិ កម្ម-ប្បច្ចយា** អព្យាកតធម៌ អាស្រ័យកុសលធម៌ កើតឡើង ព្រោះកម្មប្បច្ច័យ ។

បានដល់ចិត្តសមុដ្ឋានរូប អាស្រ័យកុសលក្ខន្ធកើតឡើង (កម្មប្បច្ច័យក្នុងវារៈនេះ មានតែសហជាតកម្មប្ប-ច្ច័យតែប៉ុណ្ណោះ) ។

**អព្យាកតំ ធម្មំ បដិច្ច អព្យាកតោ ធម្មោ ឧប្បជ្ជតិ កម្មប្បច្ចយា** អព្យាកតធម៌ អាស្រ័យអព្យាកតធម៌ កើតឡើង ព្រោះកម្មប្បច្ច័យ ។

បានដល់កិរិយាខន្ធ អាស្រ័យគ្នានឹងគ្នាកើតឡើងក្តី ចិត្តសមុដ្ឋានរូប អាស្រ័យអព្យាកតចិត្តកើតឡើងក្តី ព្រោះសហជាតកម្មប្បច្ច័យតែម្យ៉ាង ។

វិបាកក្ខន្ធ អាស្រ័យគ្នានឹងគ្នា (ក្នុងចិត្តុប្បាទមួយដួង១) កើតឡើងក្តី កម្មជរូបខណៈបដិសន្ធិអាស្រ័យវិបាកក្ខន្ធកើតឡើងក្តី ព្រោះសហជាតកម្មប្បច្ច័យផង ព្រោះនានក្ខណិកកម្មប្បច្ច័យផង ។

វិបាកក្ខន្ធខណៈបដិសន្ធិ អាស្រ័យហទយវត្ថុកើតឡើងក្តី កម្មជរូប អាស្រ័យកម្មជរូបកើតឡើងក្តី ព្រោះនានក្ខណិកកម្មប្បច្ច័យតែម្យ៉ាង ។

**បដិច្ចវារៈ ខុសគ្នាអំពីបញ្ហាវារៈ គឺ បញ្ហាវារៈមានបច្ចយុប្បន្នធម៌ អាស្រ័យបច្ច័យតែមួយជាន់ប៉ុណ្ណោះ នោះជា ជន-កប្បច្ច័យក្តី ឧបត្ថម្ភកប្បច្ច័យក្តី អនុបាល-ប្បច្ច័យក្តី គឺបានទាំងអស់ ។**

**ចំណែកបដិច្ចវារៈគឺចំពោះធម៌អាស្រ័យនឹងធម៌ ដោយសហជាតធម៌ កើតឡើងព្រោះជនកប្បច្ច័យតែម្យ៉ាង** ។ ឧទាហរណ៍ **កុសលោ ធម្មោ អកុសលស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ។**

កុសលធម៌ ជាបច្ច័យនៃអកុសលធម៌ ដោយអារម្មណប្បច្ច័យ ។

នេះជាបញ្ហាវារៈទី ២ នៃអារម្មណប្បច្ច័យ បានដល់លោកិយកុសលធម៌ជាអារម្មណប្បច្ច័យនៃអកុសលធម៌ ប៉ុន្តែចំពោះបដិច្ចវារៈគឺទាល់តែធម៌ដែលអាស្រ័យនឹងធម៌ជាសហជាតធម៌មួយជាន់សិនឱ្យបានត្រឹមត្រូវ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ទោះជាអារម្មណ៍អ្វីក៏បានដែរ ដូចជា **កុសលំ ធម្មំ បដិច្ច កុសលោ ធម្មោ ឧប្បជ្ជតិ អារម្មណប្បច្ចយា** កុសលធម៌អាស្រ័យកុសលធម៌ទើបកើតឡើងព្រោះអារម្មណប្បច្ច័យ បានដល់កុសលធម៌ និង កុសលធម៌ ជាសហជាតធម៌នឹងគ្នា ។

នៅក្នុងកុសលត្តិកៈ បដិច្ចវារៈ មានវិសជ្ជនា ១៣៩ វារៈ ដូចបានរាប់រួចហើយ មាន ៩វារៈ ក្នុង ១២ បច្ច័យ មាន ៣វារៈក្នុង ១០បច្ច័យ មាន ១វារៈ ក្នុងវិបាកប្បច្ច័យ ក្នុងបច្ច័យ ២៣ មានវិសជ្ជនា ១៣៩វារៈ ដោយព្រះអង្គលះចោល ១០៣៧ បុច្ឆាវារៈ ។

ក្នុងបុច្ឆាវារៈ ១១៧៦ ចំពោះតែ **ឯកមូលកៈ** មូលគឺព្រោះបច្ច័យតែ ១ ប៉ុណ្ណោះ ។

ព្រះអង្គទ្រង់សំដែងបុច្ឆាវារៈដោយ **ទុមូលកៈ**គឺដោយមូល ២ ដូចជា **សិយា កុសលំ ធម្មំ បដិច្ច កុសលោ ធម្មោ ឧប្បជ្ជេយ្យ ហេតុប្បច្ចយា អារម្មណប្បច្ចយា ។** ប្រែថា - កុសលធម៌អាស្រ័យកុសលធម៌ កើតឡើងព្រោះហេតុប្បច្ច័យ (ផង) ព្រោះអារម្មណប្បច្ច័យ (ផង) គប្បីមានឬ?

ព្រះអង្គសំដែងមូលគឺ បច្ច័យ ២នេះអស់ ៤៩វារៈ

រួចទើបព្រះអង្គសំដែងមូលពីរទៀត ដោយរក្សាទុកនូវ **ហេតុមូលកៈ** គឺហេតុប្បច្ចយា ប៉ុន្តែផ្លាស់អារម្មណប្បច្ចយាមកជាអធិបតិប្បច្ចយាវិញ ដូចជា **សិយា កុសលំ ធម្មំ បដិច្ច កុសលោ ធម្មោ ឧប្បជ្ជេយ្យ ហេតុប្បច្ចយា អធិបតិប្បច្ចយា ។** ទ្រង់សំដែងរហូត ៤៩វារៈទៀត ។

ក្នុង **ទុមូលកៈ**នេះ ព្រះអង្គសំដែង ៤៩វារៈ តាមអនុលោមប្បច្ច័យ ២៣លើក ដោយរក្សាទុក **ហេតុមូលកៈ** ហើយផ្លាស់បច្ច័យខាងចុងរហូតដល់ **ហេតុប្បច្ចយា អវិគតប្បច្ចយា ។**

ក្នុងទុមូលកន័យ ព្រះអង្គទ្រង់ត្រាស់សំដែង (៤៩វារៈគុណនឹងបច្ច័យ ២៣ទុកៈ)=១១២៧ បុច្ឆាវារៈ ។

**តិមូលកៈ** ព្រោះបច្ច័យ ៣ ដូចជា **សិយា កុសលំ ធម្មំ បដិច្ច កុសលោ ធម្មោ ឧប្បជ្ជេយ្យ ហេតុប្បច្ចយា អារម្មណប្បច្ចយា អធិបតិប្បច្ចយា ។**

កុសលធម៌ អាស្រ័យកុសលធម៌ កើតឡើង ព្រោះហេតុប្បច្ច័យ អារម្មណប្បច្ច័យ អធិបតិប្បច្ច័យ គប្បីមាន ឬ? (វិសជ្ជនាបានពិតប្រាកដ)

ធម្មតាកុសលធម៌ អាស្រ័យកុសលធម៌ ទើបកើតឡើង ព្រោះបច្ច័យច្រើនយ៉ាងទៀត មិនចំពោះតែមូល ៣ ប៉ុណ្ណោះទេ ។

ព្រះអង្គទ្រង់សំដែងបុច្ឆាវារៈ ៤៩វារៈ ដោយ **តិមូលកៈ**រហូត ២២លើក ដោយរាល់លើកទ្រង់ផ្លាស់បច្ច័យ ១ខាងចុង ដូចជាលើកទី ២ គឺ **ហេតុប្បច្ចយា អារម្មណប្បច្ចយា អនន្តរប្បច្ចយា ។**

លើកទី ២២គឺ **ហេតុប្បច្ចយា អារម្មណប្បច្ចយា អវិគតប្បច្ចយា ។**

ក្នុងតិមូលកៈនេះ មានបុច្ឆាវារៈ (៤៩វារៈគុណនឹងបច្ច័យ ២២តិកៈ)=១០៧៨ វារៈ ។

**ចំណែក ចតុមូលក:** ព្រោះបច្ច័យ ៤

**សិយា កុសលំ ធម្មំ បដិច្ច កុសលោ ធម្មោ ឧប្បជ្ជេយ្យ ហេតុប្បច្ចយា អារម្មណប្បច្ចយា អធិបតិប្បច្ចយា អនន្តរប្បច្ចយា ៗលៗ ហេតុប្បច្ចយា អារម្មណប្បច្ចយា អធិបតិប្បច្ចយា អវិគតប្បច្ចយា ៗ** ទាំងអស់មាន (៤៩វារៈគុណនឹង ២១ចតុកៈ)=១០២៩ វារៈ ។

សូមពុទ្ធបរិស័ទដែលមានបញ្ញា គប្បីជ្រាបអំពីការសំដែងមូលកៈយ៉ាងនេះរហូតដល់ន័យដែលមានមូល ២៤ គឺព្រះអង្គទ្រង់សំដែងក្នុង ៤៩បុច្ឆាវារៈ តែមួយលើក ដោយព្រោះបច្ច័យ ២៤ តែម្តង ។

**បុគ្គលមបុច្ឆាវារៈ តាំងតែអំពីមូល ១ រហូតដល់មូល២៤ មាន១៤៧០០វារៈ នេះចំពោះហេតុបទ គឺហេតុប្បច្ច័យជាមូល ៗ**

ព្រះអង្គទ្រង់សំដែងអារម្មណប្បច្ច័យជាមូលវិញម្តងតាំងតែអំពីទុមូលកៈមក ដូចជា **សិយា កុសលំ ធម្មំ បដិច្ច កុសលោ ធម្មោ ឧប្បជ្ជេយ្យ អារម្មណប្បច្ចយា ហេតុប្បច្ចយា ៗ**

ព្រះអង្គសំដែងរក្សាទុកនូវអារម្មណប្បច្ចយា មានរបៀបដូចហេតុមូលកៈដែរ ដូច្នេះចំពោះបុច្ឆាវារៈក្នុងអារម្មណមូលកៈ ក៏ត្រូវមាន **១៤៧០០** ដែរ ។

មិនចំពោះតែហេតុមូលកៈ និង អារម្មណមូលកៈប៉ុណ្ណឹងទេ គឺព្រះអង្គទ្រង់ត្រាស់សំដែងបច្ច័យដទៃទៀត ឱ្យជាមូលកៈដូចៗគ្នា ដូច្នេះចំពោះ **កុសលត្តិកៈក្នុងអនុលោមន័យ** មាន(១៤៧00គុណនឹងបច្ច័យមូលកៈ២៤)= **៣៥២៨០០វារៈ ៗ**

**✵នៅពេលនឹកគិតត្រូវការ ប្រាថ្នាឱ្យខ្លួនបានសំរេចធម៌ជាន់ខ្ពស់ ពេលនោះគួររលឹកសិក្សា សភាវធម៌ពិត ដែលតំព្វូវប្រាកដ ដែលសភាវធម៌នោះ ពុំមែនជា**

សត្វ បុគ្គល តួខ្លួនយើងឡើយ ការរំលត់សេចក្តីត្រូវការ មិនមានសេចក្តីប្រាថ្នា ដោយសារ កំណត់ដឹងនូវសភាវធម៌តាមសេចក្តីពិតបានគឺ ជាសេចក្តីស្ងប់ សុខដ៏ទូលាយ ជាជោគជ័យដ៏ធំ ៗ

៚

# អដ្ឋកថា ធម្មសង្គណី

≈≈≈≈≈

## ចតុត្ថជ្ឈាន (ចតុក្កន័យ) ១២យ៉ាង

រូបាវចរចតុត្ថជ្ឈាននេះណា រូបាវចរចតុត្ថជ្ឈាននោះ ចំណែកកុសលក្តី ចំណែកកិរិយាក្តី ក្នុងមួយចំណែក១ មាន ១២យ៉ាងគឺ :

**១- ជាបាទនៃធម៌ទាំងពួង**

២- ប្រព្រឹត្តទៅក្នុង **អាកាសកសិណ**

៣- ប្រព្រឹត្តទៅក្នុង **អាលោកកសិណ**

៤- ប្រព្រឹត្តទៅក្នុង **ព្រហ្មវិហារ**

៥- ប្រព្រឹត្តទៅក្នុង **អានាបាន:**

៦- ប្រព្រឹត្តទៅក្នុង **ឥទ្ធិវិធ:**

៧- ប្រព្រឹត្តទៅក្នុង **ទិព្វសោត**

៨- ប្រព្រឹត្តទៅក្នុង **ចេតោបរិយញ្ញាណ**

៩ - ប្រព្រឹត្តទៅក្នុង **យថាកម្មូបគញ្ញាណ**

១០ - ប្រព្រឹត្តទៅក្នុង **ទិព្វចក្ខុ**

១១ - ប្រព្រឹត្តទៅក្នុង **បុព្វេនិវាសញ្ញាណ**

១២ - ប្រព្រឹត្តទៅក្នុង **អនាគតំសញ្ញាណ**

បណ្តាចតុត្ថជ្ឈានទាំងអស់នោះ ចតុត្ថជ្ឈានក្នុងកសិណ ៨ ឈ្មោះថា **ចតុត្ថជ្ឈានជាបាទនៃធម៌ទាំងពួង** ពិតណាស់ ចតុត្ថជ្ឈានក្នុងកសិណ ៨នោះ ជាបាទនៃវិបស្សនាខ្លះ ជាបាទនៃអភិញ្ញាទាំងឡាយខ្លះ ជាបាទនៃនិរោធខ្លះ ជាបាទនៃវដ្តៈខ្លះ ។

**ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងកសិណពីរទៀតគឺ អាកាសកសិណ និងអាលោកកសិណ** ជាបាទនៃវិបស្សនាខ្លះ ជាបាទនៃអភិញ្ញាទាំងឡាយខ្លះ ជាបាទនៃវដ្តៈខ្លះ តែមិនជាបាទនៃនិរោធប៉ុណ្ណោះ ។

**ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងព្រហ្មវិហារ** និង **អានាបានសមាធិ**ជាបាទនៃវិបស្សនា និងជាបាទនៃវដ្តៈប៉ុណ្ណោះ គឺមិនជាបាទនៃអភិញ្ញាទាំងឡាយ និង មិនជាបាទនៃនិរោធឡើយ ។

បណ្តាចតុត្ថជ្ឈានទាំងអស់នោះ ឈានដែលមានកសិណជាអារម្មណ៍ទាំង ១០ ឈ្មោះថា **នវត្តព្វារម្មណ៍** គឺមានអារម្មណ៍ដែលមិនគប្បីពោលដោយអំណាចនៃបរិត្តារម្មណ៍ជាដើម (នវត្តព្វារម្មណ៍=អារម្មណ៍បញ្ញត្តិ) ព្រោះប្រារព្ធកសិណប្បញ្ញត្តិប្រព្រឹត្តទៅ ។

ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុង **ព្រហ្មវិហារ** (ឧបេក្ខាព្រហ្មវិហារ) ក៏ឈ្មោះថា **នវត្តព្វារម្មណ៍** ព្រោះប្រារព្ធសត្វប្បញ្ញត្តិជាអារម្មណ៍ប្រព្រឹត្តទៅ ។

ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុង **អានាបានសមាធិ** ក៏ឈ្មោះថា **នវត្តព្វារម្មណ៍** ព្រោះប្រារព្ធនិមិត្តជាអារម្មណ៍ប្រព្រឹត្តទៅ ។

ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុង **ឥទ្ធិវិធៈ** រមែងមានអារម្មណ៍ជាបរិត្តៈ និង មហគ្គតៈ យ៉ាងណា ? គឺថា

ក្នុងកាលណាព្រះយោគាវចរមានបំណងធ្វើកាយឱ្យអាស្រ័-យចិត្តហើយទៅ (ហោះទៅ) ដោយកាយដែលមើលមិនឃើញ ក៏ញ៉ាំងកាយឱ្យផ្លាស់ប្តូរទៅ ដោយអំណាចនៃចិត្ត ហើយក៏បានតាំងទុក រមែងលើកកាយឡើងក្នុងមហគ្គតៈ ក្នុងកាលនោះ ឥទ្ធិវិធៈនោះ ក៏មានអារម្មណ៍ជា **បរិត្តៈ** ព្រោះមានរូបកាយជាអារម្មណ៍ ដោយធ្វើអត្ថាធិប្បាយថា មានអារម្មណ៍ដែលបានហើយ ដោយការប្រកប ។

ក្នុងកាលណាព្រះយោគាវចរធ្វើចិត្តឱ្យអាស្រ័យកាយ មានសេចក្តីបំណង នឹងទៅដោយកាយដែលមើលឃើញ ក៏ញ៉ាំងចិត្តឱ្យផ្លាស់ប្តូរទៅតាមអំណាចនៃកាយ រមែងតាំងចិត្តដែលមានឈានជាបាទទុក គឺរមែងលើកឡើងតាំងទុកក្នុងរូបកាយ ក្នុងកាលនោះ ឥទ្ធិវិធៈនោះ ក៏មានអារម្មណ៍ជា **មហគ្គតៈ** ព្រោះមានមហគ្គតចិត្តជាអារម្មណ៍ ដោយធ្វើអត្ថាធិប្បាយថា មានអារម្មណ៍ដែលបានដោយការប្រកប ។

ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅដោយ **ទិព្វសោត** មានអារម្មណ៍ជា **បរិត្តៈ** តែម្យ៉ាង ព្រោះប្រារព្ធសំលេងជាអារម្មណ៍ប្រព្រឹត្តទៅ ។

ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅដោយ **ចេតោបរិយញ្ញាណ** មានអារម្មណ៍ជា **បរិត្តៈ** ជា **មហគ្គតៈ** និង ជា **អប្បមាណៈ** យ៉ាងណា ? គឺថា ក្នុងពេលដែលដឹងចិត្តជាកាមាវចររបស់អ្នកដទៃ ចេតោបរិយញ្ញាណនោះ **ក៏មានអារម្មណ៍ជាបរិត្តៈ** ក្នុងពេលដែលដឹងរូបាវចរចិត្ត និង អរូបាវចរចិត្ត របស់អ្នកដទៃ **ក៏មានអារម្មណ៍ជាមហគ្គតៈ** ក្នុងពេលដែលដឹងមគ្គ និង ផល របស់អ្នកដទៃ **ក៏មានអារម្មណ៍ជាអប្បមាណៈ** ក្នុងអធិការនេះ បុថុជ្ជន រមែងមិនដឹងចិត្តរបស់ព្រះសោតាបន្ន ព្រះសោតាបន្នរមែង មិនដឹងចិត្តរបស់ព្រះសកទាគាមី ដោយអាការយ៉ាងនេះ គប្បីជ្រាបរហូតដល់ព្រះអរហន្ត ប៉ុន្តែព្រះអរហន្តរមែងដឹងចិត្តនៃបុគ្គលទាំងអស់ ក៏ព្រះអរិយ បុគ្គលដទៃទៀតដែលខ្ពស់ រមែងដឹងចិត្តនៃបុគ្គល

ដែលទាប គប្បីជ្រាបសេចក្តីផ្សេងគ្នា ដូចពោលមកនេះ ។

ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុង **យថាកម្មូបគ–ញ្ញាណ** រមែងមានអារម្មណ៍ជា **បរិត្តៈ** ក្នុងពេលដែលដឹងកម្មជាកាមាវចរ **មានអារម្មណ៍ជា មហគ្គតៈ** ក្នុងពេលដែលដឹងកម្មជារូបាវចរ និង អរូបាវចរ ។

ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុង **ទិព្វចក្ខុ** មានអារម្មណ៍ជា **បរិត្តៈ** តែម្យ៉ាង ព្រោះមានរូបជាអារម្មណ៍ ។

ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុង **បុព្វេនិវាស–ញ្ញាណ** មានអារម្មណ៍ដែលជា **បរិត្តៈ មហគ្គតៈ អប្បមាណៈ** យ៉ាងណា? គឺថា ក្នុងពេលដែលតាមរលឹកដល់ខន្ធជាកាមាវចរ បុព្វេនិវាសញ្ញាណនោះ **ក៏មានអារម្មណ៍ជា បរិត្តៈ** ក្នុងពេលដែលតាមរលឹកដល់ខន្ធជារូបាវចរ និង អរូបាវចរ **ក៏មានអារម្មណ៍ជា មហគ្គតៈ** ក្នុងពេលតាមរលឹកដល់មគ្គដែលខ្លួនឯង ឬបុគ្គលដទៃចំរើនហើយ និង ផលដែលខ្លួនឯង ឬអ្នកដទៃធ្វើឱ្យជាក់ច្បាស់ហើយក្នុងអតីតៈ **ក៏មានអារម្មណ៍ជាអ–ប្បមាណៈ** សូម្បីបុព្វេនិវាសញ្ញាណ ក្នុងការពិចារណាមគ្គ. ផល ព្រះនិព្វាន ដោយអំណាចការតាមរលឹកដល់ព្រះសម្មា-សម្ពុទ្ធជាម្ចាស់ទ្រង់មានវដ្តៈដាច់ហើយយ៉ាងនេះថា ព្រះពុទ្ធជាម្ចាស់ទាំងឡាយក្នុងអតីតៈ ចំរើនមគ្គហើយ ធ្វើផលឱ្យជាក់ច្បាស់ហើយ បរិនិព្វានហើយ ដោយនិព្វានធាតុ ដូចនេះ ក៏មានអារម្មណ៍ជាអប្បមាណៈ ។

**បុព្វេនិវាសញ្ញាណ** មានអារម្មណ៍ដែលមិនគប្បីពោលគឺ **នវត្តព្វារម្មណ៍** ក្នុងពេលដែលតាមរលឹកគោត្រ និង និមិត្តបបរិកសិណជាដើម ដោយន័យជាអាទិ៍ថា ព្រះដ៏មានព្រះភាគជាម្ចាស់ ព្រះនាមថា **វិបស្សី** បានត្រាស់ដឹងហើយក្នុងអតីតកាល ព្រះនគររបស់ព្រះអង្គមានឈ្មោះថា **ពន្ធុមតី** ព្រះរាជបិតាមានព្រះនាមថា **ព្រះចៅពន្ធុមរាជ** ព្រះរាជមាតាមានព្រះនាមថា **ពន្ធុមតី** ដូចនេះ ។

សូម្បីចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុង **អនាគតំសញ្ញាណ** ក៏ន័យនេះដូចគ្នា ពិតណាស់ អនាគតំសញ្ញាណ **មានអារម្មណ៍ជាបរិត្តៈ** ក្នុងពេលដែលដឹងថា បុគ្គលនេះក្នុងអនាគត នឹងកើតក្នុងកាមាវចរដូចនេះ ។

អនាគតំសញ្ញាណ **មានអារម្មណ៍ជា មហគ្គតៈ** ក្នុងពេលដែលដឹងថា បុគ្គលនេះក្នុងអនាគតកាល នឹងកើតក្នុងរូបាវចរ ឬអរូបាវចរដូចនេះ **មានអារម្មណ៍ជា អប្បមាណៈ** ក្នុងពេលដែលដឹងដល់បុគ្គល អ្នកមានវដ្តៈដាច់ហើយថា ក្នុងអនាគតកាល បុគ្គលនេះនឹងចំរើនមគ្គ នឹងធ្វើផលឱ្យជាក់ច្បាស់ នឹងបរិនិព្វានដោយនិព្វានធាតុដូចនេះ ។

**មានអារម្មណ៍ដែលមិនគប្បីពោល** (នវត្តព្វារម្មណ៍=បញ្ញត្តិ) ក្នុងពេលដែលដឹងឈ្មោះ និង គោត្រ ដោយន័យមានជាអាទិ៍ថា ក្នុងអនាគតកាល ព្រះដ៏មានព្រះភាគជាម្ចាស់ ព្រះនាមថា **ព្រះអរិយមេត្តេយ្យ** នឹងត្រាស់ដឹងឡើង ព្រាហ្មណ៍នាមថា **សុព្រហ្ម** នឹងជាព្រះពុទ្ធបិតា ព្រាហ្មណី នាមថា **ព្រហ្មវត្តី** នឹងជាព្រះមាតាដូចនេះ ។

✵ ចតុត្ថជ្ឈានមានពីរទៀតគឺ **ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងអរូបាវចរ** និង **ចតុត្ថជ្ឈានក្នុងការអស់អាសវៈទាំងឡាយ**(លោកុត្តរចតុត្ថជ្ឈាន).

## <u>អំពីកាលជាអារម្មណ៍</u>

ចតុត្ថជ្ឈាន ៥ខាងដើមក្នុងចតុត្ថជ្ឈាន ១២យ៉ាង នោះមាន **នវត្តព្វារម្មណ៍** គឺអារម្មណ៍ដែលមិនគប្បីពោលថាជាអតីតៈ ថាជាអនាគត ថាជាបច្ចុប្បន្នឡើយ (ព្រោះមានបញ្ញត្តិជាអារម្មណ៍) ។

ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុង **ឥទ្ធិវិធៈ** ជាធម៌មានអារម្មណ៍ជាអតីតៈ ព្រោះសេចក្តីដែលព្រះយោគាវចរបុគ្គលបានញ៉ាំងចិត្តឱ្យផ្លាស់ប្តូរទៅតាមអំណាចនៃកាយ ប្រារព្ធឈានចិត្តក្នុង **អតីតៈជាបាទ** ឱ្យជាអារម្មណ៍

ប្រព្រឹត្តទៅ ។

**ឥទ្ធិវិធ:** មានអារម្មណ៍ជា **អនាគត** គឺដោយព្រះយោគាវចរ អធិដ្ឋានធម៌ដែលជាអនាគត ដូច **ព្រះមហាកស្សបថេរ:** ជាដើម អធិដ្ឋានក្នុងគ្រាបញ្ចុះព្រះបរមសារីរិកធាតុ ក៏មានអារម្មណ៍ជាអនាគត ។

បានឮថា **ព្រះមហាកស្សបថេរ:** កាលបញ្ចុះព្រះបរមសារីរិកធាតុ បានអធិដ្ឋានថា **ក្នុងអនាគត-កាល រហូត ២១៨ឆ្នាំ សូមគ្រឿងក្រអូបទាំងអស់នេះ កុំវិនាសទៅ ផ្កាឈើទាំងឡាយកុំស្វិតស្វួតហួតហែង ប្រទីបទាំងអស់កុំរលត់ឡើយ** ដូចនេះ របស់ទាំងអស់បាននៅដូចអធិដ្ឋាននោះឯង ។

**ព្រះអស្សគុត្តត្ថេរ:** ឃើញភិក្ខុទាំងឡាយដែលឆាន់ភត្តាហារនៅក្នុងរោងភត្ត ទើបអធិដ្ឋានថា សូមឱ្យទឹកក្នុងអាងមានរសជាតិជាទឹកដោះជូរ ក្នុងវេលាមុនភត្តរាល់ថ្ងៃដូចនេះ ទឹកដែលដងមកក្នុងវេលាមុនភត្ត ទើបមានរសជាតិជាទឹកដោះជូរ ក្នុងពេលក្រោយភត្ត ទឹកដោះក៏ប្រក្រតីជាទឹកដូចដើមនោះឯង ។

ក្នុងពេលដែលព្រះយោគាវចរធ្វើកាយឱ្យអាស្រ័យចិត្ត (គឺឱ្យប្រព្រឹត្តទៅរហ័សដូចចិត្ត) ហើយទៅដោយកាយដែលមើលមិនឃើញ ឬថាក្នុងពេលធ្វើបាដិហារ្យផ្សេងៗ **ឥទ្ធិវិធ:** នោះក៏មានអារម្មណ៍ជា **បច្ចុប្បន្ន** ព្រោះប្រារព្ធកាយក្នុងបច្ចុប្បន្នជាអារម្មណ៍ប្រព្រឹត្តទៅ ។

**ចតុត្ថជ្ឈានដែលជាទិព្វសោត** ជាធម៌មានអារម្មណ៍ជា **បច្ចុប្បន្ន** ព្រោះប្រារព្ធសំឡេងដែលមាននៅនោះឯងប្រព្រឹត្តទៅ ។

**ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងចេតោបរិយញ្ញាណ** រមែងជាធម៌មានអារម្មណ៍ជាអតីតៈ និងជាធម៌មានអារម្មណ៍ជាអនាគត ដល់បុគ្គលដែលបានដឹងចិត្តរបស់អ្នកដទៃ ក្នុងអតីតៈរវាង ៧ថ្ងៃ និង ក្នុងអនាគតរវាង

៧ថ្ងៃ បើហួសអំពី ៧ថ្ងៃហើយ ក៏មិនអាចដើម្បីដឹងចិត្ត នោះបាន ព្រោះថា ការដឹងហួសអំពី ៧ថ្ងៃទៅទៀតនោះ ជាវិស័យរបស់ **អតីតំ សញ្ញាណ** និង **អនាគតំ-សញ្ញាណ** ប៉ុន្តែដែល **ចេតោបរិយញ្ញាណ** បាន ដឹងចិត្តបច្ចុប្បន្នរបស់អ្នកដទៃ ក៏ជាធម៌មានអារម្មណ៍ជា **បច្ចុប្បន្ន** បានដល់**សន្តតិ បច្ចុប្បន្ន** និង **អទ្ធាបច្ចុប្បន្ន** ។

**បុព្វេនិវាសានុស្សតិញ្ញាណ** មាននវត្តព្វា-រម្មណ៍ និង បរមត្ថធម៌ **ជាអតីតារម្មណ៍** តែប៉ុណ្ណោះ ។

**យថាកម្មូបគញ្ញាណ** មាន **អតីតារម្មណ៍** (ដឹងកម្មជាលោកិយកុសលនិងកម្មជាអកុសលជាអតីតៈ) ។

**ទិព្វចក្ខុ** មានអារម្មណ៍ជា **បច្ចុប្បន្ន** ប៉ុណ្ណោះ ព្រោះពណ៌(វណ្ណៈ) ដែលជាអារម្មណ៍មាននៅ ។

**អនាគតំសញ្ញាណ** មានអារម្មណ៍ជា **អនា-គត**តែប៉ុណ្ណោះ និងមាននវត្តព្វារម្មណ៍ (គឺបញ្ញត្តិដែល អាស្រ័យ ខន្ធជាអនាគត ជាអារម្មណ៍) «សង្ខេបចាក អដ្ឋកថា» ។

**✵អភិញ្ញាទាំងឡាយគឺ ចិត្ត និង ចេតសិក បានដឹងនូវអារម្មណ៍ តាមពិត បុគ្គលអ្នកដឹងយ៉ាងនេះ ឬយ៉ាងនោះ គ្រាន់តែការសន្មតិប៉ុណ្ណោះ ការដឹងនូវអារម្មណ៍ អ្វីៗទាំងអស់ សូម្បីដឹងដោយ សព្វញ្ញុត-ញ្ញាណ ក៏មានត្រឹមតែចិត្ត និង ចេតសិក តែប៉ុណ្ណោះឯង សត្វ បុគ្គល នៅក្នុងរូប កាយនេះ ជាអ្នកដឹងអ្វីៗនោះ គឺមិនមាន ដោយពិត ៗ**

៚✧✧✧៙
✧✧
✧

# អារម្មណ៍ពិស្តារ

≈≈✿≈≈

✵ អ្វី១ដែលចិត្តបានដឹង គឺជាអារម្មណ៍របស់ចិត្ត និង ចេតសិក ។

អារម្មណ៍ណា១ដែលចិត្ត និង ចេតសិកបានដឹង អារ-ម្មណ៍នោះ១ទាំងអស់ ពុំមែនមនុស្ស សត្វ បុគ្គល យើង គេឡើយ ។

## អារម្មណ៍ពិស្តារ ២១យ៉ាង

**១–កាមារម្មណ៍** - បានដល់កាមចិត្ត ៥៤ ចេត-សិក ៥២ រូប ២៨ ចែកបានជា ៦ អារម្មណ៍ ។

**២–មហគ្គតារម្មណ៍** - បានដល់មហគ្គតចិត្ត ២៧ ចេតសិក ៣៥ គឺជាធម្មារម្មណ៍ ។

**៣–និព្វានារម្មណ៍** - បានដល់ព្រះនិព្វាន ជាធម្មារម្មណ៍ ។

**៤–នាមបរមត្ថជាអារម្មណ៍** - បានដល់ចិត្ត ចេតសិក និង និព្វាន ទាំងអស់ជាធម្មារម្មណ៍ ។

**៥– រូបបរមត្ថជាអារម្មណ៍** - បានដល់រូប ២៨ ចែកជាអារម្មណ៍បាន ៦ អារម្មណ៍ ។

**៦–បច្ចុប្បន្នារម្មណ៍** - បានដល់ចិត្ត ចេតសិក រូប ដែលកំពុងកើតប្រាកដមាននៅ ចែកបានជា ៦ អារម្មណ៍ ។

**៧–អតីតារម្មណ៍** - បានដល់ចិត្ត ចេតសិក រូប ដែលកន្លងទៅហើយ មាន ៦ អារម្មណ៍ ។

**៨–អនាគតារម្មណ៍** - បានដល់ចិត្ត ចេតសិក រូប ដែលនឹងកើតឡើង ឬ ដែលមិនទាន់មកដល់ មាន ៦ អារម្មណ៍ ។

**៩–កាលវិមុត្តារម្មណ៍** - បានដល់ព្រះនិព្វាន និង បញ្ញត្តិ គឺជាធម្មារម្មណ៍ ។

**១០–បញ្ញត្តិជាអារម្មណ៍**-បានដល់អត្ថបញ្ញត្តិ និង សទ្ទបញ្ញត្តិ គឺជា ធម្មារម្មណ៍ ។

**១១–បរមត្ថជាអារម្មណ៏** - បានដល់ ចិត្ត ចេតសិក រូប ព្រះនិព្វាន ចែកបានជា ៦ អារម្មណ៍ ។

**១២–អជ្ឈត្តារម្មណ៏** - បានដល់ចិត្ត ចេតសិក រូប ដែលកើតក្នុងខ្លួន ចែកជា ៦ អារម្មណ៍ ។

**១៣–ពហិទ្ធារម្មណ៏** - បានដល់ចិត្ត ចេតសិក រូប ដែលកើតក្នុងខ្លួនអ្នកដទៃ ព្រមទាំងបញ្ញត្តិអាស្រ័យ សភាវធម៌ និង និព្វាន ចែកជា ៦ អារម្មណ៍ ។

**១៤–អជ្ឈត្តពហិទ្ធារម្មណ៏** - បានដល់ចិត្ត ចេតសិក រូប ដែលកើតក្នុងខ្លួនឯងបានផង ក្នុងអ្នកដទៃបាន ផង ចែកជា ៦ អារម្មណ៍ ។

**១៥–បញ្ចារម្មណ៏** - បានដល់ គោចររូប ៧ មាន ៥ អារម្មណ៍ គឺ រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ និង ផោដ្ឋព្វារម្មណ៍ ។

**១៦–រូបារម្មណ៏** - បានដល់ ពណ៌ផ្សេងៗ ។

**១៧–សទ្ទារម្មណ៏** - បានដល់សំឡេងផ្សេងៗ ។

**១៨–គន្ធារម្មណ៏** - បានដល់ ក្លិនផ្សេងៗ ។

**១៩–រសារម្មណ៏** - បានដល់ រស ផ្សេងៗ ។

**២០–ផោដ្ឋព្វារម្មណ៏** - បានដល់ ក្តៅ ត្រជាក់ រឹង ទន់ តឹង ព្ធរ ។

**២១–ធម្មារម្មណ៏** - បានដល់ចិត្ត ៨៩ ចេតសិក ៥២ បសាទរូប ៥ សុខុមរូប ១៦ និព្វាន និង បញ្ញត្តិ ។

# ចិត្តដឹងអារម្មណ៍

✵ ធម្មជាតិដែលជាតួដឹងនូវអារម្មណ៍ ពុំមែនមនុស្ស សត្វ បុគ្គល តួខ្លួនឡើយៗ គ្រប់គ្រាគ្រប់ពេលវេលានៃការដឹង នោះជាដឹងអារម្មណ៍ប្រភេទណាក៏ដោយ គឺមានត្រឹមតែចិត្ត និងចេតសិកតែប៉ុណ្ណោះៗ

ចិត្តដឹងអារម្មណ៍ ២១យ៉ាង

**១-ចិត្តដឹងកាមារម្មណ៍មាន៥៦ដួងគឺ:**

- **ឯកន្ត:** (ចំណែកតែម្យ៉ាងគឺ ដឹងតែកាមារម្មណ៍) មាន ២៥ដួង បានដល់កាមាវចរវិបាក ២៣ កិរិយាមនោធាតុ ១ និង ហសិតុប្បាទចិត្ត ១ ។

- **អនេកន្ត:** (ចំណែកមិនតែម្យ៉ាង គឺអាចដឹងក្រៅអំពីកាមារម្មណ៍ទៀតក៏បានដែរ) មាន ៣១ដួង បានដល់ អហេតុកកិរិយាមនោវិញ្ញាណធាតុប្រកបដោយឧបេក្ខាវេទនា ១ កាមជវន ២៨ (វៀរហសិតុប្បាទចិត្ត ១) និង អភិញ្ញា ២ ។

**២-ចិត្តដឹងមហគ្គតារម្មណ៍មាន ៣៧ដួងគឺ:**

- **ឯកន្ត:** (ដឹងតែមហគ្គតារម្មណ៍) មាន ៦ដួង បានដល់អរូបទីពីរ ៣ដួង និង អរូបទីបួន ៣ដួង ។

- **អនេកន្ត:** (ដឹងផ្សេងក្រៅអំពីមហគ្គតារម្មណ៍ទៀតក៏បាន) មាន ៣១ដួង ដូចអនេកន្ត: ដែលដឹងនូវកាមារម្មណ៍ដែរ ។

**៣-ចិត្តដឹងនិព្វានារម្មណ៍មាន ១៩ដួងគឺ:**

- **ឯកន្ត:** (ដឹងតែព្រះនិព្វានប៉ុណ្ណោះ) មាន ៨ដួង បានដល់លោកុត្តរចិត្ត មគ្គ ៤ ផល ៤ ។

- **អនេកន្ត:** (មិនមែនដឹងតែព្រះនិព្វានប៉ុណ្ណោះទេ) មាន ១១ដួង បានដល់មនោទ្វារាវជ្ជនៈ ១ដួង មហាកុសលញាណសម្បយុត្តចិត្ត ៤ដួង មហាកិរិយាញាណសម្បយុត្តចិត្ត ៤ដួង និង អភិញ្ញាជវន ២ដួង ។

៤-ចិត្តដឹងនាមបរមត្ថជាអារម្មណ៍មាន៥៧ គឺ :

**-ឯកន្ត:** (ចំណែក ១) មាន ១៤ដួង បានដល់អរូបទីពីរ ៣ដួង ដឹងអរូបទីមួយជាអារម្មណ៍តែម្យ៉ាង អរូបទីបួន ៣ដួង ដឹងអរូបទីបីជាអារម្មណ៍តែម្យ៉ាង ចំណែកលោកុត្តរចិត្ត ៨ដួង ដឹងព្រះនិព្វានតែម្យ៉ាង ។

**-អនេកន្ត:** (ដឹងក្រៅអំពីនាមក៏បានទៀត) មាន ៤៣ដួង បានដល់កាមាវចរចិត្តដែលអាចកើតបានក្នុងមនោទ្វារ ៤១ដួង និង អភិញ្ញាជវន ២ដួង ។

៥-ចិត្តដឹងរូបបរមត្ថជាអារម្មណ៍មាន៥៦ដួង គឺ :

**-ឯកន្ត:** (ដឹងរូបតែម្យ៉ាង) មាន ១៣ដួង បានដល់ ទ្វិបញ្ចវិញ្ញាណ ១០ដួង និង មនោធាតុ ៣ដួង ។

**-អនេកន្ត:** (ដឹងក្រៅអំពីរូបក៏បាន) មាន ៤៣ ដួង បានដល់កាមាវចរចិត្ត ៤១ដួង (វៀរទ្វិបញ្ចវិញ្ញាណ១០ និង មនោធាតុ ៣) និង អភិញ្ញាជវន ២ដួង ។

៦-ចិត្តដឹងអារម្មណ៍ជាបច្ចុប្បន្នមាន៥៦ដួង គឺ :

**-ឯកន្ត:** (ដឹងតែបច្ចុប្បន្នារម្មណ៍) មាន ១៣ដួង បានដល់ទ្វិបញ្ចវិញ្ញាណ ១០ដួង និង មនោធាតុ ៣ដួង ។

**-អនេកន្ត:** (ដឹងក្រៅអំពីអារម្មណ៍បច្ចុប្បន្នក៏បាន) មាន ៤៣ដួង បានដល់ អហេតុកវិបាកមនោវិញ្ញាណធាតុ ៣ដួង មហាវិបាកចិត្ត ៨ដួង ហសិតុប្បាទចិត្ត ១ដួង (ត្រូវជា ១២ដួង) ចិត្ត ១២ដួងនេះ ដឹងអារម្មណ៍បានគ្រប់កាលទាំង ៣ គឺ អតីត: អនាគត និង បច្ចុប្បន្ន ។

ចិត្ត ៣១ដួងទៀតគឺ អាចដឹងអារម្មណ៍គ្រប់កាលទាំង ៣ក៏បាន ដឹងកាលវិមុត្តារម្មណ៍ក៏បាន ចិត្ត ៣១ដួងនេះ ជាអនេកន្ត: ក្នុងការដឹងកាមារម្មណ៍ និង ជាអនេកន្ត: ក្នុងការដឹងមហគ្គតារម្មណ៍ សូមមេត្តាត្រួតពិនិត្យមើលអំពីខាងដើមផងចុះ ។

**៧-ចិត្តដឹងអតីតារម្មណ៍មាន ៤៩ដួងគឺ:**

**-ឯកន្ត:** (ដឹងតែអារម្មណ៍អតីត:) មាន ៦ដួង បានដល់ឯកន្ត:នៃចិត្ត ដែលដឹងមហគ្គតារម្មណ៍ហ្នឹងឯង ។

**-អនេកន្ត:** (ដឹងក្រៅអំពីអតីតារម្មណ៍ក៏បាន) មាន ៤៣ដួង បានដល់ កាមាវចរចិត្ត ៤១ដួង និង អភិញ្ញាជវន ២ដួង ដែលជាអនេកន្ត:នៃចិត្ត ដែលដឹងនូវរូបបរមត្ថជាអារម្មណ៍ ។

**៨-ចិត្តដឹងអនាគតារម្មណ៍មាន៤៣ដួង ដោយមិនមានឯកន្ត:ចិត្ត ៤៣ដួង** ជាអនេកន្ត:នៃការដឹងរូបបរមត្ថផង ជាអនេកន្ត:នៃការដឹងអតីតារម្មណ៍ផង និង ជាអនេកន្ត:នៃការដឹងអនាគតារម្មណ៍ផង បានដល់ កាមាវចរចិត្ត ៤១ដួង (វៀរទ្វិបញ្ចវិញ្ញាណ ១០ និង មនោធាតុ ៣ដួង) និង អភិញ្ញាជវន ២ដួង ។

**៩-ចិត្តដឹងកាលវិមុត្តារម្មណ៍មាន៦០ដួងគឺ:**

**-ឯកន្ត:** (ដឹងក្រៅកាលទាំង ៣តែម្យ៉ាង) មាន ២៩ដួង បានដល់រូបាវចរចិត្ត ១៥ដួង អរូបទីមួយ ៣ដួង និង អរូបទីបី ៣ដួង (ត្រូវជា ២១ដួង) ចិត្ត ២១ដួងនេះ មានបញ្ញត្តិជាអារម្មណ៍តែម្យ៉ាង ។

ចំណែកលោកុត្តរចិត្ត ៨ដួង មានតែព្រះនិព្វានជាអារម្មណ៍ ។

**-អនេកន្ត:** (ដឹងក្រៅកាលក៏បាន ដឹងអារម្មណ៍ក្នុងកាលក៏បាន) បានដល់ចិត្ត ៣១ដួង ដែលជាអនេកន្ត:នៃចិត្តក្នុងការដឹងកាមារម្មណ៍ និង ជាអនេកន្ត:នៃការដឹងមហគ្គតារម្មណ៍ ។

១០-ចិត្តដឹងបញ្ញត្តិជាអារម្មណ៍មាន៥២ដួង គឺ :

**-ឯកន្ត:** (ដឹងបញ្ញត្តិតែម្យ៉ាង) មាន ២១ដួង ចូរមើលក្នុងឯកន្ត:នៃកាលវិមុត្តារម្មណ៍ ។

**-អនេកន្ត:** (ដឹងក្រៅអំពីបញ្ញត្តិក៏បាន) មាន ៣១ដួង ដែលជាអនេកន្ត:ក្នុងការដឹងកាមារម្មណ៍ ជាអនេកន្ត: ក្នុងការដឹងមហគ្គតារម្មណ៍ និង ជាអនេកន្ត: ក្នុងការដឹងកាលវិមុត្តារម្មណ៍ ។

**១១-ចិត្តដឹងបរមត្ថជាអារម្មណ៍មាន៧០ដួង គឺ :**

**–ឯកន្ត:** (ដឹងតែបរមត្ថប៉ុណ្ណោះ) មាន ៣៩ដួង បានដល់ :

.២៥ដួងជាឯកន្ត: ក្នុងការដឹងកាមារម្មណ៍ ។

.៦ដួងជាឯកន្ត: ក្នុងការដឹងមហគ្គតារម្មណ៍ ។

.៨ដួងជាឯកន្ត: ក្នុងការដឹងនិព្វានារម្មណ៍ ។

**–អនេកន្ត:** (ដឹងបរមត្ថក៏បាន ដឹងបញ្ញត្តិជាអារម្មណ៍ក៏បាន) មាន ៣១ដួង ដែលជាអនេកន្ត: ក្នុងការដឹងកាមារម្មណ៍ផង ដឹងមហគ្គតារម្មណ៍ផង ដឹងកាលវិមុត្តារម្មណ៍ផង និង ដឹងបញ្ញត្តិជាអារម្មណ៍ផង ។

## ១២–ចិត្តដឹងអជ្ឈត្តារម្មណ៍មាន៦២ដួងគឺ:

**–ឯកន្ត:** (ដឹងតែអជ្ឈត្តារម្មណ៍) មាន ៦ដួង បានដល់ឯកន្ត:នៃចិត្ត ដែលដឹងមហគ្គតារម្មណ៍ ។

មហគ្គតារម្មណ៍ ត្រូវជាអតីតារម្មណ៍ផង ជាខាងក្នុងផង ទើបអាចជាអារម្មណ៍នៃអរូបទីពីរ និងអរូបទីបួនបាន។

**–អនេកន្ត:** (ដឹងក្រៅអំពីអជ្ឈត្តារម្មណ៍ក៏បាន) មាន ៥៦ដួង បានដល់កាមាវចរចិត្ត ៥៤ និង អភិញ្ញាជវន ២ដួង ។

## ១៣–ចិត្តដឹងពហិទ្ធារម្មណ៍មាន៨២ដួងគឺ:

**–ឯកន្ត:** (ដឹងតែពហិទ្ធារម្មណ៍) មាន ២៦ដួង បានដល់ :

.រូបាវចរចិត្ត១៥ មានតែបញ្ញត្តិអាស្រ័យសភាវធម៌មិនជាអារម្មណ៍ ហើយនិងអរូបទីមួយមានចិត្ត ៣ដួងក៏ដូចគ្នា ប៉ុន្តែអរូបទីបី ៣ដួង ពិតមែនតែមានបញ្ញត្តិជាអារម្មណ៍ តែជា នត្ថិភាវបញ្ញត្តិ គឺមានបញ្ញត្តិដែលមិនអាស្រ័យនឹងសភាវធម៌មិនជាអារម្មណ៍ ទើបអរូបទីបីនេះមិនមាននូវពហិទ្ធារម្មណ៍ឡើយ ។

.លោកុត្តរចិត្ត ៨ដួង មានតែព្រះនិព្វានជាអារម្មណ៍ ។

**–អនេកន្ត:** (ដឹងមិនមែនតែពហិទ្ធារម្មណ៍) មាន ៥៦ដួង ដែលជាអនេកន្ត: នៃការដឹងអជ្ឈត្តារម្មណ៍ ។

**១៤-ចិត្តដឹងអារម្មណ៍បានទាំងក្នុងទាំងក្រៅ មាន ៥៦ដួង ដោយជាអនេកន្តៈតែម្យ៉ាងៗ**

**១៥-ចិត្តដឹងបញ្ញាអារម្មណ៍មាន៤៦ដួងគឺ:**

**-ឯកន្តៈ**(ដឹងតែបញ្ញារម្មណ៍) មានមនោធាតុ ៣ ដួង ។

**-អនេកន្តៈ** (ដឹងធម្មារម្មណ៍ផងក៏បាន) មាន ៤៣ដួង ដែលជាអនេកន្តៈ ក្នុងការដឹងរូបបរមត្ថ ឬជាអនេ-កន្តៈ ក្នុងការដឹងអតីតារម្មណ៍ជាដើម ។

១៦-ចិត្តដឹងវណ្ណរូបជាអារម្មណ៍មាន៤៨ ដួងគឺ :

**-ឯកន្តៈ** (ដឹងតែរូបារម្មណ៍) មានចក្ខុវិញ្ញាណ ២ដួង ។

**-អនេកន្តៈ** (អាចដឹងក្រៅអំពីវណ្ណរូប) មាន ៤៦ដួង បានដល់ កាមាវចរចិត្ត ៤៤ (វៀរទ្វិបញ្ចវិញ្ញាណ ១០) និង អភិញ្ញាជវន ២ដួង ។

**១៧-ចិត្តដឹងសទ្ទារម្មណ៍មាន ៤៨ដួងគឺ :**

**-ឯកន្តៈ** បានដល់សោតវិញ្ញាណ ២ដួង ដឹងតែសំឡេងប៉ុណ្ណោះ ។

**-អនេកន្តៈ** បានដល់ចិត្ត ៤៦ដួង ដែលជាអនេ-កន្តៈ នៃការដឹងវណ្ណរូប (៥៤-១០) + ២ ។

**១៨-ចិត្តដឹងគន្ធារម្មណ៍មាន ៤៨ដួងគឺ :**

**-ឯកន្តៈ** បានដល់ឃានវិញ្ញាណ ២ដួង ដឹងតែក្លិនប៉ុណ្ណោះ ។

**-អនេកន្តៈ** បានដល់ចិត្ត ៤៦ដួង ជាអនេកន្តៈ ក្នុងការដឹងវណ្ណរូបផង ដឹងសទ្ទរូបផង ។

**១៩-ចិត្តដឹងរសារម្មណ៍មាន ៤៨ដួងគឺ:**

**-ឯកន្តៈ** បានដល់ជិវ្ហាវិញ្ញាណ ២ដួង ដែលមានតែរសជាអារម្មណ៍ ។

**-អនេកន្តៈ** បានដល់ចិត្ត ៤៦ដួង ជាអនេកន្តៈ ក្នុងការដឹងវណ្ណរូប សទ្ទរូប គន្ធរូប ។

**២០-ចិត្តដឹងផោដ្ឋព្វារម្មណ៍មាន ៤៨ដួង**

ដែរគឺ :

**-ឯកន្ត:** បានដល់ចិត្ត ២ដួង ដែលដឹងផោដ្ឋព្វៈតែម្យ៉ាង ពោលគឺ កាយវិញ្ញាណ ២ដួងហ្នឹងឯង ។

**-អនេកន្ត:** បានដល់ចិត្ត ៤៦ដួង ដែលជាអនេកន្តៈ ក្នុងការដឹងវណ្ណរូបជាដើម ។

**២១-ចិត្តដឹងធម្មារម្មណ៍មាន៧៨ដួង គឺ :**

**-ឯកន្ត:** (ដឹងតែធម្មារម្មណ៍) មាន ៣៥ដួង បានដល់ :

.ចិត្ត ២១ មានតែធម្មារម្មណ៍ គឺបញ្ញត្តិ ។

.ចិត្ត ៦ មានតែធម្មារម្មណ៍ គឺមហគ្គតៈ ។

.ចិត្ត ៨ មានតែធម្មារម្មណ៍ គឺនិព្វាន ។

**-អនេកន្ត:** (មិនមែនដឹងតែធម្មារម្មណ៍) មាន ៤៣ដួង បានដល់កាមាវចរចិត្ត ៤១ដួង ដែលអាចកើតក្នុងមនោទ្វារបាន និង អភិញ្ញាជវន ២ដួង ។

# ចេតសិកដឹងអារម្មណ៍

✵**ចេតសិក ៥០** (វៀរអប្បមញ្ញា២) **ជាអនេកន្ត: ក្នុងការដឹងអារម្មណ៍ ១៣យ៉ាង គឺ :**

**១-** កាមារម្មណ៍

**២-** នាមបរមត្ថជាអារម្មណ៍

**៣-** រូបបរមត្ថជាអារម្មណ៍

**៤-** បច្ចុប្បន្នារម្មណ៍

**៥-** អនាគតារម្មណ៍

**៦-** កាលវិមុត្តារម្មណ៍

**៧-** បញ្ញារម្មណ៍

**៨-** រូបារម្មណ៍

**៩-** សទ្ទារម្មណ៍

**១០–** គន្ធារម្មណ៍

**១១–** រសារម្មណ៍

**១២–** ផោដ្ឋព្វារម្មណ៍

**១៣–** ធម្មារម្មណ៍ ។

✵**ចេតសិក ៤៧** (វៀរវិរតិ ៣ និងអប្ប-មញ្ញា ២) **ជាអនេកន្ត:ក្នុងការដឹងអារម្មណ៍ ៤យ៉ាងគឺ :**

**១–** មហគ្គតារម្មណ៍

**២–** អតីតារម្មណ៍

**៣–** បញ្ញត្តារម្មណ៍

**៤–** បរមត្ថារម្មណ៍

✵**ចេតសិក ៤៩** (វៀរឥស្សា និង អប្បមញ្ញា ២) **ជាអនេកន្ត: ក្នុងការដឹងអារម្មណ៍ ៣ យ៉ាង គឺ :**

**១–** អជ្ឈត្តារម្មណ៍

**២–** ពហិទ្ធារម្មណ៍

**៣–** អជ្ឈត្តពហិទ្ធារម្មណ៍ ។

✵**ចេតសិក ៣៦** (វៀរអកុសលចេតសិក ១៤ និង អប្បមញ្ញា ២) **ជាអនេកន្ត: ក្នុងការដឹងនិព្វានារម្មណ៍ ។**

✵**ចេតសិកជាឯកន្ត:ក្នុងការដឹងអារ–ម្មណ៍មាន ៦ចេតសិក គឺ :**

**–អប្បមញ្ញា ២** មានកាលវិមុត្តារម្មណ៍ ជាឯកន្ត: គឺបញ្ញត្តិ ដែលជាពហិទ្ធារម្មណ៍ ។

**–វិរតិ៣** មានបរមត្ថារម្មណ៍ជាឯកន្ត: គឺមិនមានអារម្មណ៍បញ្ញត្តិអ្វីណាមួយឡើយ ។

**–ឥស្សា** មានពហិទ្ធារម្មណ៍តែម្យ៉ាងជាឯកន្ត: គឺមិនមានអារម្មណ៍ជាខាងក្នុងឡើយ ។

**វិរតិចេតសិក៣**

**–លោកិយវិរតិ៣** មានតែអារម្មណ៍ជា

កាមាវចរ ដែលកាមាវចរនោះជាបច្ចុប្បន្នារម្មណ៍ និងជាអនាគតារម្មណ៍ ។

**-លោកុត្តរវិរតិ៣** មានតែព្រះនិព្វានជាអារម្មណ៍ ។

**អប្បមញ្ញា ២**

**-ករុណា**មានតែទុក្ខរបស់សត្វប្បញ្ញត្តិជាអារម្មណ៍។

**-មុទិតា**មានតែសុខរបស់សត្វប្បញ្ញត្តិជាអារម្មណ៍។

**-អកុសលចេតសិក១៤** មានអារម្មណ៍ជាលោកិយបានទាំងអស់ ព្រមទាំងបញ្ញត្តិ(វៀរតែលោកុត្តរ) ។

**-អញ្ញសមានាចេតសិក ១៣ សោភណចេតសិក ២០** (វៀរវិរតិ ៣ អប្បមញ្ញា ២) **ចេតសិកទាំង ៣៣នេះ** មានអារម្មណ៍បានទូទៅទាំងអស់ ។

αααααα

# ចិត្ត ៩១ដួង ចែកជា ៨ពួក

≈≈≈≈≈

**១-ចិត្ត ១៣ដួង មានបច្ចុប្បន្នារម្មណ៍ គឺ :**

-ទ្វិបញ្ចវិញ្ញាណ ១០ដួង

-មនោធាតុ ៣ ដួង ។

**២-ចិត្ត ១២ដួង មានអារម្មណ៍ក្នុងកាលទាំងបី គឺ :**

-មហាវិបាកចិត្ត ៨ដួង

-អហេតុកវិបាកមនោវិញ្ញាណធាតុ ៣ដួង

-ហសិតុប្បាទចិត្ត ១ដួង ។

**✵ចិត្តទាំងពីរពួកនេះ មានតែកាមាវចរជាអារម្មណ៍ប៉ុណ្ណោះ រួមនៅក្នុងជា ២៥ដួង ។**

**៣-ចិត្ត ២០ដួង មានឥតមានបច្ច័យផង មានមហគ្គតៈផង និង មានបញ្ញត្តិផងជាអារម្មណ៍គឺ :**

- អកុសលចិត្ត ១២ដួង

-មហាកុសល និង មហាកិរិយាញាណវិប្បយុត្តចិត្ត ៨ដួង ។

**៤-ចិត្ត៤ដួង មានអារម្មណ៍ទាំងអស់ វៀរតែអរហត្តមគ្គ និងអរហត្តផលប៉ុណ្ណោះ គឺ :**

-មហាកុសលញាណសម្បយុត្តចិត្ត ៤ដួង

-កុសលអភិញ្ញា ១ដួង ។

**៥-ចិត្ត២១ដួងមានបញ្ញត្តិជាអារម្មណ៍តែម្យ៉ាងគឺ :**

-រូបាវចរចិត្ត ១៥ដួង

-អរូបទីមួយ ៣ដួង

-អរូបទីបី ៣ដួង ។

**៦-ចិត្ត ៦ដួង មានតែមហគ្គតៈជាអារម្មណ៍តែម្យ៉ាងគឺ :**

-អរូបទីពីរ ៣ដួង

-អរូបទី ៤ ៣ដួង ។

**៧-ចិត្ត៨ដួង មាននិព្វានជាអារម្មណ៍តែម្យ៉ាងគឺ :**

-មគ្គចិត្តជាលោកុត្តរ ៤ដួង

-ផលចិត្តជាលោកុត្តរ ៤ដួង ។

**៨-ចិត្ត ៦ដួង មានអារម្មណ៍ទូទៅទាំងអស់ មិនមានវៀរអារម្មណ៍ណាឋគឺ:**

-មនោទ្វារាវជ្ជនចិត្ត ១ដួង

-មហាកិរិយាញាណសម្បយុត្តចិត្ត ៤ដួង

- កិរិយាអភិញ្ញា ១ដួង ។

# ចិត្ត ៨៩ ចែកជា ៧ពួក

≈≈≈≈≈

**១-ចិត្ត ២៨ដួង ដឹងអារម្មណ៍មួយៗ រៀងៗខ្លួន គឺ :**

-ទ្វិបញ្ចវិញ្ញាណ ១០ដួង មានរូបបរមត្ថជាអារម្មណ៍រៀងៗខ្លួន តាមបញ្ចទ្វារ មានចក្ខុទ្វារ ឬសោតទ្វារជាដើម ។

-អរូបទីមួយ៣ដួង មានកសិណុគ្ឃាដិមាកាសប្បញ្ញត្តិ ជាអារម្មណ៍ (អាកាសបញ្ញត្តិដែលបើកនូវកសិណ) ។

-អរូបទីបី ៣ដួង មាននត្ថិភាវប្បញ្ញត្តិជាអារម្មណ៍ (បញ្ញត្តិថាអ្វីតិចតួចមិនមាន គឺបញ្ញត្តិមិនអាស្រ័យសភាវធម៌) ។

-អរូបទីពីរដែលជាកុសល ១ដួង ដែលជាវិបាក ១ដួង មាននូវអរូបទីមួយដែលជាកុសលជាអារម្មណ៍ ។

-អរូបទីបួនដែលជាកុសល ១ដួង ដែលជាវិបាក ១ដួង មាននូវអរូបទីបីដែលជាអារម្មណ៍ ។

-លោកុត្តរចិត្ត ៨ដួង មាននិព្វានជាកុសល ជាអារម្មណ៍ ។

**២-ចិត្ត២ដួងមានអារម្មណ៍ពីរយ៉ាង ដែលអាចដឹងបានគឺ :**

-អរូបទីពីរជាកិរិយាចិត្ត ១ដួង ដឹងអរូបទីមួយជាកុសលក៏បាន ជាកិរិយាក៏បាន ។

-អរូបទីបួនជាកិរិយាចិត្ត ១ដួង ដឹងអរូបទីបីជាកុសលក៏បាន ជាកិរិយាក៏បាន ។

**៣-ចិត្ត ៣ដួង គឺមនោធាតុ ៣ ដឹងអារម្មណ៍បាន ៥យ៉ាង មានរូបារម្មណ៍ សទ្ទារម្មណ៍ជាដើម ។**

**៤-ចិត្ត៤១ដួងដឹងអារម្មណ៍បាន ៦ យ៉ាង គឺរូបារម្មណ៍រហូតដល់ធម្មារម្មណ៍ចិត្ត ៤១ ដួង គឺ :**

-អហេតុកកិរិយាមនោវិញ្ញាណធាតុប្រកបដោយឧបេក្ខាវេទនា ១ដួង ( មនោទ្វារាវជ្ជនៈ ) ។

-កាមាវចរជវន ២៩ដួង ។

-ចិត្តធ្វើតទាលម្ពណកិច្ចមាន ១១ដួង គឺមហាវិបាក ៨ដួង និង អហេតុកវិបាកមនោវិញ្ញាណធាតុ ៣ដួង ។

✵ ចិត្ត ៤១ដួងនេះ រាប់ម្យ៉ាងទៀត បានដល់កាមាវចរចិត្ត ៤១( វៀរទ្វិបញ្ចវិញ្ញាណ១០ មនោធាតុ ៣ ) ។

**៥-ចិត្ត៣ដួង ដឹងអារម្មណ៍បាន ១២ យ៉ាង បានដល់កសិណប្បញ្ញត្តិ១០ អានាបានប្បញ្ញត្តិ ១ និង មជ្ឈត្តសត្វប្បញ្ញត្តិ ១** ( ឧបេក្ខាអប្បមញ្ញា ) **ចិត្ត ៣ដួងគឺ:** បញ្ចមជ្ឈានកុសល ១ វិបាក ១ កិរិយា ១ ។

**៦-ចិត្ត ៩ដួង ដឹងអារម្មណ៍បាន១៤ យ៉ាង បានដល់កសិណប្បញ្ញត្តិ១០ អានាបានប្បញ្ញត្តិ ១ បិយមនាបសត្វប្បញ្ញត្តិ ១** ( មេត្តាអប្បមញ្ញា ) **ទុក្ខិតសត្វប្បញ្ញត្តិ ១** ( ករុណាអប្បមញ្ញា ) **និងសុខិតសត្វប្បញ្ញត្តិ ១** ( មុទិតាអប្បមញ្ញា ) **ចិត្ត៩ដួងគឺ :**

-ទុតិយជ្ឈានចិត្ត ៣ដួង

-តតិយជ្ឈានចិត្ត ៣ដួង

-ចតុត្ថជ្ឈានចិត្ត ៣ដួង ។

**៧-ចិត្ត៣ដួង ដឹងអារម្មណ៍បាន ២៥ យ៉ាង បានដល់កសិណប្បញ្ញត្តិ១០ អសុភប្បញ្ញត្តិ១០ កោដ្ឋាសប្បញ្ញត្តិ១**( កាយគតាសតិ) **អានាបានប្បញ្ញត្តិ១ បិយមនាបសត្វប្បញ្ញត្តិ ១ ទុក្ខិតសត្វប្បញ្ញត្តិ១ និង សុខិតសត្វប្បញ្ញត្តិ១ ចិត្ត៣ដួង គឺ:** បឋមជ្ឈានចិត្ត៣ដួងហ្នឹងឯង ។

## ប្រមូលសរុបចិត្ត៧ពួក

**ចិត្ត២៨ដួង** មានអារម្មណ៍ ១យ៉ាង

| | | |
|---|---|---|
| **ចិត្ត២ដួង** | មានអារម្មណ៍ | ២យ៉ាង |
| **ចិត្ត៣ដួង** | មានអារម្មណ៍ | ៥យ៉ាង |
| **ចិត្ត៤១ដួង** | មានអារម្មណ៍ | ៦យ៉ាង |
| **ចិត្ត៣ដួង** | មានអារម្មណ៍ | ១២យ៉ាង |
| **ចិត្ត៩ដួង** | មានអារម្មណ៍ | ១៤យ៉ាង |
| **ចិត្ត៣ដួង** | មានអារម្មណ៍ | ២៥យ៉ាង ។ |

## អារម្មណ៍សង្គហៈចប់ដោយសង្ខេប

≈≈≈≈≈≈≈≈≈≈

**✵ ឱកាសពេលវេលានៃការសិក្សា ព្រះពុទ្ធវចនៈរកបានដោយកម្រណាស់ ទាំងពេលវេលាដែលអាចបដិបត្តិតាមព្រះធម៌ ដើម្បីប្រដៅចិត្ត ទូន្មានចិត្តរបស់ខ្លួនឯងបាន ហៅពេញសែនក្រ ៗ**

# សមាធិសូត្រ

≈≈ ≈≈

### សំយុត្តនិកាយ ខន្ធវារវគ្គ

### បិដកលេខ ៣៣ ទំព័រ ៣២

នៅក្នុងព្រះសូត្រនោះ ទ្រង់ត្រាស់យ៉ាងនេះថា **ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយចំរើននូវសមាធិ ៗ** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានចិត្តតម្កល់មាំហើយ រមែងដឹងច្បាស់តាមសេចក្ដីពិត ។ ចុះដឹងច្បាស់នូវអ្វី តាមសេចក្ដីពិត ។ ដឹងច្បាស់ នូវការកើតឡើង និង សេចក្ដីវិនាសនៃរូប នូវការកើតឡើង និងសេចក្ដីវិនាសនៃវេទនា នូវការកើតឡើង និង សេចក្ដីវិនាសនៃសញ្ញា នូវការកើតឡើង និង សេចក្ដីវិនាសនៃសង្ខារ នូវការកើតឡើង និង សេចក្ដីវិនាសនៃវិញ្ញាណ ។

( នៅក្នុងព្រះសូត្រនេះ ព្រះអង្គទ្រង់សំដែងបន្ដទៀត អំពីការកើត និង ការវិនាសនៃបញ្ចក្ខន្ធ)

## អដ្ឋកថា សមាធិសូត្រ

ក្នុងសមាធិសូត្រ មានវិនិច្ឆ័យដូចតទៅនេះ :

ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ឃើញភិក្ខុទាំងនោះ សាបសូន្យ ចាកភាពជាអ្នកមានចិត្តតាំងនៅក្នុងអារម្មណ៍តែមួយ ហើយទ្រង់ជ្រាបថា កាលភិក្ខុទាំងនេះបាននូវចិត្ត ដែលមានអារម្មណ៍តែមួយ កម្មដ្ឋាននឹងចំរើន ដូចនេះហើយ ទើបបានត្រាស់ព្រះតម្រាស់នេះថា **សមាធឹ ភិក្ខវេ ភាវេថ** (ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយចំរើននូវសមាធិ) ជាដើម ។

# បដិសល្លានសូត្រ

**( ព្រះសូត្រនេះ នៅបន្ទាប់ជាប់គ្នានឹងសមាធិសូត្រ ទំព័រ ៣៧)**

ព្រះអង្គទ្រង់ត្រាស់ថា **បដិសល្លានេ ភិក្ខវេ យោគមាបជ្ជថ** ។ ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយ ប្រកបព្យាយាម ក្នុងការស្ងប់ស្ងាត់កាយ ។

**បដិសល្លីនោ ភិក្ខវេ ភិក្ខុ យថាភូតំ បជានាតិ** ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលស្ងប់ស្ងាត់កាយ រមែងដឹងច្បាស់តាមសេចក្តីពិត ។ (នៅមានបន្តទៀតដូចសមាធិសូត្រ) ។

## អដ្ឋកថា

ក្នុងបដិសល្លានសូត្រ មានវិនិច្ឆ័យដូចតទៅនេះ :

ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ឃើញភិក្ខុទាំងអស់នោះ ជាអ្នកវិនាសចាកកាយវិវេក ហើយទ្រង់ជ្រាបថា កាល

ភិក្ខុទាំងនេះបាននូវកាយវិវេក កម្មដ្ឋាននឹងចំរើន ទើបបាន ត្រាស់ព្រះតម្រាស់នេះថា **បដិសល្លានេ** ជាដើម ។

❋ បើពុទ្ធបរិស័ទសិក្សាព្រះពុទ្ធវចនៈមិនបានល្អ មិន បានផ្ទៀងផ្ទាត់ដោយសព្វគ្រប់ រមែងយល់ខុសចាកសម្មា បដិបត្តិ ដូចជា សមាធិសូត្រ និង បដិសល្លានសូត្រ ទ្រង់ សំដែងតាមការដែលព្រះអង្គជ្រាបអំពីឧបនិស្ស័យរបស់ភិក្ខុ ទាំងពីរក្រុម ដែលមួយក្រុមទ្រង់ត្រាស់ឱ្យចំរើនសមាធិ ប៉ុន្តែមួយក្រុមទៀត ទ្រង់ត្រាស់ឱ្យប្រកបព្យាយាមក្នុង កាយវិវេក ។

ឧបនិស្ស័យនៃសត្វលោកមិនដូចគ្នាទេ ព្រោះហេតុ នេះ ទើបទ្រង់សំដែងនូវព្រះសូត្រផ្សេងៗគ្នា ខុសៗគ្នា តម្រូវតាមអធ្យាស្រ័យ តាមឧបនិស្ស័យរបស់សត្វលោក គឺ មិនដូចជាព្រះវិន័យ និង ព្រះអភិធម្មនោះទេ ។

ព្រះវិន័យ ទ្រង់បញ្ញត្តិយ៉ាងណា សព្វថ្ងៃនេះគឺជា សាស្តាជំនួសព្រះអង្គ សាវ័កត្រូវបដិបត្តិឱ្យបានល្អ តាមសិក្ខា បទដែលទ្រង់បញ្ញត្តិហើយ ។

ការប្រព្រឹត្តិតាមវិន័យ មិនទៅតាមអធ្យាស្រ័យនៃ បុគ្គលទេ តែត្រូវទៅតាមព្រះពុទ្ធប្បញ្ញត្តិ ។

**ការគោរពសិក្ខាបទដែលព្រះសម្មាសម្ពុទ្ធ ទ្រង់បញ្ញត្តិ គឺជាការគោរពព្រះពុទ្ធពិតៗ ជាការបូជាដ៏ឧត្តម ។**

**ការតាំងចេតនាល្មើសនឹងសិក្ខាបទគឺជា ការប្រលយមុខប្រឆាំងជាមួយនឹងព្រះសម្មា-សម្ពុទ្ធ ស៊ីងមានទោសដែលគួរឱ្យស្រៀវស្លុត ខ្លាចដ៏ក្រៃលែង ។**

ចំពោះបព្វជិតដែលប្រព្រឹត្តតាមសិក្ខាបទមិនបានទេ នោះ មានតែលាចាកសិក្ខាបទ មកជាគ្រហស្ថតែប៉ុណ្ណោះ ឯង រួចហើយត្រូវប្រព្រឹត្តកុសលកម្មក្នុងភេទជាគ្រហស្ថ ដោយសេចក្តីមិនប្រមាទ គឺមិនអាចនៅជាភិក្ខុ ឬសាមណេរ ហើយរក្សាតែសិក្ខាបទខ្លះ បោះបង់ចោលសិក្ខាបទខ្លះ ស្រេច តែចិត្តខ្លួនឯងបានឡើយ ។

ចំពោះព្រះអភិធម្ម ទ្រង់សំដែងបរមត្ថធម៌ក្នុងជីវិតនៃសត្វលោកគ្រប់ភព គ្រប់ភូមិទាំងអស់ ព្រមទាំងបរមត្ថធម៌ក្រៅអំពីជីវិតនៃសត្វលោកទៀតផង ។

**បរមត្ថធម៌ចែកជាពីរគឺ :**

**១-បរមត្ថសង្ខត:** បានដល់ចិត្ត ចេតសិកនិងរូប។

**២-បរមត្ថអសង្ខត:** បានដល់ព្រះនិព្វាន ។

ជាការបញ្ជាក់ដល់ **បរមត្ថសង្ខត:** ទ្រង់សំដែងគម្ពីរ **បុគ្គលប្បញ្ញត្តិ** គឺថា មនុស្ស សត្វ បុគ្គល គ្រាន់តែជាបញ្ញត្តិតាមប្រភេទនៃបរមត្ថធម៌តែប៉ុណ្ណោះ ក្នុងបុគ្គលប្បញ្ញត្តិនោះមានចិត្ត មានចេតសិក មានរូប បរមត្ថទាំង ៣ នេះ កើតឡើងដោយអាស្រ័យហេតុ-បច្ច័យ មិនមានអ្វីឋិតថេរទៀងទាត់ជាសត្វបុគ្គលឡើយ ។

**ការរំលត់សេចក្ដីប្រកាន់ដោយឧបាទាន ចំពោះ ចិត្ត ចេតសិក និង រូប ការមិនប្រកាន់នោះ គឺជាព្រះនិព្វាន ជាការផុតចាកជរា និង មរណៈ ។**

ព្រះសុត្តន្តបិដក ទ្រង់ចងក្រងនូវធម៌ទាំងឡាយផ្សេងៗ សំដែងចេញ ញុំាងប្រយោជន៍ឱ្យដល់បុគ្គលអ្នកស្ដាប់បានសំរេច ព្រោះព្រះអង្គទ្រង់ជ្រាបអធ្យាស្រ័យរបស់សត្វលោក ព្រះអង្គជាពេទ្យព្យាបាលរោគរបស់ចិត្តដ៏យ៉ាងជំនាញជាទីបំផុត **សត្វលោកមានចំនួនច្រើនណាស់ ដែលជាអ្នកឈឺចិត្ត ហើយត្រូវបានព្រះអង្គទ្រង់សំដែងព្រះធម៌គឺព្រះសូត្រផ្សេងៗ ឱ្យបានជាឱសថដ៏ពូកែ ញុំាំងជម្ងឺគឺកិលេសឱ្យសាបសូន្យអស់ទៅ នៅតែចិត្តដែលស្អាតប្រាសចាករោគទាំងពួង ។**

សូមពុទ្ធបរិស័ទសិក្សានូវព្រះសូត្រមួយទៀត ដើម្បីបញ្ជាក់ឱ្យកាន់តែច្បាស់ អំពីផ្លូវបដិបត្តិដ៏បរិសុទ្ធ ព្រះសូត្រឈ្មោះ **អស្សុជិសូត្រ** មាននៅក្នុង **សំយុត្តនិកាយ ខន្ធវារវគ្គ** បិដកខ្មែរយើងលេខ ៣៣ ទំព័រ ២៨៥ ។

# អស្សជិសូត្រ

សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្ត **វេឡុវ័ន** ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។

សម័យនោះឯង ព្រះអស្សជិដ៏មានអាយុ នៅក្នុងអារាមរបស់សេដ្ឋីឈ្មោះ **កស្សប** មានអាពាធ ដល់នូវសេចក្ដីទុក្ខ មានជម្ងឺជាទម្ងន់ ។

គ្រានោះ ព្រះអស្សជិដ៏មានអាយុ បានហៅភិក្ខុទាំងឡាយ ជាឧបដ្ឋាកមកថា ម្នាលអាវុសោទាំងឡាយ ចូរអ្នកទាំងឡាយមកអាយ ចូរអ្នកទាំងឡាយ ទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ចូរថ្វាយបង្គំព្រះបាទារបស់ព្រះដ៏មានព្រះភាគ ដោយត្បូង តាមពាក្យរបស់ខ្ញុំព្រះករុណាថា បពិត្រព្រះអង្គដ៏ចំរើន អស្សជិភិក្ខុ មានអាពាធ ដល់នូវសេចក្ដីទុក្ខមានជម្ងឺជាទម្ងន់ លោកថ្វាយបង្គំព្រះបាទារបស់ព្រះដ៏មានព្រះភាគ ដោយត្បូង មួយទៀត ចូរអ្នកទាំងឡាយពោលយ៉ាងនេះទៀតថា បពិត្រព្រះអង្គដ៏ ចំរើន សូមព្រះដ៏មានព្រះភាគ ធ្វើនូវសេចក្ដីអនុគ្រោះ ចូលទៅរកអស្សជិភិក្ខុ ភិក្ខុទាំងនោះទទួលស្ដាប់ពាក្យ របស់ព្រះអស្សជិដ៏មានអាយុថា ករុណាអាវុសោ ហើយចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។

លុះភិក្ខុទាំងនោះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន អស្សជិភិក្ខុ មានអាពាធ ដល់នូវសេចក្ដីទុក្ខ មានជម្ងឺជាទម្ងន់ លោកថ្វាយបង្គំព្រះបាទា របស់ព្រះដ៏មានព្រះភាគ ដោយត្បូង មួយទៀត លោកពោលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគ ធ្វើនៅសេ-ចក្ដីអនុគ្រោះ ចូលទៅរកអស្សជិភិក្ខុ ។

ព្រះដ៏មានព្រះភាគទ្រង់ទទួលដោយតុណ្ហីភាព ។

គ្រានោះឯងព្រះដ៏មានព្រះភាគ ទ្រង់ស្ដេចចេញអំពីទីសម្ងំក្នុងសាយណ្ហសម័យ ហើយស្ដេចយាងទៅរក

ព្រះអស្សជិដ៏មានអាយុ ។

ព្រះអស្សជិដ៏មានអាយុ ក៏បានឃើញព្រះដ៏មានព្រះ-ភាគ កំពុងតែស្តេចយាងមកអំពីចម្ងាយ លុះឃើញហើយ ក៏សំដែងកិរិយាតតេះតតះលើគ្រែ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងព្រះអស្សជិដ៏មានអាយុដូច្នេះថា ណ្ហើយ អស្សជិ អ្នកកុំសម្តែងកិរិយា តតេះតតះលើគ្រែឡើយ នេះអាសនៈទាំងឡាយ ដែលគេតែងតាំងបំរុងទុក មានស្រាប់ហើយ តថាគតនឹង អង្គុយលើអាសនៈនោះ ។

ព្រះដ៏មានព្រះភាគទ្រង់គង់លើអាសនៈដែលគេតែងតាំងបម្រុងទុក ។

លុះព្រះដ៏មានព្រះភាគ ទ្រង់គង់ស្រេចហើយ ទើបព្រះអង្គត្រាស់សួរព្រះអស្សជិដ៏មានអាយុ ដូច្នេះថា ម្នាលអស្សជិ អ្នកល្មមអត់ធន់បានដែរឬ? អ្នកល្មមញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅបានដែរឬ? ។ល។ ទុក្ខវេទនា បានធូរថយប្រាកដ មិនចំរើនឡើងទេឬ?

ព្រះអស្សជិក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គអត់ធន់មិនបានទេ ខ្ញុំព្រះអង្គញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅមិនបានទេ ។ល។ ទុក្ខវេទនាចំរើនឡើងប្រាកដ មិនបានធូរថយឡើយ ។

**ព្រះ –** ម្នាលអស្សជិ អ្នកមិនមានសេចក្តីរង្កៀសបន្តិចបន្តួចទេឬ ? អ្នកមិនមានសេចក្តីក្តៅក្រហាយអ្វីទេឬ?

**អស្សជិ –** ព្រះករុណាព្រះអង្គ ខ្ញុំព្រះអង្គមានសេ-ចក្តីរង្កៀសជាច្រើន មានសេចក្តីក្តៅក្រហាយជាច្រើន ។

**ព្រះ –** ម្នាលអស្សជិ ចុះខ្លួនអ្នកមិនបានតិះដៀលខ្លួនឯង ដោយសីលទេឬ ?

**អស្សជិ –** បពិត្រព្រះអង្គដ៏ចំរើន ខ្លួនរបស់ខ្ញុំព្រះអង្គ មិនតិះដៀលខ្ញុំព្រះអង្គឯងដោយសីលទេ ។

**ព្រះ –** ម្នាលអស្សជិ បើខ្លួនអ្នកមិនបានតិះដៀលខ្លួនឯងដោយសីលទេ ចុះអ្នកមានសេចក្តីរង្កៀសដូចម្តេច? មានសេចក្តីក្តៅក្រហាយដូចម្តេច ?

**អស្សជិ –** បពិត្រព្រះអង្គដ៏ចំរើន ក្នុងកាលមុន ខ្ញុំព្រះអង្គរម្ងាប់នូវកាយសង្ខារ (ខ្យល់ដង្ហើមចេញ-ចូល) (ឥឡូវនេះ រម្ងាប់មិនបាន) ទើបខ្ញុំព្រះអង្គមិនបាននូវសមាធិ បពិត្រព្រះអង្គដ៏ចំរើន កាលដែលខ្ញុំព្រះអង្គ មិនបាននូវសមាធិនោះហើយ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញមិនសាបសូន្យទេឬហ្ន៎ ។

**ព្រះ –** ម្នាលអស្សជិ ពួកសមណព្រាហ្មណ៍ណា ក៏ដោយ ដែលមានសមាធិជាខ្លឹម មានសមាធិជាសាមញ្ញផល កាលបើសមណព្រាហ្មណទាំងនោះ មិនបាននូវសមាធិហើយ ក៏រមែងមានសេចក្តីត្រិះរិះយ៉ាងនេះថា យើងមិនសាបសូន្យទេឬហ្ន៎ ។

ម្នាលអស្សជិ អ្នកយល់សេចក្តីនោះដូចម្តេច រូបទៀង ឬមិនទៀង ?

**អស្សជិ –** មិនទៀងទេព្រះអង្គ ។ល។

# អដ្ឋកថា អស្សជិសូត្រ

≈≈≈≈≈

គប្បីជ្រាបវិនិច្ឆ័យនៃអស្សជិសូត្រដូចតទៅនេះ :

បទថា **កស្សបការាមេ** បានដល់ ក្នុងអារាមដែលកស្សបសេដ្ឋីឱ្យសាង ។

បទថា **កាយសង្ខារេ** បានដល់ខ្យល់ដកដង្ហើម ចូល ខ្យល់ដកដង្ហើមចេញ ។

ព្រះអស្សជិនោះ រម្ងាប់ខ្យល់ដកដង្ហើមចូល និង ខ្យល់ដកដង្ហើមចេញទាំងអស់នោះដោយ **ចតុត្ថជ្ឈាន** ។

បទថា **ឯវំ ហោតិ** មានសេចក្តីថា ឥឡូវនេះ កាលខ្ញុំព្រះអង្គមិនបានសមាធិនោះ ទើបមានសេចក្តីគិតយ៉ាងនេះ ។

បទថា **នោ ច ខ្វាហំ បរិហាយាមិ** ដោយសេចក្តីថា យើងនៅមិនវិនាសសាបសូន្យចាកព្រះសាសនាទេឬហ្ន៎ ។

បានឮថា សមាបត្តិរបស់លោក តាំងមាំ តម្កល់ស្មើ (ជាអប្បនា) បានសាបសូន្យទៅ ព្រោះទោសគឺអាពាធ ព្រោះដូច្នោះ លោកទើបគិតយ៉ាងនេះ ។

បទថា **សមាធិសារកា សមាធិសាមញ្ញា** មានសេចក្តីថា សមាធិនោះឯង ជាសារៈ និង ជាសាមញ្ញផល តែក្នុងសាសនារបស់យើង តថាគត នៅមិនមែនជាសារៈ **វិបស្សនា មគ្គ និង ផល** ជាដើម (ឯណោះទេ) **ទើបជាសារៈ** ព្រោះហេតុនេះ អ្នកហ្នឹងឯង កាលវិនាសសាបសូន្យនូវសមាធិ ដូចម្តេចទើបគិតថា យើងវិនាសសាបសូន្យចាកសាសនា ។

កាលព្រះដ៏មានព្រះភាគ លួងលោមព្រះថេរៈយ៉ាងនេះហើយ តទៅដែលព្រះអង្គផ្តើមសំដែងធម៌ មានបរិវដ្ដៈ ៣ ដល់ព្រះថេរៈនោះ ទើបទ្រង់ត្រាស់ពាក្យថា **តំ កឹ មញ្ញសិ អស្សជិ រូបំ និច្ចំ វា អនិច្ចំ វាតិ ។** ម្នាលអស្សជិ អ្នកយល់សេចក្តីនោះដូចម្តេច រូប ទៀង ឬមិនទៀង ? ជាដើម ។

ក្រោយមក ពេលដែលព្រះអង្គទ្រង់សំដែងអំពីធម៌ ដែលមានជាប្រចាំ (ខន្ធ៥) ដល់ព្រះថេរៈ ព្រះអស្សជិក៏បានសម្រេចជាព្រះអរហន្ត ក្នុងពេលចប់ទេសនា អំពីបរិវដ្ដៈ ៣ (ទ្រង់ត្រាស់សួរធម៌វិលជុំវិញខន្ធ៥) ។

# បរិវដ្ដៈ ៣ ក្នុងខន្ធ ៥

≈≈≈≈≈

## ស្រង់ចាក យមកសូត្រ

ភិក្ខុយមកៈមានទិដ្ឋិអាក្រក់ មានសភាពយ៉ាងនេះថា អាត្មាអញយល់ច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយថា ភិក្ខុជាខីណាស្រព តែទម្លាយកាយហើយ ខាងមុខអំពីសេចក្ដីស្លាប់ទៅ រមែងដាច់សូន្យ មិនកើតទៀតទេ ។

ព្រះសារីបុត្របានជួយដោះទិដ្ឋិអាក្រក់ ឱ្យចេញអំពីសន្ដាននៃព្រះភិក្ខុយមកៈ ដោយបានតាំងនូវសំនួរក្នុងបរិវដ្ដៈ ៣ ដូចតទៅ :

**សា –** ម្នាលអាវុសោយមកៈ លោកសំគាល់សេចក្ដីនោះដូចម្ដេច លោកពិចារណាឃើញរូបថា ជាសត្វ ជាបុគ្គលឬ ?

**យ –** មិនដូច្នោះទេ អាវុសោ ។

**សា –** លោកពិចារណាឃើញវេទនាថា ជាសត្វ ជាបុគ្គលឬ ?

**យ –** មិនដូច្នោះទេ អាវុសោ ។

**សា –** លោកពិចារណាឃើញសញ្ញាថា ជាសត្វ ជាបុគ្គលឬ ?

**យ –** មិនដូច្នោះទេ អាវុសោ ។

**សា –** លោកពិចារណាឃើញសង្ខារថា ជាសត្វ ជាបុគ្គលឬ?

**យ –** មិនដូច្នោះទេ អាវុសោ ។

**សា –** លោកពិចារណាឃើញវិញ្ញាណថា ជាសត្វ ជាបុគ្គលឬ ?

**យ –** មិនដូច្នោះទេ អាវុសោ ។

**សា –** ម្នាលអាវុសោយមកៈ លោកសំគាល់សេចក្ដីនោះថាដូចម្ដេច លោកពិចារណាឃើញ សត្វ បុគ្គល មានក្នុងរូប ឬ ?

**យ –** មិនដូច្នោះទេ អាវុសោ ។

**សា –** លោកពិចារណាឃើញ សត្វ បុគ្គល ផ្សេងអំពីរូប ឬ ?

**យ –** មិនដូច្នោះទេ អាវុសោ ។

**សា –** លោកពិចារណាឃើញសត្វ បុគ្គល មានក្នុងវេទនា ឬ ?

**យ –** មិនដូច្នោះទេ អាវុសោ ។

**សា –** លោកពិចារណាឃើញ សត្វ បុគ្គល ផ្សេងអំពីវេទនា ឬ ?

**យ –** មិនដូច្នោះទេ អាវុសោ ។

**សា –** លោកពិចារណាឃើញ សត្វ បុគ្គល មានក្នុងសញ្ញា ឬ ?

**យ –** មិនដូច្នោះទេ អាវុសោ ។

**សា –** លោកពិចារណាឃើញ សត្វ បុគ្គល ផ្សេងអំពីសញ្ញា ឬ ?

**យ –** មិនដូច្នោះទេ អាវុសោ ។

**សា –** លោកពិចារណាឃើញ សត្វ បុគ្គល មានក្នុងសង្ខារ ឬ ?

**យ –** មិនដូច្នោះទេ អាវុសោ ។

**សា –** លោកពិចារណាឃើញ សត្វ បុគ្គល ផ្សេងអំពីសង្ខារ ឬ ?

**យ –** មិនដូច្នោះទេ អាវុសោ ។

**សា –** លោកពិចារណាឃើញ សត្វ បុគ្គល មានក្នុងវិញ្ញាណ ឬ ?

**យ –** មិនដូច្នោះទេ អាវុសោ ។

**សា –** លោកពិចារណាឃើញ សត្វ បុគ្គល ផ្សេងអំពីវិញ្ញាណ ឬ ?

**យ –** មិនដូច្នោះទេ អាវុសោ ។

**យ –** ម្នាលអាវុសោយមកៈ លោកសំគាល់សេចក្តីនោះដូចម្តេច លោកពិចារណាឃើញ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណថា ជាសត្វ ជាបុគ្គល ឬ ?

**យ –** មិនដូច្នោះទេ អាវុសោ ។

**សា –** ម្នាលអាវុសោយមកៈ លោកសំគាល់សេចក្តីនោះ ដូចម្តេច លោកពិចារណាឃើញ សត្វ បុគ្គល នេះថា មិនមានរូប មិនមានវេទនា មិនមានសញ្ញា មិនមានសង្ខារ មិនមានវិញ្ញាណឬ ?

**យ –** មិនដូច្នោះទេ អាវុសោ ។

**សា –** ម្នាលយមកៈដ៏មានអាយុ ដោយពិត ដោយប្រាកដ លោកស្រាវជ្រាវរកសត្វ បុគ្គលក្នុងខន្ធ៥ ជាបច្ចុប្បន្ននេះមិនឃើញផង គួរដែរឬ ដែលលោកបានអះអាងថា អាត្មាអញយល់ច្បាស់នូវធម៌ ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដែងថា ភិក្ខុជាខីណាស្រព តែកាលណាទម្លាយកាយហើយ ខាងមុខអំពីសេចក្តីស្លាប់ទៅ រមែងដាច់សូន្យ មិនកើតទៀតទេ ។

**យ –** លោកម្ចាស់សារីបុត្រដ៏មានអាយុ កាលអំពីដើម ខ្ញុំមិនដឹងថា ទិដ្ឋិរបស់ខ្ញុំនោះ ជាទិដ្ឋិអាក្រក់ តែឥឡូវនេះ ខ្ញុំលះបង់នូវទិដ្ឋិអាក្រក់នោះហើយ ព្រោះបានស្តាប់ធម្មទេសនានេះរបស់ព្រះសារីបុត្រដ៏មានអាយុ មួយទៀត ខ្ញុំព្រះករុណាក៏បានសំរេចនូវធម៌ដ៏វិសេសហើយ ។

❋ឧបាទានក្ខន្ធទុក្ខ កាលដែលរលត់ទៅ មិនមានសត្វរលត់ផ្សេងទៀតឡើយ ។

❋ក្នុងអបាយភូមិ ៤ ក៏ដោយ ក្នុងមនុស្សទេវតា ឬព្រហ្មក៏ដោយ ឱ្យតែជាខន្ធ គឺនៅក្នុងសាមញ្ញលក្ខណៈទាំង-អស់ ។

❋វិញ្ញាណដឹងអារម្មណ៍ ដ៏ជាទិព្វក្នុងទេវលោក ក៏មិនមែនជាតួយើងអ្នកដឹងដែរ ។

❋នៅក្នុងកំណើតមនុស្សពិតមែន ប៉ុន្តែបានកំណត់ដឹងនូវកាយដែលប្រកបដោយមហាភូតរូប ៤ ហើយបានឃើញដោយបញ្ញាដ៏ប្រពៃ ចំពោះវិញ្ញាណដែលដឹងនូវអារ-ម្មណ៍ថា ត្រឹមតែជាវិញ្ញាណប៉ុណ្ណោះ កំណើតមនុស្សនេះប្រសើរជាងសេចក្តីប្រកាន់តួខ្លួន ទោះជានៅក្នុងកំណើតទេវតា ឬកំណើតព្រហ្មក៏ដោយ ។

❋ បញ្ចក្ខន្ធគឺជាព្រៃស្ទុក ពោរពេញទៅដោយសត្វសាហាវ ។

❋ ដូចម្ដេចក៏មិនដឹងឥឡូវទៅ ដើម្បីបានទៅដល់ទីដែលផុតទុក្ខព្រួយឆាប់ៗ ។

❋ បើនៅតែក្រៅសាលាទេ ពេលចេះពេលដឹងគឺអត់មានតែម្ដង ។

❋ ហាត់ដឹងសន្សឹមៗទៅ វាមានទៅខាតពេលវេលាឯណា ។

❋ សភាវធម៌សំរាប់សិក្សាឱ្យបានដឹង មានគ្រប់ពេលវេលាទាំងអស់ ទាំងគ្រូបង្ហាត់បានដល់ព្រះធម៌ ព្រះ-វិន័យ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងហើយ បញ្ញត្តិហើយ ក៏មានដោយពិត ឯចំណែកទីបំផុតថ្នាក់គឺមគ្គញ្ញាណក៏នៅមានដែរ តើចាំដល់ពេលណាទៀត ទើបបានចូលសិក្សាក្នុងសាលាលោក ៦នេះ ។

# សតិសូត្រ សតិវគ្គ

≈≈≈≈≈

**( សំយុត្តនិកាយ សគាថវគ្គ)**

(៥៧) ទេវតានោះ ឈរក្នុងទីដ៏សមគួរហើយ បានពោលគាថានេះ ក្នុងសំណាក់នៃព្រះដ៏មានព្រះភាគថា :

ភិក្ខុអ្នកមានស្មារតី គប្បីប្រញាប់វៀរ **ដើម្បីលះបង់នូវកាមរាគៈ** ដូចជាបុរសដែលគេប្រហារដោយលំពែង ឬដូចជាបុគ្គលដែលភ្លើងឆេះលើក្បាល

## សារត្ថប្បកាសិនីអដ្ឋកថា

## អដ្ឋកថាសតិសូត្រ

សួរថា ក្នុងគាថានេះ ទេវតាពោលយ៉ាងណា?

ឆ្លើយថា ទេវតាពោលថា បុរសត្រូវចាក់ដោយលំពែង ប្រញាប់ព្យាយាម ធ្វើនូវការខ្នះខ្នែងរហ័សរហួន ដើម្បីនឹងរក្សាមុខរបួស ដោយការដកនូវលំពែងចេញ និង

បុរសដែលត្រូវភ្លើងឆេះនៅលើក្បាល ប្រញាប់ព្យាយាម ធ្វើនូវការខ្នះខ្នែងភ្លាមៗ ដើម្បីពន្លត់ភ្លើង យ៉ាងណា បពិត្រព្រះដ៏មានព្រះភាគជាម្ចាស់ ភិក្ខុក៏ត្រូវយ៉ាងនោះដែរ គប្បីមានសតិមិនប្រមាទ ដើម្បីលះបង់នូវកាមរាគៈ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ព្រះតម្រិះថា គាថាដែលទេវតានេះនាំមកតាំងទុក ធ្វើសេចក្ដីឧបមាយ៉ាងមាំទាំ ប៉ុន្តែកាន់យកប្រយោជន៍បានបន្តិចបន្តួច សូម្បីមានការពោលដដែលៗឱ្យច្រើនដងក៏ដោយ ព្រោះគេពោលដល់ការលះ ដោយការគ្របសង្កត់កាមរាគៈតែប៉ុណ្ណោះ ។

កាមរាគៈដែលមគ្គនៅមិនទាន់បានដកចេញលះចោលដរាបណា ដរាបនោះ ក៏នៅមានការតាមចងជាប់ជានិច្ចកាលតទៅ ។

ព្រោះដូច្នោះ កាលដែលព្រះអង្គទ្រង់កាន់យកនូវសេចក្ដីឧបមានោះៗឯង ហើយទ្រង់ផ្លាស់ប្ដូរការសម្ដែង ឱ្យមកជាការលះបង់កិលេសដោយអំណាចអរិយមគ្គវិញ ទើបទ្រង់ត្រាស់នូវព្រះគាថាទី ២បន្ត អំពីគាថារបស់ទេវតាដូច្នោះថា :

(៥៨) **សត្តិយា វិយ ឱមដ្ឋោ**
**ឌយ្ហមានេវ មត្ថកេ**
**សក្កាយទិដ្ឋិប្បហានាយ**
**សតោ ភិក្ខុ បរិព្វជេតិ ។**

ប្រែថា ភិក្ខុអ្នកមានស្មារតី គប្បីប្រញាប់វៀរ **ដើម្បីលះបង់នូវសក្កាយទិដ្ឋិ** ដូចជាបុរសដែលត្រូវគេប្រហារដោយលំពែង ឬដូចជាបុគ្គលដែលភ្លើងឆេះលើក្បាល ។

**ជំនួយសតិភាគទី ៤**
**ចប់តែប៉ុណ្ណោះ**
**ជាទីរលឹកឆ្នាំសិក្សាទី ១០**
**ព.ស ២៥៤២-៤៣**

# ពាក្យផ្តើម

សៀវភៅជំនួយសតិភាគទី៤នេះ មានមេរៀនព្រះអភិធម្ម ច្រើនជាងភាគមុនៗ ប៉ុន្តែមានធម៌មួយចំនួនទៀត ពន្យល់អំពីជីវិតប្រចាំថ្ងៃ បើពុទ្ធបរិស័ទមានឧបនិស្ស័យយ៉ាងណាៗ គប្បីសិក្សាយ៉ាងនោះចុះ ។

សៀវភៅនេះ ខ្ញុំព្រះករុណា ខ្ញុំបាទ បានរៀបចំយ៉ាងផ្ចិតផ្ចង់នូវមេរៀនព្រះអភិធម្មគម្ពីរបដ្ឋានគឺ **ហេតុប្បច្ច័យ** និង **អារម្មណប្បច្ច័យ** តាម **ព្រះអភិធម្មបិដក** និង**អដ្ឋកថា** ព្រមដោយឯកសារពិគ្រោះផ្សេងៗទៀត ដូចជាសៀវភៅបដ្ឋានរបស់ **ព្រះភិក្ខុ** សុមន្ត នន្ទិកោ សៀវភៅអភិធម្មត្ថសង្គហៈ របស់ **លោកអាចារ្យ សំផន ស្រីវរាទិត្យ** ជាដើម ។

សៀវភៅមេរៀនធម៌ជំនួយសតិនេះ មានពន្យល់អំពីការបដិបត្តិចំរើនសតិប្បដ្ឋាន ដែលជាផ្លូវទៅកាន់ទីរំលត់ទុក្ខ ។

ការសិក្សាមេរៀនព្រះអភិធម្ម មានប្រយោជន៍ដ៏ធំធេងក្នុងការយល់អំពីជីវិតប្រចាំថ្ងៃ និងជាឧបការៈដល់ការចំរើនសតិប្បដ្ឋាន។

ធម៌ណាដែលកើតឡើង រមែងកើតអំពីហេតុនៃធម៌នោះ នេះជាទិសដៅ និង ជាចំណុចសំខាន់សំរាប់ពុទ្ធបរិស័ទបានឃើញបានចាក់ធ្លុះ ហើយរមែងបានដល់នូវទីពឹងដ៏ក្សេម ។

ចំពោះសៀវភៅជំនួយសតិទាំង ៤ភាគនេះ បើមានការខ្វះខាតដោយប្រការណា ខ្ញុំម្ចាស់សូមទទួលការបំពេញបន្ថែមដោយសេចក្តីត្រេកអរជ្រះថ្លា ។

ដោយកុសលធម្មទាន ដ៏ជាអតិសារសម្បត្តិនេះ សូមគំនរនៃបុណ្យកុសល បានសំរេចដល់ពុទ្ធបរិស័ទបរិបូណ៌ដោយបញ្ញាសម្បត្តិ បានឆ្លងកាត់អន្លង់នៃសេចក្តីទុក្ខដោយជោគជ័យ គ្រប់ព្រះ អង្គ និង គ្រប់គ្នា សូមអនុមោទនា ! ។

**ខ្ញុំព្រះករុណា**

**ខ្ញុំបាទ ប៊ុត សាវង្ស**

≈≈≈≈≈

**៥រោច ខែ ពិសាខ**

**ព.ស ២៥៤៣**

**សំរាប់ជាធម្មទានតែប៉ុណ្ណោះ**

# មាតិកាធម៌


**លេខរៀង** **ទំព័រ**

១-ត្រូវចេះរស់ជាមួយនឹងជីវិតបច្ចុប្បន្ន .................................. ១
២-បទពិចារណាជុំវិញជីវិត ................................................. ៧
៣-ហេតុប្បច្ចយោ ......................................................... ១៥
៤-បច្ចយុប្បន្នធម៌ ......................................................... ១៩
៥-សហេតុកចិត្តជរូប ១៧ ............................................... ២៥
៦-សហេតុកបដិសន្ធិកម្មជរូប ២០ .................................... ២៨
៧-បច្ចនិកធម៌ ............................................................ ៣៧
៨-សរុបអង្គធម៌នៃហេតុប្បច្ច័យ ..................................... ៤០
៩-បញ្ហាវារៈនៃហេតុប្បច្ច័យ ......................................... ៤៤
១០-សមាធិជាបទដ្ឋាននៃបញ្ញា ...................................... ៥៩
១១-ហេតុប្បច្ច័យសភាគៈ .............................................. ៦៩
១២-ហេតុប្បច្ច័យសភាគៈតាមបញ្ហាវារៈ ........................... ៧១
១៣-សភាគប្បច្ច័យមានក្នុងបញ្ហាវារៈ ............................... ៧៣
១៤-កាល.ភូមិ.បុគ្គល.ទ្វារ របស់ហេតុប្បច្ច័យ ..................... ៧៧
១៥-បទពិចារណា ......................................................... ៨១
១៦-ជីវិតជារបស់ខ្ចីគេ .................................................... ៨៤
១៧-អារម្មណប្បច្ច័យ .................................................... ៨៩
១៨-ពន្យល់ពាក្យអារម្មណ៍ ............................................. ៩៩
១៩-អារម្មណ៍របស់វិបស្សនា ........................................... ១០៥
២០-បញ្ហាវារៈនៃអារម្មណប្បច្ច័យ ..................................... ១០៩
២១-បទគួរយល់ដឹង ....................................................... ១១៧
២២-គប្បីយល់ដឹងក្នុងសតិ-វិបស្សនាថែមទៀត ..................... ១២១
២៣-បទគួរយល់ដឹងថែមទៀត .......................................... ១៤៣
២៤-ប្រយោជន៍នៃការសិក្សាអារម្មណប្បច្ច័យ ....................... ១៦១
២៥-អារម្មណប្បច្ច័យសភាគៈ ........................................... ២០៣
២៦-ន័យ ៦ ដ៏ជ្រៅ ........................................................ ២០៥
២៧-ចតុត្ថជ្ឈាន ១២យ៉ាង ............................................... ២៣៣
២៨-អារម្មណ៍ពិស្តារ ...................................................... ២៤៦
២៩-ចិត្តដឹងអារម្មណ៍ពិស្តារ ............................................. ២៥០
៣០-ចេតសិកដឹងអារម្មណ៍ពិស្តារ ....................................... ២៦២
៣១-ចិត្ត ៩១ដួង ចែកជា ៨ពួក ......................................... ២៦៦
៣២-ចិត្ត ៨៩ដួង ចែកជា ៧ពួក ......................................... ២៦៩
៣៣-សមាធិសូត្រ .......................................................... ២៧៤
៣៤-បដិសល្លានសូត្រ ..................................................... ២៧៦
៣៥-អស្សជិសូត្រ .......................................................... ២៨២
៣៦-បរិវដ្ដៈ ៣ ក្នុង ខន្ធ ៥ ............................................... ២៩០
៣៧-សតិសូត្រ សតិវគ្គ ................................................... ២៩៧